សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ភស្តុតាងក្នុងរឿងក្តីព្រហ្មទណ្ឌ

ស្រាវជ្រាវថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ណែម មុន្នី**

លោក **ឡាំ ប្រាក់ច័ន្ទ**

សាស្ត្រាចារ្យណែនាំ

**ឯកឧត្តម កេង សុម៉ារិទ្ធ**



ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ណែម មុន្នី** និងខ្ញុំបាទ **ឡាំ ប្រាក់ច័ន្ទ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ ដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវកតញ្ញូតាធម៌ និងអំណរគុណយ៉ាងជ្រាវជ្រៅបំផុតចំពោះ ៖

- **លោកឳពុក អ្នកម្តាយ** ដែលបានផ្តល់កំណើតចិញ្ចឹមថ្នាក់ថ្នមបីបាច់ថែរក្សា ផ្តល់នូវក្តីស្រឡាញ់ប្រកបដោយព្រហ្មវិហារធម៌អប់រំទូន្មានប្រៀនប្រដៅ និងទំនុកបម្រុងគ្រប់បែបយ៉ាងទាំងសម្ភារៈ ទាំងស្មារតី និងថវិកាឲ្យកូនបានរៀនសូត្រដល់បច្ចុប្បន្ននេះ ។
- ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឲ្យយើងបានខ្ញុំបាទចូលសិក្សានៅសាកលវិទ្យានេះ និងបង្ករលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ។
- លោកសាស្ត្រាចារ្យ **ឯកឧត្តម កេង សុម៉ារិទ្ធ** ជាសាស្ត្រាចារ្យណែនាំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងដ៏មមាញឹកក្នុងការបង្ហាត់បង្រៀន ព្រមទាំងផ្តល់ការណែនាំ ដើម្បីរៀបចំសារណាបញ្ចប់ការសិក្សានេះឡើង។
- ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ បុគ្គលិកសិក្សា នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានបង្ហាត់បង្រៀន និងបង្កលក្ខណៈងាយស្រួលដល់ការសិក្សាយើងខ្ញុំ។
- សូមសម្តែងនូវអំណរគុណយ៉ាងជ្រាវជ្រៅបំផុតថែមទៀត ចំពោះអ្នកនិពន្ធ និងអ្នកប្រាជ្ញព្រមទាំងទស្សនៈវិទូល្បីៗក្នុងលោក ដែលយើងខ្ញុំបានសិក្សាស្រាវជ្រាវពីស្នាដៃរបស់លោកក្នុងការបំពេញកិច្ចការស្រាវជ្រាវកន្លងមក។

សូមមេត្តាទទួលនូវអំណរគុណដ៏ជ្រាវជ្រៅបំផុត និងមិនអាចបំភ្លេចបាន ចំពោះឧបការគុណដ៏ធំធេងពីយើងខ្ញុំ។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់ លោកអ្នកមានគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសាស្ត្រាចារ្យទាំងអស់ សូមឲ្យបានប្រកបតែជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋម ខ្ញុំបាទ **ណែម មុន្នី** និង ខ្ញុំបាទ **ឡាំ ច្រាក់ច័ន្ទ** សូមគោរពលោកសាស្ត្រាចារ្យព្រមទាំងស្វាគមន៍ដល់មិត្តអ្នកអានគ្រប់រូប ជាពិសេស សិស្ស និស្សិត ជាទីរាប់អាន។

ក្នុងនាមជានិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងរាជធានីភ្នំពេញបានរៀបចំនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រក្រោមប្រធានបទស្តីពី **ភស្តុតាងក្នុងរឿងក្តីព្រហ្មទណ្ឌ** នេះឡើង ដោយសារមើលឃើញថានៅមានកង្វះខាតនៅមូលដ្ឋាន និងឯកសារសម្រាប់ក្នុងការអនុវត្តន៍ របស់មន្ត្រីអនុវត្តន៍ច្បាប់ផងនោះ ហេតុនេះហើយបានជាយើងទាំងពីរអ្នកបានសម្រេចចិត្តក្នុងការរៀបចំសារណា ពីប្រធានបទមួយនេះ ព្រមទាំងមានការគាំទ្រនិងលើកទឹកចិត្តបង្ហាញយ៉ាងទំហឹងពីសំណាក់លោកសាស្ត្រាចារ្យ**ឯកឧត្តម កេច សុម៉ារិទ្ធ** ដែលជាសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រនៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណានេះនឹងចូលរួមជាវិភាគទានដ៏សំខាន់នៅក្នុងការយល់ដឹងអំពី ទ្រឹស្តីបែបវិទ្យាសាស្ត្រនៃភស្តុតាង ជាមូលដ្ឋានដើម្បីឈានទៅដល់ការអនុវត្តជាក់ស្តែងសម្រាប់ធ្វើការ ការកំណត់ទៅលើសញ្ញាណនៃភស្តុតាង ការវាយតម្លៃទៅលើភស្តុតាង និងការផ្ទៀងផ្ទាត់ទៅលើប្រភេទភស្តុតាងនៅក្នុងប្រព័ន្ធយុត្តិធម៌។ យើងខ្ញុំសង្ឃឹមទៀតថា សារណាមួយនេះនឹងក្លាយជាឯកសារស្រាវជ្រាវ ដែលបាននឹងកំពុកជួបប្រទះនូវកង្វះខាតផងដែរ។

យើងខ្ញុំក៏សូមអភ័យទោសផងដែរ នូវរាល់កង្វះខាតទាំងឡាយដែលមាននៅក្នុងសារណានេះ យើងខ្ញុំរងចាំទទួលការរិះគន់ដើម្បីកែលម្អពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ មិត្តអ្នកអានទាំងអស់គ្នា។

ជាចុងក្រោយនេះ សូមជូនពរដល់អ្នកអានគ្រប់រូបឲ្យជួបប្រទះតែនឹងភាពសុខដុមរមនារុងរឿងថ្កុំថ្កើង និងមានសុភមង្គលជានិរន្តន៍កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ១
**ជំពូកទី១. គោលការណ៍ទូទៅនៃភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ** ........................................ ៣
**ផ្នែកទី១. គោលការណ៍ទូទៅនៃភស្តុតាង** ........................................ ៣
**កថាខណ្ឌទី១. និយមន័យនៃភស្តុតាង** ........................................ ៣
**កថាខណ្ឌទី២. សញ្ញាណទូទៅនៃភស្តុតាង** ........................................ ៤
២.១. ព្រឹត្តិការណ៍ ........................................ ៤
២.២ ការដាក់បន្ទុក និងការដោះបន្ទុក ........................................ ៤
២.៣. បន្ទុកនៃភស្តុតាងឬកាតព្វកិច្ចនៃការបង្ហាញភស្តុតាង ........................................ ៦
ក. ខ្លឹមសារទូទៅចំពោះបន្ទុកភស្តុតាង ........................................ ៦
ខ. បន្ទុកភស្តុតាងក្នុងដំណាក់កាលស៊ើបអង្កេត ........................................ ៧
២.៤. ដំណើរការនៃសក្ខីកម្ម ឬមធ្យោបាយនៃការបញ្ជាក់ភស្តុតាង ........................................ ៧
**កថាខណ្ឌទី៣. គោលបំណងនៃភស្តុតាង** ........................................ ៨
**កថាខណ្ឌទី ៤. គោលការណ៍នៃភស្តុតាង** ........................................ ៨
៤.១. គោលការណ៍សច្ចភាពនៃភស្តុតតាង ឬគោលការណ៍សម្ភារៈ ........................................ ៩
៤.២. គោលការណ៍ជឿទុកចិត្តរបស់ចៅក្រម ........................................ ១០
ក.ខ្លឹមសាររួមនៃគោលការណ៍ជឿទុកចិត្តរបស់ចៅក្រមទៅលើអង្គហេតុ ........................................ ១០
ខ. គោលការណ៍ជឿទុកចិត្តដោយសេរីរបស់ចៅក្រមទៅលើអង្គហេតុ ........................................ ១១
៤.៣. គោលការណ៍សច្ចធារណ៍នៃនិរទោស ........................................ ១២
ក. ដំណាក់កាលចោទប្រកាន់ ........................................ ១២
ខ. កំហុសត្រូវបានរកឃើញ ........................................ ១៣
គ. ត្រូវដកការចោទប្រកាន់ ........................................ ១៣
**កថាខណ្ឌទី៥. ទម្រង់នៃភស្តុតាង** ........................................ ១៥
៥.១.មូលដ្ឋានគ្រឹះនៃការចាត់ថ្នាក់ទៅលើទម្រង់នៃភស្តុតាង ........................................ ១៦
ក .ក្រុមទីមួយចំពោះទម្រង់នៃការចោទប្រកាន់ ........................................ ១៦
ខ .ក្រុមទីពីរចំពោះទម្រង់ដែលជាប្រភពនៃការផ្តល់ព័ត៌មាន ........................................ ១៧

គ. ក្រុមទីបីចំពោះទម្រង់នៃអង្គហេតុគ្រឹះ ........ ១៨
៥.២ ប្រភេទនៃទម្រង់ភស្តុតាង ........ ២០
ក. ភស្តុតាងផ្ទាល់ ........ ២០
ខ. ភស្តុតាងប្រយោល ........ ២០
គ. ភស្តុតាងបង្ហាញ ........ ២១
ឃ. ភស្តុតាងទស្សនៈ ........ ២១
ង. ភស្តុតាងដែលបានដឹង ឮតៗគ្នា ........ ២១
ច. ភស្តុតាងដាក់បន្ទុក ........ ២១
ឆ. ភស្តុតាងដោះបន្ទុក ........ ២២
ជ. ភស្តុតាងប្រវេសនីយ ........ ២២
៥.៣. ទម្ងន់របស់ទម្រង់នីមួយៗនៃភស្តុតាង ........ ២២
ក. ទម្ងន់នៃភស្តុតាងផ្ទាល់ ........ ២២
ខ. ទម្ងន់នៃភស្តុតាងប្រយោល ........ ២២
គ. ទម្ងន់នៃភស្តុតាងបន្ទាប់បន្សំ ........ ២៣
**ផ្នែកទី២. ប្រភេទភស្តុតាង ឬប្រព័ន្ធភស្តុតាង ........ ២៣**
**កថាខណ្ឌទី១. ការបំភ្លឺរបស់សាក្សី ........ ២៥**
១.១. ប្រភេទបុគ្គលអាចក្លាយជាសាក្សី ........ ២៨
១.២. សិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី ........ ៣០
ក. ការបង្ហាញខ្លួនរបស់សាក្សី ........ ៣០
ខ. សិទ្ធិនានារបស់សាក្សី ........ ៣២
គ. កាតព្វកិច្ចពិសេសរបស់សាក្សី ........ ៣៤
ឃ. សាក្សីមានកាតព្វកិច្ចនិយាយតែការពិត ........ ៣៦
១.៣. ការវាយតម្លៃលើការបំភ្លឺរបស់សាក្សី ........ ៣៦
១.៤. កត្តានានាដែលមានឥទ្ធិពលទៅលើភាពត្រឹមត្រូវនៃការបំភ្លឺរបស់សាក្សី ........ ៣៧
ក. គុណសម្បត្តិនៃការយល់ដឹង និងគុណសម្បត្តិនៃការចងចាំ ........ ៣៨
ខ. រោគសញ្ញាផ្សេងៗដែលប៉ះពាល់ដល់ប្រព័ន្ធប្រសាទ និងផ្លូវចិត្ត ........ ៣៩
គ. គុណភាពនៃការដឹងភ្លាមៗរបស់សាក្សី ........ ៣៩
ឃ. ការរៀបចំទីតាំង និងការតាំងសំនួរនានាទៅលើសាក្សី ........ ៤១

១.៥. ការបំភ្លឺនានារបស់សាក្សីដែលមានអាយុតិច ឬកុមារ ....................................................៤៣
**កថាខណ្ឌទី២. សេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ និងការបំភ្លឺរបស់អ្នកជំនាញ** ........................... ៤៤
២.១. កម្មវត្ថុនៃការបំភ្លឺរបស់អ្នកធ្វើកោសល្យវិច្ច័យ(អ្នកជំនាញ)និងសេចក្តីសន្និដ្ឋានរបស់គាត់......... ៤៤
ក.អត្ថន័យនៃសេចក្តីសន្និដ្ឋាន ........................................................................................ ៤៥
ខ. ប្រភេទនៃការធ្វើកោសល្យវិច្ច័យ ................................................................................. ៤៦
២.២. ការផ្ទៀងផ្ទាត់ទៅលើសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ ................................................... ៤៨
២.៣. ការវាយតម្លៃទៅលើសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ...................................................... ៤៨
**កថាខណ្ឌទី៣. ភស្តុតាងជាវត្ថុ**................................................................................................ ៤៨
៣.១. អត្តិភាពពិសេសនៃភស្តុតាងជាវត្ថុ ................................................................................ ៤៩
៣.២. ប្រភេទនៃទ្រព្យនានាដែលជាកម្មវត្ថុនៃភស្តុតាងជាវត្ថុ........................................................ ៥១
ក. ប្រភេទទ្រព្យដែលមិនអាចប្រគល់វិញ.......................................................................... ៥១
ខ. ប្រភេទនៃទ្រព្យដែលអាចប្រគល់វិញបាន ................................................................... ៥២
**កថាខណ្ឌទី៤. ការបំភ្លឺរបស់ជនរងគ្រោះ**..................................................................................៥៣
៤.១.ខ្លឹមសាររួមនៃការបំភ្លឺរបស់ជនរងគ្រោះ.............................................................................៥៣
៤.២. កម្មវត្ថុនៃការបំភ្លឺរបស់ជនរងគ្រោះ ..................................................................................៥៣
៤.៣. ឥទ្ធិពលពីខាងក្រៅរបស់ជនរងគ្រោះ ............................................................................... ៥៤
៤.៤. ឥទ្ធិពលផ្ទាល់ដែលលេចចេញពីជនរងគ្រោះ ....................................................................... ៥៦
ក. ករណីជនរងគ្រោះស្លាប់ .......................................................................................... ៥៦
ខ. ករលើជនរងគ្រោះជាកុមារមានអាយុតិច ......................................................................៥៧
៤.៥. ការវាយតម្លៃលើការបំភ្លឺរបស់ជនរងគ្រោះ ........................................................................ ៥៨
**កថាខណ្ឌទី៥. កំណត់ហេតុអង្កេត និងឯកសារសំណោរនានា** ..................................................... ៥៩
៥.១.កំណត់ហេតុអង្កេត ....................................................................................................... ៥៩
៥.២. ឯកសារសំណោរនានា................................................................................................. ៦១
កថាខណ្ឌទី៦. សេចក្តីពន្យល់ផ្ទាល់របស់ជនជាប់ចោទ ................................................................... ៦២
**ជំពូកទី ២.នីតិវិធីនៃការប្រមូលភស្តុតាងនិងការបង្ហាញភស្តុតាង** ............................................ ៦៥
**ផ្នែកទី ១. ការស៊ើបអង្កេតស្រាវជ្រាវប្រមូលភស្តុតាង** ............................................................... ៦៥
**កថាខណ្ឌទី១. ការស៊ើបអង្កេតដោយមន្ត្រីនគរបាលយុត្តិធម៌** ..................................................... ៦៥
១.១. ការស៊ើបអង្កេតបទល្មើសជាក់ស្តែង ដោយមន្ត្រីនគរបាលយុត្តិធម៌............................. ៦៥

១.១.១. ការចុះទៅកាន់ទីកន្លែងកើតហេតុ ........ ៦៥
១.១.២. ការធ្វើកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ........ ៦៦
១.១.៣. វិធាននៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង ........ ៦៦
ក. វិធានទាក់ទងនឹងការឆែកឆេរ ........ ៦៦
ខ. ការបិទស្លាកបោះត្រាលើភស្តុតាង ........ ៦៧
គ. កំណត់ហេតុនៃការស្តាប់ចម្លើយ ........ ៦៧
ឃ. ការស្តាប់ចម្លើយជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ........ ៦៧
ង. ការស្តាប់ចម្លើយសាក្សី ........ ៦៧
ច. ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ ........ ៦៨
ឆ. ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា ........ ៦៨
១.២. ការស៊ើបអង្កេតបឋមដោយមន្ត្រីនគរបាលយុត្តិធម៌ ........ ៦៨
១.២.២. កំណត់ហេតុ ឬរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ........ ៦៨
១.២.៣. តម្លៃកំណត់ហេតុ ឬរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ........ ៦៩
១.៣. ការរំលោភនីតិវិធី ........ ៦៩
១.៤. ការស្រាវជ្រាវ និងប្រមូលភស្តុតាងដោយតំណាងអយ្យការ ........ ៧០
១.៤.១. ការចុះដល់កន្លែងកើតហេតុ ........ ៧១
១.៤.២. ការចាត់ឲ្យស៊ើបអង្កេតបឋម ........ ៧១
១.៤.៣. ការចាត់ឲ្យស៊ើបសួរដោយតំណាងអយ្យការ ........ ៧១
ក. ដីកាសន្និដ្ឋានចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ........ ៧២
ខ. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ........ ៧២
គ. ដីកាសន្និដ្ឋានស្ពាព ........ ៧៣
**កថាខណ្ឌទី២. ការស្រាវជ្រាវ និងប្រមូលភស្តុតាងដោយចៅក្រមស៊ើបសួរ** ........ ៧២
២.១. ដំណើការស៊ើបសួរ ........ ៧៤
២.២. ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យ ........ ៧៤
ក. ករណីគ្មានខ្លួន ........ ៧៥
ខ. ករណីមានខ្លួន ........ ៧៥
២.៣. ការឃុំខ្លួនបណ្តោះអាសន្ន ........ ៧៦
២.៤. ការសួរចម្លើយ និងការស្តាប់ចម្លើយ ........ ៧៦

២.៤.១. ការសួរចម្លើយជនត្រូវចោទ ............................................................ ៧៦
២.៤.២. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ............................................... ៧៧
២.៤.៣. ការស្តាប់ចម្លើយសាក្សី.................................................................. ៧៨
២.៥. ការឆែកឆេរ និងការចាប់យកវត្ថុតាង.................................................... ៧៨
២.៥.១. ការស្តាប់ទូរស័ព្ទ .......................................................................... ៧៨
២.៦. ដីកាចាត់ឲ្យស៊ើបសួរជំនួស ................................................................ ៧៩
២.៧. ដីកាសម្រេចឲ្យនៅក្រៅឃុំ.................................................................... ៨០
២.៧.១. កាដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ.............................. ៨០
២.៨. ការបិទការស៊ើបសួរ............................................................................ ៨១
២.៨.១. ដីកាដំណោះស្រាយ ......................................................................... ៨១
២.៨.២. ដីកាដំណោះស្រាយបញ្ជប់ .................................................................. ៨១
**ផ្នែកទី ២. ការបង្ហាញ និងការវាយតម្លៃលើភស្តុតាង** ................................................ ៨២
**កថាខណ្ឌទី១ ការបង្ហាញភស្តុតាង** .............................................................. ៨២
១.១. មធ្យោបាយនៃការបង្ហាញភស្តុតាង ........................................................ ៨២
១.១.១.ភស្តុតាងដែលបង្ហាញតាមរយៈសាក្សី ......................................................៨៣
១.១.២. ការសារភាព........................................................................................៨៣
១.១.៣. ការពិនិត្យគ្រប់មុខសញ្ញា ..........................................................................៨៣
១.២. លក្ខខណ្ឌនៃការបញ្ជាក់ភស្តុតាង និងការបង្ហាញភស្តុតាង ................................ ៨៤
១.២.១. វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ........................................ ៨៤
១.២.២. ការផ្ទៀងផ្ទាត់ភស្តុតាង ........................................................................ ៨៦
ក. ការផ្ទៀងផ្ទាត់ភស្តុតាង............................................................................ ៨៦
ខ. ការប្រដូចគ្នានៃភស្តុតាង ........................................................................ ៨៦
គ. ការផ្ទៀងផ្ទាត់ទៅលើប្រភពនៃភស្តុតាង.......................................................៨៧
គ.១. អំពីអត្ថិភាព ឬនត្ថិភាពនៃប្រភេទអង្គហេតុ............................................... ៨៨
គ.២. អំពីហេតុផលនៃអត្ថិភាព និងនត្ថិភាពចំពោះអង្គហេតុ ................................ ៨៨
**កថាខណ្ឌទី២. ការវាយតម្លៃទៅលើភស្តុតាង** .................................................... ៨៩
២.១. វិធីសាស្រ្តក្នុងការវាយតម្លៃលើភស្តុតាង .................................................... ៨៩
២.១.១. លក្ខណៈក្នុងការវាយតម្លៃ................................................................... ៩០

ក. ការវិភាគចំពោះភស្តុតាង ........ ៩១
ខ. ការចែកជាផ្នែកចំពោះភស្តុតាង ........ ៩១
គ. ការចែកជាផ្នែកឱ្យដាច់ពីគ្នានៃភស្តុតាង ........ ៩១
ឃ. ការប្រៀបធៀបតាមលំដាប់ ........ ៩២
ង. ការធ្វើសំយោគទៅលើភស្តុតាង ........ ៩២
២.១.២. ការជឿជាក់ទៅលើភស្តុតាង ........ ៩២
២.២. ភស្តុតាងពេញលេញ ឬលក្ខណៈពេញលេញនៃភស្តុតាង ........ ៩៣
២.២.១. លក្ខណៈគ្រប់គ្រាន់នៃភស្តុតាង ........ ៩៣
២.៣. អានុភាពនៃការវាយតម្លៃលើភស្តុតាង ........ ៩៤
២.៣.១. អានុភាពនៃការវាយតម្លៃដោយតំណាងអយ្យការចំពោះភស្តុតាង ........ ៩៥
២.៣.២. អានុភាពនៃការវាយតម្លៃដោយចៅក្រមស៊ើបសួរចំពោះភស្តុតាង ........ ៩៥
២.៣.៣. អានុភាពនៃវាយតម្លៃក្នុងពេលជំនុំជម្រះ ........ ៩៥
២.៣.៤. អានុភាពនៃការសម្រេចលើកលែងការចោទប្រកាន់ ........ ៩៦
២.៤. ការមោឃភាពចំពោះកិច្ចនៃនីតិវិធី ........ ៩៦
២.៤.១. ការសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលសភាស៊ើបសួរលើកមកជំនុំជម្រះ ........ ៩៧
២.៤.២. ការបង្ហាញភស្តុតាងដាក់បន្ទុកក្នុងពេលសវនាការ ........ ៩៧
២.៤.៣. បន្ទុកជាចម្បងរបស់ព្រះរាជអាជ្ញា ........ ៩៧
២.៥. បន្ទុកបង្ហាញភស្តុតាងជាបន្ទាប់បន្សំ ........ ៩៨
**សេចក្តីសន្និដ្ឋាន** ........ ៩៩
**អនុសាសន៍** ........ ១០១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលប្រកាន់យករបបលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដោយគោរពសិទ្ធិមនុស្សដូចដែលមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិ, កតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិទាំងឡាយដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស, សិទ្ធិនារី និងសិទ្ធិកុមារ។ ដូច្នេះសិទ្ធិសេរីភាព និងអាយុជីវិតមនុស្សម្នាក់ៗ គឺត្រូវបានធានាដោយច្បាប់ ពោលគឺមនុស្សម្នាក់ៗមានសិទ្ធិសេរីភាពក្នុងការរស់រានមានជីវិតនិងសន្តិសុខផ្ទាល់ខ្លួន។ ក៏ប៉ុន្តែក្នុងសង្គមនីមួយៗតែងតែមាននូវអំពើរំលោភបំពានទៅលើសិទ្ធិក៏ដូចជាអំពើដែលប៉ះពាល់ដល់សន្តិសុខរបស់បុគ្គលណាមួយផ្សេងទៀតដែលយើងអាចហៅបានថាជាបទល្មើស។ ស្ថាប័នតុលាការ ជាអ្នកមានសិទ្ធិអំណាចក្នុងការផ្តន្ទាទោសទៅលើជនទាំងឡាយណាដែលបានប្រព្រឹត្តនូវបទល្មើសដែលនាំឲ្យប៉ះពាល់ដល់អ្នកដទៃ ក៏ដូចជាសណ្តាប់ធ្នាប់សាធារណៈ។

នៅពេលណាដែលមានមានរឿងក្តីមួយបានកើតឡើងហើយជាប្រភេទរឿងក្តីព្រហ្មទណ្ឌផង គឺប្រាកដណាស់ទាមទារអោយអ្នកអនុវត្តន៍ច្បាប់ ដែលមានសិទ្ធអំណាចអនុវត្តន៍សិទ្ធអំណាចរបស់ខ្លួនអោយត្រឹមត្រូវនឹងមានមូលដ្ឋានច្បាប់ច្បាស់លាស់។

**ភស្តុតាង** គឺសំខាន់បំផុតចំពោះកាតព្វកិច្ចរបស់ស្ថាប័នតុលាការក្នុងការដោះស្រាយរឿងក្តី ហើយច្បាប់ក៏បានកំណត់ឲ្យតុលាការអនុវត្តតាមនីតិវិធីក្នុងការប្រមូលការពិនិត្យការវាយតម្លៃ និងទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួនផងដែរចំពោះភស្តុតាងក្នុងរឿងក្តីព្រហ្មទណ្ឌ។

ស្ថាប័នតុលាការគឺជាស្ថាប័នមួយ ដែលផ្តល់នូវយុត្តិធម៌ជូនពលរដ្ឋគ្រប់រូបដូចនេះហើយមុននឹងឈានទៅរកការចេញសេចក្តីសម្រេច និងផ្តន្ទាទោសទៅលើជនណាម្នាក់នោះស្ថាប័នតុលាការត្រូវមាននីតិវិធីក្នុងការស្រាវជ្រាវរកឬស៊ើបរកនូវ**ភស្តុតាង** ដែលបញ្ជាក់ពីកំហុសរបស់ជននោះឲ្យបានច្បាស់លាស់ ហើយលើសពីនេះដើម្បីអោយការអនុវត្តន៍បានត្រឹមត្រូវទៅតាមយុត្តិការនៅក្នុងវិស័យយុត្តិធម៌ផងគឺ មានមូលដ្ឋានយ៉ាងច្បាស់លាស់។

ដោយយល់ឃើញថា ភស្តុតាងមានសារៈសំខាន់ក្នុងរឿងក្តីនីមួយៗទើបយើងខ្ញុំជានិស្សិតឆ្នាំទី៤ បានខិតខំរៀបចំនូវសារណាមួយឡើងក្រោមប្រធានបទ "**ភស្តុតាងក្នុងរឿងក្តីព្រហ្មទណ្ឌ**" ដើម្បីទុកជាឯកសារសម្រាប់អ្នកសិក្សាគ្រប់កម្រិតនិងសម្រាប់តម្រូវការផ្សេងៗ ព្រោះភស្តុតាងគឺដើរតួរយ៉ាងសំខាន់សម្រាប់ស្ថាប័នតុលាការក្នុងការដាក់បន្ទុក ឬដោះបន្ទុកចំពោះភាគីណាមួយនៅក្នុងរឿងក្តីដើម្បីចេញសេចក្តីសម្រេច និងផ្តន្ទាទោសទៅលើជនល្មើសប្រកបដោយសុក្រឹត្យនិងយុត្តិធម៌ ព្រមទាំងផ្តល់នូវសំណងជម្ងឺចិត្តជូនជនរងគ្រោះឲ្យសមស្របទៅនឹងព្យសនកម្មដែលជនរងគ្រោះបានទទួលម៉្យាងទៀតគឺ ដើម្បីការពារសណ្តាប់ធ្នាប់សង្គមឲ្យបានល្អផងដែរ។

តាមការសិក្សាស្រាវជ្រាវកន្លងមកយើងខ្ញុំនឹងខិតខំប្រឹងប្រែងធ្វើការបង្ហាញ និងអធិប្បាយឲ្យបានលម្អិត និងមានភាពច្បាស់លាស់ទៅលើចំណុចមួយចំនួនដែលក្នុងនោះរួមមាន ៖

**ជំពូកទី ១៖ គោលការណ៍ទូទៅនៃភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ**

**ជំពូកទី ២៖ ការស្រាវជ្រាវស្វែងរកភស្តុតាង និងការបង្ហាញភស្តុតាង**

ចំពោះខ្លឹមសារលម្អិតនៃជំពូកនីមួយៗខាងលើនេះ និងមានការអធិប្បាយព្រមទាំងបង្ហាញជូនទាំងស្រុងនៅក្នុងអត្ថន័យនៃសារណាបញ្ចប់ការសិក្សារបស់ក្រុមយើងខ្ញុំដូចដែលមានការរៀបរាប់ខាងក្រោមដូចតទៅ៖

# ជំពូកទី ១

# គោលការណ៍ទូទៅនៃភស្តុតាង

## ផ្នែកទី១. គោលការណ៍ទូទៅនៃភស្តុតាង

### កថាខណ្ឌទី១. និយមន័យនៃភស្តុតាង

ភស្តុតាង គឺជាព្រឹត្តិហេតុ ឬអង្គហេតុទាំងឡាយដែលអង្គហេតុទាំងនោះត្រូវបានកំណត់ដោយច្បាប់ទៅលើទម្រង់នីតិវិធីនានារបស់វា ដើម្បីធ្វើការបង្ហាញ ឬបដិសេធន៍ទៅលើព្រឹត្តិការណ៍នៃបទល្មើសណាមួយបាន ដោយអង្គហេតុទាំងនោះបង្ហាញនូវការដាក់បន្ទុក «ឃោរឃៅ» ឬដោះបន្ទុកដោះសារចំពោះការទទួលខុសត្រូវរបស់បុគ្គល ព្រមទាំងកំណត់បាននូវ កំរិតខ្ពស់ ឬទាប និង ធ្ងន់ ឬស្រាលទៅលើការទទួលខុសត្រូវរបស់បុគ្គលទាំងនោះទៀតផង[1]។ នេះបង្ហាញថា ភស្តុតាងគឺជាព្រឹត្តិហេតុ ឬអង្គហេតុទាំងឡាយណាដែលទម្រង់នីតិវិធីនៃការបង្ហាញអង្គហេតុទាំងនោះត្រូវបានកំណត់ដោយច្បាប់។ ទម្រង់នីតិវិធីក្នុងការបង្ហាញនេះធ្វើឲ្យឃើញកាន់តែច្បាស់អំពីអំពើល្មើសណាមួយ ឬក៏ធ្វើឲ្យមានការបដិសេធន៍ចំពោះបទល្មើសណាមួយបាន ដោយក្នុងនោះអង្គហេតុបែបនេះវាបញ្ជាក់បាននូវការដាក់បន្ទុក ឬបដិសេធតាមរយៈនៃអំពើដែលមានលក្ខណៈឃោរឃៅ ឬលក្ខណៈដោះសារចំពោះការទទួលខុសត្រូវរបស់បុគ្គល។ ជាពិសេសទម្រង់នីតិវិធីនៃការបង្ហាញនេះស្តែងបាននូវការកំរិតអំពីស្ថាននានានៃអំពើរបស់បុគ្គល ដែលបានប្រព្រឹត្តិនោះ ធ្វើឲ្យចៅក្រមអាចកំរិតបាននូវស្ថាននានាក្នុងការកំណត់ទោសទាប ឬខ្ពស់បានទៀតផង។ តាមនិយមន័យនេះលោក «ហ្វាយនីតស្គី.អ៊ី.យ៉ា»(Fojnickij Ivanovich Jakovlevich) កើតនៅឆ្នាំ១៨៤៧ ស្លាប់ឆ្នាំ១៩១៣ជាអ្នកជំនាញឧក្រឹដ្ឋនិច្ឆ័យដ៏ល្បីល្បាញជនជាតិរុស្សីបានសរសេរថា «ដើម្បីលុបចោលនូវភាពគ្រោះថ្នាក់ដល់ដំណើរការយុត្តិធម៌របស់តុលាការ ឬក៏យ៉ាងហោចណាស់ធ្វើឲ្យកាន់តែខ្សោយទៅៗនៃភាពគ្រោះថ្នាក់ទាំងឡាយដោយសារតែមូលហេតុនៃភាពខុសឆ្គងម្តងម្កាល ឬការភ័ន្តច្រឡំក្នុងការធ្វើសេចក្តីសម្រេចរបស់តុលាការ នោះចាំបាច់ត្រូវតែមានការគិតយ៉ាងល្អិតល្អន់ និងប្រកបដោយភាពរឹងមាំបំផុតទៅលើភស្តុតាងដែលជាមធ្យោបាយដ៏រឹងមាំក្នុងការអះអាងរបស់តុលាការ។ ភស្តុតាងទាំងឡាយដែលមិនជឿទុកចិត្តបាន វាអាចនាំឲ្យតុលាការធ្វើសេចក្តីសម្រេចមានភាពខុសឆ្គងទៅតាមវិធីកុហកមួយដល់សាធារណជន»។ គំនិតនេះមានន័យថាមិនត្រូវចាប់បង្ខំឲ្យមនុស្សមានកំហុសតាមតែទំនើងចិត្តរបស់តុលាការនោះទេ ប្រសិនបើបុគ្គលមិនបានប្រព្រឹត្ត ឬក៏គ្មានការបញ្ជាក់

[1] ក្រមនីតិវិធីព្រហ្មទណ្ឌៈ ស្មារតីមាត្រា១កថាខណ្ឌ១ **ក្រមនីតិវិធីព្រហ្មទណ្ឌ មានគោលបំណងកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ដើម្បីកំណត់អោយច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ ។** និងក្រមព្រហ្មទណ្ឌស្មារតីមាត្រា២៤ **បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ ។**

ដោយភស្តុតាង។ ចរិតនៃការបង្ខំឲ្យមានទោសបែបនេះត្រូវបានឆ្លុះ បញ្ចាំងដោយគំនិតលោក សេណេកា (Licius Annaeus Sereka) ជាអ្នកប្រាជ្ញបូរាណរ៉ូមកើតប្រហែល ៨ឆ្នាំមុនគ្រឹស្តសករាជ ហើយស្លាប់ក្នុងឆ្នាំ៦៥នៃគ្រឹស្តសករាជយើងនេះបានសរសេរថា «កំហុសដែលកើតឡើងដោយការបង្ខំនៃឥទ្ធិពលពីខាងក្រៅណាមួយ កំហុសនោះពុំមែនជាអំពើចេតនារបស់បុគ្គលនោះទេ»។ គំនិតរបស់លោកបានឆ្លុះបញ្ចាំងអំពីការកកើតនៃអង្គ ហេតុមួយបញ្ជាក់បាននូវខ្លឹមសារដោយឯករាជ្យ។

## កថាខណ្ឌទី២. សញ្ញាណទូទៅនៃភស្តុតាង

### ២.១. ព្រឹត្តិការណ៍

ក្នុងអត្ថន័យនៃព្រឹត្តិការណ៍នេះ គឺសំដៅទៅលើសកម្មភាពនៃទំនាក់ទំនងជាមិត្ត ឬជាអមិត្ត រវាងភាគីរងគ្រោះ និងភាគីល្មើស ហើយដែលព្រឹត្តិការណ៍នេះបានសុះសាយ ឬលាន់ឮ ព្រមទាំងលាតត្រដាងយ៉ាងច្បាស់លាស់ដល់សាធារណៈជន។ តាមន័យនេះក្រមនីតិវិធីព្រហ្មទណ្ឌបានកំនត់ក្នុងមាត្រា១១១ថា «កាលណាបានដឹងពីអំពើដែលអាចជាបទឧក្រិដ្ឋ ឬបទ មជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេត...»។ និងមាត្រា៣៥៧ កថាខណ្ឌទី២ វាក្យខណ្ឌ១បានចែងថា«អង្គហេតុត្រូវតែច្បាស់លាស់ និងគ្មានការសង្ស័យ»។ ពាក្យថា«បានដឹងពីអំពើ និងអង្គហេតុត្រូវតែច្បាស់លាស់» នេះគឺវាបញ្ជាក់នូវការកកើតព្រឹត្តិការណ៍ណាមួយរួចទៅហើយ តែពុំមានន័យថាចង់បង្ហាញអំពីព្រឹត្តិការណ៍ដែលនឹងកកើតនោះទេ។

ចំពោះពាក្យថា«ទំរង់នីតិវិធីវិញ វាជាមធ្យោបាយក្នុងការទទួលបាននូវភស្តុតាងត្រឹមត្រូវតាមច្បាប់ដូចមានចែងក្នុងគន្លឹះទី៣«ការស៊ើបអង្កេត»មាតិកាទី១ជំពូក២ និងមាតិកាទី៣ ជំពូកទោល។ ចំពោះគន្លឹះទី៤វិញ វាបញ្ជាក់អំពី«ការស៊ើបសួរ»មាតិកាទី១ ជំពូក២ ផ្នែកទី២ រហូតដល់ផ្នែកទី៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ នៅក្នុងគន្លឹះទី៣ និងទី៤នេះវាបញ្ជាក់យ៉ាងច្បាស់លាស់អំពីបែបបទក្នុងការចងក្រងនូវសំណុំរឿងក្តីព្រហ្មទណ្ឌសម្រាប់តុលាការដែលការចងក្រង ឬបង្កជាសំណុំរឿងក្តីព្រហ្មទណ្ឌបែបនេះគេហៅថា «ទំរង់នីតិវិធីនៃការបង្ហាញអង្គហេតុ»។ តាមរយៈនៃទម្រង់នីតិវិធីក្នុងការបង្ហាញអង្គហេតុនេះ ធ្វើឲ្យតុលាការបានយល់ដឹងអំពីខណៈនានានៃអំពើរបស់ជនល្មើស ហើយអាចកំណត់បាននូវកំរិតទោស និងស្ថាននានាចំពោះការទទួលខុសត្រូវរបស់បុគ្គលដែលបានប្រព្រឹត្តិអំពើទាំងនោះ ។

### ២.២ ការដាក់បន្ទុក និងការដោះបន្ទុក

ខ្លឹមសារនៃការដោះបន្ទុក និងការដាក់បន្ទុកនេះគឺជាភារកិច្ចរបស់បុគ្គលដែលមានអំណាចតាមផ្លូវច្បាប់ ដើម្បីបង្ហាញនូវការពិតទៅលើរបកគំហើញនានាដែលខ្លឹមសារនោះបានកើតចេញពី

ព្រឹត្តិការណ៍ណាមួយដោយព្រឹត្តិការណ៍នោះជាប្រភពឯកឯង[2]។ ក្នុងន័យនេះ ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពីការស៊ើបសួររបស់ចៅក្រមតាមមាត្រា១២៧ ថា «ចៅក្រមស៊ើបសួរ បំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថា មានប្រយោជន៍សំរាប់បង្ហាញឱ្យឃើញការពិតដោយអនុលោមតាមច្បាប់។

ចៅក្រមស៊ើបសួរមានករណីយកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក»។ រីឯមាត្រា ៣៥០ក៏បានកំនត់អំពីសមត្ថកិច្ចជំនុំជម្រះតាមកថាខណ្ឌ២ និង៣ថា «ប្រសិនបើពិនិត្យឃើញថាមានពិរុទ្ធភាពលើជនជាប់ចោទ តុលាការប្រកាសផ្តន្ទាទោសតាមច្បាប់បញ្ញតិ។ ប្រសិនបើតុលាការយល់ឃើញថាអំពើនោះមិនមែនជាបទល្មើសទេ ឬក៏ជនជាប់ចោទគ្មានកំហុសទេ ជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ»។ ចំពោះមាត្រា៣២៥ កថាខណ្ឌ១ វាក្យខណ្ឌទី៣ បានកំណត់ថាប្រធានសវនាការមានករណីយកិច្ចសួរចម្លើយជនជាប់ចោទនេះទាំងខាងផ្នែកដាក់បន្ទុកទាំងខាងផ្នែកដោះបន្ទុក»។

សូមបញ្ជាក់ថា ការដាក់បន្ទុកឬដោះបន្ទុកមិនមែនជាកាតព្វកិច្ចរបស់ភាគីរងគ្រោះ និងភាគីជនល្មើសនោះឡើយតែជាកាតព្វកិច្ចរបស់មន្ត្រីអនុវត្តច្បាប់។ មន្ត្រីអនុវត្តច្បាប់ជាបុគ្គលដែលរដ្ឋផ្តល់សិទ្ធិអំណាចឲ្យបំពេញកិច្ចក្នុងលក្ខខណ្ឌដែលច្បាប់កំណត់។ បុគ្គលប្រភេទនេះសុទ្ធតែមានអំណាចសាធារណៈដូចជា៖ ចៅក្រមជាមន្ត្រីអនុវត្តច្បាប់ដែលស្ថិតនៅក្នុងលក្ខខណ្ឌនៃកិច្ចវិនិច្ឆ័យ រីឯមន្ត្រីស៊ើបអង្កេតស្ថិតនៅក្នុងលក្ខខណ្ឌនៃកិច្ចស៊ើបអង្កេត និងរុករកដោយមន្ត្រីបែបនេះមានដូចជា៖ មន្ត្រីនគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញាជាដើម។ ប៉ុន្តែក៏មិនមានន័យថា ភាពគ្មានពិរុទ្ធ ឬក៏ភាពមានពិរុទ្ធចំពោះបុគ្គលណាមួយអាស្រ័យទៅនឹងឆន្ទៈរបស់សមត្ថកិច្ចនោះឡើយ ប៉ុន្តែវាអាស្រ័យទៅនឹងវត្តមាននៃអង្គហេតុតែប៉ុណ្ណោះ។ ដោយពាក់ពន្ធ័តែអង្គហេតុនេះហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌបានចងកាតព្វកិច្ចរបស់ស្ថាប័នអយ្យការទៅនឹងអង្គហេតុនានានោះតាមបញ្ញត្តិមាត្រា ១២៥ ក្នុងកថាខណ្ឌទី១វាក្យខណ្ឌ១ និង២ថា «ចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុនោះប៉ុណ្ណោះ»។ ចំណុចនេះបង្ហាញថា ក្នុងកិច្ចផ្តើមចំពោះការស៊ើបអង្កេតទៅលើបទល្មើសព្រហ្មទណ្ឌអាចធ្វើទៅបានលុះត្រាតែមានអង្គហេតុសង្ស័យ។

[2] ពាក្យថា**ប្រភពឯកឯង** នៅក្នុងន័យនេះគឺសំដៅទៅរកខ្លឹមសារនៃឯករាជ្យភាពចំពោះភស្តុតាង ។ ការប្រកាន់យកគោលការណ៍ នេះដោយផ្អែកលើទស្សនៈធំៗពីរគឺ៖ **គ្មានអ្នកណាម្នាក់ក្លាយខ្លួនជាចៅក្រមនៅក្នុងសំណុំរឿងរបស់ខ្លួនបានឡើយ** និងទស្សនៈ ទីពីរ**គ្មានបុគ្គលណាម្នាក់ក្លាយជាវរជននៅក្នុងព្រឹត្តិការណ៍ ដែលខ្លួនបង្កើតនោះឡើយ** ។ ជាពិសេសទស្សនៈបែបនេះត្រូវ ជៀសវាងនូវការប្រឌិតអង្គហេតុ ឬប្រឌិតព្រឹត្តិការណ៍ ។ អង្គហេតុដែលប្រឌិតគ្មានកម្មវត្ថុក្នុងការបញ្ជាក់សក្ខីកម្មទេ។

## ២.៣. បន្ទុកនៃភស្តុតាងឬកាតព្វកិច្ចនៃការបង្ហាញភស្តុតាង

### ក. ខ្លឹមសារទូទៅចំពោះបន្ទុកភស្តុតាង

កាតព្វកិច្ចនៃការបង្ហាញភស្តុតាង គឺជាវិធានដែលបានបង្កប់នូវអត្ថន័យដ៏ពិសេសសំខាន់បំផុត។ តាមខ្លឹមសារនៃវិធានេះជាភាសាឡាតាំងថា «Onus probandi» ដែលពាក្យនេះមានន័យថា «បន្ទុកនៃភស្តុតាង ឬកាតព្វកិច្ចនៃការបង្ហាញភស្តុតាង»។ ដោយយោងតាមគោលការណ៍សច្ចធារណ៍នៃនិរទោសដែលមានខ្លឹមសារថា «ជនជាប់ចោទចាត់ទុកថាគ្មានកំហុសដរាបណាកំហុសរបស់ជននោះនឹងមិនត្រូវបានរកឃើញ»។ ប៉ុន្តែវាលេចចេញពីលក្ខខណ្ឌនេះត្រូវមានកាតព្វកិច្ចក្នុងការបង្ហាញនូវកំហុសរបស់ជនជាប់ចោទតាមរយៈនៃការបំពេញកិច្ចរបស់ស្ថាប័ន ដែលមាននាទីជាអ្នកធ្វើការចោទប្រកាន់ទៅលើជនដែលត្រូវបានចោទនោះ»។ ចំពោះជនដែលត្រូវបានចោទប្រកាន់នេះមិនមានបន្ទុក ឬកាតព្វកិច្ចបង្ហាញនូវភាពគ្មានកំហុសរបស់ខ្លួននោះឡើយ។ ប៉ុន្តែជនជាប់ចោទមានសិទ្ធិដោះសារចំពោះការចោទប្រកាន់មកលើខ្លួន ដើម្បីបង្ហាញថាខ្លួនគ្មានកំហុសតាមការចោទប្រកាន់នោះបាន ប៉ុន្តែការដោះសារបែបនេះគឺជាសិទ្ធិពុំមែនមានន័យថាជាកាតព្វកិច្ចរបស់ជនជាប់ចោទនោះឡើយ។ ដោយហេតុនេះហើយ ប្រសិនបើជនដែលត្រូវបានចោទប្រកាន់រូបណាមួយមិនបានបញ្ជាក់ជាមុនទាន់ពេលវេលាអំពីភស្តុតាងទាំងឡាយដើម្បីធ្វើការដោះសារ ឬបដិសេធន៍ចំពោះការចោទប្រកាន់ ពីអង្គការស៊ើបអង្កេត ឬតុលាការដោយសារតែមានហេតុផល ឬខណៈផ្សេងៗ (Circumstance)ធ្វើជាឧបសគ្គនាំឲ្យគាត់មិនអាចធ្វើការបញ្ជាក់ភស្តុតាងពីដំបូងៗបាន ឧបសគ្គបែបនេះមិនអាចយកមកធ្វើជាលេសរបស់ស្ថាប័នស៊ើបអង្កេត ឬតុលាការក្នុងការដាក់បន្ទុកទៅលើជនជាប់ចោទរូបនោះបានទេ។ ហេតុផល ឬខណៈទាំងឡាយដែលគាត់មិនអាចធ្វើការបញ្ជាក់សក្ខីកម្មបានពីដំណាក់កាលដំបូងៗនេះ មិនអាចយកមកធ្វើជាភស្តុតាងក្នុងការដាក់បន្ទុក ឬដាក់ទោសទៅលើរូបគាត់បានឡើយ ពីព្រោះតែតុលាការធ្វើសេចក្តីសម្រេចដោយផ្អែកលើអង្គហេតុ។ គឺថា «ការសន្និដ្ឋានអំពីកំហុសរបស់ជនជាប់ចោទ ត្រូវតែយកចេញពីភស្តុតាងដែលភស្តុតាងនោះត្រូវបានបង្ហាញឲ្យមានលក្ខណៈសមស្របទៅនឹងការចោទប្រកាន់តែពុំមែនសន្និដ្ឋានចេញពីអ្វីៗ ដែលជនត្រូវចោទមិនអាចដោះសារបានទៅលើការចោទប្រកាន់នោះឡើយ»។ មានន័យថាមិនត្រូវយកចំណុចណាមួយដែលជនជាប់ចោទមិនអាចរកអង្គហេតុ មកធ្វើការបដិសេធបានចំពោះការចោទប្រកាន់ ចំណុចនោះមិនអាចចាត់ទុកថាជាកំហុសរបស់ជនជាប់ចោទរូបនោះបានទេ ពីព្រោះសមត្ថកិច្ចជាអ្នកស្វែងរកអង្គហេតុមិនមែនរង់ចាំទទួលយកអង្គហេតុ ដែលជនជាប់ចោទលើកមកបញ្ជាក់នោះឡើយ។

ដូចនេះ «កិច្ចដែលជនជាប់ចោទខកខានមិនបានផ្តល់នូវភស្តុតាងចំពោះភាពគ្មានកំហុសរបស់ខ្លួន កិច្ចដែលបានខកខានបែបនេះមិនអាចចាត់ទុកជាកំហុសរបស់ជនជាប់ចោទនោះបានឡើយ»។ ជាឧទាហរណ៍: ជនជាប់ចោទ "ក" បានរងនូវការចោទប្រកាន់ពីបទលួចរថយន្តមួយគ្រឿង។ នៅក្នុងលំហូរនីតិវិធីនៃតុលាការ ជននេះមិនដែលបានប្រាប់ថា ខ្លួនមានឯកសារទិញលក់ចំពោះរថយន្តនោះទេពីព្រោះគាត់ជាមនុស្សភ្លេចច្រើន។ ហេតុផលដែលនាំឲ្យគាត់មិនបានបង្ហាញឯកសារលក់ទិញនេះមិនមែនជាមូលហេតុយកទៅធ្វើជាភស្តុតាង ដើម្បីដាក់ទោសទណ្ឌនោះឡើយពីព្រោះថា រឿងក្តីព្រហ្មទណ្ឌតម្រូវឲ្យគោរពនូវគោលការណ៍ឆន្ទានុសិទ្ធិរបស់ចៅក្រម និងកាតព្វកិច្ចរបស់ភាគីរដ្ឋ ក៏ប៉ុន្តែក្នុងរឿងក្តីរដ្ឋប្បវេណីវិញត្រូវគោរពគោលការណ៍សិទ្ធិបំភ្លឺរបស់ភាគី (អាចប្រើប្រាស់គោលការណ៍ឆន្ទានុសិទ្ធិរបស់តុលាការបានដែរក្នុងករណីដែលតុលាការចង់ផ្ទៀងផ្ទាត់)។

## ខ. បន្ទុកភស្តុតាងក្នុងដំណាក់កាលស៊ើបអង្កេត

យើងអាចពិនិត្យមើលអំពីការស៊ើបអង្កេតបឋមត្រូវបានរក្សានូវគោលការណ៍មួយដោយ ក្នុងនោះកាតព្វកិច្ចនៃការបង្ហាញភស្តុតាងចំពោះកំហុសរបស់ជនជាប់ចោទគឺជា «បន្ទុកមួយរបស់អ្នកដែលធ្វើការចោទប្រកាន់» (ដូចជាស្ថាប័នអយ្យការ ឬអង្គការចោទប្រកាន់ផ្សេងៗទៀត) ក៏ប៉ុន្តែ «អង្គការនេះពុំមែនមានកាតព្វកិច្ចបញ្ជាក់ភស្តុតាងថាគ្មានកំហុសនោះឡើយ» (មើលស្មារតីនៃមាត្រា៥៦, មាត្រា១១១ និងមាត្រា១១២នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ)។

ដូចនេះការអង្កេតបឋម កាតព្វកិច្ចអំពីការបង្ហាញភស្តុតាងចំពោះកំហុសរបស់ជនជាប់ចោទជាបន្ទុកមួយរបស់តំណាងអយ្យការ និងរបស់ចៅក្រមស៊ើបសួរ ហើយ «កាតព្វកិច្ចរបស់ពួកអ្នកទាំងនេះមិនត្រូវអាចបំលែងទៅជាកាតព្វកិច្ចក្នុងការបង្ហាញភស្តុតាងថាគ្មានកំហុស ចំពោះជនជាប់ចោទនោះឡើយ»។ ក្នុងន័យនេះតើតុលាការមានភារកិច្ចក្នុងការបង្ហាញភស្តុតាងដែរ ឬទេ? តាមទ្រឹស្តី ឬគោលការណ៍នេះ តុលាការមិនមានកាតព្វកិច្ចក្នុងការបង្ហាញភស្តុតាងនោះទេ ពីព្រោះថាតុលាការមិនអាចធ្វើសេចក្តីសម្រេច ឬការអះអាងអំពីកំហុសរបស់ជនដែលត្រូវបានចោទប្រកាន់នោះនៅមុនចេញសាលក្រមបានឡើយ»។ ផ្ទុយទៅវិញ «បើសិនជាតុលាការ ធ្វើការអះអាងជាមុនចំពោះកំហុសរបស់ជនជាប់ចោទថាមានទោស នោះពិតណាស់ថាតុលាការធ្វើសកម្មភាពបុរេវិនិច្ឆ័យ ឬលំអៀងរួចទៅហើយ»។

## ២.៤. ដំណើរការនៃសក្ខីកម្ម ឬមធ្យោបាយនៃការបញ្ជាក់ភស្តុតាង

ដំណើរការនៃសក្ខីកម្ម គឺជាមធ្យោបាយនៃការបញ្ជាក់ភស្តុតាងដែលត្រូវបានកំណត់ដោយច្បាប់យ៉ាងជាក់លាក់ដើម្បីធានាភាពត្រឹមត្រូវដល់ប្រភពនៃអង្គហេតុ។ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានកំនត់ខ្លឹមសារនេះតាមមាត្រាជាច្រើននៅក្នុងគន្លឹះទី៣ មាតិកាទី២ «ការស៊ើបអង្កេតករណីជាក់

ស្តែង» និងមាតិកាទី៣ «ការស៊ើបអង្កេតបឋម» រីឯគន្លឺទី៤ និយាយអំពី«ការស៊ើបសួរ»។ សូមបញ្ជាក់ថា មធ្យោបាយនៃការបញ្ជាក់សក្ខីកម្មក្នុងដំណាក់កាលទាំង៤នេះមិនចាំបាច់អនុវត្តតាមលំដាប់លំដោយទេ គឺយកដំណាក់កាលណាមួយមកប្រើក៏បានដែរដោយអាស្រ័យនឹងប្រភេទរឿងក្តីព្រហ្មទណ្ឌតែប៉ុណ្ណោះ។ ការបញ្ជាក់សក្ខីកម្មតាមមធ្យោបាយរបៀបនេះគេអាចហៅថា «ការប្រមូលភស្តុតាង» ដែលជាកន្សោមនៃការបញ្ជាក់សក្ខីកម្មទៅលើអង្គហេតុនីមួយៗ។ ជាទូទៅមធ្យោបាយនៃការបញ្ជាក់ភស្តុតាង (ការបញ្ជាក់សក្ខីកម្ម) ឬការប្រមូលភស្តុតាង នេះកើតចេញតាមដំណាក់កាលជាច្រើន។

## កថាខណ្ឌទី៣. គោលបំណងនៃភស្តុតាង

គោលបំណងនៃភស្តុតាង គឺចង់បង្ហាញអំពីការប្រមូលព័ត៌មានឱ្យបានពេញលេញនិង គ្រប់គ្រាន់ព្រមទាំងឱ្យបានច្បាស់លាស់ និងត្រឹមត្រូវតាមនីតិវិធីនៃច្បាប់ដែលបានបង្កើតនូវទឡ្ហីកក្នុងការកំណត់អំពីអត្ថិភាពនៃបទល្មើស អត្តសញ្ញាណរបស់ជនប្រព្រឹត្តិបទល្មើសហើយឈានទៅដល់ការសម្រេចសេចក្តី របស់តុលាការដោយត្រឹមត្រូវតាមផ្លូវច្បាប់។

ភស្តុតាងក្នុងរឿងក្តីព្រហ្មទណ្ឌ អាចត្រូវបានចាត់ទុកថាមានប្រយោជន៍ និងជឿទុកចិត្តបាន លុះត្រាតែការប្រមូលភស្តុតាងទាំងនោះបានធ្វើទៅតាមលក្ខខណ្ឌគ្រឹះនៃច្បាប់។

តាមស្មារតីនៃក្នុងក្រមនីតិវិធីព្រហ្មទណ្ឌក្នុងមាត្រា១ដែលបង្ហាញពីគោលបំណងនៃការគោរពវិធាន «មានគោលបំណងកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តិតាមដោយហ្មត់ចត់ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ។ បទប្បញ្ញត្តិនៃក្រមនេះត្រូវយកទៅអនុវត្តចំពោះរឿងព្រហ្មទណ្ឌកាលណាពុំមានវិធានដោយឡែកថែងដោយច្បាប់ពិសេសទេនោះ»។

## កថាខណ្ឌទី ៤. គោលការណ៍នៃភស្តុតាង

អត្ថន័យនៃពាក្យថាភស្តុតាង គឺមានបំណកស្រាយមួយចំនួនដូចខាងក្រោមៈ

**ទី១.**គ្រប់ភស្តុតាងអាចចាត់ទុកថាមានប្រយោជន៍ល្អបាន លុះត្រាតែភស្តុតាងទាំងនោះប្រមូលបានមកតាមលក្ខខណ្ឌគ្រឹះនៃច្បាប់នីតិវិធី។ អត្ថិភាពនៃភស្តុតាងដែលប្រមូលបានទាំងនោះមានខ្លឹមសារសមស្របទៅនឹងតម្រូវការទាំងឡាយដែលមាននៅក្នុងអង្គសេចក្តី។ លក្ខខណ្ឌគ្រឹះនៃច្បាប់នីតិវិធីក្នុងការកំនត់អំពីការប្រមូលភស្តុតាងមានដូចជាៈ សណ្តាប់ធ្នាប់នានានៃការប្រមូលភស្តុតាង និងវិធាននៃការវាយតម្លៃ ឬការផ្ទៀងផ្ទាត់ទៅលើភស្តុតាងជាដើម។ល។ ដែលខ្លឹមសារនៃភស្តុតាងទាំងអស់នោះវាមានអត្ថន័យគ្រប់គ្រាន់សម្រាប់កិច្ចការអង្គសេចក្តីដែលគេហៅថា **ច្បាប់ភស្តុតាងឬនីតិភស្តុតាង** ។

**ទី២.**ច្បាប់ភស្តុតតាង គឺជាចំណែក ឬផ្នែកមួយនៃនីតិវិធីព្រហ្មទណ្ឌ ឬច្បាប់ពិសេស ឬក៏វាជាចំណែកមួយនៃនីតិវិធីរដ្ឋប្បវេណីផងដែរ។ មានន័យថាវិធាននៃភស្តុតាងត្រូវបានគេបញ្ញត្តិនៅក្នុងច្បាប់នីតិវិធី (បើកឱ្យមានប្តឹងតវ៉ាចំពោះភស្តុតាងស្មារតីក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ១១២)។

**ទី៣.**នៅក្នុងបញ្ញត្តិគ្រឹះសំខាន់ៗនៃច្បាប់ភស្តុតាងមានកំនត់អំពីសកម្មភាព និងកិច្ចការរបស់អង្គការស៊ើបអង្កេត»។ អង្គការស៊ើបអង្កេត និងសកម្មភាពរបស់អង្គការទាំងនេះមានដូចជា៖ ស្ថាប័នមន្ត្រីនគរបាលយុត្តិធម៌ ស្ថាប័នអយ្យការ និងស្ថាប័នតុលាការជាដើមដោយការកំណត់បែបនេះមានគោលបំណងបែងចែកអំពីព្រំដែននៃសមត្ថកិច្ចរបស់អង្គការនីមួយៗឲ្យបានជាក់លាក់ ជាពិសេស «មានគោលការណ៍ក្នុងការដឹកនាំធ្វើប្រតិបត្តិការ»។

**ទី៤.**បណ្តុំនៃគោលការណ៍ទាំងឡាយ ដែលផ្ទុកក្នុងបញ្ញត្តិគ្រឹះនេះក្លាយជាគោលការណ៍ដ៏សំខាន់សម្រាប់ធ្វើ «សកម្មភាពទៅតាមបទបញ្ញត្តិដែលកំនត់អំពីនីតិវិធីទាក់ទិនទៅនឹងភស្តុតាងនានា» នោះគេអាចហៅអំពីបណ្តុំនៃគោលការណ៍របៀបនេះថាជា «ទ្រឹស្តីនៃភស្តុតាងតុលាការ»។

**ទី៥.**គោលការណ៍ទាំងអស់នេះអាចធ្វើសកម្មភាពបានទៅតាមលក្ខខណ្ឌនៃអត្ថិភាព ដែលបានកំណត់ដោយច្បាប់នីតិវិធីព្រហ្មទណ្ឌ ឬបទដ្ឋាននីតិវិធីនានាផ្សេងៗទៀត(ចំពោះប្រព័ន្ធគតិយុត្តិកុងទីណង់តាល់) និងទៅតាមលក្ខខណ្ឌនៃអត្ថិភាពចំពោះសេចក្តីសម្រេចរបស់តុលាការស្របតាមគោលការណ៍នៃការអនុវត្តជាក់ស្តែងរបស់តុលាការ (ចំពោះប្រព័ន្ធគតិយុត្តិអង់គ្លេសាក់សុង)។

ដូច្នេះដើម្បីយល់ដឹងទៅលើទ្រឹស្តីនៃភស្តុតាងឲ្យបានស៊ីជម្រៅ ចាំបាច់ត្រូវសិក្សាទៅលើគោលការណ៍សំខាន់ៗបីជាចម្បងដែលមានដូចជា:

**ទី១.**សច្ចភាពនៃភស្តុតាង៖ វាគឺជាគោលការណ៍មួយត្រូវកំណត់គោលដៅ និងកំណត់បានអំពីលទ្ធផលនានាដែលទទួលបានពីការប្រើប្រាស់ភស្តុតាងទាំងអស់នោះ។

**ទី២.**គោលការណ៍ជឿទុកចិត្តរបស់ចៅក្រម៖ នេះគឺជាគោលការណ៍ដែលកំណត់នូវការវាយតំលៃទៅលើភស្តុតាងដោយចៅក្រម។

**ទី៣.**គោលការណ៍សច្ចធារណ៍នៃនិរទោស៖ នេះគឺជាគោលការណ៍មួយដែលបញ្ជាក់ថាភាពគ្មានទោសដរាបណាជននោះពុំត្រូវបានរកឃើញកំហុស និងត្រូវបានប្រកាសថាមិនមានទោស.

## ៤.១. គោលការណ៍សច្ចភាពនៃភស្តុតាង ឬគោលការណ៍សម្ភារៈ

នៅក្នុងនីតិវិធីព្រហ្មទណ្ឌ គោលការណ៍សច្ចភាពនៃភស្តុតាងដើរតួនាទីសំខាន់បំផុតនៅក្នុងចំណោមនៃប្រភេទភស្តុតាងនានា ដោយសារតែគោលការណ៍នេះប្រកាន់ខ្ជាប់នូវខ្លឹមសារ ឬខណៈនានានៃអង្គហេតុមិនមានការប្រែប្រួលខ្លាំងដូចការបំភ្លឺរបស់សាក្សីនោះទេ។ គោលការណ៍នេះកើត

ឡើងតាមការសន្និដ្ឋានរបស់អង្គការស៊ើបអង្កេត និងតុលាការស្ដីអំពីខណៈទាំងឡាយនៃអង្គហេតុជាវត្ថុ ឬជាសម្ភារៈដែលបានបន្សល់ទុកនូវស្នាមជាននានាបន្ទាប់ពីស្ថាប័នទាំងនេះបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់។ សេចក្ដីសន្និដ្ឋាននេះត្រូវបានសម្រេចឡើងយ៉ាងចំៗហើយច្បាស់លាស់បំផុតអំពីសកម្មភាពនានានៃអំពើណាមួយតាមរយៈនៃអង្គហេតុជាសម្ភារៈ (គោលការណ៍ហេតុផល ឬគោលការណ៍សច្ចធម៌) ក្នុងគោលបំណងធ្វើការបញ្ជាក់អំពីភាពមានទោស ឬគ្មានទោស(និរទោស) ទៅលើបុគ្គលក្នុងការទទួលខុសត្រូវពីបទល្មើសព្រហ្មទណ្ឌ ដែលមានចែងដោយច្បាប់សារធាតុ (ប្រទេសដែលមិនចាត់ទុកសេចក្ដីសម្រេចរបស់តុលាការជាប្រភពនៃច្បាប់) ឬទម្លាប់អនុវត្តរបស់តុលាការ(ប្រទេសដែលចាត់ទុកសេចក្ដីសម្រេចរបស់តុលាការជាប្រភពនៃច្បាប់)។

គោលការណ៍សច្ចភាពជាសំភារៈមានគោលដៅពិតប្រាកដ និងច្បាស់លាស់បំផុតនៅក្នុងនីតិវិធីព្រហ្មទណ្ឌ។ គោលការណ៍ដែលមានចែងនៅក្នុងនីតិវិធីព្រហ្មទណ្ឌនេះសំដៅកំរិតវិធាន និងកំរិតសកម្មភាពទៅលើអង្គការស៊ើបអង្កេត និងស្ថាប័នតុលាការដើម្បីឱ្យស្ថាប័នទាំងពីរនេះមានសមត្ថភាពគ្រប់គ្រាន់នាពេលចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ ដោយសមត្ថភាពបែបនេះកំណត់បានអំពីខណៈទាំងឡាយនៃអង្គហេតុក្នុងអតីតកាលឲ្យឃើញជាក់ច្បាស់ថា មានលក្ខណៈស៊ីសង្វាក់ដូចគ្នាទៅនឹងសកម្មភាពនៃអំពើដែលបានប្រព្រឹត្តិជាក់ស្ដែង(អង្គហេតុ)ដូច្នោះដែរ។ ប៉ុន្តែចៅក្រម និងអ្នកស៊ើបអង្កេត ជានិច្ចកាលមិនអាចធ្វើខ្លួនជា «អ្នកសង្កេតការណ៍ ឬអ្នកតាមឃ្លាំមើលទៅលើអង្គហេតុនានាដែលពួកគេត្រូវកំណត់ និងសម្រេចនោះឡើយ»។ម្យ៉ាងទៀតអ្នកស៊ើបអង្កេត និងតុលាការត្រូវមានចំណេះដឹងអំពីច្បាប់សារធាតុ និងច្បាប់នីតិវិធីឱ្យបានច្បាស់លាស់ទោះជានៅក្នុងសាខានីតិសាស្ត្រអ្វីក៏ដោយ។ គោលការណ៍សម្ភារៈនៃភស្តុតាងមានមូលដ្ឋានធំបំផុតក្នុងការសម្រេចសេចក្ដីរបស់តុលាការដោយផ្អែកលើភស្តុតាង ពីព្រោះតែអង្គហេតុដែលបានកើតចេញពីអំពើណាមួយ អង្គហេតុនោះសុទ្ធតែបន្សល់ទុកនូវអត្ថន័យជាស្លាកស្នាម តាមខណៈនានានៃអំពើដែលបានប្រព្រឹត្តិដោយជនជាប់ចោទ ឬជនល្មើស។ ការរៀបចំ និងការប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទជាសកម្មភាពដែលបានកកើតឡើងដោយពុំបានឃើញផ្ទាល់ភ្នែកពីអ្នកស៊ើបអង្កេត និងពីចៅក្រមនោះឡើយ។

### ៤.២. គោលការណ៍ជឿទុកចិត្តរបស់ចៅក្រម

### ក.ខ្លឹមសាររួមនៃគោលការណ៍ជឿទុកចិត្តរបស់ចៅក្រមទៅលើអង្គហេតុ

នេះគឺជាគោលការណ៍មួយទៀត ដែលបង្ហាញអំពីសកម្មភាពរបស់ចៅក្រមប្រកបដោយវិចារណញ្ញាណ ដែលសកម្មភាពនេះស្ដែងឡើងតាមរយៈនៃកិច្ចក្នុងការវាយតំលៃរបស់ខ្លួនទៅលើ

ភស្តុតាងក្នុងគោលបំណងធ្វើឱ្យមានការជឿទុកចិត្ត និងទទួលយកបានពីគ្រប់ភាគីក្នុងលក្ខខណ្ឌនៃមូលដ្ឋានហេតុផលពិត ឬមូលដ្ឋានសច្ចភាព។

តាមគោលការណ៍នេះ កាលណាមានការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ តុលាការត្រូវតែឈរនៅលើមូលដ្ឋាននៃភស្តុតាងគ្រប់គ្រាន់ ទោះជាភស្តុតាងទាំងនោះកើតចេញពីសញ្ញាណ ឬប្រភពណាមួយក៏ដោយ ឱ្យតែភស្តុតាងទាំងនោះធ្វើឱ្យមានការជឿជាក់ទៅលើអត្ថិភាពនៃអង្គហេតុបាន(ប្រមូល ត្រួតពិនិត្យ និងវាយតំលៃតាមស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា៥៦, មាត្រា១១០, មាត្រា១១៨ និងមាត្រា៣២១)។ ភស្តុតាងទាំងនោះបានកកើតឡើងស្របតាមខណៈទាំងឡាយនៃអង្គហេតុពិតដែលបានបញ្ជាក់ ឬបង្ហាញដោយឯកឯងនៃអង្គហេតុទាំងនោះ។ គ្មានភស្តុតាងណាមួយដែលធ្វើឱ្យតុលាការសម្រេចជាមុនបានដោយពុំផ្អែកតាមការផ្ទៀងផ្ទាត់ និងការវាយតំលៃទៅលើភស្តុតាងតាមការប្រមូលផ្តុំនៃគ្រប់ខណៈទាំងអស់របស់កិច្ចការអង្គសេចក្តី(សំណុំរឿង) នោះឡើយ។ ដោយផ្អែកលើគំនិតបែបនេះ គោលការណ៍ជឿទុកចិត្តរបស់ចៅក្រមត្រូវប្រកាន់យកនូវជំហរជាបន្តបន្ទាប់ដូចខាងក្រោមៈ

**គោលជំហរអព្យាក្រឹត្យរបស់ចៅក្រមចំពោះអង្គហេតុ**

- គោលការណ៍ទាត់ចោលគំនិតបុរេវិនិច្ឆ័យចំពោះអង្គហេតុ
- គោលជំហរផ្ទៀងផ្ទាត់លើអង្គហេតុ

### ខ. គោលការណ៍ជឿទុកចិត្តដោយសេរីរបស់ចៅក្រមទៅលើអង្គហេតុ

ជាការពិតគោលការណ៍ជឿទុកចិត្តដោយសេរីរបស់ចៅក្រម មិនត្រូវបានចងដោយច្បាប់នោះទេ តែត្រូវចងដោយ **មនសិការៈនិងសតិសម្បជញ្ញៈ** របស់ចៅក្រមគួបផ្សំនឹងចំណេះដឹងជាសារធាតុ និងនីតិវិធីនៃវិទ្យាសាស្ត្រនីតិសាស្ត្រផ្ទាល់ខ្លួន។ ការចងដោយច្បាប់ទៅលើភស្តុតាងមិនមានលក្ខណៈគ្រប់គ្រាន់នោះទេ ពីព្រោះច្បាប់មិនអាចកំណត់បានគ្រប់តែភស្តុតាងដែលកើតពីអំពើនានានោះបានទេ ប៉ុន្តែច្បាប់នីតិវិធីគ្រាន់តែចែងអំពីគោលធំៗប៉ុណ្ណោះសម្រាប់ជាវិធានរួមនៃការប្រមូលភស្តុតាង។ វិធានរួមនេះមានដូចជាវិធាននៃការសរសេរកំណត់ហេតុរឿងក្តីព្រហ្មទណ្ឌ តាមមាត្រា២៤២ កថាខណ្ឌ២នៃក្រមនីតិវិធីព្រហ្មទណ្ឌថា៖ កំណត់ហេតុស្រង់យ៉ាងត្រឹមត្រូវនូវសំណួរ ចម្លើយ និងចម្លើយដែលឆ្លើយដោយឯកឯង។ តាមកថាខណ្ឌនេះមិនមែនគោរពគោលការណ៍ជឿទុកចិត្តដោយសេរីរបស់ចៅក្រមនោះទេ តែជាគោលការណ៍កំណត់ដោយច្បាប់ទៅលើភស្តុតាង។ ប៉ុន្តែគោលការណ៍ជឿទុកចិត្តដោយសេរីរបស់ចៅក្រម គឺទុកសិទ្ធិឱ្យចៅក្រមប្រកាន់យកក្របខណ្ឌឆន្ទានុសិទ្ធិដោយក្នុងនោះចេះផ្ទៀងផ្ទាត់ ចេះវាយតម្លៃទៅលើស្ថានភាពរួមនៃភស្តុតាងក្នុងរឿងក្តីណាមួយ។ ចំពោះការផ្ទៀងផ្ទាត់ និងការវាយតម្លៃរបស់ចៅក្រមវិញ ច្បាប់មិនបានចែងនៅក្នុងនីតិវិធីឱ្យ

បានគ្រប់លក្ខខណ្ឌនោះទេ គឺត្រូវទាមទារឱ្យចៅក្រមឆ្លងកាត់ការបណ្ដុះបណ្ដាលទាំងទ្រឹស្ដីទាំងបទពិសោធន៍ និងព្រមទាំងការស្រាវជ្រាវដោយខ្លួនឯង ជាពិសេសស្ថាប័នរដ្ឋមានតួនាទីចម្បងក្នុងការបណ្ដុះបណ្ដាលនិងធ្វើសុក្រឹត្យការជាប្រចាំ។ ប៉ុន្តែគោលការណ៍ជឿទុកចិត្តដោយសេរីនេះមានដែនកំណត់ទោះបីជាមាត្រា៣២១បានចែងហើយក៏ដោយក៏មាត្រា៤០១, មាត្រា៤៤៣ កថាខណ្ឌ១ និង ៤៤៥ ចំណុចទី៤នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំរិតព្រំដែនយ៉ាងប្រាកដប្រជាបំផុត។ ការកំរិតនូវគោលការណ៍ឆន្ទានុសិទ្ធិនេះ គឺមិនអនុញ្ញាត្តិឲ្យចៅក្រមលើកយកអង្គហេតុដែលគ្មាននៅក្នុងសំណុំរឿងមកធ្វើការអះអាងអ្វីបានឡើយ ពីព្រោះចំនុចនៃអង្គហេតុណាដែលបានធ្វើការវិនិច្ឆ័យរួចហើយចំណុចនោះមានអាជ្ញាអស់ជំនុំជាសារជាតុដែលចងចៅក្រមទៅនឹងកំរិតសមត្ថភាពជាសារជាតុ។

## ៤.៣. គោលការណ៍សច្ចធារណ៍នៃនិរទោស

គោលការណ៍នេះគឺមានន័យថា **ជនជាប់ចោទចាត់ទុកថាគ្មានទោសដ៏រាបណាកំហុសរបស់ជននោះនឹងមិនត្រូវបានរកឃើញនៅក្នុងសណ្ដាប់ធ្នាប់តាមផ្លូវច្បាប់។** គោលការណ៍សច្ចធារណ៍នៃនិរទោសនេះជាភាសាឡាតាំងថា Praesumtio boniviri។ គោលការណ៍នេះ កើតមានតាមដំណាក់កាលមួយចំនួនក្នុងពេលអនុវត្តទៅលើចំណាត់ការចំពោះបណ្ដឹងព្រហ្មទណ្ឌ។

មានដូចខាងក្រោម:

### ក. ដំណាក់កាលចោទប្រកាន់

នៅក្នុងពេលអនុវត្តដំណើរការស៊ើបអង្កេត និងការចោទប្រកាន់របស់តុលាការហាក់ដូចជាមានគំនិតបុរេវិនិច្ឆ័យមួយបានលេចឡើង ដោយក្នុងនោះស្ថាប័នចោទប្រកាន់មានចរិតលម្អៀងទៅលើភាគីម្ខាងហើយត្រូវបានទាត់ចោលភាគីម្ខាងផ្សេងទៀត ពោលគឺសកម្មភាពរបស់ស្ថាប័នស៊ើបអង្កេតខិតជិតទៅរកការចោទប្រកាន់ចំពោះភាគីម្ខាងទៀត (ជនត្រូវចោទ)។ រីឯកិច្ចការតុលាការក្នុងពេលចាប់ផ្ដើមសវនាការ ហាក់មានទំនាក់ទំនងបុរេវិនិច្ឆ័យរួចទៅហើយក្នុងការកំណត់ជាមុននូវកំហុសរបស់ជនដែលត្រូវចោទ និងតាមកិច្ចការនេះចាំបាច់តំរូវឱ្យមានការស៊ើបអង្កេតយ៉ាងពេញលេញបំផុតទៅលើភស្តុតាងទាំងអស់នូវគ្រប់ខណ: និងគ្រប់ពេលវេលា ឬគ្រប់ហេតុការណ៍ (មើលស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា១២៤, មាត្រា១២៥, មាត្រា១២៦) មុននឹងធ្វើការវិនិច្ឆ័យ។

ដំណាក់កាលនេះអ្នកចោទប្រកាន់ ឬតុលាការតែងតែប្រកាន់យកនូវការសន្មត់ជាមុនថាពិតជាមានអង្គហេតុនេះ ឬអង្គហេតុនោះបានកើតពិតមែនដើម្បីយកធ្វើជាលេសតាមផ្លូវច្បាប់សម្រាប់ធ្វើការចោទប្រកាន់ទៅលើបុគ្គលណាមួយ។

### ខ. កំហុសត្រូវបានរកឃើញ

តុលាការអាចទទួលស្គាល់ជនជាប់ចោទ ថាមានទោសហើយវិនិច្ឆ័យលើជននោះបានដរាបណាកំហុសរបស់ជននោះត្រូវបានបង្ហាញឱ្យឃើញថាគ្មានការសង្ស័យ និងជឿទុកចិត្តបានយ៉ាងពេញលេញអំពីកំហុសនោះ (ក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា៣៥០ កថាខណ្ឌទី២ និងកថាខណ្ឌទី៧ មាត្រា៣៨នៃរដ្ឋធម្មនុញ្ញបានកំណត់ស្រាប់)។ ចំណុចនេះបង្ហាញថាការសង្ស័យនេះ ត្រូវតែសម្រេចផ្តល់ជាប្រយោជន៍ទៅឲ្យជនជាប់ចោទនោះវិញមិនមែនឲ្យប្រយោជន៍ទៅភាគីរងគ្រោះនោះទេ ប្រសិនបើបន្ទាប់ពីធ្វើការចោទប្រកាន់ដោយយកលេសនេះ ឬនោះមកធ្វើជាទឡ្ហីករណ៍ តែកំហុសរបស់ជនជាប់ចោទនៅតែរកមិនឃើញហើយស្ថិតក្នុងការសង្ស័យដដែល។ ការដែលមិនផ្តល់ជាប្រយោជន៍ឲ្យទៅភាគីរងគ្រោះនេះ ដោយសារតែជនជាប់ចោទត្រូវបានគេដាក់បន្ទុកដោយយកលេសផ្សេងៗមកធ្វើជាលក្ខខណ្ឌ រីឯជនរងគ្រោះវិញមានសេរីភាពគ្រប់យ៉ាង ហើយលេសបែបនេះនៅតែមិនច្បាស់លាស់ចំពោះអត្ថិភាពនៃកំហុសរបស់ជនជាប់ចោទនោះដដែល។ ដោយគោរពគោលការណ៍នេះបន្ទាប់ពីធ្វើការផ្ទៀងផ្ទាត់ និងវាយតម្លៃទៅលើអង្គហេតុគ្រប់ជ្រុងជ្រោយរួចមក តុលាការត្រូវតែប្រកាន់គោលជំហរ**លើកចោលការចោទប្រកាន់ ប្រសិនបើមិនធ្វើដូច្នេះទេ នោះការសម្រេចឲ្យមានទោសរបស់ចៅក្រមគឺជាការសោកស្តាយមួយមិនអាចជួសជុលបាន**។ ដើម្បីការពារកុំឲ្យមានការដាក់ទោសទៅលើជនសង្ស័យដោយគ្រាន់តែយកលេសពីការសង្ស័យបែបនេះ ទើបចៅក្រមបុរាណរ៉ូមឈ្មោះ «សេណេកា ឬយុវវ័យ សេណេកា» (Lucius Annaeus Seneca minor ) កើតឆ្នាំ០៤ មុនគ្រិស្តសករាជ និងស្លាប់ឆ្នាំ៦៥ ក្នុងគ្រិស្តសករាជយើងនេះបានសរសេរថា ចៅក្រមម្នាក់ដែលបានកាត់ក្តីឲ្យជនជាប់ចោទម្នាក់គ្មានកំហុសក្លាយទៅជាអ្នកមានទោស សេចក្តីសម្រេចរបស់ចៅក្រមរូបនោះវាស្មើនឹងដាក់ទណ្ឌកម្មមកលើខ្លួនឯងដូច្នោះដែរ។ គំនិតនេះបង្ហាញឱ្យចៅក្រមមានភាពប្រុងប្រយ័ត្នអំពីអង្គហេតុពិត និងអង្គហេតុប្រឌិត។ ពីព្រោះថាការយល់ដឹងស៊ីជម្រៅទៅលើអង្គហេតុប្រឌិត និងអង្គហេតុពិតជាគន្លឹះនៃការធ្វើសេចក្តីសម្រេចដោយឯករាជ្យរបស់ចៅក្រម។

ដោយភ្ជាប់ទៅនឹងកំហុសដែលត្រូវបានរកឃើញនេះ អ្នកប្រាជ្ញខ្លះបង្ហាញគំនិតថាកំហុសព្រហ្មទណ្ឌអាចដាក់ទោសទណ្ឌបាន លុះត្រាតែកំហុសនោះកើតឡើងពីអំពើដោយចេតនារបស់ជនជាប់ចោទ ពោលគឺមិនត្រូវដាក់ទោសទាំងបង្ខំនោះឡើយ។

### គ. ត្រូវដកការចោទប្រកាន់

នេះជាមូលដ្ឋានចុងក្រោយនៃគោលការណ៍សច្ចធារណ៍នៃនិរទោស ប្រសិនបើនៅក្នុងដំណើរការនៃនីតិវិធីរបស់តុលាការពុំមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទមានកំហុសទេនោះ ការចោទប្រកាន់ត្រូវតែបានដកចេញជាបន្ទាន់ហើយជននោះត្រូវបានទទួលស្គាល់ថាជាបុគ្គល

គ្មានកំហុសក្នុងការទទួលខុសត្រូវអំពីបទព្រហ្មទណ្ឌដែលបានចោទប្រកាន់រួចមកហើយនោះ។ អត្ថន័យបែបនេះ មើលក្រមនីតិវិធីព្រហ្មទណ្ឌតាមស្មារតីនៃមាត្រា៣៥០កថាខណ្ឌ ទី៣ និងមាត្រា ៣៨ កថាខណ្ឌទី៦នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងមើលចំណុចទី៦ស្ដីអំពី **បំណកស្រាយនៃការសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ**ដែលមានអធិប្បាយនៅខាងចុងនៃអត្ថបទនេះ។

ការដកចោលអំពីការចោទប្រកាន់នេះវាផ្សារភ្ជាប់ទៅនឹងគោលការណ៍សច្ចភាពនៃភស្តុតាង និងគោលការណ៍ឯករាជ្យភាពនៃអំណាចតុលាការដូចមាត្រា១២៩, មាត្រា១៣០នៃរដ្ឋធម្មនុញ្ញបានកំណត់ស្រាប់។ ទោះបីជាតុលាការទទួលបានសិទ្ធិឯករាជ្យលើការសម្រេចសេចក្ដីក៏ដោយចុះ ក៏ប៉ុន្តែបើចៅក្រមភាគច្រើនមានសមត្ថភាពយល់ដឹងនៅមានកំរិតទៅលើការវាយតម្លៃចំពោះភស្តុតាងនោះ«**ភាពឯករាជ្យរបស់ចៅក្រម ឬតុលាការវានឹងក្លាយទៅជាមរណៈភាពនៃយុត្តិធម៌ទៅវិញ**»។ ដោយហេតុនេះហើយទើបចៅក្រមត្រូវតែពឹងលើវិជ្ជាខ្លួនឯងដើម្បីការពារនូវឯករាជ្យភាពនៃអំណាចនេះ។ គំនិតការពារឯករាជ្យភាពនេះមានស្របនឹងគំនិតរបស់អ្នកច្បាប់បូរាណរ៉ូមលោក ស៊ីដស៊ីរ៉ូន បានសរសេរថា «សច្ចភាពគ្មានអ្នកណាម្នាក់ការពារវាបានទេ ក្រៅតែពីខ្លួនវាផ្ទាល់ជាអ្នកការពារ»។ នេះមានន័យថាបើចៅក្រម «យល់ត្រូវគាត់នឹងធ្វើសេចក្ដីសម្រេចមួយប្រកបដោយវិចារណញ្ញាណដែលសេចក្ដីសម្រេចបែបនេះហើយក្លាយជាអ្នកការពារចៅក្រមដោយខ្លួនឯង» ពោលគឺមិនចាំបាច់មានអ្នកដទៃមកជួយការពារនោះឡើយ។ លោកបានសរសេរថា «ចៅក្រមគឺ ជាច្បាប់ចេះនិយាយ រីឯច្បាប់គឺជាចៅក្រមគ»។ មានន័យថា ចៅក្រមជាអ្នកមានចំណេះដឹងក្នុងការបកស្រាយច្បាប់ និងបកស្រាយនូវអង្គហេតុមិនមែនចៅក្រមជាបុគ្គលគ្រាន់តែរង់ចាំប្រថាប់ត្រានោះទេ។ ជាពិសេសនោះចៅក្រមមិនមែនជាបុគ្គលដើរតួក្នុងការអនុវត្តច្បាប់ដោយគ្រាន់តែជាអ្នកចេះរកលេសផ្សេងៗ ដើម្បីបង្គ្រប់លក្ខខណ្ឌក្នុងការធ្វើអំណោយដល់ច្បាប់នោះឡើយ។ ពោលគឺមិនត្រូវគិតថា ចៅក្រមចេះរកនូវគ្រឿងផ្សំផ្សេងៗសម្រាប់តែបង្អប់ទៅនឹងលក្ខខណ្ឌនៃច្បាប់ជាការស្រេចនោះទេ តែត្រូវគិតដល់ទស្សនៈសច្ចធម៌នៃច្បាប់នោះផងដែរដែលការគិតបែបនេះហើយ ទើបបានជាមានករណីយុត្តិសាស្ត្ររបស់តុលាការ(Jurisprudence of court)។ ករណីយុត្តិសាស្ត្រនេះមានវិធានជាក់លាក់ ហើយជាសមត្ថកិច្ចរបស់តុលាការជាន់ខ្ពស់ ក្នុងការថ្លឹងថ្លែងអំពីតុល្យភាពនៃទ្រឹស្ដីសច្ចធម៌អំពីកង្វះចន្លោះនៃលក្ខខណ្ឌដែលមានចែងដោយច្បាប់បានអនុម័តឡើងពីស្ថាប័ននីតិបញ្ញត្តិ។

គោលគំនិតនៃការជាយុត្តិសាស្ត្រនេះ ជាតុល្យភាពនៃសច្ចធម៌រវាងអ្នកបង្កើត និងអនុម័តច្បាប់ (អំណាចនីតិបញ្ញត្តិ) ជាមួយអ្នកវិនិច្ឆ័យក្តី (អំណាចតុលាការ)។

## កថាខណ្ឌទី៥. ទម្រង់នៃភស្តុតាង

ទម្រង់នៃភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ មានលក្ខណៈផ្សេងៗគ្នាទៅតាមអង្គហេតុនីមួយៗ ដែលបានបង្កជាបទល្មើស ហើយទម្រង់នៃភស្តុតាងត្រូវបានចែងជាប្រភេទនីមួយៗ។

ភស្តុតាងនៃបទល្មើសព្រហ្មទណ្ឌ អាចធ្វើបានដោយប្រើគ្រប់មធ្យោបាយទាំងអស់ដើម្បីឱ្យចៅក្រមអាចមានភាពជឿជាក់បាន ។

យើងអាចឱ្យន័យម្យ៉ាងទៀតថា ភស្តុតាងក្នុងរឿងក្តីព្រហ្មទណ្ឌគឺជាអ្វីៗទាំងអស់ដែលបានកើតឡើងឬបានបន្សល់ទុកយ៉ាងពិតប្រាកដហើយស្ថាប័នស៊ើបអង្កេតគឺ អយ្យការ និងតុលាការទទួលស្គាល់ ដែលអាចយកមកធ្វើជាមូលដ្ឋានសម្រាប់សំអាងតាមការកំណត់របស់ច្បាប់ ដើម្បីបញ្ជាក់ថាអំពើមានធាតុផ្សំជាបទល្មើសព្រហ្មទណ្ឌ ម្ចាស់នៃអំពើនោះមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌនិង កម្រិតនៃការទទួលខុសត្រូវ។

ប៉ុន្តែឯកសារទាំងអស់នោះមិនមែនសុទ្ធតែត្រូវបានចាត់ទុកជាវត្ថុភស្តុតាងទាំងអស់នោះទេ ដោយតម្រូវឱ្យយើងត្រូវពិនិត្យនិងសិក្សាអំពីភស្តុតាងជាលំដាប់របស់វា។

ភស្តុតាង គឺជាព្រឹត្តិការណ៍ដែលបានកើតឡើងជាក់ស្តែង និងពិតប្រាកដមិនមែនជាការប៉ាន់ស្មានរបស់ជនណាម្នាក់នោះទេ។

ព្រឹត្តិការណ៍ឬរឿងហេតុដែលសាក្សីបានឃើញដោយផ្ទាល់នឹងភ្នែកឮផ្ទាល់នឹងត្រចៀក ទើបអាចចាត់ទុកថាជាភស្តុតាងដែលត្រូវយកមកសិក្សាស្រាវជ្រាវបាន។ ព្រឹត្តិការណ៍ទាំងនោះត្រូវតែមានទំនាក់ទំនងជាមួយបទល្មើសដែលវាបានបំភ្លឺយ៉ាងច្បាស់លាស់អំពីដំណើររឿងនោះ។ ព្រឹត្តិការណ៍ទាំងនោះត្រូវស្ថាប័នស៊ើបអង្កេត គឺអយ្យការ និងតុលាការប្រមូលបានតាមការកំណត់របស់ក្រមនីតិវិធីព្រហ្មទណ្ឌនោះទើបអាចធានាបាននូវលក្ខណៈពិតប្រាកដ និងមានតម្លៃជាភស្តុតាងបាន។

ដើម្បីងាយស្រួលក្នុងការយល់ដឹងទៅលើ «ខ្លឹមសារ ឬអត្ថន័យរួមនៃភស្តុតាង» ចាំបាច់តម្រូវឱ្យញែកនូវខ្លឹមសារទាំងនោះដាក់ទៅតាមក្រុមរបស់វា។ ការដាក់តាមក្រុមរបស់វានេះ បង្ហាញនូវការចាត់ថ្នាក់ទៅលើខ្លឹមសារនៃភស្តុតាង ប៉ុន្តែវាពុំមែនមានន័យថា ជាការចាត់ថ្នាក់នូវប្រភេទនៃភស្តុតាងនោះទេ ពីព្រោះការចាត់ថ្នាក់ទៅលើទម្រង់នៃភស្តុតាងគឺគេសំដៅយកតែខ្លឹមសារគ្រឹះនៃភស្តុតាង(ភស្តុតាងដាក់បន្ទុក ឬដោះបន្ទុក) រីឯប្រភេទនៃភស្តុតាងវិញគេ សំដៅទៅលើមធ្យោបាយនានានៃការប្រមូលភស្តុតាងដែលគេហៅថាជាប្រព័ន្ធនៃភស្តុតាង។ ការដាក់តាមក្រុមនៃភស្តុតាងនេះសំដៅទៅលើខ្លឹមសារមានលក្ខណៈជាទម្រង់នៃភស្តុតាងប៉ុណ្ណោះ។

## ៥.១.មូលដ្ឋានគ្រឹះនៃការចាត់ថ្នាក់ទៅលើទម្រង់នៃភស្តុតាង

ការចាត់ថ្នាក់ទៅលើទម្រង់នៃភស្តុតាងគឺគេទាញយកចេញពីខ្លឹមសារ ឬពីអត្ថន័យនៃទ្រឹស្តីភស្តុតាងមានជាអាទិ៍៖ យកចេញពីកម្មវត្ថុនៃភស្តុតាង ឬពីមធ្យោបាយនៃការបង្ហាញសក្ខីកម្ម (បញ្ជាក់សក្ខីកម្ម)ជាដើម ហើយដោយយោងទៅលើកត្តាគ្រឹះនៃខ្លឹមសារបែបនេះគេអាចចាត់ថ្នាក់ទៅលើភស្តុតាងជាទម្រង់បីក្រុមសំខាន់ៗគឺៈ

### ក .ក្រុមទីមួយចំពោះទម្រង់នៃការចោទប្រកាន់

ភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុកនៅក្នុងក្រុមទីមួយនេះគេយកខ្លឹមសារវាចេញពីកម្មវត្ថុនៃការចោទប្រកាន់។ ការចាត់ថ្នាក់នៅក្នុងក្រុមទីមួយនេះគឺគេសំដៅទៅលើអ្វីៗ ដែលជាកម្មវត្ថុនៃការចោទប្រកាន់តែប៉ុណ្ណោះគឺថា តើមានភស្តុតាងអ្វីខ្លះដែលនាំឱ្យអយ្យការ និងតុលាការធ្វើការចោទប្រកាន់បាន? ខ្លឹមសារនៅក្នុងក្រុមទីមួយនេះ ត្រូវបានបញ្ញត្តិដោយក្រមនីតិវិធីព្រហ្មទណ្ឌទៅលើខណៈនានា ដោយក្នុងនោះសំអាងទៅលើតែលក្ខខណ្ឌនៃការចោទ ប្រកាន់ប៉ុណ្ណោះមានជាអាទិ៍៖ «ខ្លឹមសារខ្លះនៃបទល្មើសជាក់ស្តែងក្នុងគន្ថីទី២ មាតិកាទី១ ជំពូកទី៤ ផ្នែកទី២ និងមាតិកាទី៤ ជំពូក២ ផ្នែកទី៤ និង គន្ថីទី៣មាតិកា២ជំពូក១,២,៣,៤ និងទី៥។ លក្ខខណ្ឌគ្រឹះសំខាន់នៃអត្ថន័យភស្តុតាងនៅក្នុងក្រុមទីមួយនេះគេពឹងផ្អែកទៅលើ «លេសនៃការចោទប្រកាន់ ទោះបីជាអំពើនោះមានទោស ឬគ្មានទោសនោះគេនៅពុំទាន់គិតដល់នោះទេ» ពោលគេសំឡឹងមើលទៅលើទ្រង់ទ្រាយនៃភស្តុតាងច្រើនជាងការវាយតម្លៃទៅលើភស្តុតាង។ ការមើលទៅលើទម្រង់នៃភស្តុតាងធ្វើឡើងដោយផ្ទាល់ទៅលើអង្គហេតុ ដែលប្រមូលបានតាមរយៈទីតាំងកើតហេតុមកធ្វើជាលេសនៃកម្មវត្ថុរបស់បទល្មើស ហើយលើសនេះមានបញ្ញត្តិដោយច្បាប់សារធាតុ ប៉ុន្តែពុំទាន់គិតដល់ខ្លឹមសារនៃខណៈនានារបស់អង្គហេតុ ឬធាតុចេតនានៃអង្គហេតុនោះទេ។ នៅក្នុងច្បាប់នីតិវិធីតែងតែបញ្ញត្តិនូវខ្លឹមសារដែលពាក់ព័ន្ធនឹងទម្រង់ចំពោះកម្មវត្ថុនៃការចោទប្រកាន់នេះ ក្នុងចំណាត់ការដំបូងៗនៃបទព្រហ្មទណ្ឌ ។

នៅក្នុងខ្លឹមសារនៃបទបញ្ញត្តិទាំងនេះវាស្តែងឱ្យឃើញនូវទម្រង់នៃភស្តុតាងខ្លះៗ ដែលនាំឱ្យមានមូលហេតុអាចធ្វើការចោទប្រកាន់បានជាជំហានៗដូចជាមាត្រា៤២, ៤៣, ៤៤, ៤៥, ៤៦, ៤៧,៤៨ និង៤៩ ជាដើម។ ខ្លឹមសារសំខាន់នៅក្នុងក្រុមនេះគឺគេអាចធ្វើការចោទប្រកាន់បានទៅគ្រប់តែជនល្មើសដោយគ្រាន់តែសំអាងទៅលើគ្រឿងបន្ទាល់ ដែលមានលក្ខណៈបន្ទាប់បន្សំមកធ្វើជា «**លេស**»ប៉ុណ្ណោះ។ ដោយសារតែតម្រូវឲ្យមានសំអាងជាលេសនេះហើយទើបអ្នកប្រាជ្ញទស្សនៈវិទូបុរាណក្រិចលោកឈ្មោះ «**អារីស្តូត**» (Aristotel)កើតឆ្នាំ៣៨៤ និងស្លាប់ឆ្នាំ ៣២២មុនគ្រឹស្តសករាជយើងនេះបានសរសេរថា «គ្រប់បទល្មើសព្រហ្មទណ្ឌតម្រូវឲ្យមានគ្រឿងបន្ទាល់ជាចាំបាច់ដើម្បីយក

មកធ្វើជាលេសដំបូងបំផុត»។ នេះបង្ហាញថា បន្ទាល់ដំបូងនេះហើយដែលជាលេសនាំឲ្យមានការចោទប្រកាន់កើតឡើង ប៉ុន្តែមិនមែនគ្រប់តែលេសដែលនាំឲ្យមានការចោទប្រកាន់នេះសុទ្ធសឹងតែនឹងក្លាយជាភស្តុតាងនាំឲ្យមានទោសនោះទេ ពោលគឺគ្រាន់តែជាការសង្ស័យប៉ុណ្ណោះ។ ដោយផ្អែកលើមូលដ្ឋាននៃបន្ទាល់បន្ទាប់បន្សំយកមកធ្វើជាលេសក្នុងការចោទប្រកាន់នេះហើយ ទើបទ្រឹស្តីនៃច្បាប់នីតិវិធីមិនហាមឃាត់ដល់សិទ្ធិដោះសាររបស់ជនជាប់ចោទនោះឡើយ ហើយជាពិសេសគំនិតបែបនេះអ្នកច្បាប់បុរាណរ៉ូមដ៏ល្បីមុនគ្រិស្តសករាជលោក «**ស៊ីដស៊ីរ៉ូន**» បានសរសេរថា «ការដោះសាររបស់ជនជាប់ចោទគឺជាកាតព្វកិច្ចនៃការវិនិច្ឆ័យរបស់ចៅក្រម»។ នេះបញ្ជាក់កាន់តែច្បាស់ថាជនល្មើសមានសិទ្ធិឆ្លើយដោះសារ ឬបដិសេធន៍បានតែសេចក្តីដោះសារនេះជាកាតព្វកិច្ចចាំបាច់ដែលត្រូវវិនិច្ឆ័យដោយចៅក្រម មិនមែនដោយជនល្មើសនោះទេ។ កាតព្វកិច្ចក្នុងការវិនិច្ឆ័យរបស់ចៅក្រមទៅលើសេចក្តីដោះសាររបស់ជនជាប់ចោទ គឺជាមូលដ្ឋានចម្បងមួយដែលនាំឲ្យកើតមាននូវកាតព្វកិច្ចនៃការស្វែងរកភស្តុតាងត្រូវតែធ្វើឡើងដោយភាគីរដ្ឋ ពីព្រោះរដ្ឋជាអ្នកធានានូវសណ្តាប់ធ្នាប់សន្តិសុខជាសាធារណៈ។

### ខ .ក្រុមទីពីរចំពោះទម្រង់ដែលជាប្រភពនៃការផ្តល់ព័ត៌មាន

ភស្តុតាងដំបូង និងភស្តុតាងបន្តបន្ទាប់ ឬបន្ទាប់បន្សំ ភស្តុតាងដំបូង ឬបឋម និងភស្តុតាងបន្តបន្ទាប់ ឬបន្ទាប់បន្សំនៅក្នុងក្រុមទីពីរនេះគេ សំដៅទៅលើតែប្រភពនៃការផ្តល់ព័ត៌មានស្តីអំពីអង្គហេតុណាមួយតែប៉ុណ្ណោះ»។ គឺមានន័យថា «ការផ្តល់ព័ត៌មានស្តីអំពីអង្គហេតុណាមួយគឺជាប្រភពដ៏សំខាន់សំរាប់យកមកធ្វើជាភស្តុតាងនៅក្នុងក្រុមនេះ»។ តាមខ្លឹមសារនៃក្រុមទីពីរនេះក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិខ្លឹមសារ និងលក្ខខណ្ឌខ្លះៗមានជាអាទិ៍៖ ប្រភពពតិមានអំពីអង្គហេតុមាននៅក្នុងគន្លឹទី៣មាតិកាទី៣ ជំពូកទោល និង«ភស្តុតាងជាបន្តបន្ទាប់» មាននៅគន្លឹទី៤ មាតិកា១ ជំពូកទី១ និងជំពូកទី២ពី ផ្នែកទី២ដល់ទី៨។

តាមទ្រឹស្តីក្នុងគំនិតក្រុមទីពីរនេះ គឺត្រូវយកពតិមានមកធ្វើជាប្រភពដ៏សំខាន់ដែលជាដើមហេតុដំបូងបំផុតនាំឲ្យគេអាចចាប់ផ្តើមធ្វើការចោទប្រកាន់បាន ឬចាប់ផ្តើមធ្វើចំណាត់ការទៅលើរឿងក្តីព្រហ្មទណ្ឌ។ ការប្រកាន់គោលជំហរបែបនេះពីព្រោះថា «ការផ្តល់ពតិមានទាំងឡាយស្តីអំពីអង្គហេតុណាមួយ គឺជាតម្លៃពិតដែលកម្រនឹងមានអ្នកបំភ្លេចបានដោយងាយនោះឡើយ»។ ការដែលមនុស្សមិនអាចងាយនឹងបំភ្លេចចំពោះពតិមានពិតៗនេះ ដោយសារតែពតិមានទាំងនោះវាបានភ្ជាប់ខ្លួនទៅនឹងអត្ថន័យយ៉ាងជាក់លាក់ចំពោះអង្គហេតុដែលបានកកើតឡើងនោះ។ ខ្លឹមសារនៃពតិមានពិតនេះមិនងាយនឹងត្រូវបំភ្លេចបាននោះទេដូចអ្នកច្បាប់ និងក៏ជាអ្នកនយោបាយបុរាណរ៉ូមល្បីម្នាក់មានឈ្មោះថា «**យុរវ៉ែយខ្លីញី**» (Gaius Plnius Caecilius Secondus)កើតឆ្នាំ៦១ និងស្លាប់ឆ្នាំ១១៣

ក្នុងគ្រឹស្តសករាជយើងនេះបានសរសេរថា «ព័ត៌មានទាំងឡាយណាដែលមិនបានយកទៅអនុវត្តព័ត៌មានទាំងអស់នោះពិបាកនឹងបំភ្លេចចោលវាណាស់»។ នេះមានន័យថា អ្វីៗដែលមនុស្សបានដឹងរួចហើយ បែរជាការដឹងលឺទាំងនោះមិនព្រមបំលែងពត៌មានដែលបានដឹងនោះឲ្យទៅជាសក្ខីកម្មពិតក្នុងសកម្មភាពនៃការអនុវត្តតាមវិស័យណាមួយក្នុងសង្គមមនុស្សបានទេ អ្វីៗដែលជាព័ត៌មានដ៏ពិតនិងដ៏ជាក់លាក់បំផុត ទាំងអស់នោះបានដក់ជាប់ទៅនឹងផ្លូវចិត្តរបស់មនុស្ស ហើយធ្វើឲ្យមនុស្សមានអារម្មណ៍ប្រុងប្រយត្ន័ជានិច្ចពីព្រោះថា ព័ត៌មាននោះអាចជាប្រយោជន៍ ឬអាចជាទុក្ខទោសដល់ខ្លួនឬក៏ជាប្រយោជន៍របស់អ្នកដទៃ តែប្រយោជន៍អ្នកដទៃបែបនេះអាចជាកិត្តិយសរបស់បុគ្គលផ្ទាល់ខ្លួនផងក៏មានដែរ ដែលការយកចិត្តទុកដាក់បែបនេះវាអាស្រ័យទៅតាមស្ថានភាពរបស់បុគ្គលនៅក្នុងសង្គម។ ជាការពិតហើយ អត្ថន័យនៃទស្សនៈបែបនេះមានលក្ខណៈទស្សនៈវិជ្ជាស៊ីជម្រៅណាស់។ <u>ជាឧទាហរណ៍:</u> បុគ្គលម្នាក់ៗទោះខ្លួនបានប្រព្រឹត្តិល្អ ឬអាក្រក់ក្ដី បុគ្គលទាំងនោះមិនបានកត់ត្រាអំពីការវាយតម្លៃទៅលើសកម្មភាពទាំងនោះដាក់ក្នុងឯកសារណាមួយប្រចាំថ្ងៃទុកនោះទេ ប៉ុន្តែសកម្មភាពទាំងនោះត្រូវបានកត់ត្រាទុកនៅក្នុងចិត្តរបស់បុគ្គលដែលទទួលដឹងព័ត៌មានរួចជាស្រេចទៅហើយ។ ការកត់ត្រាទុកក្នុងចិត្តនេះហើយដែលជាមូលហេតុធ្វើឲ្យមនុស្សមានជម្ងឺផ្លូវចិត្តបានក្នុងករណីដែលការកត់ត្រាទុកកាន់តែច្រើនឡើងៗ នូវពត៌មាននានាដែលបុគ្គលខ្លួនឯងមិនបានទម្លាយជាសារធារណៈ ឬក៏មិនបានយកទៅដោះស្រាយឲ្យបានស្រឡះប្រកបដោយតម្លាភាព និងយុត្តិធម៌។

ទោះបីជាក្រុមទីពីរនេះចាត់ទុកព័ត៌មានជាប្រភពនៃភស្តុតាងក៏ដោយចុះ ក៏ការចាត់ទុកបែបនេះមិនមែនសុទ្ធតែជាជម្រើសដាច់ស្រេចនោះបានឡើយ ប៉ុន្តែវាជាមូលដ្ឋានសម្រាប់ឲ្យអ្នកចាត់ការរឿងក្ដីព្រហ្មទណ្ឌមានជាពន្លឺក្នុងការស្រាវជ្រាវ និងប្រមូលភស្តុតាងតែប៉ុណ្ណោះ។

### គ. ក្រុមទីបីចំពោះទម្រង់នៃអង្គហេតុគ្រឹះ

ភស្តុតាងផ្ទាល់ និងភស្តុតាងប្រយោល ភស្តុតាងផ្ទាល់ និងភស្តុតាងប្រយោលនៅក្នុងក្រុមទីបីនេះគឺជាក្រុមដែលគេទាញចេញពី «អង្គហេតុគ្រឹះ» ដែលខ្លឹមសាររបស់វាច្រើនមានបញ្ញត្តិនៅដំណាក់កាលជំនុំជម្រះ។ ខ្លឹមសារដែលឆ្លើយតបទៅនឹងលក្ខខណ្ឌនៃអង្គហេតុគ្រឹះនេះត្រូវបានបញ្ញត្តិដូចមានចែងនៅក្នុងស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌតាមគន្ថីទី៥ មាតិកាទី១ ជំពូកទី២, ជំពូកទី៣ និងជំពូកទី៤ផ្នែកទី១។

ជាការពិតណាស់ នៅក្នុងក្រុមទីបីនេះជាក្រុមដែលទម្រង់នៃភស្តុតាងមានខ្លឹមសារប្រាកដប្រជាបំផុតពីព្រោះតែក្រុមនេះគេដកចេញពីអង្គហេតុគ្រឹះ។ **អង្គហេតុគ្រឹះ ជាអង្គហេតុដែលបានបញ្ញត្តិលក្ខខណ្ឌទាំងអស់របស់វានៅក្នុងច្បាប់សារធាតុមិនដូចអង្គហេតុរណប ឬអង្គហេតុបន្ទាប់ ប**

**នូវនោះទេ ដែលអង្គហេតុរណបបែបនេះវាអាស្រ័យតែនឹងអំពើរបស់ជនជាប់ចោទ ហើយទុកលទ្ធភាពឲ្យចៅក្រមធ្វើការបកស្រាយប៉ុណ្ណោះ។** ការប្រកាន់យកគោលជំហរតាមក្រុមទីបីនេះជាការអនុវត្តយ៉ាងតឹងតែងបំផុតចំពោះការចោទប្រកាន់ទាំងឡាយមុននឹងធ្វើឡើងដោយអង្គការអយ្យការ ឬតុលាការ។ ស្ថាប័នចោទប្រកាន់ត្រូវមានកាតព្វកិច្ចប្រមូលភស្តុតាងឲ្យបានយ៉ាងតិចលើសពីវិមតិសង្ស័យ បើមិនដូច្នោះទេការចោទប្រកាន់ដែលធ្វើឡើងនោះពិតជាគ្មានតម្លៃអ្វីក្នុងប្រពន្ធ័យុត្តិធម៌នោះឡើយ។ រាល់ការចោទប្រកាន់ពុំមែនសុទ្ធតែមានទោសនោះទេ ប៉ុន្តែបើការចោទប្រកាន់ធ្វើឡើងដោយងាយស្រួលពេកវានឹងក្លាយជាសកម្មភាពរុកកួន និងរំខានផ្លូវចិត្តពីភាគីរដ្ឋទៅលើភាគីពលរដ្ឋទៅវិញ។ ស្ថាប័នស៊ើបអង្កេត ឬអយ្យការទោះបីខ្លួនដឹងជាមុនថា បើការចោទប្រកាន់របស់ខ្លួនត្រូវបានធ្វើឡើងទៅលើបុគ្គលណាមួយដែលបុគ្គលនោះគ្មានទោស ហើយខ្លួននៅតែប្រកាន់ជំហរធ្វើការចោទប្រកាន់ដោយសារខ្លួនយល់ថា ការប្រកាសអំពីភាពគ្មានទោសនេះគង់តែត្រូវបានធ្វើឡើងដោយតុលាការជាក់ជាមិនខាន។ គំនិតបែបនេះត្រូវបានកវីរ៉ូមឈ្មោះ «**អាពូឡឺយ៍**» (Apuleius) ចាប់កំណើតប្រហែលឆ្នាំ១២៥ មុនគ្រឹស្តសករាជតែកាលបរិច្ឆេទនៃការស្លាប់របស់គាត់មិនមានឯកសារបញ្ជាក់នោះទេ លោកនេះបានសរសេរថា «អាចធ្វើការចោទប្រកាន់ទៅលើជនដែលគ្មានកំហុសបាន ប៉ុន្តែការប្រកាសអំពីទោសអាចធ្វើឡើងបានទៅលើតែជនដែលមានកំហុសប៉ុណ្ណោះ»។ ការគិតបែបនេះហើយបានជាស្ថាប័នដែលមានតួនាទីក្នុងការចោទប្រកាន់ត្រូវបានដាក់ចូលទៅក្នុងភាគីបុរេវិនិច្ឆ័យជាមួយនឹងអំណាចនីតិប្រតិបត្តិដូចជាស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៤០ កថាខណ្ឌ៣ ចែងថា «ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ ព្រះរាជអាជ្ញារាយការណ៍ជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលត្រូវរាយការណ៍បន្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌»។ មាត្រានេះវាភ្ជាប់ខ្លួនទៅនឹងចរិតនយោបាយ ដែលឆ្លុះបញ្ចាំងតាមរយៈប្រពន្ធ័យុត្តិធម៌ក្នុងការអនុវត្តច្បាប់របស់អំណាចនីតិប្រតិបត្តិទៅលើចំណាត់ការនៃហេតុការណ៍ ឬព្រឹត្តិការណ៍ដែលកើតមាននៅក្នុងសង្គមជាក់ស្តែង។ ក្នុងករណីដែលធ្វើឲ្យមាននិទណ្ឌភាពនៅក្នុងសង្គម នោះអំណាចនយោបាយក៏ត្រូវប្រែប្រួលតាមរយៈនៃឆន្ទៈរបស់ពលរដ្ឋផងដែរពោលគឺការបោះឆ្នោតនេះឯង។

ដូច្នេះការចោទប្រកាន់ទៅលើបុគ្គលណាមួយពីស្ថាបន័អយ្យការ មិនមានការលំបាកនោះទេ ដោយសារខ្លួនមានអំណាច និងយកលេសអំពីការកាន់កាប់នូវតួនាទីក្នុងការតាមដានចំពោះ ការអនុវត្តច្បាប់។ ប៉ុន្តែការចោទប្រកាន់បែបនេះនឹងមានបញ្ហាអយុត្តិធម៌ចំពោះជនជាប់ចោទក្នុងករណីដែលអំណាចតុលាការមិនឯករាជ្យ និងខ្វះសមត្ថភាពចំពោះការយល់ដឹងទៅលើទ្រឹស្តីអង្គហេតុ។ ភាពងាយស្រួលក្នុងការធ្វើចោទប្រកាន់ពីពួកអ្នកមានតួនាទីនេះ ត្រូវបានលោក «គ្វីទីលៀន» (Marcus Fabius Qintillanus)ជាគ្រូវោហាសាស្ត្រល្បីម្នាក់ និងជាមេធាវីបុរាណរ៉ូម កើតឆ្នាំ៣៥ និង

ស្លាប់ឆ្នាំ៩៦នៃគ្រឹស្តសករាជយើងនេះបានសរសេរថា «ការចោទប្រកាន់វាងាយស្រួលជាងការការពារ, ការធ្វើឲ្យមានរបួសវាងាយស្រួលជាងការព្យាបាលរបួស»។ ទស្សនៈរបស់លោកបង្ហាញយ៉ាងច្បាស់ថា ការចោទប្រកាន់វាងាយបំផុត ពីព្រោះការចោទប្រកាន់ជាកិច្ច ការដែលមិនសូវពិចារណាច្រើនទេ ប្រសិនបើអ្នកបំពេញកិច្ចមានចេតនាបំផ្លាញអ្នកដទៃ ហើយចាត់ទុកអ្នកដទៃជាឧបសគ្គក្នុងជីវិតរបស់អ្នកចោទប្រកាន់។

## ៥.២ ប្រភេទនៃទម្រង់ភស្តុតាង

បន្ទាប់ពីមានមូលដ្ឋានយ៉ាងច្បាស់លាស់ក្នុងការកំណត់ពីទម្រង់នៃភស្តុតាងក្នុងនោះយើងអាចចែកភស្តុតាងជាពីរប្រភេទធំៗ ភស្តុតាងផ្ទាល់ និង ភស្តុតាង ប្រយោល។

បើទោះបីជាយើងបានបែកចែកទម្រង់នៃភស្តុតាងជាពីរធំៗក្តី ក៏នៅមានទម្រង់ភស្តុតាងតូចៗមួយចំនួនសម្រាប់ធ្វើការផ្ទៀងផ្ទាត់បន្ថែមពីលើនោះទៀតផងដែរ ។

ហើយខាងក្រោមនេះគឺជាប្រភេទនៃទម្រង់ភស្តុតាង ៖

### ក. ភស្តុតាងផ្ទាល់

គឺជាការសារភាពអំពីកំហុស និងរៀបរាប់អំពីព្រឹត្តិការណ៍នានាដែលបានភ្ជាប់ជាមួយនឹងសក្ខីកម្មនៃបទល្មើស របស់ជនល្មើសទៅកាន់តុលាការ ។ ក្នុងនោះផងដែរ ភស្តុតាងផ្ទាល់ក៏អាចជាព័ត៌មានគ្រប់ប្រភេទដែលបញ្ជាក់ច្បាស់អំពីព្រឹត្តិការណ៍ផ្ទាល់ដែលអាចអះអាង ឬអាចបដិសេធចោលនៅធាតុផ្សំមួយ ឬច្រើននៃបទល្មើសណាមួយបាន។ ភស្តុតាងដែលបង្ហាញយ៉ាងច្បាស់នៅអត្ថិភាពនៃបទល្មើសណាមួយ។ សកម្មភាព ឬការផ្តល់នូវភស្តុតាងទាំងឡាយដែលតុលាការអាចពិចារណាក្នុងការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់ថា ជាការពិតដែលអាចជឿទុកចិត្តបានដោយមិនចាំបាច់ត្រូវឆ្លងកាត់ការបកស្រាយ ឬការបញ្ជាក់ពីអ្នកជំនាញឡើយ។

### ខ. ភស្តុតាងប្រយោល

ជាព័ត៌មានគ្រប់ប្រភេទដែលប្រមូលបានទៅតាមកាលៈទេសៈនានានៃបទល្មើសដោយមិនចំពោះ។ ភស្តុតាងប្រយោលបានបង្ហាញពីព្រឹត្តិការណ៍នានាដាច់ដោយឡែកពីគ្នាដែលកាលណាគេធ្វើការផ្តុំនៅព័ត៌មានទាំងនោះ គេអាចធ្វើការកំណត់ដើម្បីឈានទៅរកភស្តុតាងដោយផ្ទាល់បាន ។ ដូចជានៅពេលមានបុរសម្នាក់ស្លាប់នៅលើដងវិថីដោយគ្រោះថ្នាក់ចរាចរណ៍ បន្ទាប់មកមាន សាក្សីម្នាក់ដែលបានឃើញហេតុការណ៍បានឆ្លើយថា "មុនពេលដែលកើតហេតុគេបានឃើញ បុរសម្នាក់បានបើកបររថយន្ត Camry ផលិតឆ្នាំ ២០០២ មិនចាំស្លាកលេខ) ក្នុងស្ថានភាពស្រវឹង ដែលបានបើកបរយ៉ាងលឿននឹងបញ្ច្រាស់ទិស រួចក៏បានជ្រុលទៅបុកជនរងគ្រោះនោះបណ្តាលឲ្យ បាត់បង់

ជីវិត រួចក៏បានជិះរត់គេចខ្លួនបាត់"។ ចម្លើយនេះជាភស្តុតាងមិនផ្ទាល់ដែលតម្រូវ ឲ្យតុលាការ ត្រូវតែស្វែងរកភស្តុតាងមកបញ្ជាក់បន្ថែមដើម្បីអាចកំណត់ពីអត្តសញ្ញាណរបស់ជន ល្មើសបាន ។

### គ. ភស្តុតាងបង្ហាញ

ជាភស្តុតាងសម្រាប់យកមកធ្វើជាមូលដ្ឋាន ដើម្បីអាចឈានទៅរកភស្តុតាងបន្ថែមទៀតដូចជាប្លង់ ស្ថានភាពទីតាំងកន្លែងកើតហេតុ ដែលវាមិនមែនជាភស្តុតាងសម្រាប់ផ្តន្ទាទោសនោះទេ។

### ឃ. ភស្តុតាងទស្សនៈ

ជាភស្តុតាងដែលសាក្សីបង្ហាញអំពីទស្សនៈរបស់ខ្លួន ។ ការបង្ហាញ ឬសេចក្តីសន្និដ្ឋាននេះវាមិនអាចយកជាការបាននោះទេ ព្រោះថាការបង្ហាញនេះសាក្សី ជនរងគ្រោះមិនបានដឹង មិនបានឮនោះទេដូចនេះវាពុំមានតម្លៃជាសក្ខីកម្មដើម្បីបញ្ជាក់ពីពិរុទ្ធភាពនៃបទល្មើសឡើយ។ ប៉ុន្តែអ្នកជំនាញអាចយកភស្តុតាងទស្សនៈនេះទៅធ្វើសេចក្តីសន្និដ្ឋាន ទាញហេតុផលដើម្បីបញ្ជាក់ពីការពិតបាន ។

ក្នុងករណី នៅយប់មុនពេលកើតហេតុមានសាក្សីបានឃើញបុរសម្នាក់ និងជនរងគ្រោះបានមានទំនាស់នឹងគ្នានៅក្នុងរង់ផឹកស៊ី រួចជនរងគ្រោះបានវាយទៅកាន់បុរសម្នាក់នោះ។ នៅថ្ងៃបន្ទាប់គេក៏បានប្រទះឃើញសាកសពរបស់ជនរងគ្រោះ ដេកស្លាប់ដោយមានស្លាកស្នាមវាយ នឹងកាប់ជាច្រើនកន្លែង ហើយសាក្សីបានបង្ហាញពីទស្សនៈរបស់ខ្លួនហើយសន្និដ្ឋានថាបុរសម្នាក់នោះជាអ្នកប្រព្រឹត្តិ។ ការបង្ហាញអំពីទស្សនៈរបស់ខ្លួនទៅកាន់អ្នកជំនាញបែបនេះអាចឲ្យគេធ្វើសេចក្តីសន្និដ្ឋានទាញហេតុផលដើម្បីបញ្ជាក់ពីការពិតបាន ។

### ង. ភស្តុតាងដែលបានដឹង ឮតៗគ្នា

គឺជាភស្តុតាងទាំងឡាយណាដែលបានដឹង ឮតៗគ្នាមកពីសាក្សីប្រយោលដែលបានដឹងនៅរឿងហេតុខ្លះៗ មិនបានឃើញផ្ទាល់ភ្នែក ឬបានឮផ្ទាល់ត្រចៀកឡើយ ប៉ុន្តែជាព័ត៌មានដែលបានឮតៗគ្នាមក ។ ភស្តុតាងនេះមិនបានតម្លៃធ្វើជាមូលដ្ឋានផ្តន្ទាទោសចំពោះជនល្មើសបាននោះទេ ក៏ប៉ុន្តែវាមានផលប្រយោជន៍ដើម្បីស្រាវជ្រាវទៅរកភស្តុតាងផ្ទាល់បាន។

### ច. ភស្តុតាងដាក់បន្ទុក

គ្រប់ភស្តុតាងដែលអាចធ្វើជាមូលដ្ឋាន សម្រាប់ធ្វើបណ្តឹងអាជ្ញារបស់អង្គអយ្យការ និងសម្រាប់ធ្វើជាមូលដ្ឋានដល់ចៅក្រមជំនុំជម្រះន និងដើម្បីកំណត់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ភស្តុតាងដាក់បន្ទុកនេះផងដែរក៏ត្រូវបានលើកឡើង ដើម្បីឲ្យចៅក្រមអាចពិចារណាអំពីស្ថានទម្ងន់

ទោសទៅលើជនជាប់ចោទ ។ ភស្តុតាងនេះក៏អាចជាប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីជាមូលដ្ឋានក្នុងការទាមទារសំណងជម្ងឺចិត្តផងដែរ។

### ឆ. ភស្តុតាងដោះបន្ទុក

ជាភស្តុតាងដែលផ្តល់ដោយភាគីប្រព្រឹត្តបទល្មើស និងអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ដើម្បីប្រឆាំងនឹងភស្តុតាងដាក់បន្ទុក ឬការពារខ្លួនឲ្យរួចផុតពីការចោទប្រកាន់ទាំងស្រុង ឬមួយផ្នែក ឬការសម្រាលបទល្មើស ឬការស្នើសុំឲ្យតុលាការប្រើប្រាស់នូវវិធានស្របទោសជាដើម ។ ភស្តុតាងដោះបន្ទុកនេះ ក៏ត្រូវបានលើកឡើងដើម្បីឲ្យចៅក្រមអាចពិចារណាអំពីស្ថានសម្រាលទៅលើជនជាប់ចោទផងដែរ ។

### ជ. ភស្តុតាងប្រវេសនីយ

ភស្តុតាងប្រវេសនីយ គឺជាភស្តុតាងដែលបានបន្សល់ទុកនៅនឹងកន្លែងកើតហេតុហើយតុលាការត្រូវតែទទួលយក។

ករណី៖ ស្លាកស្នាមដែលបន្សល់ទុកនៅលើជនរងគ្រោះជាស្លាកស្នាមកាប់នឹងវត្ថុមុតស្រួចទើបបណ្តាលឲ្យជនរងគ្រោះស្លាប់ ដូចនេះយើងមិនអាចប្រកែកថាជាការស្លាប់ដោយសារគ្រាប់កាំភ្លើងនោះទេ។

## ៥.៣. ទម្ងន់របស់ទម្រង់នីមួយៗនៃភស្តុតាង

### ក. ទម្ងន់នៃភស្តុតាងផ្ទាល់

ភស្តុតាងផ្ទាល់ មានទម្ងន់ធ្ងន់ជាងគេ ព្រោះថាវាបានបញ្ជាក់យ៉ាងច្បាស់លាស់អំពីព្រឹត្តិការណ៍ ជាក់ស្តែងនៃបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្ត។ ដើម្បីឲ្យភស្តុតាងផ្ទាល់មានតម្លៃតាមច្បាប់ យើងអាចបញ្ជាក់តាមលក្ខខណ្ឌមួយចំនួនដូចជា ៖

- ឲ្យជនសង្ស័យធ្វើគ្រាប់តាមឡើងវិញនូវសកម្មភាព ប្រព្រឹត្តបទល្មើសនៅកន្លែងកើតហេតុ
- ពិនិត្យធាតុផ្សំអត្តនោម័ត (ចេតនា) ដែលឈានទៅដល់ការប្រព្រឹត្តបទល្មើស និងបញ្ជាក់អំពីមូលហេតុ
- ធ្វើការផ្ទៀងផ្ទាត់ភាពស៊ីសង្វាក់គ្នារវាងភស្តុតាងផ្ទាល់ និងភស្តុតាងប្រយោលផ្សេងៗទៀតដែលប្រមូលបាន។

### ខ. ទម្ងន់នៃភស្តុតាងប្រយោល

ភស្តុតាងប្រយោលមានទម្ងន់ស្រាលជាងភស្តុតាងផ្ទាល់ ពីព្រោះថាភស្តុតាងនេះគ្រាន់តែបាន បញ្ជាក់អំពីកាលៈទេសៈនៃបទល្មើស ដែលដាច់ដោយឡែកៗពីគ្នាតែប៉ុណ្ណោះ ។ ដូចនេះ

ហើយទោះ ក្នុងករណីណាក៏ដោយ គេមិនអាចប្រើប្រាស់ភស្តុតាងប្រយោលដើម្បីកំណត់អំពីពិរុទ្ធភាពជនជាប់ចោទបានទេ។ ភស្តុតាងប្រយោលគ្រាន់តែប្រើប្រាស់ដើម្បីបង្រ្គប់អត្ថន័យឲ្យភស្តុតាងផ្ទាល់តែប៉ុណ្ណោះ ។

### គ. ទម្ងន់នៃភស្តុតាងបន្ទាប់បន្សំ

ភស្តុតាងបន្ទាប់បន្សំមានទម្ងន់ស្រាលជាងគេ ភស្តុតាងនេះពុំមានតម្លៃអ្វីទាល់តែសោះក្នុងការកំណត់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ប្រយោជន៍នៃភស្តុតាងបន្ទាប់បន្សំ គឺត្រឹមតែអាចឲ្យគេឈានទៅរកភស្តុតាងផ្ទាល់បានតែប៉ុណ្ណោះ។

## ផ្នែកទី២. ប្រភេទភស្តុតាង ឬប្រព័ន្ធភស្តុតាង

អត្ថន័យរួមនៃប្រព័ន្ធភស្តុតាង គ្រប់អង្គហេតុសុទ្ធតែមានប្រយោជន៍ដល់ការកកើតឡើងនៃរឿងក្តីណាមួយ។ អង្គហេតុទាំងនោះវាបង្កើត និងបញ្ជាក់បាននូវខ្លឹមសារជាភស្តុតាងដោយឯកឯង ហើយតាមរយៈនៃភស្តុតាងទាំងនេះ គេអាចចាត់ទុកវាជាប្រភពនៃការផ្តល់ព័ត៌មាននានាស្តីអំពីអង្គហេតុទាំងនោះ។ អង្គហេតុទាំងនេះបញ្ជាក់បាននូវវិធានដោយឯកឯងមួយយ៉ាងពិតប្រាកដត្រង់ថា «គ្រប់ខណៈទាំងឡាយនៃអង្គហេតុបង្កើតឱ្យមានកម្មវត្ថុនៃការបង្ហាញភស្តុតាង ឬកម្មវត្ថុនៃការបញ្ជាក់សក្ខីកម្ម»។ ដោយសារតែសំណុំរឿងក្តីមួយយមានអង្គហេតុច្រើនប្រភេទ ហើយអង្គហេតុនីមួយៗនោះមានកម្មវត្ថុនៃការបញ្ជាក់សក្ខីកម្មដោយឡែកៗពីគ្នា ដែលជាបច្ច័យនាំទៅរកការបញ្ជាក់សក្ខីកម្មផ្សេងៗពីគ្នាចំពោះប្រភេទនៃបទល្មើសព្រហ្មទណ្ឌ(ឧក្រិដ្ឋ មជ្ឈិម លហុ)។ ដោយការបញ្ជាក់សក្ខីកម្មខុសៗគ្នាចំពោះអង្គហេតុនេះហើយ ធ្វើឲ្យមានការចាត់ជាប្រភេទនៃភស្តុតាង ឬជាប្រពន្ធ័នៃភស្តុតាង។ ត្រង់នេះបានបញ្ជាក់កាន់តែច្បាស់ទៀតអំពីការលេចឡើងនៃអង្គហេតុ ឬខណៈទាំងឡាយចំពោះអំពើល្មើសនៅក្នុងសំណុំរឿងក្តីព្រហ្មទណ្ឌពិតណាមួយ ដែលបានប្រព្រឹត្តិដោយបុគ្គលជាក់លាក់ណាមួយនោះ ប្រាកដជាមានភស្តុតាងបណ្តុំចូលគ្នាមានលក្ខណៈជាខ្លឹមសារស៊ីសង្វាក់ជាប្រព័ន្ធក្នុងទិដ្ឋភាពច្រើនប្រភេទ។ <u>ជាឧទាហរណ៍:</u> នៅក្នុងសំណុំរឿងឃាតកម្មមួយគេប្រមូលបាននូវភស្តុតាងមួយចំនួនមានដូចជា៖ សាក្សី៣នាក់បានបំភ្លឺកាំបិតចុងស្រួចមួយ, ឈាមប្រឡាក់អាវជនល្មើសមានក្រុមឈាមដូចគ្នានឹងក្រុមឈាមជន រងគ្រោះ, សំបុត្រមួយច្បាប់សរសេរដោយដៃជនរងគ្រោះ...។ល។ ហើយភស្តុតាងទាំងអស់នេះធ្វើឱ្យគេរកឃើញនូវអំពើជាកំហុសរបស់ជនល្មើស ដែលបានប្រព្រឹត្តិទៅលើជនរងគ្រោះក្នុងបទល្មើសឃាតកម្ម។ នៅក្នុងសំណុំរឿងក្តីព្រហ្មទណ្ឌនេះមានអង្គហេតុដូចជាសាក្សី កាំបិត ឈាម និងសំបុត្រជាដើម។ល។ ទាំងអស់នេះសុទ្ធតែមានកម្មវត្ថុក្នុងការបញ្ជាក់សក្ខីកម្មផ្សេងៗពីគ្នាដែលក្នុងទ្រឹស្តីភស្តុតាងអាចហៅបានថាជា «ប្រភេទនៃភស្តុតាង ឬជាប្រព័ន្ធនៃភស្តុតាង»។

ប្រភេទនៃភស្តុតាងទាំងនេះ គឺជាប្រភពព័ត៌មាននានាដែលផ្តល់ឱ្យយើងបានដឹងទៅលើកម្មវត្ថុនៃការកកើតអង្គហេតុ ឬលទ្ធភាពដែលបានកកើតនូវអង្គហេតុទាំងនោះ។ ជាការពិតណាស់ប្រភេទនៃ ភស្តុតាងគឺជា«មធ្យោបាយមួយសំរាប់រុករកឱ្យឃើញនូវការពិតទៅលើអង្គហេតុនានានៃរឿងក្តីនីមួយៗ» ប៉ុន្តែមធ្យោបាយទាំងនោះពុំមែនចាប់បង្ខំឱ្យមាននូវប្រភេទនៃភស្តុតាងដូចៗគ្នានោះបានទេ ពីព្រោះការលេចឡើងនូវប្រភេទនៃភស្តុតាងចំពោះរឿងក្តីទាំងនោះ «អាស្រ័យទៅនឹងការកកើតនៃព្រឹត្តិការណ៍ចំពោះបទល្មើស»។ មានន័យថា គ្រប់ប្រភេទនៃបទល្មើសពុំមានភស្តុតាងដូចៗគ្នានោះទេដោយក្នុងនោះអាចមានតិច ឬច្រើនអាស្រ័យទៅនឹងមធ្យោបាយក្នុងការប្រព្រឹត្តិបទល្មើសរបស់ជនជាប់ចោទតែប៉ុណ្ណោះ។ ចំពោះ «មធ្យោបាយដើម្បីស្វែងរកនូវប្រភេទនានាចំពោះភស្តុតាងទាំងនោះវិញ គឺអាស្រ័យទៅលើកំរិតយល់ដឹងអំពីបច្ចេកទេសរបស់ស្ថាប័នស៊ើបអង្កេត (ព្រះរាជអាជ្ញា, មន្ត្រីនគរបាលយុត្តិធម៌) និងតុលាការ(ចៅក្រម) បូករួមទាំងសកម្មភាពនានាដែលមាននាទីក្នុងការអនុវត្តិច្បាប់ ឬជាស្ថាប័នជំនួយដល់ប្រព័ន្ធយុត្តិធម៌ (អ្នកជំនាញ អ្នកឯកទេស មេធាវី)» ជាដើម។ល។ ដែលប្រទេសនីមួយៗ បានបង្កើតស្ថាប័នបែបនេះឡើងក្នុងគោលបំណងការពារយុត្តិធម៌ដល់គ្រប់ស្រទាប់វណ្ណៈរបស់សង្គម និងក៏ជាគំនិតលើកតម្កើងនូវតម្លៃវប្បធម៌របស់ជាតិសាសន៍មួយនៅក្នុងភាពរុងរឿង ដែលទាក់ទីនទៅនឹងការសម្រេចសេចក្តីដោយតុលាការឈរលើហេតុផលឬភស្តុតាង។ ប្រសិនបើប្រព័ន្ធការពារយុត្តិធម៌មានកំរិតខ្សោយ នោះមានន័យថាការរំលោភសិទ្ធិលើពលរដ្ឋកំពុងមានសកម្មភាពខ្លាំងក្លាដែលជាហេតុធ្វើឲ្យឆ្លុះបញ្ចាំងនូវលក្ខខណ្ឌមិនស្មើភាពគ្នាចំពោះមុខច្បាប់។

ដោយផ្អែកលើមូលដ្ឋានក្នុងការចាត់ជាប្រភេទនៃភស្តុតាងនេះ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានកំណត់នូវមធ្យោបាយ ក្នុងការរុករកទៅលើប្រភេទនានានៃភស្តុតាងទៅតាមលទ្ធភាពនៃការវិវត្តន៍របស់សង្គម។ មធ្យោបាយនៃការរុករកនូវប្រភេទភស្តុតាងទាំងនេះពុំបានកំនត់តាមលំដាប់លំដោយធ្វើឱ្យមានភាពងាយស្រួលដល់អ្នកសិក្សា និងអ្នកអនុវត្តនោះឡើយ ប៉ុន្តែយើងអាចសង្កេតទៅលើខ្លឹមសារដែលមានបញ្ញត្តិនៅក្នុងស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ នោះមានលក្ខណៈជាប្រភេទភស្តុតាង៦ផ្សេងៗគ្នា ហើយដោយនៅក្នុងប្រភេទនីមួយៗទាំងនោះត្រូវបានបញ្ញត្តិនូវខ្លឹមសាររបស់វាទៅតាមបីដំណាក់កាលនៃនីតិវិធីចំណាត់ការលើសំណុំរឿងក្តីព្រហ្មទណ្ឌមានដូចជា៖ **ដំណាក់កាលទី១ «ជំហានស៊ើបអង្កេត» ដំណាក់កាលទី២ «ជំហានស៊ើបសួរ»** និង**ដំណាក់កាលទី៣ «ជំហានជំនុំជម្រះ»** (ស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌចំពោះប្រពន្ធ័យុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជា)។ ទាំងនេះពុំមានន័យថា មានមាត្រាតែមួយបានបញ្ញត្តិគ្រប់គ្រាន់ទៅលើប្រភេទនៃភស្តុតាងទាំងប្រាំមួយនោះទេ តែមានមាត្រាចែងនៅរាយពាសពេញទៅតាមដំណាក់កាលនៃចំណាត់ការក្តីក្នុងរឿងព្រហ្ម

ទណ្ឌ។ គឺខ្លឹមសារនៃប្រភេទទាំងនេះហើយដែលជាប្រភពដ៏សំខាន់ ហើយអាចបញ្ជាក់នូវសក្ខីកម្មទៅលើប្រភេទនៃអង្គហេតុនានា ដែលមានន័យ គ្រប់គ្រាន់សម្រាប់រឿងក្តីណាមួយបាន និងដោយឈរលើមូលដ្ឋាននៃភស្តុតាងទាំងនេះធ្វើឱ្យតុលាការចេញសេចក្តីសម្រេចមួយបានស្តីអំពី «ពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពរួមទាំងចំណាត់ថ្នាក់នៃការទទួលខុសត្រូវរបស់ជនជាប់ចោទនោះបានទៀតផង»។

### កថាខណ្ឌទី១. ការបំភ្លឺរបស់សាក្សី

ការបំភ្លឺរបស់សាក្សីគឺជា ភស្តុតាងគ្រឹះដ៏រឹងមាំបំផុតមួយដែលមាន «វិសាលភាពធំធេងបំផុត គ្របដណ្តប់មិនត្រឹមតែទៅលើសំណុំរឿងព្រហ្មទណ្ឌទាំងមូលនោះទេ ប៉ុន្តែគ្របដណ្តប់ទៅគ្រប់សំណុំរឿងក្តីនានាដែលដោះស្រាយដោយនីតិវិធីតុលាការ»។

ការបំភ្លឺរបស់សាក្សីនេះ គឺជាសេចក្តីថ្លែងការណ៍អំពីអង្គហេតុទាំងឡាយដែលសេចក្តីថ្លែងការណ៍នោះមានខ្លឹមសារ ឬអត្ថប្រយោជន៍សម្រាប់កិច្ចការព្រហ្មទណ្ឌដែលសេចក្តីថ្លែងទាំងនោះបានធ្វើឡើងដោយបុគ្គលនានាស្តីអំពីអង្គហេតុទាំងឡាយដែលពួកគេបានដឹង ហើយដើម្បីឲ្យខ្លឹមសារនៃអង្គហេតុទាំងនោះបានក្លាយជាព័ត៌មានជូនទៅស្ថាប័នស៊ើបអង្កេត និងតុលាការ ជាពិសេសសេចក្តីថ្លែងការណ៍នោះ ត្រូវបានធ្វើឡើងតាមសណ្តាប់ធ្នាប់នៃការកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ ឬដោយច្បាប់ពិសេស។

សាក្សី គឺជាបុគ្គលដែលត្រូវបានសាកសួរដោយស្ថាប័នស៊ើបអង្កេត និងតុលាការអំពីហេតុដែលសាក្សីនោះបានទទួលដឹង (Perception) ដោយអង្គហេតុនោះមានអត្ថន័យសម្រាប់រឿងក្តីព្រហ្មទណ្ឌស្ថិតក្នុងលក្ខខណ្ឌនៃសណ្តាប់ធ្នាប់ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូចមាត្រា១៥៣ កថាខណ្ឌទី១ ចែងថា«ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលចំលើយនោះអាចមានប្រយោជន៍នៅក្នុងការសំដែងឱ្យឃើញការពិត។ និងមាត្រា១១៤ កថាខណ្ឌទី១ ចែងថា «មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬដែលអាច ផ្តល់ព័ត៌មានស្តីពីរឿងហេតុ»។ ចំពោះមាត្រា៩៤ កថាខណ្ឌទី១ ចែងថា «មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបាន»។ និងមាត្រា១៧៩ កថាខណ្ឌទី១ ចែងថា «មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយសាក្សី»។

ការចាប់យកវិធាននៃការប្រមូលភស្តុតាងតាមប្រភេទនៃការបង្ហាញរបស់សាក្សី បានធ្វើឱ្យស្ថាប័នស៊ើបអង្កេត និងតុលាការមានលទ្ធភាពគ្រប់គ្រាន់អាចកំណត់បានអំពីខណៈនានានៃអង្គហេតុនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។ ការបង្ហាញ ឬការបំភ្លឺរបស់សាក្សីគឺជាការបំភ្លឺដែលធ្វើឡើងដោយ

មនុស្សកំពុងមានជីវិតភស្តុតាងមានជីវិត ហើយការបំភ្លឺនេះមានគោលបំនងធ្វើឱ្យបានដឹង និងបានយល់ច្បាស់នូវអង្គហេតុនានាមានដូចជា៖ សកម្មភាពនានាដែលសកម្មភាពនៃអំពើទាំងនោះជាធាតុផ្សំដ៏សំខាន់ចំពោះ ភស្តុតាងនៃបទល្មើសព្រហ្មទណ្ឌ។ ភស្តុតាងប្រភេទផ្សេងៗទៀតមិនមានជីវិតនោះទេដែលគេហៅថា «**ភស្តុតាងស្លាប់**» ពីព្រោះវាមិនចេះនិយាយមានដូចជាវត្ថុតាងជាដើមដែលភស្តុតាងប្រភេទបែបនេះយើងអាចយល់បានតាមការលេចឡើងចំពោះ ខណៈនានានៃអង្គហេតុតែប៉ុណ្ណោះ។

អត្ថន័យនៃ «ការបំភ្លឺរបស់សាក្សី» មានខ្លឹមសារពិសេសធំធេងណាស់សម្រាប់ធ្វើការស៊ើបអង្កេត និងដោះស្រាយរឿងក្តីព្រហ្មទណ្ឌ ហើយមានតែការជួយពីការបំភ្លឺរបស់សាក្សីនេះឯងដែលធ្វើឱ្យមានលទ្ធភាពរកឃើញ និងកំណត់បាននូវអង្គហេតុសំខាន់ៗ ឬអង្គហេតុគ្រឹះបាន។ ជានិច្ចកាល ស្ថាប័នស៊ើបអង្កេត និងតុលាការតែងតែធ្វើការវាយតំលៃទៅលើការបំភ្លឺរបស់សាក្សីនានាថាតើការបំភ្លឺនោះគួរទុកចិត្តបាន ឬក៏ជាការខុសឆ្គង ឬជាការបំភ្លឺកុហក។ ការទម្លុះបាននូវការសង្ស័យបែបនេះគឺត្រូវតែពឹងផ្អែកទៅលើវិធានតែមួយគត់គឺ ការផ្ទៀងផ្ទាត់ជាមុនចំពោះ អង្គហេតុនានាដែលសាក្សីបានបំភ្លឺប្រៀបធៀបជាមួយនឹងអង្គហេតុផ្សេងៗដទៃទៀត ទើបអាចជៀសវាងបាននូវការទទួលស្គាល់ដោយខុសឆ្គងមួយដល់ការធ្វើសេចក្តីសម្រេចចុងក្រោយ។

ជាការពិតគ្រប់បុគ្គលនៅពេលខ្លះក៏តម្រូវឱ្យឆ្លើយក្នុងឋានៈជាសាក្សីផងដែរដូចជា មាត្រា ១៧៩ កថាខណ្ឌទី១ ហើយពេលខ្លះក៏មិនអនុញ្ញាត្តិឱ្យឆ្លើយក្នុងឋានៈជាសាក្សីដែរ ដោយសារតែមានតម្រុយពិរុទ្ធភាពដូចជា មាត្រា១៧៩ កថាខណ្ឌទី២ វាក្យខណ្ឌទី៣ និងមាត្រា១៥៧បានកំណត់ស្រាប់។ ម្យ៉ាងទៀតសាក្សីមានវិសមិតភាពជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីដូចជា មាត្រា ៣១២ បានកំណត់រួចហើយ ក៏ប៉ុន្តែសិទ្ធិរបស់សាក្សីក៏ដូចគ្នាទៅនឹងសិទ្ធិរបស់អ្នកជំនួយ ឬអ្នកបកប្រែនោះផងដែរដូចជាមាត្រា១៩៤, មាត្រា១៥៥ និងមាត្រា៣៣០ជាដើមបានកំណត់ស្រាប់។ នៅពេលខ្លះសាក្សីត្រូវបានតុលាការសាកសួរដោយពុំចាំបាច់កោះហៅនោះទេ ឱ្យតែសាក្សីទាំងនោះមានវត្តមាននៅក្នុងបន្ទប់ តែត្រូវមានការស្នើសុំរបស់ភាគីដូចជា មាត្រា៣២៤ បានកំណត់ស្រាប់ ប៉ុន្តែបើសាក្សីទាំងឡាយដែលបំភ្លឺទៅធ្វើឱ្យគ្មានប្រយោជន៍ក្នុងការស្វែងរកឱ្យឃើញនូវការពិត សាក្សីរូបនោះក៏អាចត្រូវគេជំទាស់បានដែរដូចជា មាត្រា៣២៧ជាដើមបានកំណត់ស្រាប់។

ជាទូទៅការយកចម្លើយរបស់សាក្សីនៅក្នុងចំណាត់ការលើរឿងក្តីព្រហ្មទណ្ឌ ត្រូវបានធ្វើឡើងតាមពីរដំណាក់កាលឯណោះមុននឹងទទួលយកបាន ក្នុងនោះមានដំណាក់កាល«**ស៊ើបអង្កេត**» (នគរបាលយុត្តិធម៌,អយ្យការ,ចៅក្រមស៊ើបសួរ) និងដំណាក់កាល «**តុលាការ**» (ជំនុំជម្រះ)។ ប៉ុន្តែលក្ខខណ្ឌខ្លះនៅក្នុងពេលជំនុំជម្រះចំពោះតែសាក្សីដែលដាក់បន្ទុក ហើយសាក្សីរូបនេះគាត់បាន

ឆ្លើយតាំងពីដំណាក់កាលស៊ើបអង្កេតមកនោះ តែបែរជាគាត់មិនព្រមចូលមកក្នុងពេលសវនាការវិញ សាក្សីរូបនេះត្រូវតែមានវិធានការនាំខ្លួនជាចាំបាច់បំផុតពីអាជ្ញាធរតុលាការ ដើម្បីឲ្យមានវត្តមានរបស់គាត់ក្នុងការសួរតទល់មុខគ្នានាពេលដេញដោល។ ដោយយោងទៅលើលក្ខខណ្ឌនេះ ក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិតាមមាត្រា២៩៧ ថា«សាក្សីខាងដាក់បន្ទុកដែលមិនទាន់បានសួរចម្លើយតទល់គ្នាជាមួយជនជាប់ចោទត្រូវតែកោះហៅឲ្យចូលរួមក្នុងសវនាការ»។ រីឯមាត្រា៤៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ បានចង្អុលនូវលក្ខខណ្ឌនៃការទទួលទោសតាមច្បាប់សារធាតុ ឬក្រមព្រហ្មទណ្ឌ។ មាត្រា៤៧៧ កថាខណ្ឌ២ បានចែងថា៖

ដីការកោះហៅត្រូវបញ្ជាក់ថា៖

- បុគ្គលពាក់ពន្ធ័ត្រូវបានកោះហៅក្នុងឋានៈជាសាក្សី
- ការមិនចូលបង្ហាញខ្លួននៅពេលសវនាការ ការមិនព្រមឆ្លើយឲ្យព័ត៌មានក្នុងឋានៈជាសាក្សី ឬការឆ្លើយឲ្យព័ត៌មានក្លែងក្លាយត្រូវផ្ដន្ទាទោសតាមច្បាប់។

គោលគំនិតដែលទាមទារឲ្យសាក្សីដាក់បន្ទុកទៅលើជនជាប់ចោទ ត្រូវតែមានវត្តមានក្នុងពេលសវនាការនេះ គឺជាវិធាននៃការចងកាតព្វកិច្ចរបស់សាក្សីទៅនឹងអង្គហេតុទាំងឡាយដែលភ្ជាប់ខ្លឹមសារនៃអង្គហេតុទាំងនោះទៅនឹងនីតិវិធីរបស់តុលាការ។ វិធានបែបនេះតុលាការចង់ផ្ទៀងផ្ទាត់អំពីខណៈទាំងឡាយនៃអង្គហេតុដែលសាក្សីដាក់បន្ទុកនោះ បានឆ្លើយក្នុងដំណាក់កាលស៊ើបអង្កេតពិតជាមានអង្គហេតុដូច្នោះមែន ឬក៏ជាអារម្មណ៍របស់សាក្សី។ ការមិនគោរពចំពោះវិធានបែបនេះក៏អាចជាមោឃភាពនៃចំណាត់ការក្នុងរឿងក្ដីព្រហ្មទណ្ឌរបស់តុលាការផងដែរ ដោយសារតែតុលារការរំលោភទៅលើសិទ្ធិការពារខ្លួនរបស់បុគ្គលដូចមានចែងក្នុងមាត្រា២៥២ កថាខណ្ឌ២នៃក្រមនីតិវិធីព្រហ្មទណ្ឌថា «នាំឲ្យមានមោឃភាពផងដែរ កាលណាការបំពានវិធាន ឬទម្រង់ការសំខាន់ណាមួយដែលចែងដោយក្រមនេះ ឬបទប្បញ្ញត្តទាំងឡាយស្ដីពីនីតិវិធីព្រហ្មទណ្ឌធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគី ដែលទទួលរងការបំពាននេះ។ វិធាន និងទម្រង់ការ ដែលមានលក្ខណៈសំខាន់នោះមានជាអាទិ៍គឺ វិធានទម្រង់ការ ដែលមានបំណងធានាការគោរពសិទ្ធិការពារខ្លួន»។

ការចងកាតព្វកិច្ចរបស់សាក្សីទៅនឹងអង្គហេតុ ជាមធ្យោបាយមួយទប់ស្កាត់ដល់ភាពទំនើងចិត្តរបស់សាក្សីទាំងឡាយ ដែលយកអារម្មណ៍របស់ខ្លួនផ្ទាល់ធ្វើជាលេសសម្រាប់ដាក់បន្ទុកទៅលើអ្នកដទៃ(ជនជាប់ចោទ)។ ប៉ុន្តែតុលាការត្រូវតែមានចំណេះដឹងស្ដីអំពីអង្គហេតុយ៉ាងពិតប្រាកដដោយពុំអាចមានស្ថាប័នណាយល់ដឹងស៊ីជម្រៅបានដូចតុលាការនោះឡើយ។ ភាពស៊ីជម្រៅនៃអង្គហេតុនេះមានន័យថា «អង្គហេតុណាក៏ដោយកាលណាវាកកើតមកហើយ អង្គហេតុនោះសុទ្ធតែ

មានចំនុចសំខាន់របស់វាមិនអាចខ្វះបានឡើយ។ ចំណុចសំខាន់របស់អង្គហេតុនោះគឺគេអាចថ្លឹងថ្លែងបានហើយច្បាស់លាស់ ឬជាក់លាក់បំផុត ប៉ុន្តែអារម្មណ៍ ឬចម្ងារម្មណ៍របស់មនុស្សដែលរៀបរាប់ឡើងវិញអំពីព្រឹត្តិការណ៍ដែលគាត់បានឃើញរួចហើយ នោះវាអាចធ្វើឲ្យមានការប្រែប្រួលខុសពីធាតុដើមប្រមាណចាប់ពី ១រហូតដល់១០ឯណោះ» (គោលការណ៍ចិត្តវិទ្យា)។ ដោយសារតែចិត្តមនុស្សប្រែប្រួលបែបនេះហើយ ទើបតុលាការ ប្រើប្រាស់វិធាននៃការផ្ទៀងផ្ទាត់ និងសិក្សាទៅលើសំដីរបស់បុគ្គលនានាមានដូចជាសាក្សី, ជនជាប់ចោទ, ជនរងគ្រោះដោយប្រយត្ន័ប្រយែងបំផុតនៅក្នុងសំណុំរឿងក្តីព្រហ្មទណ្ឌពីព្រោះថា មនុស្សជាភស្តុតាងមានជីវិតហើយចេះនិយាយតាមតែចិត្តរបស់ខ្លួនដែលគេនឹកឃើញ ពោលគឺមនុស្សមានការស្រមើស្រមៃមិនចេះចប់នោះទេទោះបីជាអង្គហេតុមិនបានកកើតមកក៏ដោយចុះ ក៏មនុស្សអាចស្រមៃថាកើតមានបានដែរហើយតាមទស្សនៈតក្កវិជ្ជាចំពោះសច្ចធម៌បានកំណត់ថា «ដរាបណាគ្មានអង្គហេតុណាមួយបានកកើតឡើងទេ នោះការបង្កើតឲ្យមានសេចក្តីសន្និដ្ឋាននានាក៏គ្មានតម្លៃអ្វីនោះដែរ»។

ដើម្បីស្វែងយល់អំពីការបំភ្លឺរបស់សាក្សី យើងអាចសិក្សាទៅលើលក្ខខណ្ឌខ្លះមួយចំនួនដែលត្រូវបានបញ្ញត្តិទៅលើសកម្មភាពនានារបស់សាក្សីមានជាអាទិ៍៖

ក. ប្រភេទបុគ្គលដែលអាចក្លាយជាសាក្សី

ខ. សិទ្ធិ និងកាតព្វកិច្ចរួមរបស់សាក្សី

គ. ការវាយតម្លៃទៅលើការបំភ្លឺរបស់សាក្ស

ឃ. ចិត្តវិទ្យានៃការបំភ្លឺរបស់សាក្សី

ង. កត្តានានាដែលមានឥទ្ធិពលទៅលើភាពត្រឹមត្រូវនៃការបំភ្លឺរបស់សាក្សី,

ច. ការសន្និដ្ឋាន និងយោបល់របស់សាក្សី

ឆ. ការបំភ្លឺនានារបស់សាក្សីដែលមានអាយុតិច ឬកុមារ ។

ដើម្បីចាត់ទុកថាសាក្សីជាភស្តុតាងបាន ចូរពិនិត្យនូវលក្ខខណ្ឌទាំងនេះមានជាបន្តបន្ទាប់ដូចខាងក្រោម៖

### ១.១. ប្រភេទបុគ្គលអាចក្លាយជាសាក្សី

បុគ្គលណាក៏ដោយក៏មានសិទ្ធិធ្វើជាសាក្សីទាំងអស់រួមទាំងបុគ្គលនោះជាទណ្ឌិតទៀតផង[3]។ ជាទូទៅបុគ្គលគ្រប់រូប អាចត្រូវផ្តល់ចម្លើយដែលទាក់ទីនទៅនឹងពតិមានស្តីអំពីអង្គហេតុណាមួយ

[3] មើលសាលដីការតុលាការកំពូលនៃ អ.វ.ត.ក ចុះថ្ងៃទី៣.០២.២០១២ ដែលសម្រេចដាក់គុក កាំង ហ្កិចអៀវហៅឌុចអស់មួយជីវិត ។ នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ឌុច ត្រូវបានតុលាការ អ.វ.ត.ក កោះហៅមកបំភ្លឺក្នុងសំណុំរឿង០០៣/០២ ទាក់ទីននឹងការបោសសំអាតមន្ទីរ២១ ដែលជាសំណុំរឿងថ្មី ។

ដែលបានកកើតរួចហើយ។ ដូចជា មាត្រា១៥៣ កថាខណ្ឌទី១ ចែងថា«ចៅក្រមស៊ើប សួរអាចស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលចម្លើយនោះអាចមានប្រយោជន៍នៅក្នុងការសំដែងឱ្យឃើញការពិត»។ និងមាត្រា៩៤ កថាខណ្ឌទី១ចែងថា «មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលអាចផ្តល់ពត៌មានស្តីអំពីរឿងហេតុបាន»។ តាមខ្លឹមសារនៃមាត្រាទាំងពីរនេះរួមទាំងខ្លឹមសារនៃមាត្រា៣២៩នៃក្រមនីតិវិធីព្រហ្មទណ្ឌផង ទោះបីជាបុគ្គលនោះស្ថិតក្នុងស្ថានភាពបែបណាក៏ដោយពោលគឺ «បុគ្គលណាក៏ធ្វើសាក្សីបានដែរឱ្យតែគាត់អាចបង្ហាញឱ្យឃើញនូវការពិត រីឯអាយុរបស់សាក្សីវិញក៏មិនបានកំនត់នោះដែរ ប៉ុន្តែបើតាមស្មារតីនៃមាត្រា១៥៦ កថាខណ្ឌទី៦ បានចែងថា «កុមារអាយុតិចជា១៨ឆ្នាំរួចពីការធ្វើសម្បថ»។ នេះបញ្ជាក់ច្បាស់ថា សាក្សីមិនត្រូវបានកំណត់អាយុនោះទេ។ ប៉ុន្តែនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានកំណត់នូវលក្ខខណ្ឌខ្លះ(គោលការណ៍វិសមិតភាពនៃការបំពេញមុខងាររបស់មន្ត្រីអនុវត្តច្បាប់) ដែលបុគ្គលមួយចំនួនមិនអាចធ្វើជាសាក្សីបាននៅក្នុងវិធានខ្លះៗនៃមធ្យោបាយក្នុងការប្រមូលភស្តុតាងដូចជាមាត្រា៩១ កថាខណ្ឌទី២ ចែងអំពីការឆែកឆេរថា «មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់។ សាក្សីត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌។ សាក្សីមិនអាចជានគរបាល ឬកងរាជអាវុធហត្ថដែលជាកងកំលាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ»។

ប៉ុន្តែច្បាប់បានអនុញ្ញាត្តិឲ្យមានការជ្រើសរើសសាក្សីក្នុងលក្ខខណ្ឌនៃការឆែកឆេរនេះ ទុកជូនទៅព្រះរាជអាជ្ញា ដើម្បីជម្នះនូវឧបសគ្គនានាក្នុងដំណើរការស៊ើបអង្កេតដូចមាត្រា១១៣នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពីវិធានឆែកឆេរដដែលនោះតាមកថាខណ្ឌទី៤ វាក្យខណ្ឌ័ទី៣, ទី៤ និង៥ថា «ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើចំពោះមុខសាក្សីពីរនាក់។ សាក្សីត្រូវចាត់តាំងដោយព្រះរាជអាជ្ញា។ សាក្សីមិនអាចជានគរបាល ឬកងរាជអាវុធហត្ថដែលជាកងកំលាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ»។ ចំពោះករណីដែលសំណុំរឿងក្តីកំពុងត្រូវបានចាត់ការដោយចៅក្រមស៊ើបសួរវិញនោះ ចៅក្រមរូបនេះមានសិទ្ធិចាត់តាំងសាក្សីដោយខ្លួនឯង ហើយគោលការណ៍នេះត្រូវបានកំនត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌក្នុងស្មារតីនៃមាត្រា១៥៩ កថាខណ្ឌទី២ វាក្យខណ្ឌទី១ និងទី២ បានចែងទៀតថា «ចៅក្រមស៊ើបសួរត្រូវឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើចំពោះមុខសាក្សីពីរនាក់ដែលខ្លួនចាត់តាំង។ សាក្សីមិនអាចជានគរបាល ឬកងរាជអាវុធហត្ថដែលជាកំលាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ»។

## ១.២. សិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី

សាក្សីទាំងឡាយត្រូវមានកាតព្វកិច្ចទៅតាមច្បាប់កំណត់នៃប្រទេសនីមួយៗ។ ការកំណត់ទៅលើកាតព្វកិច្ចនេះពុំមានលក្ខណៈដូចៗគ្នាទាំងអស់នោះទេ ដោយអាស្រ័យទៅតាមស្ថានភាព និងនយោបាយនៃប្រទេសនីមួយៗជាប្រវត្តិសាស្ត្រក្នុងការសំដែងឱ្យឃើញនូវការពិតចំពោះរឿងក្តីនានានៅក្នុងប្រពន្ធ័យុត្តិធម៌សង្គម។ ជាឧទាហរណ៍: មាត្រា១៥៤ កថាខណ្ឌទី១នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា «មុននឹងឆ្លើយទៅនឹងសំណួរ សាក្សីម្នាក់ៗត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា និយាយតែការពិត»។ ប៉ុន្តែគេអាចសង្កេតឃើញនូវគោលការណ៍រួមរបស់ច្បាប់ទាំងនោះដែលកំណត់ទៅលើកាតព្វកិច្ចរបស់សាក្សីមានដូចជា៖ ការបង្ហាញខ្លួនរបស់សាក្សី, សិទ្ធិនានារបស់សាក្សី, កាតព្វកិច្ចពិសេសរបស់សាក្សី, កាតព្វកិច្ចសាក្សីនិយាយតែការពិត ។

### ក. ការបង្ហាញខ្លួនរបស់សាក្សី

សាក្សីមានកាតព្វកិច្ចបង្ហាញខ្លួនទៅតាមការកោះហៅរបស់ស្ថាប័នស៊ើបអង្កេត និងស្ថាប័នតុលាការ។ សាក្សីនេះមានកាតព្វកិច្ចគោរពតាមច្បាប់ជាធរមានដូចមាត្រា៣១៥នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា «សាក្សីត្រូវតែចូលមកបង្ហាញខ្លួននៅមុខតុលាការតាមការកោះហៅ។ តុលាការអាចប្រើកងកម្លាំងសាធារណៈដើម្បីបង្ខសាក្សីឱ្យចូលបង្ហាញខ្លួន»។ ចំពោះមាត្រា១៥៣ កថាខណ្ឌទី៣បានចែងទៀតថា «បុគ្គលគ្រប់រូបដែលត្រូវបានចៅក្រមស៊ើបសួរកោះ ហៅក្នុងឋានៈជាសាក្សីត្រូវតែមកបង្ហាញខ្លួន»។ ចំពោះមាត្រា២៩៧ បានកំនត់អំពីសាក្សីដាក់បន្ទុកថា «សាក្សីខាងដាក់បន្ទុកដែលមិនទាន់បានសួរចម្លើយតទល់គ្នាជាមួយជនជាប់ចោទ ត្រូវតែកោះហៅឱ្យចូលរួមក្នុងសវនាការ» រីឯសាក្សីក៏អាចមកបំភ្លឺនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌បានផងដែរដូចជា មាត្រា១៧៩ កថាខណ្ឌទី៣បានកំនត់រួចជាស្រេច។ នេះបង្ហាញថាសាក្សីត្រូវបានចូលបង្ហាញខ្លួនក្នុងគ្រប់ដំណាក់កាលតាំងពីនីតិវិធីស៊ើបអង្កេត និងស៊ើបសួររហូតដល់នីតិវិធីជំនុំជម្រះ។

ប៉ុន្តែច្បាប់នីតិវិធីក៏បានពិចារណាអំពីករណីលើកលែងខ្លះដល់សាក្សីផងដែរ នៅគ្រប់លក្ខខណ្ឌដែលមិនអាចមានលទ្ធភាពមកបង្ហាញខ្លួនបានដោយមូលហេតុផ្សេងៗដូចជា៖ មានជម្ងឺ, វិស្សមកាល, ឬបញ្ហាគមនាគមន៍ជាដើមដូចមាត្រា១៥៨ បានចែងថា «ប្រសិនបើសាក្សីឈឺ ឬមិនអាចធ្វើដំណើរបាន ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីអាចចុះទៅកាន់លំនៅឋាន ឬទីកន្លែងដែលសាក្សីនោះនៅ ដើម្បីទទួលចម្លើយ» រីឯមាត្រា១៣៦ ក្រមនីតិវិធីរដ្ឋប្បវេណីវិញបានកំណត់ក្នុងចំណុចទី១ថា «ការសាកសួរសាក្សីនៅក្រៅតុលាការ

១.តុលាការអាចសាកសួរសាក្សីនៅក្រៅតុលាការបានក្នុងករណីដូចខាងក្រោមនេះ:

ក. សាក្សីគ្មានករណីកិច្ចចូលខ្លួនទៅតុលាការដែលទទួលបណ្តឹង ឬមានមូលហេតុត្រឹមត្រូវដែលមិនអាចចូលខ្លួនទៅតុលាការបាន។

ខ. ការចូលខ្លួនរបស់សាក្សីទៅតុលាការដែលទទួលបណ្តឹង បណ្តាលឱ្យមានការចំណាយទៅលើពេលវេលា ឬសោយហ៊ុយមិនសមរម្យ។

គ. គូភាគីពុំមានការតវ៉ា។

២.បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ តុលាការអាចឲ្យចៅក្រមដែលទទួលបញ្ជា ឬចៅក្រមដែលទទួលការប្រគល់សិទ្ធិទៅធ្វើការសាកសួរសាក្សីនៅក្រៅតុលាការបាន»។ តាមចំណុចទី២នៃមាត្រានេះដូចគ្នាទៅនឹងស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា១៣១ ស្តីអំពីការចាត់តាំងឲ្យស៊ើបសួរជំនួស។

តាមខ្លឹមសារនៃមាត្រា១៥៨ (ក្រមនីតិវិធីព្រហ្មទណ្ឌ) និងមាត្រា១៣៦ (ក្រមនីតិវិធីរដ្ឋប្បវេណី)ទាំងពីរនេះ វាមិនមែនជាមូលហេតុនៃការមិនគោរពតាមច្បាប់នោះឡើយ តែជាការផ្តល់សិទ្ធិដល់សាក្សីដែលមានធុរៈផ្សេងៗក្នុងកាលៈទេសៈចាំបាច់ណាមួយ។ ប៉ុន្តែប្រសិនបើសាក្សីពុំបានចូលបំភ្លឺតាមការកោះហៅ គឺអាជ្ញាធរមានវិធានការផ្សេងៗដូជាមាត្រា១៥៣ កថាខណ្ឌទី៤ ចែងថា «ក្នុងករណីរឹងទទឹង ចៅក្រមស៊ើបសួរអាចសុំឱ្យកងកម្លាំងសាធារណៈបង្ខំសាក្សីនេះឱ្យចូលមកបង្ហាញខ្លួនបាន។ ចៅក្រមស៊ើបសួរចេញបញ្ជាឱ្យចូលមកបង្ហាញខ្លួន»។ និងមាត្រា១៧៩ កថាខណ្ឌទី៣ វាក្យខណ្ឌទី២, ទី៣ និង ទី៤ ក៏បានកំណត់ផងដែរ ជាពិសេសទៀតនោះមាត្រា៩៤ ក៏បានផ្តល់សិទ្ធិឱ្យមន្ត្រីនគរបាលយុត្តិធម៌មានវិធានការទៅលើសាក្សីផងដែរ។ សាក្សីក៏ត្រូវបានទទួលការផាកពិន័យផ្សេងៗ ឬដាក់ទណ្ឌកម្មផងដែរដូចជាមាត្រា៥៤៥នៃក្រមព្រហ្មទណ្ឌបានចែងថា «បទផ្តល់សក្ខីកម្មក្លែងក្លាយ និងការលើកលែងសក្ខីកម្មភូតកុហកដែលធ្វើក្រោយពីបានស្បថនៅមុខតុលាការ ឬនៅមុខមន្ត្រីនគរបាលយុត្តិធម៌ដែលធ្វើសកម្មភាពនៅក្នុងក្របខណ្ឌនៃដីកាចាត់តាំងឲ្យសួរចម្លើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានទៅ ១០លានរៀល។

សាក្សីភូតកុហកត្រូវបានលើកលែងឲ្យរួចផុតពីទោស ប្រសិនបើសាក្សីនេះប្រែក្រឡាស់ដោយឯកឯងនូវសក្ខីកម្មរបស់ខ្លួន ហើយនិយាយតែការពិតមុនសេចក្តីសម្រេចបញ្ចប់នីតិវិធីស៊ើបសួរ ឬនីតិវិធីជំនុំជម្រះ»។ និងស្មារតីនៃមាត្រា១៣២ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីចែងនៅចំណុចទី១, ចំណុចទី២ និងចំណុចទី៣ថា ករណីយកិច្ចរបស់សាក្សី

១.លើកលែងតែក្នុងករណីដែលមានកំនត់ពិសេសនៅក្នុងក្រមនេះ ឬច្បាប់ផ្សេងតុលាការអាចសាកសួរជនណាមួយជាសាក្សីក៏បាន។

២.តុលាការអាចបង្គាប់ឱ្យនាំខ្លួនសាក្សីដែលមិនព្រមចូលខ្លួនមកតុលាការ ដោយគ្មានមូលហេតុត្រឹមត្រូវដោយដីកាសម្រេចបាន។

៣.ប្រសិនបើសាក្សីមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី១.០០០.០០០(មួយលាន)រៀលបានដោយដីកាសម្រេច។ ចំពោះមាត្រា៥៣៨ (បទបដិសេធក្នុងការចូលខ្លួន)នៃក្រមព្រហ្មទណ្ឌបានចែងថា «បទបដិសេធក្នុងការចូលខ្លួន រាល់បុគ្គលណាដែលត្រូវបានកោះហៅឱ្យមកឆ្លើយជាសាក្សីនៅមុខអយ្យការ ឬចៅក្រមស៊ើបសួរ ឬមុខតុលាការព្រហ្មទណ្ឌ ហើយមិនព្រមចូលខ្លួនតាមដីកាកោះហៅនោះដោយគ្មានមូលហេតុសមស្រប ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែទៅ៦ខែ និងពិន័យជាប្រាក់ពីមួយសែនរៀលទៅមួយលានរៀល»។ មាត្រា៥៣៨នេះវាជាការដាក់ទោសទៅលើសាក្សីដែលមិនអនុវត្តតាមមាត្រា២៩៧ និងមាត្រា៤៧៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប៉ុន្តែមិនបានដាក់ទោសទៅល សាក្សីនៅក្នុងនីតិវិធីរដ្ឋប្បវេណីនោះទេ ពីព្រោះប្រសិនបើសាក្សីក្នុងសំណុំរឿងក្តីរដ្ឋប្បវេណីមិនព្រមចូលខ្លួនតាមការកោះហៅ សាក្សីរូបនោះត្រូវតែពិន័យជាប្រាក់ដូចមានចែងក្នុងចំណុចទី៣ នៃមាត្រា១៣២ក្រមនីតិវិធីរដ្ឋប្បវេណី (អាចតវ៉ាបានអំពីដីការសម្រេចនោះមានក្នុងចំណុចទី៤ នៃមាត្រា១៣២)។

សរុបមកវិញ ច្បាប់បានដាក់លក្ខខណ្ឌយ៉ាងតឹងតែងចំពោះសាក្សីក្នុងករណីដែលពួកគេមិនព្រមបង្ហាញខ្លួននៅចំពោះមុខអាជ្ញាធរសារធារណៈ ដែលច្បាប់តម្រូវដោយមិនទាន់គិតដល់កំហុសផ្សេងៗទៀតនោះផង ។

## ខ. សិទ្ធិនានារបស់សាក្សី

តាមការពិតសាក្សីមានកាតព្វកិច្ចផ្តល់ការបំភ្លឺ និងមានសិទ្ធិជាច្រើនទៀតជាអាទិ៍ៈ រៀបរាប់នូវអ្វីៗទាំងអស់ដែលគាត់បានដឹងអំពីរឿងនោះ និងមានកាតព្វកិច្ចឆ្លើយនូវរាល់សំណួររបស់ស្ថាប័នស៊ើបអង្កេត តុលាការ និងភាគីបន្ទាប់ពីសាក្សីនោះបានចូលខ្លួនតាមការកោះហៅ។ ករណីដែលសាក្សីត្រូវសួរតទល់គ្នាក្នុងដំណាក់កាលជំនុំជម្រះដូចជាមាត្រា២៩៧ ចែងថា «សាក្សីខាងដាក់បន្ទុកដែលមិនទាន់បានសួរចម្លើយតទល់គ្នាជាមួយជនជាប់ចោទ ត្រូវតែកោះហៅឱ្យចូលរួមក្នុងសវនាការ»។ មាត្រានេះបានបង្ហាញអំពីកាត្វកិច្ចរបស់សាក្សី ចំណែកសាក្សីខ្លះដែលអយ្យការមិនបានកោះហៅចូលរួមក្នុង សវនាការក៏គេអាចអញ្ជើញចូលរួមតាមរយៈដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទបានផងដែរដូចមាត្រា២៩៨ បានចែងថា «ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីអាចនាំចូលរួមក្នុងសវនាការនូវសាក្សីទាំឡាយណាដែលព្រះរាជអាជ្ញាមិនបានកោះហៅដោយខ្លួនជាអ្នកចេញសោហ៊ុយ»។ ចំពោះមាត្រា៣២៦ បានផ្តល់សិទ្ធិឱ្យសាក្សីបំភ្លឺ និងទទួលឆ្លើយនូវសំណួរទាំងឡាយពីព្រះរាជអាជ្ញា មេធាវី និងភាគីតាមរយៈនៃការអនុញ្ញាត្តិពីប្រធានសវនាការជាពិសេសទៅ

ទៀតនោះមាត្រា៣២៦ នេះបានចងនីតិវិធីតុលាការទៅនឹងអង្គហេតុដែលអាចស្តែងចេញតាមរយៈកំណត់ហេតុសវនាការ។ ប៉ុន្តែព្រះរាជអាជ្ញា មេធាវី និងភាគីក៏អាចជំទាស់ទៅនឹងសាក្សីនោះបានដែរ ប្រសិនបើការឆ្លើយនោះគ្មានការពិតដូចជាមាត្រា៣២៧បានបញ្ញត្តិថា «ព្រះរាជអាជ្ញា មេធាវី និងភាគីអាចជំទាស់នឹងការស្តាប់សាក្សី ដែលខ្លួនយល់ឃើញថា ចម្លើយនេះគ្មានប្រយោជន៍អ្វីដល់ការសំដែងឲ្យឃើញការពិត។ ក្នុងករណីមានការតវ៉ាប្រធានសវនាការសម្រេចដោយឥស្សរចិត្តថាតើត្រូវស្តាប់ ឬមិនត្រូវស្តាប់ចម្លើយសាក្សីនេះ»។

ចំពោះសិទ្ធិរបស់សាក្សីនៅក្នុងដំណាក់កាលស៊ើបសួរវិញ មាត្រា១៥៣ កថាខណ្ឌទី២ ចែងថា «ចៅក្រមស៊ើបសួរស្តាប់ចម្លើយសាក្សីដាច់ពីគ្នាដោយគ្មានវត្តមានជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ ចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីបានផងដែរ»។ ប៉ុន្តែសាក្សីក៏មានសិទ្ធិឆ្លើយក្នុងករណីសួរតទល់គ្នាបានផងដែរ តាមការស្នើសុំរបស់ជនត្រូវចោទដូចមាត្រា១៣៣ កថាខណ្ឌ១ចែងថា «នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឲ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីសួរតទល់គ្នា ឬចុះទៅដល់ទីកន្លែងកើតហេតុ»។ រីឯដើមបណ្តឹងរដ្ឋប្បវេណីវិញក៏អាចមានសិទ្ធិស្នើសុំឲ្យសួរសាក្សីបានដែរដូចមាត្រា១៣៤ បានកំណត់ក្នុងកថាខណ្ឌ័ទី១ថា «នៅគ្រប់ពេលវេលានៃការសាកសួរដើមបណ្តឹងរដ្ឋប្បវេណី អាចសុំដល់ចៅក្រមស៊ើបសួរឲ្យស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទ សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង»។ មាត្រាទាំងនេះបានគាំទ្រដល់វិធាននៃការផ្ទៀងផ្ទាត់ភស្តុតាង ដែលធ្វើឡើងក្នុងដំណាក់កាលស៊ើបសួរ។

ចំពោះសិទ្ធិរបស់សាក្សីត្រូវបានរិតត្បិតបន្ថែមទៀតនៅក្នុងលក្ខខណ្ឌ ដែលសាក្សីនោះបានដឹងអំពីហេតុការណ៍ណាមួយដោយក្នុងនោះបានចូលខ្លួនមកហើយតែមិនព្រមផ្តល់ការបំភ្លឺ ឬមិនព្រមផ្តល់ចម្លើយវិញ សាក្សីនោះក៏ត្រូវទទួលខុសត្រូវដែរ។ ខ្លឹមសារនេះត្រូវបានព្រមានចាប់តាំងតែពីការចេញដីកាកោះហៅម្ល៉េះដូចជាមាត្រា៤៧៧ កថាខណ្ឌ័ទី២បានចែងថា «ដីកាកោះហៅត្រូវបញ្ជាក់ថាៈ

- បុគ្គលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈសាក្សី
- ការមិនចូលបង្ហាញខ្លួននៅពេលសវនាការ ការមិនព្រមឆ្លើយឱ្យព័ត៌មានក្នុងឋានៈជាសាក្សី ឬការឆ្លើយឱ្យព័ត៌មានក្លែងក្លាយត្រូវផ្តន្ទាទោសតាមច្បាប់»។

មាត្រា៤៧៧នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះបានរិតបន្តឹងចំពោះសិទ្ធិនានារបស់សាក្សី ប៉ុន្តែសិទ្ធិសាក្សីនេះកាន់តែបន្តឹងថែមទៀតនៅពេលដែលសាក្សីបានស្គាល់ជនល្មើស ហើយបែរជាមិនព្រមប្រាប់ដល់ចៅក្រម សាក្សីរូបនោះក៏ត្រូវមានទោសផងដែរ។ លក្ខខណ្ឌនេះត្រូវបានកំណត់តាម

មាត្រា៥៣៧នៃក្រមព្រហ្មទណ្ឌថា «បទបដិសេធការផ្ដល់ចម្លើយរាល់បុគ្គលណាដែលបានប្រកាសជាសាធារណៈថា ខ្លួនស្គាល់ចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតនៅក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយប្រកែកមិនព្រមឆ្លើយនឹងសំណួរដែលចៅក្រមបានសួរពីរឿងនេះដល់ខ្លួន នោះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១ខែទៅ១ឆ្នាំ និងពិន័យជាប្រាក់ពីមួយសែនរៀលទៅពីរលានរៀល»។

ជាងនេះទៅទៀត ការរិតត្បិតតឹងរ៉ឹងទៅលើសាក្សីមិនត្រឹមតែស្ថិតនៅក្នុងលក្ខខណ្ឌដែលគាត់បានដឹងនូវអំពើទុច្ចរិតរបស់ជនជាប់ចោទប៉ុណ្ណោះទេ សូម្បីតែសាក្សីបានដឹងពីអំពើល្អរបស់ជនត្រូវចោទហើយបែរជាមិនព្រមប្រាប់ដល់តុលាការវិញ សាក្សីរូបនេះក៏មានទោសផងដែរដូចមាត្រា៥៣៩ក្រមព្រហ្មទណ្ឌបានចែងថា «បទមិនផ្ដល់ភស្តុតាងនៃភាពគ្មានទោស និងការលើកលែងរាល់បុគ្គលណាដែលមានភស្តុតាងបង្ហាញឲ្យឃើញភាពស្លូតត្រង់របស់ជនត្រូវចោទ ជនជាប់ចោទ ពិរុទ្ធជន ឬទណ្ឌិត ហើយមិនផ្ដល់ភស្តុតាងនោះដល់អាជ្ញាធរតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតទេ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំទៅ៣ឆ្នាំ និងពិន័យជាប្រាក់ ពី២លានរៀលទៅ៦លានរៀល។ ប៉ុន្តែត្រូវបានលើកលែងឲ្យរួចផុតពីទោសៈ

១. ចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតនៃបទល្មើសដែលចោទប្រកាន់ ។

២. បុព្វញាតិ និងបច្ឆាញាតិ បងប្អូនប្រុសស្រីរបស់ចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិត ។

៣. សហព័ន្ធរបស់ចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិត ។

៤. បុគ្គលដែលត្រូវរក្សាអាថ៌កំបាំងខាងវិជ្ជាជីវៈ»។

តាមខ្លឹមសារនៃមាត្រានេះបង្ហាញយ៉ាងប្រាកដថាសាក្សីមានសិទ្ធិឆ្លើយ ឬនិយាយដោយសេរីមែន តែត្រូវបានកំរិតព្រំដែនតាមរយៈនៃខ្លឹមសារអង្គហេតុដាក់បន្ទុក និងដោះបន្ទុកចំពោះបទល្មើស។

## គ. ភាតព្វកិច្ចពិសេសរបស់សាក្សី

ចំពោះកាតព្វកិច្ចរបស់សាក្សីវិញគាត់ក៏មានលក្ខខណ្ឌដែលត្រូវការពារខ្លួនផងដែរ ពោលគឺសាក្សីគ្មានកាតព្វកិច្ចត្រូវតែឆ្លើយទៅលើសំណួរទាំងឡាយណា ដែលចំលើយនៃសំណួរបែបនោះនាំឱ្យមានការដាក់បន្ទុកក្នុងការទទួលខុសត្រូវនូវបទល្មើសព្រហ្មទណ្ឌមកលើសាក្សីខ្លួនឯង វិញនោះបានឡើយ។ មានកាតព្វកិច្ចពិសេសបែបនេះពីព្រោះថា សាក្សីមានកាតព្វកិច្ចបំភ្លឺបានតែទៅលើអង្គហេតុនៃព្រឹត្តិការណ៍ណាមួយដែលបានកកើត និងបានដឹងសម្រាប់យកធ្វើជាទឡ្ហីកម្មគាំទ្រដល់នត្ថិភាព ឬគាំទ្រដល់អត្ថិភាពនៃបទល្មើសដែលមិនជាប់ពាក់ព័ន្ធទៅនឹងរូបគាត់តែប៉ុណ្ណោះ ប៉ុន្តែប្រសិនបើការបំភ្លឺនោះធ្វើឱ្យខ្លួនមានទោសទៅវិញ នោះខ្លួនមានសិទ្ធិបដិសេធក្នុងការបំភ្លឺនោះពី

ព្រោះសាក្សីក្នុងលក្ខខណ្ឌនេះត្រូវប្រើប្រាស់សិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។ កាតព្វកិច្ចពិសេសនេះក៏មានកំនត់នៅក្នុងរឿងក្ដីរដ្ឋប្បវេណីផងដែរដូចជា មាត្រា១៣៨នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា «សិទ្ធិបដិសេធនូវការផ្ដល់ចម្លើយជាកសិណសាក្សីៈ

១.ប្រសិនបើការផ្ដល់នូវចម្លើយជាកសិណសាកទាក់ទងនឹងហេតុដែលធ្វើឱ្យសាក្សី ឬសហពន្ធ័របស់សាក្សី ឬញាតិឯទៀតរបស់សាក្សីអាចទទួលរងនូវការចោទប្រកាន់អំពីបទអាជ្ញា ឬទទួលការផ្ដន្ទាទោស នោះសាក្សីអាចបដិសេធនូវការផ្ដល់ចម្លើយជាកសិណសាក្សីបាន។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរចំពោះការផ្ដល់ចម្លើយជាកសិណសាក្សីទាក់ទងនឹងហេតុ ដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដែលបានរៀបរាប់ខាងលើនេះ ឬបណ្ដាលឱ្យមានការបែកបាក់ធ្ងន់ធ្ងរដល់ទំនាក់ទំនងគ្រួសារ។

២.សាក្សីអាចបដិសេធនូវការផ្ដល់ចម្លើយជាកសិណសាក្សីបាន

ក.ក្នុងករណីដូចកថាខណ្ឌ័ទី១នៃមាត្រា១៣៣ (ការសាកសួរសាក្សីជាមន្ត្រីរាជការ) ខាងលើ ។

ខ.ក្នុងករណីដែលវេជ្ជបណ្ឌិត ទន្តបណ្ឌិត ឱសថការី គិលានុបដ្ឋាកយិកា គិលានុបដ្ឋាក ឱសថការី មេធាវី អ្នកមានមុខងារក្នុងសាសនា ឬអ្នកដែលធ្លាប់មានមុខងារខាងលើនេះ ត្រូវទទួលការសាកសួរអំពីអង្គហេតុ ដែលបានដឹងក្នុងការបំពេញតួនាទីរបស់ខ្លួនហើយដែលត្រូវលាក់ការសម្ងាត់។

គ.ក្នុងករណីដែលសាកសួរអំពីហេតុ ដែលទាក់ទងនឹងការសម្ងាត់ក្នុងបច្ចេកទេសឬវិជ្ជាជីវៈ។

៣.បញ្ញត្តិនៃកថាខណ្ឌទី២ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលសាក្សីទទួលការលើកលែងពីករណីយកិច្ចលាក់ការសម្ងាត់»។

នៅក្នុងន័យដែលសាក្សីមានកាតព្វកិច្ចមិនព្រមឆ្លើយនេះគឺ «ច្បាប់បានផ្ដល់សិទ្ធិការពារខ្លួនដល់ជនគ្រប់រូបតាមផ្លូវតុលាការក្នុងរឿងក្ដីព្រហ្មទណ្ឌដូចមាត្រា៣៨ កថាខណ្ឌ៨នៃរដ្ឋធម្មនុញ្ញបានចែងថា «ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ»។ កថាខណ្ឌនេះបានបង្ហាញថា សិទ្ធិការពារខ្លួនត្រូវបានផ្ដល់ជូនឲ្យបុគ្គលគ្រប់រូបជ្រើសរើសមេធាវីការពារតាមផ្លូវតុលាការ។ ពីព្រោះថារាល់ការបំភ្លឺរបស់សាក្សីមិនចាំបាច់មានមេធាវីដូចជនត្រូវចោទនោះឡើយ ដោយសារតែក្នុងខណៈដែលសាក្សីបំភ្លឺនេះគាត់កំពុងតែប្រើប្រាស់សិទ្ធិការពារខ្លួនតាមច្បាប់(សិទ្ធិនានារបស់សាក្សី) ប៉ុន្តែបើសាក្សីនេះដឹងខ្លួនថា អាចមានការប្រឈមទៅនឹងបទល្មើសព្រហ្មទណ្ឌ (មានតម្រុយពិរុទ្ធភាព) នៃ

ចម្លើយចំពោះសំណួរ នោះសាក្សីត្រូវការចាំបាច់នូវសិទ្ធិមិនឆ្លើយ(កាតព្វកិច្ចពិសេស) ហើយក្នុងខណៈបែបនេះសាក្សីត្រូវការចាំបាច់ប្រើប្រាស់សិទ្ធិការពារខ្លួនតាមផ្លូវតុលាការ(ជ្រើសរើសមេធាវី)។

## ឃ. សាក្សីមានកាតព្វកិច្ចនិយាយតែការពិត

ជាការពិតហើយច្បាប់តែតែងកំណត់បុគ្គលទាំងឡាយ ដែលពាក់ពន្ធ័នៅក្នុងនីតិវិធីតុលាការនិយាយតែការពិតប៉ុណ្ណោះមានដូចជាៈ ជនរងគ្រោះ, សាក្សី, ជនជាប់ចោទជាដើម។ល។ ប៉ុន្តែក៏មានពួកគេខ្លះអាចនិយាយមិនពិតហើយការនិយាយបែបនេះមិនមានច្បាប់ដាក់ទោសនោះទេ ផ្ទុយទៅវិញគ្រប់សាក្សីមិនអាចនិយាយកុហកបានទេ ប្រសិនបើសាក្សីនិយាយកុហកនោះ ច្បាប់នឹងត្រូវដាក់ទោសមិនអាចអត់ឱនបានឡើយ នេះហើយដែលហៅថាកាតព្វកិច្ចចាំបាច់របស់សាក្សីក្នុងការនិយាយតែការពិត។ តាមច្បាប់សាក្សីនិយាយតែការពិតនេះគឺជាកាតព្វកិច្ចដែលចងសាក្សីទៅនឹងអង្គហេតុ និងនីតិវិធីតុលាការដូចជាមាត្រា៣២៨ កថាខណ្ឌទី២បានចែងថា«មុននឹងឆ្លើយទៅនឹងសំណួរ សាក្សីនីមួយៗត្រូវស្បថថាខ្លួននិយាយតែការពិតស្របតាមសាសនា ឬជំនឿរបស់ខ្លួន»។ ផ្ទុយមកវិញបើសាក្សីនិយាយកុហកនោះត្រូវទទួលទោសព្រហ្មទណ្ឌ ឬពិន័យផ្សេងៗដូចមាត្រា៥៤៥នៃក្រមព្រហ្មទណ្ឌបានចែងរួចហើយ ប៉ុន្តែសាក្សីណាដែលមានភស្តុតាងបញ្ជាក់បាននូវភាពគ្មានទោសដល់ជនត្រូវចោទ បែរជាមិនព្រមផ្តល់ភស្តុតាងនោះដល់តុលាការក៏ត្រូវមានវិធានការផងដែរដូចជា មាត្រា៥៣៩នៃក្រមព្រហ្មទណ្ឌបានបញ្ញត្តិស្រាប់។

ចំពោះការនិយាយតែការពិតរបស់សាក្សី គឺពិតជាមានប្រភេទច្រើនទៀតដែលអាចឱ្យយើងងាយស្រួលក្នុងការសិក្សាទៅលើចរិតលក្ខណៈរបស់បុគ្គលក្នុងការផ្តល់ព័ត៌មានអំពីអង្គហេតុ។ ប្រភេទក្នុងការនិយាយតែការពិតនេះត្រូវបានគេមើលឃើញតាមរូបភាពជាច្រើនដូចជា: និយាយការពិតដោយគ្មានការបង្ខិតបង្ខំ, ផ្តល់សិទ្ធិឲ្យសាក្សីក្នុការកែប្រែចម្លើយជាដើម។

## ១.៣. ការវាយតម្លៃលើការបំភ្លឺរបស់សាក្សី

ការវាយតម្លៃទៅលើការបំភ្លឺនានា គឺជាការងារដ៏មានអត្ថន័យ និងលំបាកបំផុតពីព្រោះថាសាក្សីខ្លះនិយាយមកពាក់ព័ន្ធដូចជាកុហក, បំផ្លើស ឬក៏ត្រូវបានទិញទឹកចិត្តឱ្យនិយាយដើម្បីឱ្យរួចផុតពីការដាក់បន្ទុកចំពោះជនជាប់ចោទក៏មានដែរ សកម្មភាពទាំងអស់នេះរបស់សាក្សីសុទ្ធតែជាតួនាទីរបស់ស្ថាប័នស៊ើបអង្កេត និងចុងបញ្ចប់របស់តុលាការជាអ្នកសម្រេច។ ប៉ុន្តែដើម្បីជំនះឲ្យបានទៅលើសកម្មភាពអវិជ្ជមានទាំងនេះ គេត្រូវការវាយតម្លៃទៅលើការបំភ្លឺរបស់សាក្សីដោយឈរលើកត្តាគ្រឹះនៃទ្រឹស្តីចិត្តវិទ្យាគតិយុត្តិ និងបទពិសោធន៍នានាដែលមាននៅក្នុង ជំនាញនីមួយៗ។

កត្តាគ្រឹះនៃចិត្តវិទ្យាគតិយុត្តិនេះគឺជា មូលដ្ឋានចម្បងមួយដែលសិក្សាទៅលើតែផ្លូវចិត្តរបស់មនុស្សមានជាអាទិ៍ៈ ធម្មារម្មណ៍(Emotion), ឆន្ទៈ(ចេតនា ឬអចេតនា), ការចងចាំ, ឋានៈបុគ្គលជា

ដើម។ល។ ដែលធាតុទាំងនេះ កើតមានទៅតាមដំណើរការនៃសកម្មភាពរបស់សាក្សី ។ ដោយផ្អែកលើកត្តាគ្រឹះនៃចិត្តវិទ្យាគតិយុត្តិនេះ គេអាចសង្កេតឃើញសញ្ញាណរួមនៃដំណើរការផ្លូវចិត្តរបស់សាក្សី ឬមនុស្សទូទៅបានដោយក្នុងនោះមានដូចជាៈ វេទនារម្មណ៍(Sensation), កំរិតនៃការទទួលដឹងនានា(Perception), ការចងចាំ(Memory), និការគិត(thinking)។ ការលេចឡើងនូវដំណើរការផ្លូវចិត្តបែបនេះអាចស្ថិតនៅយូរ ឬឆាប់ជាមួយនឹងខ្លួនរបស់សាក្សីដោយអាស្រ័យទៅនឹងកត្តាមូលដ្ឋានគ្រឹះនៃផ្លូវចិត្តរបស់មនុស្សម្នាក់ៗ។ ចំពោះមនុស្សម្នាក់ៗតែងតែកើតមាននូវគុណសម្បត្តិផ្លូវចិត្តជាច្រើនប្រភេទមានជាអាទ៍៖ ភាពរីករាយ, ភាពធុញទ្រាន់(តប់ប្រមល់), ភាពសកម្មភាពអសកម្ម និងអារម្មណ៍ផ្សេងៗទៀតដែលធាតុទាំងនេះអាចស្ថិតនៅជាមួយនឹងខ្លួនសាក្សី (មនុស្សទូទៅ) បានយូរជាងអ្វីៗ ដែលជាសញ្ញាណរួមនៃកាលេចឡើងក្នុងដំណើរការផ្លូវចិត្ត។ ប៉ុន្តែបាតុភូតនៃចិត្តវិទ្យារបស់មនុស្សចាប់កកើតមានតាំងពីកំណើតរហូតដល់ចាស់ តែវាអាចប្រែប្រួលដោយសារឥទ្ធិពលនៃសង្គមដូចជាការអប់រំជាដើម។ នៅក្នុងចំណុច នេះយើងមិនបានលំអិតទៅលើទ្រឹស្តី និងវិធាននានានៃចិត្តវិទ្យាគតិយុត្តិនោះទេ ប៉ុន្តែអាចប្រាប់ជាសញ្ញាណរួមមួយសម្រាប់ឲ្យអ្នកច្បាប់ ឬអ្នកសិក្សាមានមូលដ្ឋានសម្រាប់ធ្វើការវាយតម្លៃទៅលើការបំភ្លឺរបស់សាក្សីតែប៉ុណ្ណោះ។ ចំពោះខ្លឹមសារនៃបទពិសោធដែលមាននៅក្នុងជំនាញវិញសៀវភៅនេះអធិប្បាយផ្តោតទៅលើតែអ្នកជំនាញដែលធ្លាប់ធ្វើការយ៉ាងស្ទាត់ និងចេះថ្មីកបំផុតប៉ុណ្ណោះនៅក្នុងវិស័យនានាដែលពួកគេទទួលបន្ទុកក្នុងការធ្វើកោសល្យវិច្ច័យនិយាយជារួម ប៉ុន្តែនិយាយដោយឡែកក្នុងចំណុចនេះគឺសំដៅទៅអ្នកធ្វើកោសល្យវិច្ច័យខាងរោគចិត្ត ឬអ្នកជំនាញខាងចិត្តវិទ្យា។

ការវាយតម្លៃទៅលើការបំភ្លឺរបស់សាក្សីមានភាពស្មុគស្មាញណាស់ ពីព្រោះវាពាក់ព័ន្ធទៅនឹងចំណេះដឹងទាំងទ្រឹស្តី និងការអនុវត្តរបស់អ្នកវាយតម្លៃ។ ប្រសិនបើគ្មានបទពិសោធន៍ទាំងទ្រឹស្តី និងការអនុវត្តន៍ជាក់ស្តែងទេ នោះការវាយតម្លៃទៅលើការបំភ្លឺរបស់សាក្សីមិនអាចសម្រេចផលបានឡើយពីព្រោះថាសាក្សីគឺជា មនុស្សហើយចេះប្រើអារម្មណ៍ប្រឌិតនូវអង្គហេតុដែលមិនកើតមានឲ្យទៅជាកើតមានដូចអង្គហេតុពិតមែនទែនដូច្នោះដែរ។ ដោយសាតែមនុស្សចេះប្រើអារម្មណ៍នេះហើយទើបធ្វើឲ្យមនុស្សចេះកុហក។

## ១.៤. កត្តានានាដែលមានឥទ្ធិពលទៅលើភាពត្រឹមត្រូវនៃការបំភ្លឺរបស់សាក្សី

ដោយអាស្រ័យទៅនឹងដំណើរការនៃការៀបចំចំពោះការបំភ្លឺរបស់សាក្សីផ្ទាល់ខ្លួន ក្នុងពេលដែលគាត់ធ្វើការបំភ្លឺ សកម្មភាពទាំងនេះអាចឲ្យគេកំណត់បាននូវកត្តាសំខាន់ៗដែលមានប្រយោជន៍ដល់ភាពជឿជាក់ទៅលើការបំភ្លឺរបស់សាក្សី។ កត្តាគ្រឹះទាំងនេះអាចមានចំនួនយ៉ាងច្រើន

ដែលមិនអាចមានលទ្ធភាពរាប់បានអស់នោះឡើយ ប៉ុន្តែកត្តាសំខាន់ៗ និងពិសេសៗ ជានិច្ចកាលត្រូវបានជួបប្រទះឃើញ និងអាចកំណត់បានជាក្រុមដែលពាក់ព័ន្ធទៅនឹងលក្ខណៈឯកត្តបុគ្គលរបស់សាក្សីមួយចំនួន។ លក្ខណៈឯកត្តបុគ្គលនោះវាទាក់ទិនទៅនឹងលក្ខខណ្ឌខាងក្នុង(ផ្លូវចិត្ត) របស់សាក្សី និងខណៈនានាផ្នែកឥរិយាបថខាងក្រៅ ហើយដែលលក្ខណៈបែបនេះ ត្រូវបានផ្តល់ជាសញ្ញាណឲ្យយើងបានដឹងនៅពេលដែលសាក្សីបានធ្វើការបំភ្លឺអំពីព្រឹត្តិការណ៍នានា ដែលគាត់បានទទួលដឹងដោយផ្ទាល់នៅចំពោះមុខអ្នកស៊ើបអង្កេត និងតុលាការ។ កត្តាគ្រឹះសំខាន់ៗដែលអាចជះឥទ្ធិពលអាក្រក់ទៅលើភាពត្រឹមត្រូវនៃការបំភ្លឺទាំងនោះមានជាអាទិ៍៖ គុណសម្បត្តិនៃការយល់ដឹង និងគុណសម្បត្តិនៃការចងចាំ, រោគសញ្ញាផ្សេងៗដែលប៉ះពាល់ដល់ប្រពន្ធ័ប្រសាទ និងប៉ះពាល់ដល់ផ្លូវចិត្ត, គុណភាពនៃការដឹងភ្លាមៗរបស់សាក្សី, ការយល់ដឹងលើបាតុភូតជាក់ស្តែង, ចន្លោះពេលដឹង និងការបំភ្លឺ, ការរៀបចំទីតាំង និងការតាំងសំណួរទៅលើសាក្សី, ការស្រមើស្រមៃក្នុងការបំភ្លឺរបស់សាក្សី។

## ក. គុណសម្បត្តិនៃការយល់ដឹង និងគុណសម្បត្តិនៃការចងចាំ

គុណសម្បត្តិនៃការយល់ដឹង និងគុណសម្បត្តិនៃការចងចាំរបស់សាក្សីមានទំនាក់ទំនងគ្នាមិនអាចខ្វះបានឡើយ។ ជាការពិតគុណសម្បត្តិបែបនេះស្តែងឲ្យយើងដឹងតាមរយៈនៃគម្លាតចម្ងាយ ឬ គម្លាតនៃរយៈពេលជាដើម ប៉ុន្តែវាផ្សារភ្ជាប់ជាមួយនឹងអារម្មណ៍ដូចជា៖ សភាពនៃការមើលឃើញជិត ឬឆ្ងាយរបស់សាក្សី, ភាពឃើញច្បាស់ ឬមិនច្បាស់របស់សាក្សី, ការស្តាប់បានល្អ ឬអាក្រក់របស់សាក្សី, សភាពទទួលដោយអារម្មណ៍យឺត ឬលឿនរបស់សាក្សី, ភាពយកចិត្តទុកដាក់ ឬស្មារតីមិនមូល(Distraction)របស់សាក្សី, ភាពឆ្លាត ឬភាពល្ងង់របស់សាក្សី។ល។ ដែលសញ្ញាណទាំងអស់នេះវាបញ្ជាក់នូវទំនាក់ទំនងផ្លូវចិត្តរបស់សាក្សីដែលគាត់បានជួបប្រទះ ហើយវត្តមាននៃសញ្ញាណបែបនេះអាចជះឥទ្ធិពលដល់គុណភាពនៃការបំភ្លឺរបស់សាក្សី។ ឥទ្ធិពលនៃកត្តានេះមិនមែនទាំងអស់សុទ្ធតែមិនត្រូវបានប្រែប្រួល និងពុះពារជម្នះមិនបាននោះឡើយពីព្រោះថា «មនុស្សឆ្លាតម្នាក់ដែលយល់ដឹងទៅលើឥទ្ធិពលនៃកត្តានានា ដែលមានលក្ខណៈអវិជ្ជមានប្រហាក់ប្រហែលគ្នានេះ គាត់ជានិច្ចកាលអាចធ្វើឱ្យឃើញនូវលទ្ធភាពនៃកំហុសត្រង់ចំនុចណាមួយ ដែលកំហុសនោះស្ថិតក្នុងការទទួលដឹងដោយអារម្មណ៍របស់គាត់ ឬក៏ស្ថិតក្នុងការចងចាំរបស់គាត់ ហើយចុងក្រោយគាត់ធ្វើឱ្យបាត់បង់នូវសកម្មភាព ដែលជាកំហុសមួយនោះបានដោយខ្លួនឯង»។ <u>ជាឧទាហរណ៍:</u> មនុស្សម្នាក់ស្តាប់មិនសូវបាននោះទេ ប៉ុន្តែគាត់នឹងព្យាយាមយ៉ាងយកចិត្តទុកដាក់បំផុតដើម្បីស្តាប់នូវអ្វីៗដែលគេនិយាយមកកាន់គាត់ឬក៏និយាយទៅកាន់អ្នកដទៃដែលនេះបញ្ជាក់ថា គាត់មិនធានាបានគ្រប់គ្រាន់នូវសំលេងទាំងអស់នោះទេ ប៉ុន្តែនៅពេលដែលគាត់ទទួលដឹងនូវអ្វីៗដែលគេបាន

និយាយនោះ គាត់បានឮហើយគាត់នឹងធ្វើការសិក្សាត្រៀមបំរុងទុកជាមុនដោយខ្លួនឯងនូវលទ្ធភាពដែលនឹងអាចកើតមានជាកំហុសដោយចៃដន្យចំពោះការស្តាប់នោះ។ ប្រសិនបើខណៈទាំងអស់នោះត្រូវបានធ្វើការកត់សំគាល់ដោយផ្ចិតផ្ចង់ពីអ្នកសាកសួរដូចជា ចៅក្រម និងអ្នកស៊ើបអង្កេតទៅលើសាក្សីម្នាក់នោះ កំហុសមួយក្នុងការបំភ្លឺបែបនេះនឹងមិនត្រូវបានលេចឡើងឡើយ ហើយក៏មិនមានលទ្ធផលអវិជ្ជមានណាមួយកើតឡើងផងដែរចំពោះការបំភ្លឺទាំងនោះរបស់សាក្សី។

## ខ. រោគសញ្ញាផ្សេងៗដែលប៉ះពាល់ដល់ប្រព័ន្ធប្រសាទ និងផ្លូវចិត្ត

យើងឃើញថា ប្រសិនបើបុគ្គលម្នាក់ដែលត្រូវបានកោះហៅក្នុងឋានៈជាសាក្សី ហើយដែលគាត់ត្រូវបានរងដោយសុខភាពផ្លូវចិត្តណាមួយដូចជា៖ ជម្ងឺប្រព័ន្ធប្រសាទ និងជម្ងឺផ្លូវចិត្តជាដើម។ ជម្ងឺប្រព័ន្ធប្រសាទ និងជម្ងឺដែលពាក់ពន្ធ័នឹងផ្លូវចិត្តទាំងអស់នេះសុទ្ធតែជាគុណវិបត្តិដែលអាចជះឥទ្ធិពលធំធេងខ្លាំងណាស់ទៅលើគុណភាពនៃការបំភ្លឺរបស់សាក្សី។ ជម្ងឺផ្សេងៗទាំងនេះធ្វើឱ្យបាត់បង់នូវសមត្ថភាពរបស់បុគ្គលដែលក្លាយខ្លួនជាសាក្សី។ នៅគ្រប់លក្ខខណ្ឌទាំងអស់កាលណាមានលេចឡើងនូវការសង្ស័យដែលមាននិន្នាការទាក់ទងនឹងប្រភេទនៃជម្ងឺនានារបស់សាក្សីនោះ អ្នកស៊ើបអង្កេត ឬតុលាការចាំបាច់ត្រូវតែចាត់តាំងអ្នកជំនាញផ្នែករោគផ្លូវចិត្តជាបន្ទាន់បំផុត បើពុំដូច្នោះទេ ចម្លើយទាំងប៉ុន្មានដែលសាក្សីបានឆ្លើយនឹងត្រូវបាត់បង់តម្លៃជាភស្តុតាងនោះមិនខានឡើយ សូម្បីតែភាគីនៅក្នុងរឿងក្តីក៏តម្រូវឲ្យមានការជួយខាងផ្លូវចិត្តនេះផងដែរ។

## គ. គុណភាពនៃការដឹងភ្លាមៗរបស់សាក្សី

ជាការពិតណាស់ ធម្មជាតិនៃមនុស្សគ្រប់រូបអ្វីៗដែលមនុស្សទទួលបានតាមរយៈអារម្មណ៍ភ្លាមៗទៅលើព្រឹត្តិការណ៍ណាមួយ មនុស្សអាចចងចាំបានល្អបំផុតបន្ទាប់ពីហេតុការណ៍បានបញ្ចប់ភ្លាមៗ ប៉ុន្តែបើទុករយៈពេលយូរបន្តិចវិញ ព្រឹត្តិការណ៍នោះសាក្សីអាចភ្លេចដោយអន្លើៗបាន ក៏ប៉ុន្តែបើព្រឹត្តិការណ៍នោះវាពាក់ពន្ធ័នឹងផលប្រយោជន៍របស់សាក្សីវិញ គាត់មិនត្រឹមតែមិនភ្លេចនោះទេតែគាត់អាចទន្ទេញរត់មាត់ទៀតផង។ ការចងចាំបានល្អនេះជាគុណសម្បត្តិពិសេសមួយរបស់សាក្សីចំពោះព្រឹត្តិការណ៍ហើយអ្នកស៊ើបអង្កេត និងតុលាការគួរតែយល់ដឹងជាមុនអំពីផ្លូវចិត្តបែបនេះរបស់សាក្សី។ គុណសម្បត្តិរបស់សាក្សីដែលគាត់ផ្តល់ការបំភ្លឺក្នុងខណៈពេលដែលគាត់បានដឹង ភ្លាមៗទៅលើព្រឹត្តិការណ៍ណាមួយដែលគាត់បានទទួលដឹងនោះមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះជីវិតផ្លូវចិត្តរបស់គាត់ពុំទាន់ត្រូវបានរងនូវឥទ្ធិពលផ្សេងៗពីខាងក្រៅដើម្បីលុប ឬក៏បញ្ចុះបញ្ចូល ឬកែសម្រួលណាមួយអំពីការទទួលដឹងទៅលើព្រឹត្តិការណ៍នោះទេ ដែលចំណុចនេះធ្វើឲ្យការបំភ្លឺនេះបង្ហាញបានអំពីខណៈជាច្រើននៃអង្គហេតុមានលក្ខណៈសុក្រឹត្យបំផុត។

ការចងចាំទៅលើព្រឹត្តិការណ៍បានល្អនេះ ត្រូវបានគេយកទៅប្រើប្រាស់ក្នុងការសួរយកចម្លើយទៅលើជនសង្ស័យផងដែរដូចក្នុងករណីឃាត់ខ្លួនបានភ្លាមៗ ចាំបាច់ត្រូវធ្វើកំណត់ហេតុសួរចម្លើយ ភ្លាមៗដោយមិនមានការពន្យាពេលនោះឡើយ។ ការផ្តល់ចម្លើយភ្លាមៗនេះវាមានគុណភាពខ្ពស់ខាងតម្លៃនៃភស្តុតាងពោលគឺ

**ទី១**.ជននេះមិនទាន់ត្រូវបានជួបសន្ទនា ឬបានយោបល់ពីឥទ្ធិពលណាមួយនៅឡើយ,

**ទី២**.ព្រឹត្តិការណ៍ដែលបានកើតថ្មីៗនោះគាត់នៅចាំបានល្អ

**ទី៣**.ចម្លើយរបស់គាត់មានការពិតច្រើនជាងនៅពេលបន្ទាប់ (ភាគច្រើនចម្លើយដែលឆ្លើយដោយឯកឯងគឺគ្រប់ខណៈនៃអង្គហេតុត្រូវបានបំភ្លឺធ្វើឱ្យយើងឃើញច្បាស់)។

ជាការពិតណាស់ ទោះបីការដឹងភ្លាមៗរបស់សាក្សីបានផ្តល់គុណភាពជាភស្តុតាងក៏ដោយក៏គុណសម្បត្តិបែបនេះវាផ្តល់នូវគុណវិបត្តិមិនតិចនោះដែរ ពីព្រោះថាការដឹងភ្លាមៗរបស់សាក្សី ក៏អាចធ្វើឲ្យជះឥទ្ធិពលអាក្រក់ដល់ការបំភ្លឺរបស់គាត់ផងដែរ។ ឥទ្ធិពលអាក្រក់នោះមានសកម្មភាពជាច្រើនប្រភេទទាក់ទឹនទៅនឹងលក្ខណៈសម្បត្តិរបស់សាក្សី។ លក្ខណៈសម្បត្តិជាសកម្មភាពដែលជះឥទ្ធិពលទាំងនេះមានជាអាទ៍៖

•**ទី១**.ភាពភ័យខ្លាចដ៏ខ្លាំងដែលសាក្សីបានឃើញផ្ទាល់ភ្នែកទៅលើព្រឹត្តិការណ៍ណាមួយអាចបង្កើតឱ្យសាក្សីមានការបំផ្លើស ឬបញ្ចេញបញ្ចូលពាក្យសម្តីលើសពីអ្វីដែលខ្លួនបានឃើញ ឬបានដឹងទៅទៀតដើម្បីធ្វើឲ្យអ្នកសាកសួរមានការចាប់អារម្មណ៍មកលើខ្លួនដែលចំណុចនេះគេអាចហៅថាអារម្មណ៍ភិតភ័យ ពីព្រោះថាភាពភ័យខ្លាចស្ថិតនៅនឹងភ្នែករបស់សាក្សី។

•**ទី២**.លក្ខណៈឈឺចាប់របស់សាក្សី ក៏អាចជះឥទ្ធិពលខ្លាំងបំផុតទៅលើការទទួលដឹងរបស់សាក្សីអំពីព័ត៌មាននៃអង្គហេតុពិតណាមួយបានផងដែរ ពីព្រោះថាសេចក្តីឈឺចាប់តាមផ្លូវកាយ ឬផ្លូវចិត្តវាមានឥទ្ធិពលទៅវិញទៅមកហើយក្នុងខណៈដែលសាក្សីបានទទួលដឹងនូវព្រឹត្តិការណ៍ណាមួយភ្លាមៗ ធ្វើឲ្យគាត់មិនអាចរៀបរាប់បាននោះទេ តែពីការសម្តែងកិរិយាហួសចិត្ត ឬអាកប្បកិរិយាមិនចេញស្តីផ្សេងៗទៀតដែលជាហេតុ ធ្វើឲ្យអ្នកសាកសួរមិនទទួលបានព័ត៌មានអ្វីជាដុំកំភួនពីផលប្រយោជន៍នៃការដឹងភ្លាមៗរបស់សាក្សីនេះឡើយ។

•**ទី៣**.លក្ខណៈស្រវឹងរបស់សាក្សីចំពោះការទទួលដឹងភ្លាមៗទៅលើព្រឹត្តិការណណាមួយ ក៏អាចធ្វើឲ្យចម្លើយរបស់គាត់គ្មានតម្លៃពេញលេញបានដែរពីព្រោះថា ជាតិស្រវឹង (សារធាតុ អាល់កុល ឬសារធាតុញៀននានា) ជាប្រភពធ្វើឲ្យប្រព័ន្ធប្រសាទកាត់បន្ថយការចងចាំ និងកាត់បន្ថយការពិចារណាក្នុងឋានៈនៃភាពជាមនុស្ស(ថនិកសត្វថ្នាក់ខ្ពស់) ហើយដោយសារតែសញ្ញាណនៃការកាត់បន្ថយនូវការចងចាំ និងខ្វះការពិចារណានេះហើយ ទើបធ្វើឲ្យអ្នកប្រើប្រាស់គ្រឿងស្រវឹងគ្រប់

ប្រភេទរួមទាំងអ្នកប្រើប្រាស់គ្រឿងញៀនផងបានជម្រុញឲ្យចិត្តពុះកញ្ជ្រោល ខ្វះការគ្រប់គ្រងដូចមនុស្សធម្មតាក្នុងស្ថានភាពប្រក្រតី។

ក្នុងការអនុវត្តជាក់ស្តែងនៅតាមសាលាជម្រះក្តីគ្រប់យុត្តាធិការ រាល់ចម្លើយទាំងអស់របស់ភាគីនៅក្នុងសំណុំរឿងក្តីមានការប្រែប្រួលមិនត្រឹមតែជាចម្លើយរបស់សាក្សីនោះទេ ប៉ុន្តែចម្លើយជនរងគ្រោះ ជនជាប់ចោទក៏សុទ្ធតែមានលក្ខណៈបែបនេះដែរ។ ដើម្បីបញ្ជាក់ថាចម្លើយក្នុងដំណាក់កាលណាមួយមានប្រសិទ្ធិភាព គេតម្រូវឲ្យពិនិត្យទៅលើកំណត់ហេតុដែលយកចម្លើយពីដំណាក់កាលដំបូងបំផុត មកធ្វើជាគោលគ្រឹះសម្រាប់ផ្ទៀងផ្ទាត់ទៅនឹងចម្លើយដែលបានធ្វើជាបន្តបន្ទាប់ទៀតនៃលំហូរនីតិវិធីរបស់តុលាការ។ ប៉ុន្តែវិធានផ្ទៀងផ្ទាត់បែបនេះមិនមែនជាវិធីដាច់ណាត់នោះទេ តែជាគន្លឹះមួយសម្រាប់ឈានទៅផ្ទៀងផ្ទាត់បានជាមួយនឹងខណៈនានានៃប្រភេទភស្តុតាងផ្សេងៗដទៃទៀត។

## ឃ. ការរៀបចំទីតាំង និងការតាំងសំនួរនានាទៅលើសាក្សី

នេះជាស្ថានភាពនៃការសាកសួរទៅលើសាក្សីរបស់ស្ថាប័នស៊ើបអង្កេត និងតុលាការដោយចេះរៀបចំឱ្យបានត្រឹមត្រូវទាំងទីកន្លែង ពេលវេលា ឬពាក្យសំដី។ ប្រសិនបើអ្នកសាកសួរគ្មានការប៉ិនប្រសព្វ និងគ្មានបទពិសោធបែបចិត្តវិទ្យាធ្វើឲ្យអ្នកឆ្លើយទាក់ទាញបានទេ នោះចម្លើយទាំងឡាយដែលទទួលបានមិនឆ្លុះបញ្ចាំងអំពីខណៈនានានៃអង្គហេតុនោះឡើយ។ អ្នកសាកសួរត្រូវប្រើគ្រប់មធ្យោបាយដើម្បីទទួលបានចម្លើយជាខណៈនៃអង្គហេតុតែមិនត្រូវព្យាយាមលួងលោម ដើម្បីបញ្ចុះបញ្ចូលតាមការស្រមើស្រមៃរបស់ខ្លួននោះឡើយ។

កត្តានេះយើងបានបង្ហាញរួចទៅហើយថា ការសាកសួររបស់ស្ថាប័នស៊ើបអង្កេត និងតុលាការនៅក្នុងស្ថានភាពណាមួយ ដែលមិនប្រក្រតីពាក់ពន្ធ័នឹងផ្លូវចិត្តរបស់សាក្សីអាចជះឥទ្ធិពលអាក្រក់ទៅលើការបំភ្លឺនោះជាមិនខានឡើយ។ ប៉ុន្តែការលើកឡើងកន្លងមកអធិប្បាយតែទៅលើចំណុចអវិជ្ជមានដែលកើតពីសាក្សីប៉ុណ្ណោះ ប៉ុន្តែក្នុងចំណុចនេះវាជាគុណវិបត្តិដែលកើតចេញពីអ្នកសាកសួរម្តងវិញ។ អ្នកសាកសួរមុននឹងធ្វើសំភាសន៍ជាមួយនឹងសាក្សីណាមួយ ចាំបាច់ត្រូវតែរៀបចំទីកន្លែង និងពេលវេលាឲ្យបានសមស្របតាមស្ថានភាពដែលធ្វើឲ្យសាក្សីមានទំនុកចិត្ត និងមានភាពកក់ក្តៅ។ ជាពិសេសត្រូវមានវិធាននៃការណែនាំឲ្យបានគ្រប់គ្រាន់ចេញពីអ្នកសាកសួរទៅលើចំណុចសំខាន់ៗដែលខ្លួនមានការចាប់អារម្មណ៍ដូចជាថាតើអ្វីខ្លះដែលគ្មានអត្ថិភាព និងអ្វីខ្លះដែលមានអត្ថិភាពសម្រាប់ឲ្យដំណឹងជាមុនទៅសាក្សី ដើម្បីបង្កលក្ខណៈងាយស្រួលដល់សាក្សីក្នុងការត្រៀមទុកជាមុន និងមានទំនុកចិត្តមកលើអ្នកសាកសួរបានមួយចំណែកផងដែរ ប៉ុន្តែមានករណីខ្លះសាកក៏អាចបាក់ទឹកចិត្តផងដែរ ប្រសិនបើសាក្សីរូបនោះមានការពាក់ព័ន្ធនឹងចំណុចទុច្ចរិតណាមួយ

ឬក៏ធ្វើឲ្យបាត់បង់ប្រយោជន៍ណាមួយ(អាចជាសាក្សីកុហក)ដែលសាក្សីកំពុងតែរៀបចំ។ វិធានសាកសួរខ្លះដែលពាក់ព័ន្ធនឹងជម្ងឺផ្សេងៗរបស់សាក្សី អ្នកសាកសួរមិនត្រូវបង្ខំភ្លាមៗបាននោះឡើយ ពីព្រោះថា ចម្លើយដែលបានមកអាចមានការខ្វះខាតយ៉ាងធំធេង។ ប៉ុន្តែអ្នកសាកសួរមិនត្រូវយកលេសអំពីស្ថានភាព ឬវិធានបែបនេះធ្វើជាមូលហេតុ សំរាប់ជួយសំរួលសំនួរទៅតាមបំណងរបស់ខ្លួននោះឡើយ ពោលគឺមិនត្រូវប្រើវិធី ឬប្រើមធ្យោបាយលួងលោមណាមួយ ទោះជាតាមរូបភាពណាក៏ដោយក្នុងគោលបំណងដើម្បីឲ្យសាក្សីឆ្លើយឲ្យតែបានទៅតាមអ្វីដែលខ្លួនបានគិតទុកជាមុននោះឡើយ។ ដោយសារហេតុនេះហើយ ទើបច្បាប់នីតិវិធីបានកំណត់អំពីវិធានមួយចំនួនក្នុងការសួរដើម្បីជៀសវាងឲ្យបាននូវភាពទំនើងចិត្តរបស់អ្នកសាកសួរ តែពុំមានចែងក្នុងក្រមនីតិវីព្រហ្មទណ្ឌនោះទេសម្រាប់កម្ពុជា ក៏ប៉ុន្តែយើងអាចយកខ្លឹមសារនៃស្មារតីក្រមនីតិវិធីរដ្ឋប្បវេណីក្នុងមាត្រា ១៣៩ មកសិក្សាជាវិធាននៃការដាក់សំនួរបាន ពីព្រោះនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌទោះបីមិនបានចែងអំពីរបៀបនៃការសាកសួរក៏ដោយចុះ ក៏ក្រមនីតិវិធីនេះបានចងកាតព្វកិច្ចនៃការសាកសួរតាមមាត្រា២៤២ ក្នុងកថាខណ្ឌ២ រួចទៅហើយផងដែរ។ វិធីកំរិតក្នុងការដាក់សំនួរតាមក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា១៣៩ ចែងថា ការកំរិតទៅលើសំនួរ ៖

១.ចំពោះសំណួរ បើអាចធ្វើបានត្រូវធ្វើដាច់ដោយឡែក និងច្បាស់លាស់។

២.លើកលែងតែករណីដែលមានមូលហេតុត្រឹមត្រូវ មិនអាចសាកសួរបានឡើយនូវសំណួរខាងក្រោមនេះ៖

ក. សំនួរដែលប្រមាថមើលងាយ ឬធ្វើឲ្យច្របូកច្របល់ដល់សាក្សី។

ខ. សំនួរនាំមុខ។

គ. សំនួរចំដែល។

ឃ.សំនួរដែលគ្មានទំនាក់ទំនងជាមួយនឹងចំនុចវិវាទ។

ង. សំនួរដែលទាមទារឲ្យថ្លែងយោបល់របស់សាក្សីផ្ទាល់ខ្លួន។

ច.សំនួរដែលទាមទារឲ្យថ្លែងនូវយោបល់អំពីអង្គហេតុដែលសាក្សីពុំបានជួបប្រទះផ្ទាល់។

៣.តុលាការអាចកំរិតនូវសំនួរតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិបាននៅពេលដែលយល់ឃើញថាសំនួរនោះផ្ទុយនឹងបញ្ញត្តិដែលមានចែងនៅក្នុងកថាខណ្ឌទី២ខាងលើនេះ។

៤.ភាគីអាចតវ៉ាចំពោះការកំរិតដែលធ្វើទៅតាមបញ្ញត្តិនៃកថាខណ្ឌទី៣ខាងលើនេះបាន។ ចំពោះមាត្រា ២៤២នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចងកាតព្វកិច្ចអ្នកសួរតាមកថាខណ្ឌទី២ នោះថា «កំណត់ហេតុស្រង់យ៉ាងត្រឹមត្រូវនូវសំនួរ ចម្លើយនិងចម្លើយដែលឆ្លើយដោយ

ឯកឯង» ដែលតាមស្មារតីនៃកថាខណ្ឌនេះ ច្បាប់នីតិវិធីព្រហ្មទណ្ឌទុកលទ្ធភាពឲ្យប្រធានសវនាការមានសិទ្ធិស្វ័យសម្រេចដោយឥស្សរចិត្តដូចមាត្រា៣២៧នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា «ព្រះរាជអាជ្ញា មេធាវី និងភាគីអាចជំទាស់នឹងការស្តាប់សាក្សីដែលខ្លួនយល់ឃើញថា ចម្លើយនេះគ្មានប្រយោជន៍អ្វីដល់ការសម្តែងឲ្យឃើញការពិត។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេច ដោយឥស្សរចិត្តថាតើត្រូវស្តាប់ ឬមិនស្តាប់ចម្លើយសាក្សីនេះ»។ ចំពោះមាត្រា១៤៦, មាត្រា១៥១ និងមាត្រា៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះសុទ្ធតែបានផ្តល់លទ្ធភាពជូនទៅចៅក្រមជាអ្នកសម្រេច ប៉ុន្តែឥស្សរចិត្តរបស់ចៅក្រមមិនអាចធ្វើតាមទំនើងចិត្តបាននោះទេ ពីព្រោះសកម្មភាពឥស្សរចិត្តនេះត្រូវបានចងដោយមាត្រា៣៤១កថាខណ្ឌ១ថា «នៅពេលសវនាការក្រឡាបញ្ជីសរសេរកំនត់ហេតុសវនាការ ដែលមានគោលដៅផ្តល់មធ្យោបាយដល់សាលាឧទ្ធរណ៍ធ្វើការត្រួតពិនិត្យនីត្យានុកូលភាពនៃនីតិវិធី និងបានយល់ដឹងអំពីការពិភាក្សាដេញដោល»។

ជាសរុបទៅ ការរៀបចំទីកន្លែងនៃការសាកសួរ និងការរៀបចំសំនួរនានាវាជាសមត្ថភាពផ្ទាល់ខ្លួនរបស់អ្នកសាកសួរ តែបើសមត្ថភាពនោះមានកំរិតយល់ដឹងទាបទៅលើចិត្តវិទ្យារបស់មនុស្ស និងខ្វះការយល់ដឹងទៅលើទ្រឹស្តីនៃនីតិវិធីចម្លើយដែលទទួលបានទាំងនោះអាចធ្វើឲ្យប៉ះពាល់ដល់ការធ្វើសេចក្តីសម្រេចចុងក្រោយរបស់តុលាការ។

## ១.៥. ការបំភ្លឺនានារបស់សាក្សីដែលមានអាយុតិច ឬកុមារ

ជាធម្មតានៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ពុំបានកំណត់ទៅលើអាយុរបស់សាក្សីនោះឡើយ(ស្មារតីមាត្រា១៥៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ក្នុងឋានៈជាសាក្សី ការសាកសួរអាចធ្វើឡើងបានទៅលើអ្នកមានអាយុតិចៗផងដែរ។ តើចាប់ពីអាយុ ឬវ័យណាទៅ? ដូចជាកុមារអាចសាកសួរបានក្នុងឋានៈជាសាក្សីដោយអាស្រ័យនឹងលក្ខណៈសម្បត្តិឯកត្តបុគ្គលរបស់កុមារ ការរីកលូតលាស់របស់កុមារ ឬក៏លក្ខណៈផ្សេងៗទៀត ដែលនាំឱ្យរកឃើញនូវអង្គហេតុនានាតាមរយៈការសាកសួរនោះជាដើម។ ប៉ុន្តែនៅពេលសាកសួរទៅលើសាក្សីជាកុមារ ចាំបាច់ត្រូវសិក្សាទៅលើលក្ខណៈពិសេសៗទាំងឡាយនេះហើយរួមទាំងជីវភាពក្នុងការរស់នៅផងដែរមានជាអាទ៍៖ ស្ថានភាពគ្រួសារ, ទីកន្លែងដែលកុមារធ្លាប់រស់នៅ ឬធ្លាប់ត្រូវបានគំរាម ឬគ្រួសារក្រ, មាន ឬក៏ក្នុងសង្គមគ្រួសារដែលពោរពេញដោយភាពជំលោះជាដើម។

កុមារភាគច្រើនមានចរិតទោរទន់ដ៏ធំសម្បើមទៅរកភាពស្រមើស្រមៃ ឬបំផ្លើសផង និងសំណូមពរក៏ធំផងដែរ។ ដោយហេតុនេះហើយនៅពេលធ្វើការផ្ទៀងផ្ទាត់ និងធ្វើការវាយតម្លៃទៅលើការបំភ្លឺរបស់សាក្សីដែលជាកុមារ ជាចាំបាច់បំផុតនោះត្រូវរកឱ្យឃើញ និងសិក្សាឱ្យបានត្រឹមត្រូវទៅ

លើធាតុផ្សំនៃការបំផ្លើសនោះចំពោះការបំភ្លឺទៅលើអង្គហេតុនានា និងសិក្សាទៅលើលទ្ធភាពនៃសំណូមពរពីភាគីម្ខាងដែលជាបុគ្គលមានប្រយោជន៍នៅក្នុងរឿងនោះដូចជា: ឪពុកម្ដាយ ឬអាណាព្យាបាលជាដើម។ ប្រសិនបើពុំបានសិក្សាទៅលើកត្តាទាំងនេះទេ នោះសេចក្ដីសម្រេចនឹងធ្លាក់ក្នុងភាពខុសឆ្គងយ៉ាងធ្ងន់ធ្ងរបំផុត ។

## កថាខណ្ឌទី២. សេចក្ដីសន្និដ្ឋានរបស់អ្នកជំនាញ និងការបំភ្លឺរបស់អ្នកជំនាញ

សេចក្ដីសន្និដ្ឋានរបស់អ្នកជំនាញ ច្បាប់នីតិវិធីបានចាត់ទុកជាប្រភេទមួយនៃភស្តុតាងនៅក្នុងសំណុំរឿងក្ដីរបស់តុលាការបានផងដែរ។

សេចក្ដីសន្និដ្ឋាន និងខ្លឹមសារនៃការបំភ្លឺនានារបស់អ្នកធ្វើកោសល្យវិច្ច័យ ឬអ្នកជំនាញគឺមានសារសំខាន់ណាស់ ពីព្រោះសេចក្ដីសន្និដ្ឋាន និងការបំភ្លឺបែបនេះគឺជាប្រភេទនៃភស្តុតាងផងដែរ។

ការបំភ្លឺរបស់អ្នកជំនាញគឺជាការផ្ដល់ព័ត៌មានទាំងឡាយដែលត្រូវបានធ្វើឡើងដោយអ្នកជំនាញ ហើយពត៌មានទាំងនេះមាននៅក្នុងខ្លឹមសារនៃការធ្វើសេចក្ដីសន្និដ្ឋានរបស់គាត់ បន្ទាប់ពីបានធ្វើការសាកសួរយកចម្លើយនានាទៅលើបុគ្គលផ្សេងៗរួចមក ជាពិសេសព័ត៌មានបែបនេះមានគោលដៅបើកឱ្យឃើញនូវការពិត ឬក៏ចង្អុលនូវចំណុចជាក់លាក់ណាមួយ។ ដើម្បីយល់ដឹងឲ្យបានគ្រប់គ្រាន់នូវអត្ថន័យចំពោះការបំភ្លឺរបស់អ្នកជំនាញ និងអត្ថន័យនៃសេចក្ដីសន្និដ្ឋានរបស់អ្នកជំនាញ ព្រះរាជអាជ្ញា និងចៅក្រមត្រូវតែយល់ដឹងទៅលើសញ្ញាណគ្រឹះសំខាន់ៗចំនួនបីគឺ:

- **ទី១**.កម្មវត្ថុនៃការបំភ្លឺ
- **ទី២**. ការផ្ទៀងផ្ទាត់ចំពោះសេចក្ដីសន្និដ្ឋាន
- **ទី៣**.ការវាយតម្លៃទៅលើសេចក្ដីសន្និដ្ឋាន ។

### ២.១. កម្មវត្ថុនៃការបំភ្លឺរបស់អ្នកធ្វើកោសល្យវិច្ច័យ(អ្នកជំនាញ)និងសេចក្ដីសន្និដ្ឋានរបស់គាត់

ការបំភ្លឺរបស់អ្នកធ្វើកោសលវិច្ច័យ (អ្នកជំនាញ) និងសេចក្ដីសន្និដ្ឋានរបស់ពួកគាត់មានកម្មវត្ថុជាក់លាក់បំផុតដែលកម្មវត្ថុជាក់លាក់នោះបានចងពួកអ្នកជំនាញតាមរយៈនៃការធ្វើសេចក្ដីសន្និដ្ឋានរបស់អ្នកជំនាញជាមួយនឹងចំណុចនៃការស្នើសុំរបស់ស្ថាប័នស៊ើបអង្កេត ឬតុលាការដែលជាមូលដ្ឋានគ្រឹះនៃព្រំដែនរបស់សេចក្ដីសន្និដ្ឋាននោះ។ ដើម្បីវាយតម្លៃបានទៅលើសេចក្ដីសន្និដ្ឋាន

របស់អ្នកជំនាញត្រូវមើលកត្តាពីរប្រភេទគឺ: **អត្ថន័យនៃសេចក្តីសន្និដ្ឋាន និងប្រភេទនៃការធ្វើកោ សល្យវិច្ឆ័យ**។

## ក.អត្ថន័យនៃសេចក្ដីសន្និដ្ឋាន

សេចក្តីសន្និដ្ឋានរបស់អ្នកធ្វើកោសល្យវិច្ឆ័យគឺជាខ្លឹមសារដែលបំភ្លឺឡើងតាមរយៈទិដ្ឋភាពសំណេរមួយដែលកើតចេញពីការសិក្សាស្រាវជ្រាវ និងធ្វើការសន្និដ្ឋានបូកសរុបអំពីការស្រាវជ្រាវនោះទៅតាមបញ្ហាណាមួយ ដែលបុគ្គលបានស្នើសុំក្នុងដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌ។

ជាគោលការណ៍រួម ច្បាប់នីតិវិធីបានកំណត់យកមូលដ្ឋានខ្លះៗក្នុងការចាត់ចែងនៃដំណើរការធ្វើកោសល្យវិច្ឆ័យ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរមិនបានកំណត់អំពីកម្មវត្ថុជាក់លាក់ដែលត្រូវធ្វើកោសល្យ វិច្ឆ័យនោះទេ ដោយគ្រាន់តែប្រើប្រាស់ន័យទូលាយតាមស្មារតីនៃមាត្រា៩៥ និងមាត្រា ១៦២ កថាខណ្ឌទី១ថា «នៅក្នុងករណីដែលមានបញ្ហាបច្ចេកទេសចោទឡើង...»។ ទោះបីជាច្បាប់នេះមិនបានកំណត់ប្រភេទកម្មវត្ថុជាក់លាក់យ៉ាងនេះក្តី ក៏ទម្លាប់នៃការអនុវត្តនៅក្នុងការប្រតិបត្តិជាក់ស្តែងទៅលើកម្មវត្ថុនៃការធ្វើកោសល្យវិច្ឆ័យមិនត្រូវបានរារាំងនោះដែរ ដោយសារថាច្បាប់នីតិវិធីបានផ្តល់សិទ្ធិធំធេងដល់អ្នកអនុវត្តច្បាប់ជាអ្នកសម្រេចអំពីកិច្ចនៃចំណាត់ការនេះ។ ដើម្បីមានមូលដ្ឋានក្នុងការចាត់ចែងអំពីការធ្វើកោសល្យវិច្ឆ័យ អ្នកស៊ើបអង្កេត ព្រះរាជអាជ្ញា ឬចៅក្រមដែលកំពុងចាត់ការសំណុំរឿងនោះត្រូវតែយល់ដឹងទៅលើសញ្ញាណនានានៃកម្មវត្ថុ ក្នុងការធ្វើកោសល្យវិច្ឆ័យចំពោះបញ្ហាជាក់លាក់ណាមួយ។ ប្រភេទនៃកម្មវត្ថុដែលជាមូលដ្ឋានសំខាន់ៗ ហើយពាក់ពន្ធ័ក្នុងការធ្វើកោសល្យវិច្ឆ័យនោះមានជាច្រើនប្រភេទដូចជា៖

- **ទី១.** អំពីមូលហេតុនៃមរណភាព ចំណុចនេះមានន័យថា រាល់មរណៈភាពដែលកើតឡើងចំពោះមនុស្សទោះជាក្នុងករណីណាក៏ដោយ ត្រូវតែមានលិខិតបញ្ជាក់ដោយស្ថាបន័ជំនាញមិនអាចខ្វះបានឡើយអំពី «មូលហេតុនៃមរណៈភាព»នោះ។ គ្រប់របកគំហើញនៃសាកសពត្រូវតែធ្វើកោសល្យវិច្ឆ័យដោយមិនអាចខ្វះបានឡើយ។

- **ទី២.** អំពីការប៉ះពាល់សុខភាព នេះជាការពិនិត្យអំពីលក្ខណៈនៃសភាវៈនានា និងធ្វើការប៉ាន់ប្រមាណអំពីកំរិតនៃព្យសនកម្មដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពមនុស្ស និងសត្វ ឬរុក្ខជាតិ។ មានន័យថា ក្នុងករណីដែលមានការប៉ះពាល់ដល់សុខភាពរបស់មនុស្សទោះជាតាមផ្លូវកាយក្តី ផ្លូវចិត្តក្តី ត្រូវតែមានការវាស់វែងនូវកំរិតនៃព្យសនកម្ម» នោះដូចជា: ពិការមួយជីវិត បាត់បង់កម្លាំងពលកម្ម ឬស្មារតីជាដើម។ ចំពោះជីវិត សត្វ រុក្ខជាតិ ឬសម្ភារៈផ្សេងៗវិញក៏តម្រូវឲ្យដឹងអំពីផលប៉ះពាល់ដែលកើតចេញពី អំពើល្មើសណាមួយនោះដែរ ដោយទាមទារនូវការប៉ាន់ប្រមាណជាក់លាក់ណាមួយដើម្បីផ្តល់ភាពងាយស្រួលដល់ការសម្រេចអំពីការទូទាត់នានា និងកំរិតទណ្ឌកម្មពីតុលាការ។

- **ទី៣.** អំពីរោគសញ្ញានៃជនល្មើស: នេះជាការបង្ហាញអំពីលក្ខណៈសម្បត្តិផ្នែកផ្លូវចិត្ត និងផ្លូវកាយរបស់បុគ្គលនានាដែលជាប់ពាក់ពន្ធ័នឹងអំពើល្មើសមានជាអាទិ៍៖ ជនសង្ស័យ, ជនជាប់ចោទ នៅក្នុងពេលដែលយើងមានការសង្ស័យចំពោះសមត្ថភាព និងការទទួលខុសត្រូវរបស់ពួកគេអំពីសិទ្ធិការពារខ្លួនដោយខ្លួនឯងដើម្បីជាផលប្រយោជន៍ច្បាប់ក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ។ មានន័យថា បើមានការសង្ស័យ អំពីគុណវិបត្តិចំពោះការការពារខ្លួនក្នុងនីតិវិធីព្រហ្មទណ្ឌ នោះចាំបាច់ត្រូវតែធ្វើកោសល្យវិច្ច័យទៅលើស្មារតី ឬក៏ផ្លូវកាយជាដើមមានដូចជា: ការនិយាយរបស់គាត់ ជូនខឹង ជូនសើច ជូនយំ ចំណែកផ្លូវកាយវិញដូចជា ត្រចៀក ភ្នែក ឬច្រមុះជាដើម ដែលមិនមានគុណភាពដូចមនុស្សធម្មតា។
- **ទី៤.** អំពីរោគសញ្ញានៃជនរងគ្រោះ នេះជាការបង្ហាញអំពីលក្ខណៈសម្បត្តិផ្នែកផ្លូវចិត្ត និងផ្លូវកាយរបស់ជនរងគ្រោះនៅពេលដែលមានការសង្ស័យ ចំពោះសមត្ថភាពនៃការទទួលអារម្មណ៍ដឹងទៅលើខណៈនានាដែលខណៈទាំងនោះមានអត្ថន័យសម្រាប់រឿងក្ដីព្រហ្មទណ្ឌ ហើយផ្ដល់នូវការបំភ្លឺដ៏ត្រឹមត្រូវបំផុត(មិនសំដៅប្រក្រតីទេ)។ មានន័យថា បើពិនិត្យមើលទៅការនិយាយរបស់គាត់ហាក់ដូចជាចាំមាត់ ឬរត់មាត់នោះក៏ត្រូវធ្វើកោសល្យវិច័យទៅលើពួកគាត់ផងដែរដើម្បីឲ្យតុលាការមានលទ្ធភាពគ្រប់គ្រាន់ចំពោះការវាយតម្លៃទៅលើកំរិតនៃព្យសនកម្មដែលរងពីអំពើល្មើស (អាចមានជនរងគ្រោះបំភ្លឺកុហក ឬក៏អាចមានស្មារតីមិនគ្រប់គ្រាន់ផងដែរ)។
- **ទី៥.** អំពីការពិនិត្យវ័យ: នេះជាការពិនិត្យទៅលើអាយុរបស់ជនសង្ស័យ, ជនជាប់ចោទ, ជនរងគ្រោះ កាលណាអាយុនេះវាមានអត្ថន័យសម្រាប់រឿងក្ដីព្រហ្មទណ្ឌ (អាចជនល្មើសមាឌធំតែមានអាយុតិច ឬក៏មាឌតូចតែអាយុច្រើនជាដើម ករណីជនល្មើសជាអនីតិជន) តាមឯកសារទាំងឡាយដែលអះអាងអំពីអាយុនៃជនទាំងនេះកំពុងកើតមានភាពស្រពិចស្រពិល ឬក៏គ្មានឯកសារតែម្តង (ករណីជនរងគ្រោះក្នុងបទរួមភេទអនីតិជនមានអាយុក្រោម១៥ឆ្នាំ)។ ការសង្ស័យអំពីអាយុនេះជូនកាលមាឌធំ អាយុតិច ឬមាឌតូចអាយុច្រើនដែលជាហេតុធ្វើឲ្យការសម្រេចក្ដីមានភាពមិនច្បាស់លាស់។ ការខ្វះឯកសារអត្តសញ្ញាណបែបនេះជាមូលហេតុនៃការសង្ស័យ ហើយដើម្បីជម្នះនូវឧបសគ្គនេះតម្រូវឲ្យមានធ្វើកោសល្យវិច្ច័យ។

## ខ. ប្រភេទនៃការធ្វើកោសល្យវិច្ច័យ

ការធ្វើកោសល្យវិច្ច័យត្រូវបានរៀបចំឡើងទៅតាមប្រភេទផ្សេងៗពីគ្នា ដោយអាស្រ័យទៅនឹងទំហំនៃកម្មវត្ថុដែលតម្រូវឱ្យធ្វើកោសល្យវិច្ច័យ។

ជាទូទៅ គេអាចសង្កេតឃើញការធ្វើកោសល្យវិច្ច័យបែបតុលាការប្រព្រឹត្តទៅតាមមធ្យោបាយជាច្រើនប្រភេទ ដោយអាស្រ័យទៅនឹងទំហំនៃកម្មវត្ថុក្នុងការធ្វើកោសល្យវិច្ច័យចំពោះបញ្ហាណាមួយនោះ។ មធ្យោបាយទាំងនោះមាន៖

- **ទី១. ឯកាធិភាពនៃឯកទេសកម្មៈ** នេះជាការបង្កើតគណៈកម្មការកោសល្យវិច្ច័យបែបតុលាការដោយនៅក្នុងនោះការធ្វើកោសល្យវិច្ច័យត្រូវតែដឹកនាំធ្វើដោយអ្នកជំនាញ (Expert) ចាប់ពីពីរនាក់ឡើងទៅ តែកម្មវត្ថុនៃការធ្វើកោសល្យវិច្ច័យត្រូវស្ថិតក្នុងរង្វង់នៃឯកទេសកម្មតែមួយប៉ុណ្ណោះ <u>ជាឧទាហរណ៍:</u> ធ្វើកោសល្យវិច្ច័យទៅលើ «រោគចិត្ត» ត្រូវតែមាន «អ្នកឯកទេសកម្មខាងផ្លូវចិត្តតែមិនអាចយកជំនាញគីមី ជំនាញនយោបាយ ឬជំនាញច្បាប់ទៅចូលជាគណៈកម្មការនេះបានទេ ពោលគឺអ្នកជំនាញត្រូវមានឯកទេសកម្មដូចគ្នា។
- **ទី២. ពហុភាពនៃឯកទេសកម្មៈ** នេះជាពហុកោសល្យវិច្ច័យដោយសកម្មភាពនៃការធ្វើកោសល្យវិច្ច័យបែបនេះតម្រូវឲ្យមានការចូលរួមពីអ្នកជំនាញ (Expert) ជាច្រើននាក់ ហើយអ្នកជំនាញទាំងនេះមានឯកទេសសកម្មផ្សេងៗពីគ្នា(Specialist)។ <u>ជាឧទាហរណ៍:</u> ធ្វើកោសល្យវិច្ច័យទៅលើកម្លាំងផ្ទុះគ្រាប់ថ្មៃដោយពួកភេរវករ។ អ្នកចូល រួមត្រូវមានជំនាញឯកទេសកម្មដូចជា៖ ខាងអាវុធជាតិផ្ទុះ ខាងគីមី(វិសេវ) ខាងយុទ្ធសាស្ត្រប្រយុទ្ធ ខាងដានវិទ្យា.....។ល។ ទើបអាចដោះស្រាយចំពោះបញ្ហាមួយនោះបាន តែមិនត្រូវយកបុគ្គលណាដែលគ្មានជំនាញឯកទេសមកចូលរួមបានឡើយ ឬក៏មានឯកទេសកម្មដែរ តែមិនពាក់ពន្ធ័ទៅនឹងកម្មវត្ថុនៃការធ្វើកោសល្យវិច្ច័យ។
- **ទី៣. កោសល្យវិច្ច័យបំពេញបន្ថែមៈ** គឺជាការធ្វើកោសល្យវិច្ច័យដែលចាត់តាំងឡើងវិញនៅពេលដែលលទ្ធផលនៃការធ្វើកោសល្យវិច្ច័យពីមុនមិនមានភាពច្បាស់លាស់ គ្រប់គ្រាន់រួមទាំងនៅពេលដែលមានលេចឡើងនូវបញ្ហាថ្មីៗ ដែលទាក់ទិនទៅនឹងការស៊ើបអង្កេតទៅលើខណៈនានានៃរឿងក្តីព្រហ្មទណ្ឌណាមួយ។ <u>ជាឧទាហរណ៍:</u> បន្ទាប់ពីធ្វើកោសល្យវិច្ច័យទៅលើក្រយៅដៃរួចមកលទ្ធផលបង្ហាញថា ក្រយៅមេដៃទាំងពីរនោះមានរង្វង់ជាគូទខ្យងដូចគ្នាទៅនឹងគំរូពិតរបស់មេដៃលោក «ក» ប៉ុន្តែតាមការពិនិត្យជាក់ស្តែងទៅលើមេដៃទាំងពីររបស់លោក «ក» បានបង្ហាញច្បាស់ថា មានស្នាមកាត់ប្រជ្រុយនៅលើក្រយៅមេដៃស្តាំរបស់គាត់។ ស្លាកស្នាមនេះត្រូវតែធ្វើកោសល្យវិច្ច័យបំពេញបន្ថែមដើម្បីបង្ហាញអំពីចំណុចស៊ីមេទ្រី ឬខ្សែរង្វង់ជាគូទខ្យងទាំងនោះមានចំណុចរត់ជាជួរឬទេចំពោះក្រយៅមេដៃស្តាំរបស់លោក«ក»។ ការធ្វើកោសល្យវិច្ច័យបំពេញបន្ថែមបែបនេះ គឺធ្វើឡើងដើម្បីបង្គ្រប់នូវអ្វីៗដែលបានធ្វើរួចហើយ ប៉ុន្តែពុំមានន័យថាធ្វើកោសល្យវិច្ច័យឡើងវិញទាំងមូលនោះឡើយ ពោលគឺមិនមានការសង្ស័យចំពោះការខុសឆ្គងនៃលទ្ធផលកោសល្យវិច្ច័យនោះទេ។

- **ទី៤. ប្រតិកោសល្យវិច្ច័យ:** គឺជាការធ្វើកោសល្យវិច្ច័យបែបតុលាការដែរដោយក្នុងនោះមានការចាត់តាំងឲ្យធ្វើឡើងវិញនៅពេលដែលមានការលេចឡើងនូវការសង្ស័យចំពោះសុពលភាពនៃលទ្ធផលរបស់អ្នកជំនាញ ឬក៏មានការប្រឈមគ្នានៅក្នុងការយល់ឃើញផ្សេងៗពីគ្នារបស់អ្នកជំនាញអំពីកោសល្យវិច្ច័យដែលបានធ្វើកន្លងមកនោះ។ <u>ជាឧទាហរណ៍:</u> សាកសពមួយត្រូវបានអ្នកជំនាញធ្វើកោសល្យវិច្ច័យសន្និដ្ឋានថា សាកសពនោះស្លាប់ដោយសារធ្វើអត្តឃាដតាមមធ្យោបាយផឹកថ្នាំសម្លាប់សត្វល្អិត។ ប៉ុន្តែនៅក្នុងបន្ទប់ដែលជាទីតាំងកើតហេតុវិញត្រូវបានអ្នកស៊ើបអង្កេតរកឃើញភេសជ្ជៈដែលមានលាយសារធាតុគីមីខុសពីថ្នាំសម្លាប់សត្វល្អិត ដែលអ្នកជំនាញបានធ្វើសេចក្តីសន្និដ្ឋានរួចហើយនោះ។ ថ្នាំសម្លាប់សត្វល្អិត និងសារធាតុគីមីនេះត្រូវតែធ្វើកោសល្យវិច្ច័យឡើងវិញដែលពាក់ព័ន្ធនឹងមរណៈភាពនៃសព។

## ២.២. ការផ្ទៀងផ្ទាត់ទៅលើសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ

ជាការពិតហើយ បន្ទាប់ពីធ្វើកោសល្យវិច្ច័យទៅលើកិច្ចការចាំបាច់នានាក្នុងដំណាក់កាលស៊ើបអង្កេតរួចមក គេសង្កេតឃើញនូវលទ្ធផលរបស់អ្នកជំនាញតាមរយៈសេចក្តីសន្និដ្ឋានរបស់ពួកគេ។ សេចក្តីសន្និដ្ឋានបែបនេះក៏ស្ថិតក្នុងប្រភេទភស្តុតាងមួយ ដែលមានតាំងពីដំណាក់កាលស៊ើបអង្កេត(អាចដំណាក់កាលស៊ើបសួរ) មកម្ល៉េះ តែក៏មានក្នុងដំណាក់កាលជំនុំជម្រះផងដែរ (ករណីធ្វើកោសល្យវិច្ច័យបំពេញបន្ថែម ឬប្រតិកោសល្យវិច្ច័យ)។

## ២.៣. ការវាយតម្លៃទៅលើសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ

រាល់សេចក្តីសន្និដ្ឋានរបស់អ្នកជំនាញគ្មានអាទិភាពណាមួយ អាចមានតម្លៃជាងប្រភេទនៃភស្តុតាងដទៃៗទៀតបានឡើយ ហើយសេចក្តីសន្និដ្ឋាននេះក៏ស្ថិតនៅក្នុងវិធាននៃការផ្ទៀងផ្ទាត់ និងការវាយតម្លៃជាចាំបាច់ដូចគ្នានឹងវិធានផ្សេងៗទៀតនៃភស្តុតាងផងដែរ។ សេចក្តីសន្និដ្ឋាននេះ បើអ្នកជំនាញធ្វើសេចក្តីសន្និដ្ឋានដោយគ្មានមូលដ្ឋានវិទ្យាសាស្ត្រ និងគ្មានចំណុចចំៗណាមួយនោះទេនោះនាំឱ្យសេចក្តីសន្និដ្ឋានក្លាយជាកម្មវត្ថុឥតចាំបាច់ ហើយមិនអាចជាមូលដ្ឋាននៃហេតុផលយកមកប្រើប្រាស់នៅតុលាការបានឡើយ។ ដោយហេតុនេះហើយបានជាស្ថាប័នស៊ើបអង្កេត ឬតុលាការមានសិទ្ធិតាមដានរាល់ដំណើរការធ្វើកោសល្យវិច្ច័យតាមរយៈរបាយការណ៍របស់ពួកអ្នកជំនាញ។

## កថាខណ្ឌទី៣. ភស្តុតាងជាវត្ថុ

កាលណាគេនិយាយពីភស្តុតាងជាវត្ថុ គឺសំដៅទៅលើរករបស់ដែលមានរូបដោយខណៈទាំង ឡាយនៃវត្ថុទាំងនោះមានខ្លឹមសារភ្ជាប់ទៅនឹងអំពីរបស់បុគ្គលណាមួយដែលពាក់ព័ន្ធទៅនឹងសំណុំរឿងក្តីនៅតុលារការ។

ដើម្បីយល់ដឹងទៅលើអត្ថន័យនៃវត្ថុតាង សូមមើលអត្ថន័យមួយចំនួនដូចខាងក្រោម៖

•**ទី១.** ភស្តុតាងជាវត្ថុ គឺជាវត្ថុទាំងឡាយណាដែលកើតឡើងមានលក្ខណៈសមស្របទៅតាមការកំណត់ដោយច្បាប់នីតិវិធី ហើយដែលវត្ថុទាំងនោះស្ថិតក្នុងលក្ខខណ្ឌទាំងឡាយ ដែលបំរើបានជាភស្តុតាងទៅតាមរឿងក្តីនានា។ មានន័យថា វត្ថុនោះជាប្រភពនៃការផ្តល់ព័ត៌មានអំពីអង្គហេតុសក្ខីកម្ម ឬអង្គហេតុគ្រឹះ ហើយជាងនេះទៅទៀតវត្ថុខ្លួនឯងនេះអាចកំណត់បាននូវអត្ថិភាពសំរាប់រឿងអង្គសេចក្តីផងដែរ ពោលគឺវត្ថុនេះជាប្រភពផ្តល់ព័ត៌មានអំពីអង្គហេតុផង និងវាខ្លួនឯងបម្រើដល់អត្ថិភាពនៃអង្គសេចក្តីផង(អាចបម្រើដល់អត្ថិភាព ឬនត្ថិភាពនៃបទល្មើស)។

•**ទី២.** ភស្តុតាងជាវត្ថុ គឺជាកម្មវត្ថុទាំងឡាយណាដែលបំរើដល់ចំណែកៗនៃភស្តុតាង គឺមានន័យថា វាជាកម្មវត្ថុទាំងឡាយដែលបានបំរើដល់ភស្តុតាងនានា ដោយភស្តុតាងជាវត្ថុនោះវាកំណត់បាននូវអង្គហេតុនៃបទល្មើស និងកំណត់បាននូវការប្រព្រឹត្តរបស់បុគ្គល ហើយត្រឡប់មកវិញភស្តុតាងនោះក៏ដោះសារ(បដិសេធន៍)បាននូវអង្គហេតុនៃការប្រព្រឹត្តរបស់ជនជាប់ចោទផងដែរ។ អត្ថន័យក្នុងចំណុចទី២នេះ គឺចង់សំដៅទៅគ្រប់វត្ថុទាំងឡាយណា ដែលវត្ថុទាំងនោះមានកម្មវត្ថុរបស់វាបម្រើដល់ការដាក់បន្ទុកផង និងដោះបន្ទុកផង។

•**ទី៣.**ភស្តុតាងជាវត្ថុគេអាចហៅម្យ៉ាងទៀតថា «ជាសាក្សីគ» ពីព្រោះសាក្សីធម្មតាជាមនុស្សដែលចេះនិយាយ និងចេះរៀបរាប់បានតាមគ្រប់សកម្មភាពដែលគេទទួលដឹងតាមវិញ្ញាណនានា។ ជាទូទៅភស្តុតាងជាវត្ថុនេះវាជាទឡ្ហីកម្មមួយ ដែលបញ្ជាក់នូវអង្គហេតុពិតហើយអាចមានអត្ថន័យដ៏សំខាន់បំផុតសំរាប់រឿងក្តីទាំងឡាយនៅក្នុងតុលាការ។

ដើម្បីយល់ដឹងឲ្យបានស៊ីជម្រៅទៅលើខ្លឹមសារនៃភស្តុតាងជាវត្ថុ អ្នកច្បាប់គួរតែពិនិត្យទៅលើកត្តាចម្បងបីដែលជាគន្លឹះរួមក្នុងការវាយតម្លៃ និងធ្វើការផ្ទៀងផ្ទាត់។ កត្តាចម្បងដែលជាវិធានរួមនៃភស្តុតាងជាវត្ថុនោះមានជាអាទិ៍៖ **កម្មវត្ថុនៃការចាត់ថ្នាក់ទៅលើវត្ថុជាភស្តុតាង, អត្ថិភាពពិសេសនៃភស្តុតាងជាវត្ថុ, ប្រភេទនៃទ្រព្យនានាដែលជាកម្មវត្ថុនៃភស្តុតាងជាវត្ថុ និងវិធានការក្នុងការការពារវត្ថុតាង។**

## ៣.១. អត្ថិភាពពិសេសនៃភស្តុតាងជាវត្ថុ

តាមពិតទៅភស្តុតាងជាវត្ថុជាប្រភេទនៃភស្តុតាងមួយរួចទៅហើយ នៅក្នុងទ្រឹស្តីភស្តុតាងរបស់តុលាការ ប៉ុន្តែប្រភេទនៃភស្តុតាងបែបនេះត្រូវបានគេសង្កេតឃើញនូវលក្ខណៈពិសេសរបស់វា។ លក្ខណៈពិសេសនៃភស្តុតាងជាវត្ថុគឺជាលក្ខណៈភាពនៃវត្ថុដែលមិនអាចជំនួសបានដោយវត្ថុដទៃ។ គឺមានន័យថា មិនអាចយកវត្ថុណាមួយទៅជំនួសវត្ថុដែលជាវត្ថុតាងនេះបានទេ គឺដូចគ្នាទៅនឹងការបំភ្លឺរបស់សាក្សីដែរត្រង់ថាគ្មានអ្នកណាម្នាក់អាចឆ្លើយជំនួសសាក្សីបានឡើយ។ បើភស្តុ

តាងជាវត្ថុនោះត្រូវបានបំផ្លាញ នោះមិនត្រូវបង្កើតវត្ថុថ្មីសម្រាប់ធ្វើជាភស្តុតាងយកមកជំនួសវាបានឡើយ បើទោះបីជាវត្ថុដែលត្រូវជំនួសនោះមានលក្ខណៈរូប និងមានសារធាតុផ្សំដូចគ្នាក៏ដោយ។ មូលហេតុដែលមិនអាចជំនួសបាននេះពីព្រោះខណៈ និងខ្លឹមសាររបស់វត្ថុតាងមានបង្កប់នូវទស្សនៈវិជ្ជាបង្ហាញមកពិភពខាងក្រៅឲ្យបានដឹងនូវធាតុចេតនា ឬអចេតនា(ធ្វេសប្រហែស)នៃអំពើរបស់ជនល្មើសដែលធ្វើសកម្មភាពក្នុងពេលកើតមានព្រឹត្តិការណ៍ណាមួយ ហើយបានស្តែងចេញតាមរយៈនៃអង្គហេតុនានា។ តាមទស្សនៈនេះ លោក«**ជៀនហ្គ្រីហ្វីតឆានី**» (Jhon Griffith Chaney)កើតឆ្នាំ១៨៧៦ និងស្លាប់ឆ្នាំ១៩១៦បានសរសេរថា «អង្គហេតុមួយដើម្បីឲ្យវាក្លាយជាភាពជាក់លាក់ច្បាស់លាស់បានលុះត្រាតែអង្គហេតុនោះត្រូវបានចំលងធាតុចេតនាបង្ហាញមកពិភពខាងក្រៅបាន»។ គំនិតនេះបានបង្ហាញថា បើទោះបីជាអង្គហេតុមួយនោះត្រូវបានបាត់បង់ទៅហើយក្តី ក៏ខណៈទាំងឡាយរបស់អង្គហេតុនោះមិនអាចបាត់បង់ទៅជាមួយនោះឡើយ ពីព្រោះថាអ្វីៗដែលបានកកើតរួចហើយ ហើយអ្វីៗទាំងអស់នោះក៏អាចរលត់បាត់បង់ទៅវិញជាធម្មតាបានដែរគឺជាច្បាប់ធម្មជាតិ។ ប៉ុន្តែចំណុចដែលចាប់អារម្មណ៍ និងចម្លែកបំផុតដែលយើងត្រូវពិចារណានោះ គឺយករបស់ថ្មីទៅជំនួសរបស់ដែលបានបាត់បង់កាលពីអតីតកាលនោះទោះជាមានសណ្ឋាន ឬសារធាតុដូចគ្នាក៏ដោយ ក៏ពេលវេលា ឬខណៈនានា និងការប្រតិស្ថាននៃរបស់ក្រោយនេះមិនដូចគ្នាទៅនឹងរបស់ដែលបានកើតពីពេលអតីតកាលនោះឡើយ។ មានន័យថាអ្វីៗដែលបានកើតពីអតីតកាលមានហេតុ និងបច្ច័យមិនដូចគ្នាទៅនឹងហេតុ និងបច្ច័យនៃសភាវៈដែលកកើតថ្មីនេះទេ។ ដោយសារតែមានលក្ខណៈពិសេសនេះហើយ ទើបភស្តុតាងជាវត្ថុស្តែងឲ្យយើងបានដឹងនូវចរិតរបស់ជនល្មើសបានតាម រយៈនៃខណៈនានារបស់វត្ថុនោះជាប់ជានិច្ចមិនអាចកាត់ផ្តាច់បានឡើយ។

សរុបមកវិញរាល់វត្ថុនីមួយៗដែលអាចប្រើប្រាស់នៅក្នុងឋានៈជាភស្តុតាងវត្ថុបាន លុះត្រាតែវត្ថុនោះទទួលបាននូវសិទ្ធិជាចាំបាច់បំផុតមួយ ដែលកំណត់ដោយច្បាប់តាមរយៈនៃនីតិវិធីចុះបញ្ជីការត្រឹមត្រូវតាមស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា៩២, មាត្រា១០៧, មាត្រា១១៣, មាត្រា១៦០)។ ការចុះបញ្ជីភស្តុតាងនេះ ដើម្បីចងកាតព្វកិច្ចរបស់អ្នកអនុវត្តច្បាប់ទៅនឹងនីតិវិធីក្នុងដំណាក់កាលនៃចំណាត់ការរឿងក្តីដូចជាក្នុងដំណាក់កាលនៃការស៊ើបអង្កេត ឬក្នុងដំណាក់កាលរបស់ចៅក្រមជំនុំជម្រះជាដើម(មានបញ្ជីរាយឈ្មោះលិខិតមើលស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា២៤៤ និងមាត្រា២៤៧ថ្មី និងស្មារតីក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា១០៧, ១០៨, ១០៩, ១១០, ១១១, ១១២)។ ដោយយោងទៅលើលក្ខណៈពិសេសនៃភស្តុតាងជាវត្ថុ និងយោងតាមខ្លឹមសារនៃការចុះបញ្ជីទៅលើវត្ថុតាងនៅក្នុងទ្រឹស្តីភស្តុតាងនេះ គេពិនិត្យឃើញមានប្រយោជន៍ជាបីប្រភេទសំខាន់ៗជាតម្លៃនៃភស្តុ

តាងវត្ថុមានជាអាទិ៍៖ **កំណត់បាននូវប្រវត្តិផ្ទាល់នៃវត្ថុតាង, កំនត់បាននូវអត្តសញ្ញាណកម្មទៅលើវត្ថុតាង, វត្ថុតាងនោះត្រូវតែបានដឹងជាសាធារណៈ និងវិសាលភាពនៃភស្តុតាងវត្ថុ។**

## ៣.២. ប្រភេទនៃទ្រព្យនានាដែលជាកម្មវត្ថុនៃភស្តុតាងជាវត្ថុ

ជាគោលការណ៍ភស្តុតាងជាវត្ថុនៅក្នុងសំណុំរឿងក្តីព្រហ្មទណ្ឌអាចជារបស់ ឬទ្រព្យដែលមានតម្លៃ ហើយភស្តុតាងបែបនេះច្បាប់នីតិវិធីត្រូវញែកឲ្យបានដាក់លាក់ក្នុងគោលបំណង ជៀសវាងនូវការទន្ទ្រានកាន់កាប់ ឬយកទៅប្រើប្រាស់ធ្វើឲ្យបាត់បង់ដល់តម្លៃនៃភស្តុតាងនៅក្នុងដំណាក់កាលនៃនីតិវិធីរបស់តុលាការ។ វត្ថុតាងទាំងនេះជាទ្រព្យមានតម្លៃដែលអាចរក្សាទុកបានយូរ ប៉ុន្តែអាចជាទ្រព្យមានតម្លៃតាមកាលៈទេសៈដែលមិនអាចរក្សាទុកបាននៅក្នុងស្ថានភាពធម្មតា (អាចត្រូវប្រើប្រាស់ការចំណាយទៅលើការថែទាំ ឬឥទ្ធិពលពីបរិយាកាស)។ ដោយសារតែទ្រព្យមានជាច្រើនប្រភេទ ទើបក្នុងទ្រឹស្តីនៃភស្តុតាងបានកំណត់នូវកម្មវត្ថុ ដែលប្រភេទនៃទ្រព្យមួយចំនួនអាចចាត់ទុកថាជាភស្តុតាងវត្ថុទៅតាមលក្ខណ្ឌរួមមួយចំនួនដែលប្រទេសមួយចំនួនបានបញ្ញត្តិទុក។ វត្ថុតាងមួយចំនួនដែលជាទ្រព្យហើយអាចកំណត់ថាជាវត្ថុតាងបានដ៏រាបណា ទ្រព្យទាំងនោះមានទ្រង់ទ្រាយជាពីរប្រភេទគឺៈ **ប្រភេទទ្រព្យដែលមិនអាចប្រគល់វិញ** និង**ប្រភេទទ្រព្យដែលអាចប្រគល់វិញ**។

### ក. ប្រភេទទ្រព្យដែលមិនអាចប្រគល់វិញ

នេះគឺជាប្រភេទនៃទ្រព្យនានាដែលជាវត្ថុស្ថិតក្នុងលក្ខខណ្ឌនៃកម្មវត្ថុ៣ប្រភេទគឺៈ

•**ទី១.**កម្មវត្ថុនៃការរឹបអូសៈនេះគឺជាប្រភេទនានានៃទ្រព្យដែលជាឧបករណ៍នៃបទល្មើស ប៉ុន្តែទ្រព្យនេះស្ថិតក្នុងលក្ខខណ្ឌនៃការរឹបអូស (ស្មារតីក្រមព្រហ្មទណ្ឌ មាត្រា១៧៨,១៧៩,៦៥៣)។

•**ទី២.**កម្មវត្ថុនៃការហាមប្រាមៈនេះគឺជាប្រភេទនៃទ្រព្យនានាដែលជាកម្មវត្ថុនៃការហាមឃាត់ផ្សេងៗតាមរូបភាពដូចជាៈធ្វើបំលាស់ទី,មិនអនុញ្ញាតឱ្យម្ចាស់ដើមវិញ, បំផ្លាញចោលជាដើម (មើលស្មារតីក្រមព្រហ្មទណ្ឌតាមមាត្រា១៧៥, ៤៨៨, ៤៨៩, ៤៩០, ៥០៨...)។

•**ទី៣.**កម្មវត្ថុនៃការអស់តម្លៃនេះជាប្រភេទនៃទ្រព្យទាំងឡាយដែលគ្មានតម្លៃក្នុងការ ប្រើប្រាស់ ហើយស្ថិតក្នុងការរង់ចាំនៃការបំផ្លាញចោល ឬផ្ទេរឱ្យមករដ្ឋជាដើម (ស្មារតីក្រមព្រហ្មទណ្ឌ មាត្រា១៧៨,៤៩៣...)។ តាមស្មារតីក្រមព្រហ្មទណ្ឌមាត្រា១៧៨ចែងថា «ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញ ចោលវត្ថុរឹបអូសកាលបើការរឹបអូសក្លាយជាស្ថាពរ វត្ថុរឹបអូសក្លាយជាកម្មសិទ្ធិរបស់រដ្ឋលើកលែងតែបទ បញ្ញត្តិដោយឡែកបានចែងអំពីការប្រគល់ផ្សេងទៀត»។

**រដ្ឋអាចលក់ ឬបំផ្លាញចោលវត្ថុរឹបអូសនៅក្នុងទម្រង់ដែលមានចែងសម្រាប់ការលក់ទ្រព្យសម្បត្តិរបស់រដ្ឋ។ ច្បាប់អាចចែងអំពីការបំផ្លាញចោលនូវវត្ថុខ្លះផងដែរ ។**

កាលបើវត្ថុរឹបអូសមិនត្រូវបានចាប់យកទេ ហើយនិងមិនអាចប្រគល់ឲ្យបានទេ នោះទណ្ឌិតត្រូវចេញសងនៃតម្លៃវត្ថុរឹបអូសនេះ។ តម្លៃនេះត្រូវកំណត់ដោយតុលាការ។ វិធានការដើម្បីប្រមូលប្រាក់នេះ ត្រូវធ្វើឡើងដូចក្នុងរឿងបង្ខំដល់រូបកាយដែរ។ ចំពោះមាត្រា១៧៩ ចែងថា «ការរឹបអូស និងសិទ្ធិតតិយ ជនៈ

ការរឹបអូសត្រូវធ្វើទៅលើវត្ថុដូចខាងក្រោមនេះ៖

១.ឧបករណ៍ ឬសម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តិបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តិបទល្មើស។

២. វត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

៣. ផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

៤. ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុនៅទីកន្លែងដែលបទល្មើសបានកើតឡើង។

ក៏ប៉ុន្តែការរឹបអូសមិនអាចត្រូវប្រកាសបានទេ ប្រសិនបើការរឹបអូសនោះប៉ះពាល់ដល់ សិទ្ធិរបស់តតិយជន»។

## ខ. ប្រភេទនៃទ្រព្យដែលអាចប្រគល់វិញបាន

នេះគឺជាជាប្រភេទនៃទ្រព្យទាំងឡាយណាដែលគ្មានតម្លៃជាភស្តុតាងផង និងមានតម្លៃជាភស្តុតាងផង ប៉ុន្តែលក្ខខណ្ឌដោយឡែកខ្លះនៃប្រភេទទ្រព្យនេះអាចផ្តល់សិទ្ធិឲ្យសមត្ថកិច្ច ឬតុលាការប្រគល់ឲ្យម្ចាស់ដើមវិញបាន ទោះជារឿងក្តីនោះមិនទាន់ចប់ជាស្ថាពរក៏ដោយ។ ជាគោលការណ៍ទ្រព្យទាំងនេះត្រូវស្ថិតក្នុងលក្ខខណ្ឌនៃកម្មសិទ្ធិជាក់លាក់ មុនពេលការចាប់យកដោយសមត្ថកិច្ច។ ទ្រព្យទាំងនេះអាចជាវត្ថុដែលចាប់យក (គ្មានជាប់ពាក់ពន្ធ័នឹងបទល្មើស ឬជាវត្ថុដែលជាប់ពាក់ពន្ធ័នឹងបទល្មើសមានដូចជាសត្វគោក្របីក្នុងអំពើចោរកម្មជាដើម) ដោយស្ថាប័នមានសមត្ថកិច្ចក្នុងពេលបំពេញការងារទៅតាមសំណុំរឿងក្តី ហើយអាចប្រគល់ទៅម្ចាស់ដើមវិញបានតាំងពីដំណាក់កាលស៊ើបអង្កេតរហូតដល់ដំណាក់កាលជំនុំជម្រះ។ លក្ខខណ្ឌបែបនេះត្រូវបានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា១១៩, ១៦១, ២៤៨, ៣៥៤ជាដើម។ មាត្រា១១៩ចែងថា «ព្រះរាជអាជ្ញាមានសមត្ថកិច្ចបង្គាប់ឲ្យប្រគល់វត្ថុដែលចាប់បាននៅក្នុងពេលសើបអង្កេតទៅម្ចាស់ដើម ប្រសិនបើវត្ថុទាំងនោះពុំមានប្រយោជន៍សម្រាប់ការសំដែងការពិតទេ នោះហើយប្រសិនបើកម្មសិទ្ធិលើវត្ថុនោះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ។

ប៉ុន្តែវត្ថុដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ឬចំពោះទ្រព្យសម្បត្តិដូចជាៈ អាវុធ ឬជាតិផ្ទុះ ព្រមទាំងវត្ថុដែលត្រូវបានកាន់កាប់ដោយខុសច្បាប់មិនអាចប្រគល់ឲ្យវិញបានទេ។ វត្ថុទាំងនោះត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬត្រូវបំផ្លាញចោល។

ក្នុងករណីមិនព្រមប្រគល់ឲ្យវិញទេ អ្នកប្តឹងអាចប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាបាន។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាគ្មានសមត្ថកិច្ចក្នុងការប្រគល់ទេ កាលណាមានការចោទប្រកាន់ធ្វើឡើងនៅចំពោះមុខយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ។

ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញានៅតែមានសមត្ថកិច្ចកាលណាការស៊ើបសួរត្រូវបានបញ្ចប់ដោយសេចក្តីសម្រេចលើកលែងចោទប្រកាន់ជាស្ថាពរ។

## កថាខណ្ឌទី៤. ការបំភ្លឺរបស់ជនរងគ្រោះ

### ៤.១.ខ្លឹមសាររួមនៃការបំភ្លឺរបស់ជនរងគ្រោះ

អត្ថន័យនេះ គឺជាការផ្តល់ព័ត៌មានដែលធ្វើឡើងដោយជនរងគ្រោះតាមរៈនៃការសាកសួរយកចម្លើយនៅគ្រប់ដំណាក់កាលនៃនីតិវិធីចំពោះចំណាត់ការរឿងក្តីព្រហ្មទណ្ឌដោយក្នុងនោះ ត្រូវបានកត់ត្រាទៅតាមសណ្តាប់ធ្នាប់ ឬវិធានដែលច្បាប់នីតិវិធីបានកំណត់។ ខ្លឹមសារទាំងនេះ ត្រូវបានរៀបរាប់ប្រហាក់ប្រហែលគ្នាទៅនឹងលក្ខខណ្ឌរបស់សាក្សីផងដែរ ពីព្រោះថាជនរងគ្រោះគឺជាសាក្សីដែលជាប្រភេទភស្តុតាងដ៏ពិសេសបំផុតដោយសារតែភស្តុតាងប្រភេទនេះចេះនិយាយ ប៉ុន្តែករណីខ្លះក៏មិនអាចនិយាយបានដែរ (ករណីជនរងគ្រោះស្លាប់)។

### ៤.២. កម្មវត្ថុនៃការបំភ្លឺរបស់ជនរងគ្រោះ

កម្មវត្ថុនេះគឺ មានលក្ខណៈដូចគ្នាទៅនឹងកម្មវត្ថុនៃការបំភ្លឺរបស់សាក្សីផងដែរ ជាពិសេសគេអាចសាកសួរជនរងគ្រោះតទល់ជាមួយនឹងជនសង្ស័យ និងជាមួយជនជាប់ចោទក៏បាន។ ការយកវិធានទាំងអស់នៃកម្មវត្ថុរបស់សាក្សីមកប្រើប្រាស់នៅក្នុងវិធាននៃការបំភ្លឺរបស់ជន រងគ្រោះនេះបានពីព្រោះថា សាក្សី និងជនរងគ្រោះសុទ្ធសឹងជាបុគ្គលដែលមាននាទីបំភ្លឺដូចគ្នា ប៉ុន្តែមានលក្ខខណ្ឌខ្លះមិនអាចយកមកប្រើរួមគ្នាបានទេ។ វិធានដែលមិនអាចប្រើលក្ខខណ្ឌរួមគ្នាបាននោះមានចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ជនរងគ្រោះជាភាគី: គឺជនរងគ្រោះខុសពីសាក្សីត្រង់ថា ជនរងគ្រោះជាភាគីម្ខាងនៅ ក្នុងនីតិវិធីព្រហ្មទណ្ឌ។ មានន័យថាជនរងគ្រោះជាភាគីការពារផលប្រយោជន៍ដោយផ្ទាល់នៅក្នុងរឿងក្តី (ប្រយោជន៍ច្បាប់ និងប្រយោជន៍សម្ភារៈ) រីឯសាក្សីជាបុគ្គលដែលមានផលប្រយោជន៍ដោយប្រយោលនៅក្នុងរឿងក្តីព្រហ្មទណ្ឌគឺផលប្រយោជន៍ច្បាប់ (ច្បាប់តម្រូវឲ្យបំភ្លឺសេចក្តីពិត) តែគ្មានផលប្រយោជន៍សម្ភារៈទេ(កណីរជាសាក្សីបំភ្លឺខុសការពិតត្រូវមានទោស ឬបទស៊ីសំណូកជាដើម)។
- ទំនាក់ទំនងជនរងគ្រោះចំពោះភស្តុតាង: គឺជនរងគ្រោះមានសិទ្ធិវាយតម្លៃទៅលើភស្តុតាងដែលសមត្ថកិច្ចប្រមូលបាន។ ការវាយតម្លៃនេះដោយប្រើប្រាស់តាម មធ្យោបាយ

ក្នុងការសំដែងចេញនូវការយល់ព្រម ឬក៏មិនយល់ព្រមចំពោះភស្តុតាងណាមួយនោះ ប៉ុន្តែគាត់(ជនរងគ្រោះ) ត្រូវតែផ្តល់ពតិមានយ៉ាងជាក់លាក់បំផុតអំពីប្រភពនានានៃភស្តុតាងណាមួយនោះរួមជាមួយនឹងអង្គហេតុនានាដែលគាត់បានដឹងជាសារធារណៈផងដែរ។ មានន័យថាមិនមែនគ្រាន់តែប្រើពាក្យថា «យល់ព្រម ឬមិនយល់ព្រម» ជាការគ្រប់គ្រាន់នោះទេ គឺតម្រូវឲ្យយកអង្គហេតុណាមួយមកធ្វើជាទឡ្ហីករណ៍ផងដែរ។ ចំពោះសាក្សីគ្មានសិទ្ធិវាយតម្លៃទៅលើភស្តុតាងដែលគេប្រមូលបាននោះឡើយ ពីព្រោះសាក្សីមានកាតព្វកិច្ចបំភ្លឺនូវអ្វីៗដែលខ្លួនបានទទួលដឹង និង ឆ្លើយនូវរាល់សំនួរនានា។ សាក្សីមិនអាចនិយាយថា ខ្លួនគាត់បានឃើញលោក «ក» ច្បាស់ជាងលោក «ខ» ឃើញលោក «ក» នោះបានទេពីព្រោះកាតព្វកិច្ចនេះជារបស់ **អ្នកស៊ើបអង្កេត ព្រះរាជអាជ្ញា និងតុលាការ។**

•ការទទួលខុសត្រូវរបស់ជនរងគ្រោះ ជនរងគ្រោះក៏ដូចជាសាក្សីផងដែរគឺ ត្រូវមានទោសបើមានការកុហុក ឬបដិសេធមិនព្រមធ្វើការបំភ្លឺ ប៉ុន្តែការមានទោសរបស់ជនរងគ្រោះគឺជាវិធីវាយបកពីជនត្រូវចោទតាមរូបភាពបណ្តឹងបកវិញ តែពុំមែនជាវិធីតបតដោយផ្ទាល់ពីអាជ្ញាធររបស់រដ្ឋនោះទេ រីឯការបដិសេធមិនព្រមធ្វើការបំភ្លឺជាវិធីដែលធ្វើឱ្យបាត់បង់នូវផលប្រយោជន៍ផ្ទាល់របស់ជនរងគ្រោះដោយសារតែខ្លួនមិនចង់ឆ្លើយ។ ជាធម្មតាជនរងគ្រោះតែងតែរិះរកមធ្យោបាយគ្រប់បែបយ៉ាងដើម្បីដាក់បន្ទុកទៅលើជនល្មើស ប៉ុន្តែច្បាប់ក៏បានកំរិតមិនឲ្យជនរងគ្រោះដាក់បន្ទុកតាមតែទំនើងចិត្តនោះដែរ គឺរដ្ឋត្រូវមានវិធានការណ៍ការពារដល់មនុស្សគ្រប់រូប។ វិធានការណ៍នេះមានដូចជា: បើកសិទ្ធិឲ្យមានការធ្វើបណ្តឹងបកវិញ (រឿងព្រហ្មទណ្ឌមើលស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ៥, ៦, ១៤២ និងស្មារតីក្រមព្រហ្មទណ្ឌមាត្រា ៥២៤) និងបណ្តឹងតបវិញ(រឿងក្តីរដ្ឋប្បវេណី ស្មារតីក្រមនីតិវិធីរដ្ឋប្បវេណីមាត្រ ៨៦)។ ចំពោះសាក្សីវិញ បើរកឃើញថាបំភ្លឺកុហកនោះត្រូវមានទោសជាចាំបាច់។

•សិទ្ធិ និងកាតព្វកិច្ចរបស់ជនរងគ្រោះ ជនរងគ្រោះខុសពីសាក្សីត្រង់ថា ការផ្តល់នូវការបំភ្លឺវាជាកាតព្វកិច្ចផង និងជាសិទ្ធិផង។ នេះមានន័យថាតុលាការ(ចៅក្រម) និងអ្នកស៊ើបអង្កេតគ្មានសិទ្ធិបដិសេធចំពោះគាត់បានទេប្រសិនបើជនរងគ្រោះរូបនោះ គាត់ចង់ផ្តល់ការបំភ្លឺ ឬមិនចង់ជាសិទ្ធិរបស់គាត់។ ក៏ប៉ុន្តែសម្រាប់សាក្សីវិញមានកាតព្វកិច្ចមិនអាចខ្វះបាន។

## ៤.៣. ឥទ្ធិពលពីខាងក្រៅរបស់ជនរងគ្រោះ

ការបំភ្លឺរបស់ជនរងគ្រោះគឺជាប្រភេទនៃភស្តុតាងមួយដ៏សំខាន់ផងដែរ ប៉ុន្តែក្នុងទ្រឹស្តីនៃភស្តុតាង គេកម្រនឹងមានការបែងចែកការបំភ្លឺរបស់ជនរងគ្រោះឱ្យនៅដាច់ជាប្រភេទនៃភស្តុតាងដោយ

ឡែកនោះណាស់។ ការមិនបែងចែកឲ្យដាច់ពីគ្នានេះ ពីព្រោះថាគេចាត់ទុកការបំភ្លឺរបស់ជនរងគ្រោះដូចគ្នាទៅនឹងការបំភ្លឺរបស់សាក្សីដែរ អញ្ចឹងហើយបានជានៅក្នុងសៀវភៅភស្តុតាង ខ្លះអ្នកនិពន្ធមានការប្រើប្រាស់ពាក្យថា «សាក្សីរងគ្រោះ» ប៉ុន្តែតាមការពិតជនរងគ្រោះមានលក្ខណៈពិសេសមួយចំនួនខុសពីសាក្សី។ នៅក្នុងប្រពន្ធ័សាខានីតិសាស្ត្ររបស់ប្រទេសខ្លះ គេបានសិក្សាទៅលើលក្ខណៈនៃជនរងគ្រោះទៅតាមប្រភេទនៃបទល្មើសវិញ។ ជាឧទាហរណ៍: នៅក្នុងបទល្មើសប្លន់យកទ្រព្យសម្បត្តិ ការបំភ្លឺរបស់ជនរងគ្រោះមានស្ថានភាពខុសគ្នាទៅនឹងសញ្ញាណនៃការបំភ្លឺរបស់ជនរងគ្រោះនៅក្នុងបទល្មើសរំលោភសេពសន្ថវៈ។ ការបំភ្លឺមានសញ្ញាណខុសគ្នានេះត្រង់ថា ជនរងគ្រោះក្នុងអំពើប្លន់ ការបំភ្លឺរបស់គាត់មានគោលដៅបង្ហាញអំពីភាពភ័យខ្លាចបាត់បង់ជីវិត និងបាត់បង់ទ្រព្យសម្បត្តិ ប៉ុន្តែការបំភ្លឺរបស់ជនរងគ្រោះនៅក្នុងបទល្មើសរំលោភសេពសន្ថវៈវិញ គ្រប់ការនិយាយរបស់គាត់មានគោលដៅបង្ហាញនូវសញ្ញាណនៃការតតាំងប្រឆាំងជាមួយនឹងជនល្មើសជានិច្ច។

ដូចនេះនៅក្នុងរឿងក្តីព្រហ្មទណ្ឌ និងតាមទ្រឹស្តីនៃភស្តុតាងគេសង្កេតឃើញលក្ខណៈរួមដែលជាចំណុចពិសេសៗរបស់ជនរងគ្រោះមានកត្តាគ្រឹះមួយចំនួន ដែលជាសញ្ញាណសម្រាប់ឲ្យអ្នកស៊ើបអង្កេត ឬតុលាការយល់ដឹងជាមុនមានដូចជា៖

•ទី១. ជនរងគ្រោះ ត្រូវមានសិទ្ធិដឹងទៅលើខ្លឹមសារនៃការចោទប្រកាន់របស់ស្ថាប័នមានសមត្ថកិច្ចដែលបានធ្វើទៅលើបុគ្គលណាមួយ ដោយអំពើក្នុងការប្រព្រឹត្តិនោះមានទំហំដ៏គ្រោះថ្នាក់បំផុត។ សិទ្ធិដឹងនេះហើយដែលធ្វើឱ្យមានការតាំងខ្លួនជាដើមបណ្តឹងបាន(ស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា៣១២, ១៣៧)។

•ទី២. ជនរងគ្រោះត្រូវមានសិទ្ធិ និងកាតព្វកិច្ចក្នុងការបំភ្លឺនូវគ្រប់អ្វីៗដែលអង្គការស៊ើបអង្កេតចង់បាន ដោយការចង់បានរបស់អ្នកស៊ើបអង្កេតបែបនេះ ត្រូវតែស្ថិតនៅក្នុងលក្ខខណ្ឌមួយដែលចាត់ទុកជាការការពារចំពោះជនរងគ្រោះ។ សិទ្ធិ និងកាតព្វកិច្ចរបស់ជនរងគ្រោះក្នុងលក្ខខណ្ឌនៃការការពារខ្លួននេះដូគ្នាទៅនឹងលក្ខខណ្ឌនៃអភ័យឯកសិទ្ធិរបស់សាក្សីដែរ ដោយហេតុនេះហើយទើបច្បាប់តម្រូវឱ្យមានការដាក់ទោសលើជនរងគ្រោះបាន (ស្មារតីក្រមព្រហ្មទណ្ឌមាត្រា៥២៤, ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា១៤០, ១៤១, ១៤២)។

•ទី៣. ជនរងគ្រោះមានសិទ្ធិជ្រើសរើសអ្នកតំណាងទៅតាមលទ្ធភាពរបស់ខ្លួន ដែលសិទ្ធិនេះសាក្សីពុំអាចមាននោះទេ (សិទ្ធិជ្រើសរើសមេធាវី)។

គ្រប់លក្ខខណ្ឌដែលបានបង្ហាញខាងលើនេះ វាជាសកម្មភាពដែលកើតចេញពីពិភពខាងក្រៅ(ពីព្រឹត្តិការណ៍) ហើយត្រូវបានជ្រាបចូលទៅក្នុងអារម្មណ៍របស់ជនរងគ្រោះ បន្ទាប់ពីត្រូវបានបំពានដោយជនល្មើសនៃព្រឹត្តិការណ៍ណាមួយ។

## ៤.៤. ឥទ្ធិពលផ្ទាល់ដែលលេចចេញពីជនរងគ្រោះ

តាមចំណុចខាងលើនេះ បានបង្ហាញអំពីលក្ខណៈរួមពិសេសៗរបស់ជនរងគ្រោះក្នុងបទល្មើសផ្សេងៗពីគ្នាដែលអាចជះឥទ្ធិពលពីខាងក្រៅចូលទៅក្នុងអារម្មណ៍របស់ជនរងគ្រោះ ប៉ុន្តែក៏មានលក្ខណៈពិសេសបំផុតផ្សេងទៀតនោះគឺ ទាក់ទិនទៅនឹងលក្ខណៈសម្បត្តិផ្ទាល់របស់ជនរងគ្រោះដែលជះត្រឡប់ទៅពិភពខាងក្រៅវិញ។

បើយើងពិនិត្យទៅលើអត្ថន័យនៃការបំភ្លឺរបស់សាក្សីវាជាការបំភ្លឺដោយមនុស្សរស់ រីឯភស្តុតាងជាវត្ថុវិញគឺជាសាក្សីគ។ ពាក្យថាសាក្សីគ មានន័យប្រហាក់ប្រហែលគ្នាទៅនឹង «ស្លាប់» ដែរបើតាមអត្ថន័យនៃពាក្យថា «ការបំភ្លឺ» ប៉ុន្តែនៅក្នុងការប្រតិបត្តិជាក់ស្តែងទៅលើសំណុំរឿងព្រហ្មទណ្ឌ អ្នកស៊ើបអង្កេត និងតុលាការបានជួបប្រទះនូវលក្ខខណ្ឌពិសេសពីរដែលមានភាពស្មុគស្មាញជាទីបំផុត ហើយស្ទើរតែបាត់បង់នូវប្រភពនៃការផ្តល់ពត៌មានស្តីអំពីអង្គហេតុមួយនោះបាន។ លក្ខខណ្ឌពិសេសនោះគឺ: **ទី១.** ជនរងគ្រោះស្លាប់ និង**ទី២.** ជនរងគ្រោះជាកុមារ ដែលមានអាយុតិច ហើយអំពើនោះបានប្រព្រឹត្តិនៅកន្លែងដែលមានតែជនរងគ្រោះ និងជនល្មើសពីរនាក់ប៉ុណ្ណោះ។

### ក. ករណីជនរងគ្រោះស្លាប់

ប្រសិនបើបានជួបប្រទះទៅលើសំណុំរឿងដែលមានជនរងគ្រោះត្រូវបានសម្លាប់ អ្នកស៊ើបអង្កេត និងតុលាការត្រូវតែពឹងផ្អែកទៅលើអ្នកជំនាញផ្សេងៗក្នុងការធ្វើកោសល្យ វិច្ច័យបែបឧក្រិដ្ឋនិច្ឆ័យ(Criminalistics) និងពេទ្យតុលាការ(កោសលវិច័យបែបវេជ្ជសាស្ត្រ)ហើយជាពិសេសត្រូវផ្ទៀងផ្ទាត់ និងវាយតម្លៃទៅលើចំនុចសំខាន់ចំនួនបីគឺ៖

- **ទី១.ភូមិសាស្ត្រ ឬទីតាំងកើតហេតុ:** ចំណុចនេះត្រូវកំនត់អំពីទីតាំងរដ្ឋបាលដែលមាន ក្នុងដែនសមត្ថកិច្ចដូចជា: ភូមិ ឃុំ សង្កាត់ ខណ្ឌ ក្រុង ខេត្ត រាជធានី និងចំនុចទីតាំងកើតហេតុត្រូវពិនិត្យអំពីចំណុចជាក់លាក់ក្នុងពេលអំពើល្មើសបានកើតឡើងដោយ គិតចំងាយរួមទាំងស្ថានភាពសណ្ឋានទីតាំង (ខ្ពស់ ឬទាប ដី ឬថ្ម ឬទឹក ...)និងវត្ថុនានាដែលនៅក្បែរចំណុចអ័ក្សនៃទីតាំងប្រព្រឹត្តិបទល្មើសនោះ។
- **ទី២.ស្លាកស្នាម ឬដានផ្សេងៗនៅទីតាំងកើតហេតុ:** ត្រូវពិនិត្យទាំងអស់នូវវត្ថុ ឬស្នាមឬសណ្ឋានផ្សេងៗដែលមាននៅជុំវិញនៃចំណុចអ័ក្សកើតហេតុ។

•**ទី៣.ការបំភ្លឺនានារបស់សាក្សី:** ត្រូវពិនិត្យរាល់ចម្លើយរបស់សាក្សីដែលមានលក្ខណៈជាទម្រង់ផ្ទាល់ ឬប្រយោលទៅតាមអត្ថន័យដែលមាននៅក្នុងកំនត់ហេតុនានា។ ចំពោះការវាយតម្លៃ និងការផ្ទៀងផ្ទាត់នេះត្រូវធ្វើដូចគ្នាទៅនឹងវិធាននៃភស្តុតាងក្នុងប្រភេទជាសាក្សី និងប្រភេទជាវត្ថុដែរ ពីព្រោះមនុស្សដែលស្លាប់ទុកដូចជាសាក្សីគេគឺត្រូវរកឱ្យឃើញនូវសម្ព័ន្ធភាពនៃអង្គហេតុទៅលើចំនុចទាំងបីនេះ។ អត្ថន័យនៃជនរងគ្រោះស្លាប់មានន័យស្មើនឹងភស្តុតាងជាវត្ថុដែរ។

## ខ. ករណីជនរងគ្រោះជាកុមារមានអាយុតិច

បើសិនជាជួបប្រទះទៅលើសំណុំរឿងដែលមានជនរងគ្រោះជាកុមារដែលមានអាយុតិចវិញ ឬក៏ជាមនុស្សដែលមានវិបល្លាសខាងស្មារតី អ្នកស៊ើបអង្កេត និងតុលាការត្រូវយកចិត្តទុកដាក់សំខាន់បំផុតទៅលើចំនុចគន្លឹះបីសំខាន់ៗផងដែរគឺ:

•**ទី១.**ពិនិត្យអំពីប្រវត្តិនៃការរស់នៅរបស់ជនរងគ្រោះមុនពេលកើតហេតុ: គឺជាការរុករកឲ្យឃើញនូវ ជីវិតរបស់ជនរងគ្រោះដែលបានស្នាក់នៅពីអតីតកាលរហូតដល់ថ្ងៃកើតហេតុដោយក្នុងនោះត្រូវប្រើប្រាស់គ្រប់មធ្យោបាយក្នុងការសាកសួរទាំងជនរងគ្រោះទាំងអ្នកដទៃ (អាចជាសាក្សី ឬក៏ជាសារព័ត៌មានផ្សេងៗ)។

•**ទី២.**សកម្មភាពពេលកំពុងប្រព្រឹត្តិរបស់ជនល្មើសដែលជនរងគ្រោះបានដឹង: ចំណុចនេះត្រូវពិនិត្យអំពីសកម្មភាពអ្វីខ្លះដែលជនរងគ្រោះបានដឹង និងចងចាំទៅលើភាពឃោរឃៅរបស់ជនល្មើសដែលអាចសម្តែងចេញដោយលក្ខណៈភ័យខ្លាច ឬការសោកសង្រេងរបស់ជនរងគ្រោះតាមរយៈសម្លេង ឬកាយវិការ។

•**ទី៣.**សកម្មភាពនានារបស់ជនជាប់ចោទបន្ទាប់ពីបានប្រព្រឹត្តិ ដោយរួមទាំងកោសល្យវិច្ច័យនានា: ចំណុចនេះត្រូវពិនិត្យសកម្មភាពនានាដែលជនល្មើសបានសម្រេចតាមគោលបំណងរបស់ខ្លួនក្នុងការប្រព្រឹត្តិទៅលើជនរងគ្រោះដែលស្តែងចេញតាមកំណត់ហេតុ និងភស្តុតាងជាវត្ថុនានា។

ចំណុចទាំងបីនេះត្រូវតែស្វែងយល់ឱ្យបាន «ហ្មត់ចត់ទៅលើជនរងគ្រោះ» ជាពិសេសជនរងគ្រោះជាកុមារដែលមានអាយុតិចគាត់ភាគច្រើនអាចនិយាយបំផ្លើសហួសប្រមាណ តែក៏អាចនិយាយបានយ៉ាងសុក្រឹត្យជាងមនុស្សចាស់ផងដែរ។ ពីព្រោះថាក្មេងពុំមានការត្រៀមទុកនោះទេ ប្រសិនបើមានហេតុការណ៍អ្វីដែលខុសប្លែកពីធម្មតា កុមារតែងយកចិត្តទុកដាក់ទៅលើព្រឹត្តិការណ៍នោះជាងមនុស្សចាស់ដែលធ្វើឲ្យកុមាររៀបរាប់បានយ៉ាងសុក្រឹត្យបំផុត។ ប៉ុន្តែនៅពេលដែលកុមារ

បានទទួលដំបូន្មាន ឬអំណោយផ្សេងៗដែលជាប្រយោជន៍ដល់កុមារ នោះចម្លើយនឹងត្រូវបានប្រែប្រួលយ៉ាងលឿនបំផុតរួមទាំងមានការទន្ទេញរត់មាត់តាមដំបូន្មាននោះផង។ ចំពោះមនុស្សចាស់វិញមិនសូវចាប់អារម្មណ៍ទៅលើព្រឹត្តិការណ៍ដែលកើតមានខុសពីធម្មតានោះទេ លើកលែងតែព្រឹត្តិការណ៍ចំឡែកនោះធ្វើឲ្យគាត់មានប្រយោជន៍ដោយផ្ទាល់ ឬប្រយោល(តាមផ្លូវអារម្មណ៍) ប៉ុណ្ណោះ។ ជាឧទាហរណ៍: ក្នុងករណីបទរំលោភផ្លូវភេទទៅលើកុមារអាយុ ៥ឆ្នាំ គឺថាកុមារមិនចេះប្រើពាក្យបច្ចេកទេសដែលទាក់ទឹនទៅនឹងបទល្មើសនោះទេ ប៉ុន្តែកុមារចេះប្រើតែពាក្យភ័យខ្លាច ឬពាក្យឈឺចាប់ដែលជនល្មើសធ្វើមកលើខ្លួនតែប៉ុណ្ណោះ។ ប៉ុន្តែបើកុមារប្រើពាក្យបច្ចេកទេសដែលទាក់ទឹនទៅនឹងបទល្មើស ហើយនិយាយ ដដែលៗនោះតុលាការត្រូវយកវិធានទាំងឡាយរបស់សាក្សីមកប្រើប្រាស់ដូចគ្នាផងដែរដើម្បីធ្វើការផ្ទៀងផ្ទាត់ និងធ្វើការវាយតម្លៃទៅលើភស្តុតាងក្នុងរឿងក្តីបែបនេះ។

ជាទ្រឹស្តីនៅក្នុងបទល្មើសរំលោភផ្លូវភេទមានសញ្ញាណសំគាល់ពីរប្រភេទទាក់ទឹននឹងជនរងគ្រោះគឺ **ទី១.** ជនល្មើសបំពានទៅលើឆន្ទៈរបស់ជនរងគ្រោះដែលក្នុងខណៈនេះជនរងគ្រោះមានស្មារតីគ្រប់គ្រាន់ដែលហៅថា«បទរំលោភសេពសន្ថវៈ និង**ទី២.** ជាការរំលោភសេពសន្ថវៈទៅលើជនរងគ្រោះជាអនីតិជន ឬជនវិបល្លាសខាងស្មារតីដែលការរួមភេទបែបនេះទោះបីជាមានការយល់ព្រមពីភាគីរងគ្រោះក៏ដោយ ក៏នៅតែចាត់ទុកថា បំពានឆន្ទៈរបស់ជនរងគ្រោះដដែល ពីព្រោះជនរងគ្រោះក្នុងលក្ខខណ្ឌបែបនេះត្រូវបានគាំពារពិសេសពីភាគីរដ្ឋដែលហៅថា**អភ័យឯកសិទ្ធិផ្លូវភេទ**។

ចំពោះការយកចម្លើយទៅលើការបំភ្លឺរបស់ជនរងគ្រោះ ក៏ធ្វើដូចគ្នាទៅនឹងសាក្សី ឬជនល្មើសដែរ គ្រាន់តែសិទ្ធិ និងកាតព្វកិច្ចខ្លះរបស់ជនរងគ្រោះមិនត្រូវបានរិតត្បិតនោះទេ។ យើងអាចមើលក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា១១៥, ៣១២ និង៣២៦ជាដើម។

## ៤.៥. ការវាយតម្លៃលើការបំភ្លឺរបស់ជនរងគ្រោះ

ការវាយតម្លៃទៅលើការបំភ្លឺរបស់ជនរងគ្រោះ ប្រព្រឹត្តិទៅតាមលក្ខខណ្ឌដូចគ្នាទៅនឹងវិធាននៃ ការវាយតម្លៃទៅលើការបំភ្លឺរបស់សាក្សីផងដែរ ប៉ុន្តែមានលក្ខខណ្ឌខ្លះមិនដូចគ្នានោះទេ។ លក្ខខណ្ឌពិសេសៗដែលខុសគ្នាពីសាក្សីនោះមានកត្តាមួយចំនួនដូចខាងក្រោម:

•អារម្មណ៍ក្តុកក្តួលរបស់ជនរងគ្រោះ ការបំភ្លឺរបស់ជនរងគ្រោះជានិច្ចកាលត្រូវបានធ្វើឡើងដោយមានផ្ទុកនូវការរំជួលចិត្តស្របជាមួយគ្នាក្នុងពេលកំពុងតែធ្វើការបំភ្លឺនោះ។ ចំពោះសាក្សីវិញឥរិយាបថរបៀបនេះគ្មានទេ តែបើជាមានវិញនោះសាក្សីរូបនេះពិតជាជាប់ទាក់ទិនទៅនឹងផលប្រយោជន៍ណាមួយជាមួយនឹងជនរងគ្រោះ ឬភាគីណាផ្សេងទៀតមានជាអាទិ៍៖ សាច់ញាតិ គូសហាពន្ធ័ ត្រូវបានគេជួល ឬទិញទឹកចិត្ត ឬក៏ បង្ខិតបង្ខំដោយមានលក្ខខណ្ឌជាដើម។ល។

•អារម្មណ៍ពេញចិត្តចំពោះការទាញយកប្រយោជន៍ជនរងគ្រោះ ជាទូទៅមានការពេញចិត្តបំផុតចំពោះការពង្រីកទំហំនៃព្យសនកម្មមកលើខ្លួនគាត់ ក្នុងគោលដៅឲ្យបានប្រយោជន៍គាប់ប្រសើរតាមរយៈនៃការធ្វើសេចក្តីសំរេចក្នុងរឿងព្រហ្មទណ្ឌដោយតុលាការ។ ចំពោះសាក្សីដែលមានចិត្តស្អាតស្អំវិញ ឥរិយាបថបែបនេះមិនអាចកើតមានឡើយ ប៉ុន្តែសាក្សីអាចបារម្ភតែម្យ៉ាងគត់ទៅលើអសន្តិសុខផ្ទាល់ខ្លួនរបស់គាត់រួមទាំងសាច់ញាត្តិអំពីការបំភ្លឺឲ្យឃើញការពិត ដែលនាំឲ្យមានបន្ទុកដល់ជនជាប់ចោទ ឬក៏ធ្វើឲ្យបាត់បង់ប្រយោជន៍ដល់ចេតនាទុច្ចរិតខ្លះរបស់ជនរងគ្រោះ។ អារម្មណ៍យកចិត្តទុកដាក់របស់ជនរងគ្រោះនេះ ជាលក្ខខណ្ឌនានាដែលជនរងគ្រោះបានសង្កេតទៅលើបទល្មើស (ការចាប់អារម្មណ៍មុនពេលប្រព្រឹត្តបទល្មើស និងក្រោយពេលប្រព្រឹត្តិ)ដែលកើតមានចំពោះរូបគាត់។ លក្ខខណ្ឌទាំងនេះវាក៏អាចមានឥទ្ធិពលទៅលើការទទួលយករបស់គាត់ចំពោះព្រឹត្តិការណ៍នានាដែលបានកើតឡើងក្នុងពេលដែលជនល្មើសបានប្រព្រឹត្តិ។ លក្ខខណ្ឌទាំងនេះមានដូចជា៖ ទីកន្លែងនៃការប្រព្រឹត្តិ(ពន្លឺ ស្ងាត់ ទីប្រជុំជន មានពិធី...)ដែលលក្ខខណ្ឌទាំងនេះក៏ជាប់ពាក់ពន្ធ័នឹងឥទ្ធិពលទៅលើគោលបំណងរបស់ជនល្មើសផងដែរ ពីព្រោះថាជនល្មើសតែងតែឆក់ឱកាសក្នុងពេលដែលអ្នកដទៃខ្វះការប្រុងប្រយ័ត្ន។ ចំពោះសាក្សីវិញ ប្រសិនបើមានការអង្កេត ឬចាប់អារម្មណ៍បែបនេះ នោះមានន័យថាបុគ្គលរូបនោះមិនមែនជាសាក្សីនោះទេ ប៉ុន្តែគាត់អាចជាអ្នកសង្កេតការណ៍ទៅវិញដែលឥរិយាបថបែបនេះគាត់អាចជាប់ពាក់ពន្ធ័នឹងអំពើល្មើសដូចជា៖ បទសមគំនិត បទជំរុញឲ្យមានការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមជាដើម....។ល។ ក្នុងករណីដែលមានការសង្ស័យ។ ប៉ុន្តែមិនត្រូវយកលេសថាខ្លួនជាកម្លាំងបង្កប់មានសិទ្ធិរៀបចំឲ្យមានបទ ល្មើសដើម្បីបានភស្តុតាងចាប់ជនល្មើសនោះទេ។

## កថាខណ្ឌទី៥. កំណត់ហេតុអង្កេត និងឯកសារសំណោរនានា

### ៥.១.កំណត់ហេតុអង្កេត

កំណត់ហេតុអង្កេតគឺ ជាឯកសារនៃទំរង់ការពិសេសដែលកត់ត្រាបាននូវគុណសម្បត្តិ និងលក្ខខណ្ឌនានាទៅលើវត្ថុផ្សេងៗដែលជាកម្មវត្ថុនៃការស៊ើបអង្កេតដូចជា: អគារ ឬទីតាំងដែលត្រូវធ្វើការស៊ើបអង្កេតដោយចៅក្រមអយ្យការ ឬតុលាការ។ កំណត់ហេតុនេះគ្របដណ្តប់ទៅលើវត្ថុផងនិងការសួរយកចម្លើយផងនៅក្នុងពេលធ្វើការស៊ើបអង្កេតទៅលើសំណុំរឿងក្តីព្រហ្មទណ្ឌ (ស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា១១៣, ១១៥)។ កំណត់ហេតុអង្កេតគឺជា ភស្តុតាងមួយប្រភេទដែលកំណត់បាននូវអត្ថិភាពសំរាប់កិច្ចនៃការងារអង្គហេតុ ដោយភស្តុតាងប្រភេទបែបនេះបានកកើតនាពេលធ្វើការអង្កេតនាទីតាំងប្រព្រឹត្តិបទល្មើស។ ជាការពិតនៅក្នុងកំណត់ហេតុអង្កេតអាចត្រូវបានផ្តល់ព័ត៌មានឲ្យយើងបានដឹងថា ទីតាំងនោះបានស្ថិតនៅក្នុងស្ថានភាពណាមួយ ហើយនៅទីតាំង

នោះបានត្រូវរកឃើញនូវ វត្ថុផ្សេងៗ និងស្លាកស្នាមនានាជាដើម។ គ្រប់អ្វីៗដែលបានរកឃើញដូចមានកត់ត្រានៅក្នុងកំណត់ហេតុទាំងនេះ បង្កើតបាននូវអត្ថន័យជាសក្ខីកម្មមួយនៃកំណត់ហេតុអង្កេត។ ព័ត៌មានដែលបង្កើតបានជាទឡ្ហីកម្មនៃអង្គហេតុតាមរយៈនៃកំណត់ហេតុអង្កេតបានចងអត្ថន័យនៃខណៈនានារបស់ អង្គហេតុទៅនឹងការអនុវត្តរបស់អ្នកស៊ើបអង្កេតចំពោះនីតិវិធីដែលមានចែងដោយច្បាប់។ កិច្ចការបែបនេះប្រសិនបើអ្នកស៊ើបអង្កេតមិនបានយកចិត្តទុកដាក់ខ្ពស់ នោះនាំឲ្យមានមោឃភាពនៃនីតិវិធី (ស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា១០៩,១១៧) និងដោយសារកំណត់ហេតុអង្កេតចាត់ទុកជាភស្តុតាងនេះហើយ ទើបច្បាប់នីតិវិធីបានកំណត់នូវវិធានដ៏ជាក់លាក់បំផុតក្នុងការសរសេរកំនត់ហេតុមិនសំដៅទៅលើតែដំណាក់កាលស៊ើបអង្កេតប៉ុណ្ណោះទេ តែគ្របដណ្តប់រួមទៅលើចំណាត់ការរឿងក្តីទាំងអស់ដែលមាននៅក្នុងប្រពន្ធ័តុលាការ(ស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា២៤២)។

នៅក្នុងសវនាការ តុលាការប្រើប្រាស់កំនត់ហេតុអង្កេតនានារបស់ស្ថាប័នស៊ើបអង្កេតមកធ្វើការពិនិត្យ(ស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា១០៨, ១១០,១១៨) និងផ្ទៀងផ្ទាត់ជាមួយនឹងភស្តុតាងក្នុងប្រភេទផ្សេងៗទៀតដែលមាននៅក្នុងសំណុំរឿង។ តុលាការផ្ទាល់ក៏អាចធ្វើការអង្កេតទៅលើទីតាំងបទល្មើសបានដែរ ប៉ុន្តែការអង្កេតនេះនឹងមិនត្រូវបានធ្វើឡើងដោយភ្លាមៗទៅលើទីតាំងនៃការប្រព្រឹត្តបទល្មើសដូចការអង្កេតរបស់អ្នកស៊ើបអង្កេតពីដំបូងៗនោះទេ។ ត្រង់នេះមានន័យថាតុលាការគ្រាន់តែធ្វើការស៊ើបសួរទៅលើទីតាំង ឬអង្គហេតុផ្សេងៗទៀត ដើម្បីបង្គ្រប់នូវការផ្ទៀងផ្ទាត់ទៅលើអត្ថិភាពនៃអង្គសេចក្តីដែលតុលាការចង់ដឹងបន្ថែមតែប៉ុណ្ណោះ (ស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា៣៣៩)។

ដូចនេះកំណត់ហេតុអង្កេតពីដំបូងៗវាជាទឡ្ហីកម្ម(បន្ទាន់)ពិសេសមួយ ពីព្រោះថាកំណត់ហេតុទាំងអស់នោះ ត្រូវបានអ្នកស៊ើបអង្កេតធ្វើឡើងសំរាប់កត់ត្រាភ្លាមៗទៅលើទីតាំងកើតហេតុបន្ទាប់ពីជនល្មើសបានប្រព្រឹត្តិរួចថ្មីៗបំផុត។ កំណត់ហេតុរបៀបនេះបានចងសម្ព័ន្ធភាពជាមួយនឹងកំណត់ហេតុយកចម្លើយនានាពីដំបូងៗរួមមានកំណត់ហេតុជាអាទិ៍៖ សាក្សី, ជនរងគ្រោះ, កំណត់ហេតុឃាត់ខ្លួន, កំណត់ហេតុឆែកឆេរ, កំណត់ហេតុចាប់យកវត្ថុតាង និងកំណត់ហេតុសាកសួរជនល្មើសជាដើម។ ការចាត់ទុកកំណត់ហេតុដំបូងៗគ្រប់ប្រភេទមានតម្លៃជាភស្តុតាងនៃសំណុំរឿងក្តីនៅតុលាការ ជានីតិវិធីមួយចងភ្ជាប់សមត្ថភាពរបស់សមត្ថកិច្ចទៅនឹងលំហូរនីតិវិធីរបស់តុលាការដូចមាត្រា២៤២ កថាខណ្ឌទី២នៃស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌចែងថា «កំណត់ហេតុស្រង់យ៉ាងត្រឹមត្រូវនូវសំណួរចម្លើយ និងចម្លើយដែលឆ្លើយដោយឯកឯង»។ កថាខណ្ឌនេះបង្ហាញយ៉ាងច្បាស់អំពីការវាស់ស្ទង់នូវសមត្ថភាពរបស់អ្នកអនុវត្តច្បាប់ក្នុងការចាត់ការទៅលើសំណុំរឿងក្តីព្រហ្មទណ្ឌ

ដែលទាក់ទឹននឹងបច្ចេកទេសនៃការសាកសួរ ដែលជាសមត្ថភាពផ្ទាល់របស់អ្នកស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា របស់ចៅក្រមស៊ើបសួរ របស់ចៅក្រមជំនុំជម្រះ។ ដោយផ្អែកលើខ្លឹមសារនៃកំណត់ហេតុអង្កេតដែលជាប្រភេទនៃភស្តុតាងក្នុងរឿងក្តីព្រហ្មទណ្ឌអាចលេចឡើងតាមទម្រង់ពីរដែលចងកាតព្វកិច្ចរបស់អ្នកអនុវត្តច្បាប់ទៅក្នុងលក្ខខណ្ឌនៃការបម្រើដល់សេចក្តីសម្រេចរបស់តុលាការគឺៈ ចំណងកាតព្វកិច្ចតាមសមត្ថភាព និងចំណងកាតព្វកិច្ចតាមលំដាប់ ។

## ៥.២. ឯកសារសំណោរនានា

ឯកសារសំណោរនានាគឺជាភស្តុតាងដ៏ចាំបាច់ផងដែរ ពីព្រោះភស្តុតាងប្រភេទបែបនេះគឺជាឯកសារទាំងឡាយណាដែលបញ្ជាក់បាននូវខណៈណាមួយ ដោយខណៈនោះវាមានអត្ថន័យសំរាប់កិច្ចការអង្គហេតុ។ ឯកសារទាំងនេះមានដូចជាៈលិខិតបញ្ជាក់ផ្សេងៗរបស់ស្ថាប័ននានា ដែលមានលក្ខណៈបញ្ជាក់ទៅលើជនជាប់ចោទ ឬក៏លិខិតផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងអត្តចរិតរបស់ជនល្មើសដូចជាអត្តសញ្ញាណកម្មនានាជាដើម។ តាមខ្លឹមសារចំពោះឯកសារសំណោរដែលមានតម្លៃជាភស្តុតាងនៅក្នុងសំណុំរឿងព្រហ្មទណ្ឌវាមានភាពរឹងមាំខ្លាំងណាស់ ប្រសិនបើខ្លឹមសារនៃឯកសារសំណោរនោះមានអត្ថន័យដូចជាភស្តុតាងវត្ថុ។

ឯកសារសំណោរនានាអាចជាភស្តុតាងវត្ថុដ៏សំខាន់ផងដែរ កាលណាឯកសារទាំងនេះត្រូវបានបញ្ជាក់នូវខ្លឹមសារច្បាស់លាស់ដូចដែលបានរៀបរាប់អំពីភស្តុតាងជាវត្ថុ ពីព្រោះថាឯកសារទុកដូចជាប្រភេទនៃវត្ថុ។ ប៉ុន្តែឯកសារសំណោរនានានេះវិញ អាចតំណាងឱ្យប្រភេទឯករាជ្យនៃភស្តុតាងដោយខ្លួនឯង តែមិនមែនជាភស្តុតាងវត្ថុនោះឡើយ ពោលគឺឯកសារសំណោរវាជាប្រភេទភស្តុតាងមួយផ្សេងទៀតដោយឯកឯងមិនស្ថិតក្រោមឥទ្ធិពលនៃភស្តុតាងប្រភេទផ្សេងទៀតនោះទេ។ ត្រង់នេះមានន័យថាឯកសារសំណោរនានាមិនអាចជាប្រភេទភស្តុតាងវត្ថុបានទេ តែវាជាប្រភេទឯករាជ្យនៃភស្តុតាងដាច់ដោយឡែកមួយ ពីព្រោះថាសំណោរទាំងឡាយដែលមាននៅលើឯកសារនេះវាបង្ហាញនូវអត្ថន័យដោយផ្ទាល់ចំពោះអង្គហេតុតាមរយៈនៃអត្ថបទដែលបានសរសេរឡើង ពោលគឺមិនមែនស្តែងតាមខណៈនៃឯកសារនោះទេ តែស្តែងតាមការអធិប្បាយនៅក្នុងអត្ថបទ។

ដូច្នេះតាមអត្ថន័យនៃឯកសារសំណោរនានានៅក្នុងទ្រឹស្តីភស្តុតាងតុលាការ គ្រប់សំណុំរឿងទោះជាក្នុងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីក្តី គេសង្កេតឃើញនូវឯកសារទាំងនោះមានទម្រង់ជាពីរប្រភេទ គឺៈ**ទម្រង់ឯកសារសំណោរទុកដូចជាភស្តុតាងវត្ថុ** និង**ទម្រង់ឯកសារសំណោរទុកដូចជាប្រភេទភស្តុតាងមួយផ្សេងទៀតដោយឯករាជ្យ** ។

## កថាខណ្ឌទី៦. សេចក្តីពន្យល់ផ្ទាល់របស់ជនជាប់ចោទ

សេចក្តីពន្យល់របស់ជនជាប់ចោទគឺ ជាប្រភេទនៃភស្តុតាងមួយប្រភេទដែរ។ ដោយធ្វើការវែកញែកទៅលើអត្ថន័យចំពោះការពន្យល់ និងការបំភ្លឺរបស់ជនជាប់ចោទតាមលក្ខណៈទ្រឹស្តីនៃនីតិវិធីព្រហ្មទណ្ឌ ប្រភេទនៃភស្តុតាងបែបនេះមានខ្លឹមសារដ៏មានសារៈសំខាន់ចំពោះការធ្វើសេចក្តីសម្រេច។ តាមក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់សិទ្ធិខ្លះៗ ដែលជនល្មើសចាំបាច់ត្រូវមានដូចជា៖ សិទ្ធិមិនឆ្លើយ, សិទ្ធិរកមេធាវីជាដើម។ល។ និងដើម្បីគោរពសិទ្ធិគោលដែលមានចែងជាសកលចំពោះជនជាប់ចោទ។ នៅក្នុងភស្តុតាងតុលាការ ការពន្យល់ និងការបំភ្លឺមិនដូចគ្នាទេ ហើយដោយសារភាពមិនដូចគ្នានេះទើបបានជាក្រមនីតិវិធីព្រហ្មទណ្ឌប្រើប្រាស់តែពាក្យថា **«ការបំភ្លឺ»**។

សួរថាតើការពន្យល់ និងការបំភ្លឺរបស់ជនជាប់ចោទវាមានអត្ថន័យដូចគ្នាដែរ ឬទេ? តើការបំភ្លឺ និងការពន្យល់មានការខុសគ្នាអ្វីខ្លះ?

ការបំភ្លឺរបស់ជនជាប់ចោទ គឺជាការបំភ្លឺដែលធ្វើឡើងដោយជនជាប់ចោទទៅលើការសាកសួរយកចំលើយអំពីពតិមានទៅតាមអត្ថិភាពនៃរឿងក្តី ពោលគឺមានន័យថាការរៀបរាប់នូវអង្គហេតុនានាព្រមទាំងពិពណ៌នាអំពីអង្គហេតុ ឬអំពីព្រឹត្តិការណ៍នានាដែលជនល្មើសបានដឹង និងបានធ្វើ។ ជនជាប់ចោទផ្តល់ ការបំភ្លឺមានន័យថា រៀបរាប់នូវរឿងរ៉ាវដែលបានកកើតឡើងនោះមានសភាពយ៉ាងដូចម្តេច? តើជនជាប់ចោទរូបនេះបានធ្វើអ្វីខ្លះ? ហើយអ្វីខ្លះដែលបានកើតឡើង?។ល។ ហើយនៅក្នុងទំនាក់ទំនងនៃការបំភ្លឺរបស់ជនជាប់ចោទនេះ ក៏ត្រូវប្រើប្រាស់វិធានដូចគ្នាទៅនឹងវិធាននៃការបំភ្លឺរបស់សាក្សីផងដែរ។

ចំពោះភាពខុសគ្នារវាងការបំភ្លឺរបស់ជនជាប់ចោទ និងការបំភ្លឺរបស់សាក្សីនៅត្រង់ចំណុចដែលច្បាប់បានបញ្ញត្តិខុសគ្នា (ស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា៩៧, ១៣៣, ១៤៥, ៣០០, ៣០២ និងក្នុងស្មារតីក្រមព្រហ្មទណ្ឌមាត្រា៥៣៩) គឺថាតួនាទីរបស់សាក្សីនៅក្នុងនីតិវិធី គាត់ត្រូវបញ្ចេញឱ្យអស់នូវកាតព្វកិច្ចរបស់គាត់ ស្តែងភាពត្រឹមត្រូវ និងភាពស្មោះត្រង់ជូនទៅស្ថាប័នស៊ើបអង្កេត និងតុលាការអំពីអ្វីៗដែលគាត់បានដឹងទៅលើព្រឹត្តិការណ៍នៃរឿងក្តីនោះ។ ចំណុចនេះបញ្ជាក់ថា សាក្សីគឺជាអ្នកផ្តល់ព័ត៌មានអំពីអង្គហេតុនានា ដែលអង្គហេតុទាំងនោះទាក់ទឹនទៅនឹងការចោទប្រកាន់របស់តំណាងអយ្យការទៅលើបុគ្គលផ្សេងទៀតគឺជនជាប់ចោទនេះឯង។

ចំពោះស្ថានភាពរបស់ជនជាប់ចោទវិញនៅក្នុងនីតិវិធី គឺមានភាពស្មុគស្មាញខ្លាំងជាទីបំផុតដោយសារតែការបំភ្លឺរបស់ជនជាប់ចោទ ពុំអាចធ្វើការប្រៀបធៀបបានជាមួយនឹងការបំភ្លឺរបស់សាក្សីនោះទេ។ ក្នុងន័យនេះ «ជនជាប់ចោទក៏ផ្តល់ការបំភ្លឺអំពីអង្គហេតុនានាដែលជននេះបានដឹងដូចសាក្សីផងដែរ ប៉ុន្តែច្បាប់នីតិវិធីបានកំនត់នូវលក្ខណៈពិសេសរបស់ជនជាប់ចោទនៅត្រង់ថា ជន

ជាប់ចោទគឺជា ប្រធាននៃសកម្មភាពក្នុងនីតិវិធីដែលក្នុងនោះគាត់កាន់កាប់នូវសិទ្ធិជំនួយបាន (មានមេធាវី) ហើយគាត់ក៏អាចការពារខ្លួនប្រឆាំងទៅនឹងការចោទប្រកាន់មកលើរូបគាត់បានផងដែរ»។ ចំពោះសាក្សីវិញគ្មានសិទ្ធិជ្រើសរើសអ្នកតំណាងដូចសិទ្ធិរបស់ជនជាប់ ចោទនោះបានឡើយ។

ភាពខុសគ្នាពីសាក្សីនោះគឺ «ជនជាប់ចោទមិនទទួលខុសត្រូវនូវការបដិសេធចំពោះការផ្ដល់ការបំភ្លឺ និងការផ្ដល់ការបំភ្លឺដោយកុហកនោះទេ ពីព្រោះការផ្ដល់ការបំភ្លឺទាំងឡាយគឺជាសិទ្ធិរបស់ជនជាប់ចោទ ប៉ុន្តែពុំមែនជាកាតព្វកិច្ចរបស់ជនជាប់ចោទនោះឡើយ»។ នៅក្នុងភាពខុសគ្នាមួយទៀតនោះគឺ «ជនជាប់ចោទផ្ដល់ការបំភ្លឺក្នុងរង្វង់តែការចោទប្រកាន់មកលើខ្លួនគាត់ ក្នុងការប្រព្រឹត្តិបទល្មើសតែប៉ុណ្ណោះ» តែសាក្សីវិញគាត់បំភ្លឺបានគ្រប់អ្វីៗទាំងអស់តាមចិត្តចង់។

លក្ខណៈពិសេសរបស់ជនជាប់ចោទនេះត្រូវបានកំនត់ដោយច្បាប់នីតិវិធីនៅត្រង់ថា ការបំភ្លឺរបស់ជនជាប់ចោទមានន័យថា «ជាការផ្ដល់ព័ត៌មានរបស់គាត់អំពីអង្គហេតុទាំងឡាយ, អំពីខណៈនានានៃរឿង ដោយនៅក្នុងពេលជាមួយគ្នានោះជនជាប់ចោទក៏មានការពន្យល់នូវរាល់ការសំដែងចេញឱ្យឃើញទៅលើទំនាក់ទំនងរបស់ជនជាប់ចោទចំពោះការចោទប្រកាន់នោះទៀតផង» ពោលគឺការរៀបរាប់ និងការពន្យល់នៅលាយឡំជាមួយគ្នាមិនអាចកាត់ផ្ដាច់បានឡើយ។

ជនដែលត្រូវបានចោទប្រកាន់ត្រូវផ្ដល់ចំលើយនូវព័ត៌មានផ្សេងៗស្ដីអំពីអង្គហេតុនានាដែលមានខ្លឹមសារសំរាប់រឿងក្ដី។ ប្រសិនបើជនជាប់ចោទទទួលស្គាល់នូវកំហុសរបស់ខ្លួន នោះគាត់រៀបរាប់ និងអធិប្បាយនូវរាល់ខណៈទាំងឡាយដែលគាត់បានប្រព្រឹត្តបទល្មើស ហើយនៅក្នុងពេលនោះដែរជាធម្មតាគាត់នាំមកឱ្យដឹងនូវទឡ្ហីករណ៍ផ្សេងៗយោងទៅលើខណៈទាំងឡាយនោះ ដែលទឡ្ហីករណ៍ទាំងនោះតាមយោបល់របស់គាត់អាចបន្ធូរបន្ថយនូវការទទួលខុសត្រូវរបស់គាត់ឱ្យមានស្ថានភាពសមរម្យ។ ផ្ទុយទៅវិញប្រសិនបើជនជាប់ចោទមិនទទួលស្គាល់នូវកំហុសរបស់គាត់ទេ នោះគាត់នឹងពិពណ៌នា ព្រមទាំងធ្វើឱ្យកាន់តែភ្លឺច្បាស់បន្ថែមទៀតនូវអង្គហេតុនានាដែលបានកើតឡើងនោះថា ពុំមែនជាកំ ហុសរបស់គាត់ទេ ដែលតាមយោបល់របស់ជនជាប់ចោទនាខណៈបែបនេះមានគោលបំណងក្នុងការលើកយកសេចក្ដីយោង ឬសំអាងផ្សេងៗអំពីខណៈនានាមកធ្វើអំណះអំណាងក្នុងន័យដោះសារ ដែលតាមគំនិតរបស់គាត់យល់ថាជាមធ្យោបាយការការពារខ្លួន ពោលគឺគាត់ចាប់យកវិធានការក្នុងវិធីសាស្ត្រធ្វើការរិះគន់ និងធ្វើការបដិសេធន៍ទៅលើការចោទប្រកាន់មកលើរូបគាត់ដោយអះអាងថារាល់សកម្មភាពនៃការចោទប្រកាន់ទាំងអស់របស់អយ្យការ ឬតុលាការគ្មានមូលដ្ឋានភស្តុតាងច្បាស់លាស់នោះទេ។

ដូចនេះហើយអត្ថន័យនៃការពន្យល់របស់ជនជាប់ចោទ និងការបំភ្លឺរបស់ជនជាប់ចោទទាំងពីរនេះវាស្ដែងចេញនូវទិដ្ឋភាពផ្សេងៗពីគ្នា តែស្ថិតក្នុងអត្ថន័យតែមួយប៉ុណ្ណោះគឺ «ការផ្ដល់ព័ត៌មាន

ដែលធ្វើឡើងដោយជនជាប់ចោទទៅតាមការចោទប្រកាន់មកលើខ្លួនគាត់ ហើយដែលអត្ថន័យនេះវាជាប្រភេទនៃភស្តុតាងមួយក្នុងចំណោមភស្តុតាងប្រភេទផ្សេងៗទៀតក្នុងរឿងក្តីព្រហ្មទណ្ឌ»។

តាមទ្រឹស្តីនៃនីតិវិធីព្រហ្មទណ្ឌ ឬក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ជាក់អត្ថន័យមិនខុសគ្នានោះឡើយត្រង់ថា ការបំភ្លឺ និងការពន្យល់របស់ជនជាប់ចោទគឺទុកដូចជាភស្តុតាងដូចប្រភេទនៃភស្តុតាងដទៃទៀតដែរ។ គួរតែចងចាំថា ប្រសិនបើការបំភ្លឺរបស់ជនជាប់ចោទក្លាយជាការពន្យល់ នោះមិនមែនគ្រប់ការពន្យល់របស់ជនជាប់ចោទសុទ្ធតែអាចក្លាយជាការបំភ្លឺទាំងអស់បាននោះទេ។ ជនជាប់ចោទអាចផ្តល់ការពន្យល់ពុំមែននៅក្នុងពេលតុលាការធ្វើសេចក្តីសំរេចនោះទេ តែធ្វើនៅមុនពេលនេះគឺក្នុងដំណាក់កាលស៊ើបអង្កេតបឋមដែលសួរចំលើយទៅលើគាត់ ហើយដូចគ្នានៅក្នុងដំណាក់កាលស៊ើបសួររបស់តុលាការក្នុងការសួរយកចម្លើយដែរ។ ជាឧទាហរណ៍: ជនជាប់ចោទដាក់ពាក្យស្នើសុំឱ្យកោះហៅសាក្សីនានាដើម្បីសួរតទល់ជាដើម។ល។ ឬក៏សួរភាគីនានាដោយធ្វើឡើងដាច់ដោយឡែកៗពីគ្នា(ស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ១៥៣ កថាខណ្ឌទី២ និងមាត្រា ១៣៣)។

ជនជាប់ចោទអាចផ្តល់ការពន្យល់បានផងដែរបន្ទាប់ពីដំណាក់កាលរៀបចំរបស់សវនាការនៃតុលាការ គឺនៅក្នុងពេលសវនាការដេញដោលរបស់ភាគី។ ជាឧទាហរណ៍: ប្រសិនបើជនជាប់ចោទគ្មានអ្នកការពារ(មេធាវី) នោះគាត់ការពារដោយខ្លួនឯងផ្ទាល់ជាដើម។ល។ ហើយពិសេសទៀតនោះការពន្យល់របស់ជនជាប់ចោទកើតមានផងដែរនៅក្នុងសំដីចុងក្រោយនៃពេលសវនាការបានបញ្ចប់ (ស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា៣៣៥ កថាខណ្ឌទី២ វាក្យខណ្ឌទី២)។ ទាំងអស់នេះគឺជាការពន្យល់របស់ជនជាប់ចោទដែលមិនមែនជាការបំភ្លឺនោះទេ ដោយហេតុនេះហើយបានជាការពន្យល់ទាំងអស់ក្នុងខណៈបែបនេះរបស់ជនជាប់ចោទមិនអាចក្លាយជាភស្តុតាងបាននោះទេ។

# ជំពូកទី ២
# នីតិវិធីនៃការប្រមូលភស្តុតាង និងការបង្ហាញភស្តុតាង
## ផ្នែកទី ១. ការស៊ើបអង្កេតស្រាវជ្រាវប្រមូលភស្តុតាង
### កថាខណ្ឌទី១. ការស៊ើបអង្កេតដោយមន្ត្រីនគរបាលយុត្តិធម៌
### ១.១. ការស៊ើបអង្កេតបទល្មើសជាក់ស្តែង ដោយមន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបានពាក្យបណ្តឹងរបស់ជនរងគ្រោះ ឬពីតតិយជនណាក៏ដោយត្រូវតែបើកការស៊ើបអង្កេតភ្លាមៗ ឬបញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យប្តឹងនោះទៅរាជអាជ្ញា ដើម្បីចាត់ការបន្តទៅតាមនីតិវិធី។ មុននឹងធ្វើការស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌ អាចសុំសេចក្តី ណែនាំពីព្រះរាជអាជ្ញាជាមុនសិន។ ចំពោះបណ្តឹងបរិហារដែលមានបង្ហាញមូល ហេតុជាក់លាក់សមហេតុផលនោះមន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា និងទទួលការណែនាំ ។

នៅក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែងនេះ មន្ត្រីនគរបាលយុត្តិធម៌មានកាតព្វកិច្ច ត្រូវរាយការណ៍ជូនទៅព្រះរាជអាជ្ញាក្នុងករណីបទល្មើសឧក្រិដ្ឋ ឬបទល្មើសមជ្ឈិមដើម្បីចុះទៅកន្លែងកើតហេតុ និងធ្វើការពិនិត្យបទល្មើស[4]។

#### ១.១.១. ការចុះទៅកាន់ទីកន្លែងកើតហេតុ

ការចុះទៅកាន់ទីកន្លែងកើតហេតុ ក្នុងករណីនេះមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះទៅកាន់ទីកន្លែងកើតហេតុផ្ទាល់តែម្តង សម្រាប់កិច្ចមួយចំនួនដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវបំពេញរួមមាន ៖

- ឡោមព័ទ្ធទីកន្លែងកើតហេតុ
- អង្កេតពិពណ៌នា ធ្វើកំណត់ហេតុ និងពិនិត្យកន្លែងកើតហេតុផ្តិតយករូបភាពគ្រប់ចំណុច
- សាកសួរសាក្សី (បើមាន)
- ការពារភស្តុតាងដើម្បីប្រមូលឲ្យអស់ (ចៀសវាងធ្វើឲ្យមានការខូចខាត ត្រូវមានការប្រុងប្រយ័ត្ន និងមានពាក់ស្រោមដៃការពារ)
- ឃាត់ខ្លួនជនសង្ស័យប្រសិនបើមាននៅនឹងកន្លែងកើតហេតុ
- សួរចម្លើយជនសង្ស័យ
- ធ្វើកំណត់ហេតុអំពីការស៊ើបអង្កេត

[4] មាត្រា៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ១.១.២. ការធ្វើកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌

ការធ្វើកំណត់ហេតុស្រាវជ្រាវ និងការពិនិត្យរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវបានបែងចែកដូចតទៅ ៖

•កំណត់ហេតុពិនិត្យកន្លែងកើតហេតុត្រូវកត់ត្រានូវព័ត៌មានផ្សេងៗ ហើយពិនិត្យថាកន្លែងកើតហេតុបានរក្សានូវស្ថានភាពដើមឬមានការប្រែប្រួល ប្រសិនបើមានការប្រែប្រួលត្រូវកត់ត្រាថាតើមានការប្រែប្រួលនូវចំណុចអ្វីខ្លះ? ការកត់ត្រានូវបរិយាកាសអាកាសធាតុ ពេលវេលានៃការពិនិត្យវត្តមានអ្នកដែលបានចូលរួមពិនិត្យ ព្រមទាំងធ្វើការពិនិត្យដោយយកចិត្តទុកដាក់គ្រប់សកម្មភាពទាំងអស់ដែលបានកើតឡើងនៅកន្លែងកើតហេតុ

•កំណត់ហេតុពិនិត្យសាកសព ត្រូវពិនិត្យឲ្យបានសព្វគ្រប់លើរាងកាយរបស់សាកសព ពិនិត្យស្លាកស្នាមសាកសព ឆែកឆេរសម្លៀកបំពាក់សាកសពព្រមទាំងធ្វើកំណត់ហេតុដកហូត បើមានលទ្ធភាពត្រូវធ្វើការប៉ាន់ស្មានថាសាកសពស្លាប់នៅពេលណា និងមូលហេតុអ្វី?

•កំណត់ហេតុពិនិត្យរបួសស្នាមជនរងគ្រោះ ឬជនសង្ស័យ

•គូសគំនូសប្លង់នៅនឹងកន្លែងកើតហេតុ

•ផ្តិតយករូបភាព ត្រូវថតយកគ្រប់ទិដ្ឋភាពគ្រប់កន្លែងកើតហេតុ ពិសេសគឺសាកសព របួសស្នាមសាកសពទាំងមូលមុនរំកិលក្រោយរំកិល

កំណត់ហេតុស្តីពីការស្រាវជ្រាវ ជារបាយការណ៍សរុបរបស់មន្ត្រីនគរបាលយុត្តិធម៌ផ្ញើជូនព្រះរាជអាជ្ញា គឺជាការរៀបរាប់អំពីដំណើរការនៃការស៊ើបអង្កេតដែលមានទម្រង់ដូចជាអង្គហេតុចម្លើយជនរងគ្រោះកំណត់ហេតុផ្សេងៗ សេចក្តីសន្និដ្ឋានរបស់អ្នកជំនាញផ្សេងៗ វត្ថុតាង សំណូមពរបណ្តឹង។

### ១.១.៣. វិធាននៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង

### ក. វិធានទាក់ទងនឹងការឆែកឆេរ

មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរក្នុងករណីបទល្មើសជាក់ស្តែង ដែលត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតនោះដោយផ្ទាល់មាត់ក៏ដោយ។ ការឆែកឆេរត្រូវធ្វើកំណត់ហេតុជានិច្ច[5]។

[5] មាត្រា៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ខ. ការបិទស្លាកបោះត្រាលើវត្ថុតាង

ករណីនេះមន្ត្រីនគរបាលយុត្តិធម៌ ដែលចាប់យកវត្ថុតាងបានត្រូវធ្វើកំណត់ហេតុក្រោយពីបានបង្ហាញដល់អ្នកកាន់កាប់ទីកន្លែង វត្ថុតាងត្រូវតែធ្វើការវេចខ្ចប់ និងបិទស្លាកបោះត្រាលើកញ្ចប់វត្ថុតាង បន្ទាប់មកត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃវត្ថុតាងដែលបានចាប់យក។ កំណត់ហេតុនៃការចាប់យកត្រូវមានការចុះហត្ថលេខា ឬផ្ដិតមេដៃពីម្ចាស់ទីកន្លែង ឬសាក្សី ២(ពីរ)នាក់។

### គ. កំណត់ហេតុនៃការស្ដាប់ចម្លើយ

ការសួរចម្លើយជនសង្ស័យត្រូវធ្វើកំណត់ហេតុជានិច្ច។ ការសួរចម្លើយជនសង្ស័យនេះទាមទារឲ្យទទួលបាននូវព័ត៌មានទាំងឡាយ ដែលជននោះបានប្រព្រឹត្តិពីដំណើររឿងទាំងឡាយ ទាំងមុនពេលកើតហេតុ ពេលកើតហេតុ និងក្រោយពេលកើតហេតុ ព្រមទាំងរឿងរ៉ាវនានាផ្សេងៗទៀតដែលទាក់ទងទៅនឹងការស៊ើបអង្កេត។ ការស្ដាប់ចម្លើយជនសង្ស័យត្រូវផ្ទៀងផ្ទាត់ទៅនឹងបទល្មើសព្រមទាំងវត្ថុតាងផ្សេងៗទៀតផងដែរជាពិសេសទាក់ទងទៅនឹងអង្គហេតុដែលមិនប្រែប្រួល។

### ឃ. ការស្ដាប់ចម្លើយជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណី

ការស្ដាប់ចម្លើយរបស់ជនរងគ្រោះ ត្រូវធ្វើការផ្ទៀងផ្ទាត់ទៅនឹងគោលការណ៍មួយចំនួនដែលទាក់ទងទៅនឹងធាតុផ្សំនៃបទល្មើស ភស្តុតាងផ្សេងៗនឹងអង្គហេតុដែលមិនប្រែប្រួល។ សម្រាប់អង្គហេតុមួយចំនួនជនរងគ្រោះបានបាត់បង់ជីវិត និងខ្លះទៀតជនរងគ្រោះជាអនីតិជនតែទោះជាយ៉ាងណាការស្ដាប់ចម្លើយរបស់ជនរងគ្រោះចាំបាច់ត្រូវតែធ្វើ។ ក្នុងករណីនេះប្រសិនបើជនរងគ្រោះស្លាប់ ឬក៏ជាអសមត្ថជនត្រូវស្ដាប់ចម្លើយ សិទ្ធិវ័ន្តរបស់ជនរងគ្រោះសម្រាប់អនីតិជនវិញក៏ដូចគ្នាដែរ ប៉ុន្តែប្រសិនបើជនរងគ្រោះ មានការយល់ដឹងក៏អាចទទួលយកចម្លើយបានផងដែរ។

### ង. ការស្ដាប់ចម្លើយសាក្សី

សាក្សីនៅក្នុងរឿងបទល្មើសរួមមាន ៖

•សាក្សីដែលបានដឹងឮ នឹងបានឃើញនូវព្រឹត្តិការណ៍ នៃបទល្មើសផ្ទាល់ (សាក្សីដោយផ្ទាល់) •សាក្សីដែលបានដឹងឮនឹងបានឃើញត្រឹមតែកាលៈទេសៈនៃបទល្មើស (សាក្សីដោយប្រយោល)

•សាក្សីដែលបានដឹងឮតៗគ្នា (សាក្សីបន្ទាប់បន្សំ)

•សាក្សីជាអ្នកជំនាញ

ការស្តាប់ចម្លើយសាក្សីត្រូវតែទទួលបានព័ត៌មាន ព្រមទាំងធ្វើការផ្ទៀងផ្ទាត់ជាមួយកំណត់ហេតុសួរចម្លើយរបស់ជនសង្ស័យ និងកំណត់ហេតុសួរចម្លើយជនរងគ្រោះផងដែរ។ រាល់ការស្តាប់ចម្លើយសាក្សីត្រូវធ្វើកំណត់ហេតុផងដែរ។

### ច. ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ

ប្រសិនបើមានតម្រូវការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស វិទ្យាសាស្ត្រដែលមិនអាចបង្អង់បានដឹងឮ នឹងបានឃើញមន្ត្រីនគរបាលយុត្តិធម៌អាចពឹងបុគ្គលគ្រប់រូបដែលមានជំនាញទោះបីជាបុគ្គលនោះមិនបានចុះឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញថ្នាក់ជាតិក៏ដោយ[6]។

### ឆ. ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា

ក្រោយពីបានបញ្ចប់ការស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើរបាយការណ៍សំយោគ និងធ្វើរបាយការណ៍បញ្ជូនកំណត់ហេតុទាំងអស់ព្រមទាំងវត្ថុតាង និងជនសង្ស័យទៅកាន់ព្រះរាជអាជ្ញាដើម្បីសម្រេចពីការធ្វើបណ្តឹងអាជ្ញា[7]។

### ១.២. ការស៊ើបអង្កេតបឋមដោយមន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ អាចស៊ើបអង្កេតបឋមដោយខ្លួនឯងបាន ឬតាមការចាត់តាំងរបស់ព្រះរាជអាជ្ញា។ ចំពោះនីតិវិធីស៊ើបអង្កេតបឋម មានលក្ខណៈដូចគ្នាទៅនឹងនីតិវិធីស៊ើបអង្កេតបទល្មើសជាក់ស្តែងដែរ លើកលែងតែចំណុចមួយចំនួនដែលរួមមានដូចខាងក្រោម ៖

- ការឆែកឆេរ (មាត្រា ១១៣ ក្រមនីតិវិធីព្រហ្មទណ្ឌ)
- បទបញ្ជាឲ្យចូលខ្លួន (មាត្រា ១១៤ ក្រមនីតិវិធីព្រហ្មទណ្ឌ)
- ការឃាត់ខ្លួនជនសង្ស័យ (មាត្រា ១១៦ ក្រមនីតិវិធីព្រហ្មទណ្ឌ)

### ១.២.២. កំណត់ហេតុ ឬរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌

កំណត់ហេតុជា លិខិតលាយលក្ខណ៍អក្សរដែលបានកត់ត្រានូវការពិនិត្យ និងលទ្ធផលនៃការស្រាវជ្រាវ។

កំណត់ហេតុត្រូវមានការចុះហត្ថលេខា ឬផ្តិតមេដាយរបស់អ្នកដែលត្រូវធ្វើកំណត់ហេតុ និងអ្នកចូលរួមព្រមទាំងមានការចុះកាលបរិច្ឆេទឲ្យបានត្រឹមត្រូវ និងច្បាស់លាស់ ហើយត្រូវចៀសវាងនូវការឆូតលុប ឬបន្ថែមបន្ថយពាក្យ។ ប្រសិនបើមានការការឆូតលុបឬបន្ថែមបន្ថយពាក្យ ឬសេចក្តី

[6] មាត្រា៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[7] មាត្រា១០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

អ្វីមួយត្រូវចុះនិទ្ទេសបញ្ជាក់ឲ្យបានច្បាស់លាស់នូវការបន្ថែមបន្ថយពាក្យនោះ ដោយមានការចុះហត្ថលេខាទទួលយល់ព្រមពីអ្នកសួរ អ្នកឆ្លើយ និងអ្នកធ្វើកំណត់ហេតុ។

មាត្រា ៧១, ៧២, ៩០, ៩៣, ៩៧, ១១៥, ១៧៨, ១៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិទាក់ទងនឹងការធ្វើកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌។

### ១.២.៣. តម្លៃកំណត់ហេតុ ឬរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌

កំណត់ហេតុ ឬរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ មិនមែនជាមូលដ្ឋាននៃការចោទប្រកាន់ទេ។ កំណត់ហេតុនេះគ្រាន់តែផ្តល់នូវធាតុផ្សំទាំងឡាយនៃបទល្មើសសម្រាប់ធ្វើជាមូលវិចារណ៍របស់ព្រះរាជអជ្ញា ឬចៅក្រមតែប៉ុណ្ណោះ។ កំណត់ហេតុ ឬរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ «ឯកសារដើម» មានន័យថាត្រូវចាត់ទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ។

ភស្តុតាងជួយអាចដាក់ជូនមកចៅក្រមដោយសេរី តាមគ្រប់មធ្យោបាយដែលស្របតាមច្បាប់។ កំណត់ហេតុ ឬរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ កាលបើបានបំពេញគ្រប់ធាតុផ្សំនៃបទល្មើសដែលធ្វើឲ្យព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់ទៅលើជនសង្ស័យបាននោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើរបាយការណ៍សំយោគមួយ សន្និដ្ឋានទៅលើរឿងក្តីនោះ ហើយភ្ជាប់ជាមួយសំណុំរឿងបញ្ជូនទៅការិយាល័យអយ្យការដើម្បីធ្វើការចោទប្រកាន់។

ក្នុងករណីណាក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌មិនមានសិទ្ធិតម្កល់រឿងទុកឥតចាត់ការនូវបណ្តឹងអាជ្ញាដែលខ្លួនបានទទួលឡើយ ទោះបីមានការសម្រុះសម្រួលព្រមព្រៀងគ្នាហើយក៏ដោយ គឺត្រូវធ្វើកំណត់ហេតុបញ្ជូនទៅ ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចជាដរាប។ មន្ត្រីនគរបាលយុត្តិធម៌ដែលទាក់ទងនឹងការស៊ើបអង្កេតរបស់ខ្លួន ត្រូវមកបង្ហាញខ្លួននៅមុខសវនាការក្នុងឋានៈជាសាក្សី។ ការចូលខ្លួនក្នុងសវនាការរបស់មន្ត្រីនគរបាលយុត្តិធម៌មានផលប្រយោជន៍ដូចជា ៖

- ការគោរពតាមនីតិវិធី
- ការរក្សានូវតម្លៃកំណត់ហេតុរបស់ខ្លួន
- ការយល់ពីចំណុចខ្វះខាតរបស់ខ្លួនក្នុងការបំពេញភារកិច្ច

## ១.៣. ការរំលោភនីតិវិធី

រាល់ភ្នាក់ងារសាធារណៈរួមទាំងមន្ត្រីនគរបាលយុត្តិធម៌ផងដែលបានរំលោភលើនីតិវិធី ឬសិទ្ធិបុគ្គលដូចមានចែងនៅក្នុងនីតិវិធីណាមួយនេះជាបទល្មើសប្រឆាំងនឹងសិទ្ធិបុគ្គលដែលអាចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ៥ឆ្នាំ។

នៅក្នុងការអនុវត្តមុខងារ ឬការបំពេញការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្ថិតក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍[8]។ ដោយមានការរាយការណ៍ពីព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ។

## ១.៤. ការស្រាវជ្រាវ និងប្រមូលភស្តុតាងដោយតំណាងអយ្យការ

ព្រះរាជអាជ្ញាមានតួនាទី ដឹកនាំមន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ដែលស្ថិតក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងការស៊ើបអង្កេតបឋមផងដែរ[9]។

ព្រះរាជអាជ្ញាជាដើមម្ចាស់នៃដើមបណ្តឹងអាជ្ញា មានន័យថាមានតែព្រះរាជអាជ្ញាទេដែលជាម្ចាស់នៃបណ្តឹងអាជ្ញា ចំណែកជនរងគ្រោះគ្រាន់តែជាដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះក្នុងរឿងក្តីព្រហ្មទណ្ឌ[10]។

ក្នុងរឿងរដ្ឋប្បវេណីមួយចំនួនដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬទាក់ទងនឹងប្រយោជន៍អនីតិជន ឬអសមត្ថជន។ល។ នោះតំណាងអយ្យការត្រូវតាំងខ្លួនជាគូក្តីដើមវិញ។ ក្នុងករណីនេះតំណាងអយ្យការត្រូវចាត់ការដោយខ្លួនឯង។

ព្រះរាជអាជ្ញា ជាអ្នកដឹកនាំនិងសម្របសម្រួលលើប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅលើនីតិវិធី និងវិធាននៃការស៊ើបអង្កេតដើម្បីធានាការចោទប្រកាន់ និងការបំពេញនីតិវិធីឲ្យមានប្រសិទ្ធភាព។

រឿងក្តីព្រហ្មទណ្ឌអាចចូលទៅកាន់ព្រះរាជអាជ្ញាតាមវិធី ៤ យ៉ាង ៖

- តាមរយៈមន្ត្រីនគរបាលយុត្តិធម៌
- ពីជនរងគ្រោះ សាច់ញាតិរបស់ជនរងគ្រោះ ឬតាមរយៈបណ្តឹងបរិហារ
- ពីមន្ត្រីមានសមត្ថកិច្ចចាត់ការរឿងព្រហ្មទណ្ឌ[11]
- ពីការផ្ទេរសមត្ថកិច្ច ពីតុលាការផ្សេងដែលមិនមែនជាសមត្ថកិច្ច

ពេលទទួលបានពាក្យបណ្តឹង ឬសុំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញាត្រូវពិនិត្យមើលលើករណីដែលបានប្តឹងមកខ្លួននោះ ដើម្បីសម្រេចចាត់ការទៅតាមនីតិវិធី។

---

[8] មាត្រា៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[9] មាត្រា៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[10] មាត្រា៧ និងមាត្រា២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[11] មាត្រា៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ១.៤.១. ការចុះដល់កន្លែងកើតហេតុ

ក្នុងប្រព័ន្ធច្បាប់ដែលមានចៅក្រមស៊ើបសួរ ការស៊ើបសួររបស់ចៅក្រមស៊ើបសួរ គឺមានសារៈសំខាន់ដើម្បីជាមូលដ្ឋានក្នុងការជំនុំជម្រះក្តីដោយចៅក្រមជំនុំជម្រះនោះ។ ជាពិសេសចំពោះបទល្មើសឧក្រិដ្ឋ ការស៊ើបសួរត្រូវតែធ្វើក្នុងករណីដែលមានបទឧក្រិដ្ឋជាក់ស្តែងកើតឡើង ហើយប្រសិនបើចៅក្រមស៊ើបសួរមិនទាន់ទទួលរឿងនៅឡើយទេ ព្រះរាជអាជ្ញាអាចចេញដីកានាំខ្លួនជនសង្ស័យបាន។ ព្រះរាជអាជ្ញាអាចសួរចម្លើយជនសង្ស័យភ្លាម ក្នុងករណីដែលមានមេធាវីអមជាមួយ ព្រះរាជអាជ្ញាត្រូវសួរនៅចំពោះមុខមេធាវីនោះតែម្តង[12]។

ព្រះរាជអាជ្ញាអាចសួរចម្លើយសាក្សីដែលមានវត្តមាននៅនឹងកន្លែងកើតហេតុ និងចេញដីកាចាត់វិធានការបណ្តោះអាសន្នទាំងឡាយ ដើម្បីជានារក្សាឲ្យបាននូវមុខសញ្ញា ឬភស្តុតាងផ្សេងៗ។ ហើយព្រះរាជអាជ្ញាក៏មានសិទ្ធិហាមមិនឲ្យជនទាំងឡាយចេញពីកន្លែងកើតហេតុផងដែរ។

ព្រះរាជអាជ្ញាអាចចូលពិនិត្យនៅក្នុងផ្ទះជនសង្ស័យ ហើយធ្វើការរឹបអូសយកវត្ថុតាងទាំងឡាយចាំបាច់សម្រាប់បំភ្លឺការពិត។

ព្រះរាជអាជ្ញាមានសិទ្ធិស្នើឲ្យអ្នកបច្ចេកទេសវាយតម្លៃលើវត្ថុតាងអ្វីមួយដែលយល់ឃើញថាចាំបាច់។ ក្នុងនោះព្រះរាជអាជ្ញាក៏មានសិទ្ធិហាមមិនឲ្យជនទាំងឡាយចេញពីកន្លែងកើតហេតុផងដែរ។

### ១.៤.២. ការចាត់ឲ្យស៊ើបអង្កេតបឋម

តំណាងអយ្យការពុំមានសិទ្ធិ ធ្វើការស៊ើបអង្កេតបឋម ចំពោះបទល្មើសលហុ មជ្ឈិម ឧក្រិដ្ឋមិនជាក់ស្តែងតាមរយៈបណ្តឹងផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណីបាននោះទេ។ ក្នុងករណីដែលព្រះរាជអាជ្ញាទទួលបានបណ្តឹងផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោះព្រះរាជអាជ្ញាត្រូវបង្គាប់ទៅមន្ត្រីនគរបាលយុត្តិធម៌ ឲ្យបើកការស៊ើបអង្កេតបឋមដើម្បីកសាងសំណុំរឿងជាមុនសិន[13]។

### ១.៤.៣. ការចាត់ឲ្យស៊ើបសួរដោយតំណាងអយ្យការ

ដើម្បីមានមូលដ្ឋាន សម្រាប់ធ្វើបណ្តឹងអាជ្ញាតំណាងអយ្យការមានសិទ្ធិសួរយកព័ត៌មានបន្ថែមដោយខ្លួនឯង ឬបង្គាប់ទៅមន្ត្រីនគរបាលយុត្តិធម៌ឲ្យនូវព័ត៌មានបន្ថែមមកឲ្យខ្លួនករណីនេះ តំណាងអយ្យការត្រូវចេញដីកាបង្គាប់ឲ្យស៊ើបសួរបន្ថែម[14]។

[12] មាត្រា១៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[13] មាត្រា១១១នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[14] មាត្រា៣៧ និងមាត្រា៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ក្នុងពេលដែលតំណាងអយ្យការពិនិត្យឃើញថា សំណុំរឿងដែលស៊ើបសួរដោយចៅក្រមស៊ើបសួរមិនទាន់មូលសព្វគ្រប់ ដែលអាចធ្វើបណ្តឹងអាជ្ញាបានតំណាងអយ្យការត្រូវចាត់ឲ្យចៅក្រមស៊ើបសួរ ស៊ើបសួរបន្ថែមនូវចំណុចខ្វះខាតទាំងឡាយបាន[15]។

តំណាងអយ្យការអាចធ្វើបណ្តឹងអាជ្ញាបានដែលមានដូចខាងក្រោម ៖

### ក. ដីការសន្និដ្ឋានចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធីមួយដែលព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ ហើយបញ្ជូនជនជាប់ចោទទៅចំពោះមុខតុលាការ ដើម្បីធ្វើការជំនុំជម្រះផ្ទាល់តែម្តងពោលគឺមិនចាំបាច់ឆ្លងកាត់នីតិវិធីស៊ើបសួររបស់ចៅក្រមស៊ើបសួរឡើយ។

តំណាងអយ្យការអាចប្រើនីតិវិធីនេះបានតែក្នុងករណីដែលសំណុំរឿងមូលសព្វគ្រប់ហើយ ដែលបទល្មើសមានធាតុផ្សំគ្រប់គ្រាន់ និងកាលបើជនជាប់ចោទនោះត្រូវទទួលទោសដាក់ពន្ធនាគារដែលអតិបរមានៃទោសមិនលើសពី ១ឆ្នាំ។ សម្រាប់បទល្មើសដែលមានចែងក្នុងច្បាប់ជលផល រុក្ខាប្រមាញ់ គយ ពន្ធដា នឹងច្បាប់ស្តីពីការងារ ក៏អាចត្រូវបានចោទប្រកាន់ដោយប្រើប្រាស់នីតិវិធីបញ្ជូន ទៅជម្រះផ្ទាល់នេះបានដែរ។

### ខ. ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ដីការបញ្ជូនរឿងឲ្យស៊ើបសួរ គឺជាលិខិតលាយលក្ខណ៍អក្សររបស់ព្រះរាជអាជ្ញា ដែលប្តឹងសុំឲ្យចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរទៅលើបទល្មើសណាមួយជាកំណត់។

នៅពេលដែលបានទទួលបណ្តឹង ជាបទល្មើសឧក្រិដ្ឋ ឬមជ្ឈមក៏ដោយព្រះរាជអាជ្ញាត្រូវតែស្នើសុំការអង្កេតភ្លាម មានន័យថាព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានមួយហៅថាដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ហើយបញ្ជូនដីកានោះទៅឲ្យចៅក្រមស៊ើបសួរដោយធ្វើការវាយតម្លៃអំពីសេចក្តីសង្ខេបនៃអង្គហេតុបទល្មើសបញ្ជាក់ពីអត្ថបទច្បាប់ និងចង្អុលឲ្យចំនួរជនដែលប្រព្រឹត្តបទល្មើសផងដែរ[16]។ ក្នុងករណីបទឧក្រិដ្ឋការធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរជាការចាំបាច់ រីឯបទល្មើសមជ្ឈមការធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដោយចាំបាច់ គឺសម្រាប់តែបទល្មើសមជ្ឈឹមណាដែលត្រូវផ្តន្ទាទោសដាក់ពន្ធធានាគារលើសពី ១ឆ្នាំ ហើយមិនមែនជាបទល្មើសមជ្ឈិមជាក់ស្តែងប៉ុណ្ណោះ។ ចំណែកឯបទល្មើសមជ្ឈិមដែលមានកម្រិតអតិបរមានៃទោស ១ឆ្នាំចុះ មានកំណត់ហេតុធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ប៉ុន្តែមិនទាន់មានភស្តុតាងគ្រប់គ្រាន់ទៅលើសហចារី ឬជនសមគំនិតក៏ត្រូវសុំទៅចៅក្រមស៊ើបសួរធ្វើការស៊ើបអង្កេតដែរ ប្រសិនបើបទល្មើសមជ្ឈឹមនោះមាន

[15] មាត្រា១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[16] មាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ទំនាក់ទំនងជាមួយនឹងបទល្មើសអាជ្ញាផ្សេងទៀតដែលមិនទាន់មានភស្តុតាងគ្រប់គ្រាន់ អាចបញ្ជូនទៅតុលាការដើម្បីជំនុំជម្រះជាមួយគ្នាបាន។

### គ. ដីកាសន្និដ្ឋានស្ថាពរ

ដីកាសន្និដ្ឋានស្ថាពរ ជាលិខិតលាយលក្ខណ៍អក្សរដែលព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានទៅលើសំណុំរឿងណាមួយប្តឹងទៅចៅក្រមស៊ើបសួរវិញ បន្ទាប់ពីបានទទួលដីកាជូនរឿងទៅពិនិត្យរបស់ចៅក្រមស៊ើបសួរ។

ដីកានេះព្រះរាជអាជ្ញាត្រូវធ្វើក្នុងរយៈពេល ១៥ថ្ងៃ ប្រសិនបើជនជាប់ចោទត្រូវបានឃុំខ្លួន និង១ខែ ប្រសិនបើជនជាប់ចោទនៅក្រៅឃុំគិតចាប់ពីថ្ងៃដែលទទួលបានសំណុំរឿងពីចៅក្រមស៊ើបសួរតាមរយៈដីកាជូនរឿងទៅពិនិត្យនោះ [17] ។ ក្នុងករណីនេះប្រសិនបើព្រះរាជអាជ្ញាយល់ថាសំណុំរឿងមិនទាន់មានលក្ខណៈមូលគ្រប់គ្រាន់អាចចោទប្រកាន់បាន ព្រះរាជអាជ្ញាអាចស្នើសុំទៅឲ្យបំពេញកិច្ចស៊ើបសួរជាថ្មីទៀត។

## កថាខណ្ឌទី២. ការស្រាវជ្រាវ និងប្រមូលភស្តុតាងដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរ អាចបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ថាមានប្រយោជន៍សម្រាប់បង្ហាញឲ្យឃើញនូវការពិត ប៉ុន្តែរាល់ការបំពេញកិច្ចស៊ើបសួរទាំងនេះត្រូវគោរពទៅតាមច្បាប់កំណត់។

ចៅក្រមស៊ើបសួរជាចៅក្រមដែលស្ថិតនៅក្នុងស្ថាប័ន តុលាការដំបូងរាជធានីខេត្តណាមួយ ឬតុលាការយោធា ដែលទទួលមុខនាទីស៊ើបសួរលើសំណុំរឿងណាមួយតាមការចាត់តាំងរបស់ប្រធានតុលាការណាមួយនោះ។ ប្រធានតុលាការ ក៏អាចចាត់តាំងខ្លួនឯងជាចៅក្រមស៊ើបសួរបានផងដែរ[18]។

ចៅក្រមស៊ើបសួរ ដែលទទួលបានការស៊ើបសួរលើសំណុំរឿងព្រហ្មទណ្ឌណាមួយ ហើយចៅក្រមនោះពុំអាចធ្វើការជំនុំជម្រះលើរឿងក្តីខ្លួនបានទទួលភារកិច្ចស៊ើបសួរនោះបានឡើយ។

ការណ៍នេះដោយសារថា ចៅក្រមស៊ើបសួរមានតួនាទីស៊ើបសួរស្វែងរកការពិតដោយប្រមែប្រមូលនូវភស្តុតាងទាំងឡាយ ទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុកដើម្បីបញ្ជាក់ និងកំណត់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ[19]។

[17] មាត្រា២៤៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[18] មាត្រា៥១នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[19] មាត្រា១២៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

នៅពេលដែលចៅក្រមស៊ើបសួរមានសមត្ថកិច្ច បានទទួលពាក្យបណ្តឹងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ឬពីជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌណាមួយដោយការតាំងខ្លួនឯងជាដើមបណ្តឹងរដ្ឋប្បវេណីផ្ទាល់ ឬក៏បានដាក់ពាក្យបណ្តឹងតាមរយៈមេធាវីរបស់ខ្លួន នោះ ចៅក្រមស៊ើបសួរត្រូវការកត់សម្គាល់មើលនូវពាក្យបណ្តឹងនោះ ដើម្បីចាត់វិធានការបញ្ជូនបណ្តឹងនេះទៅឲ្យព្រះរាជអាជ្ញាឲ្យស្របតាមនីតិវិធី។

## ២.១. ដំណើរការស៊ើបសួរ

ចំពោះបទល្មើសឧក្រិដ្ឋការស៊ើបសួរត្រូវតែធ្វើឡើងដោយខានមិនបានឡើយ រីឯបទល្មើសមជ្ឈិមវិញការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បានដែរ។

**វិសាលភាពនៃបណ្តឹង៖** ចៅក្រមស៊ើបសួរមិនអាចធ្វើការស៊ើបសួរអ្វីបានទេ ប្រសិនបើមិនបានទទួលដីកាសន្និដ្ឋាន បញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការទេនោះ។ ទោះបីជាចៅក្រមស៊ើបសួរបានទទួលផ្ទាល់នូវពាក្យបណ្តឹងណាមួយដោយខ្លួនឯងក៏ដោយ ក៏ចៅក្រមស៊ើបសួរនេះមិនអាចចាត់វិធានការស៊ើបសួរអ្វីបន្តិចបន្តួចបានដែរ ពោលគឺត្រូវតែបញ្ជូនពាក្យបណ្តឹងនោះព្រមទាំងលិខិតនានា ដែលមានភ្ជាប់មកជាមួយទៅព្រះរាជអាជ្ញាដើម្បីធ្វើការចោទប្រកាន់ជាមុនសិន។

ក្រៅពីនេះថ្វីត្បិតតែចៅក្រមស៊ើបសួរ បានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញា ហើយក៏ដោយក៏ចៅក្រមស៊ើបសួរមិនអាចពន្លាតនូវការស៊ើបសួររបស់ខ្លួនឲ្យហួសពីការបញ្ជាក់ច្បាស់លាស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញាបានឡើយ។

ដូច្នេះក្នុងករណីដែលស៊ើបសួរកំពុងធ្វើការស៊ើបសួរ ហើយបានរកឃើញអំពើណាមួយថាជាបទល្មើសព្រហ្មទណ្ឌមួយផ្សេងទៀតលេចឡើង ករណីនេះចៅក្រមស៊ើបសួរពុំអាចចាត់វិធានការស៊ើបសួរនេះបានឡើយលុះត្រាតែមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីមួយទៀតរបស់ព្រះរាជអាជ្ញា។ ប៉ុន្តែប្រសិនបើអំពីថ្មីនោះគ្រាន់តែជាស្ថានទម្ងន់ទោសទៅលើបទល្មើស ដែលកំពុងធ្វើការស៊ើបសួរនោះចៅក្រមស៊ើបសួរមិនចាំបាច់មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីមួយទៀតឡើយ។

## ២.២. ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យ

នៅពេលដែលចៅក្រមស៊ើបសួរ ទទួលបាននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញាដោយមានចង្អុលបង្ហាញប្រាប់អត្តសញ្ញាណរបស់បុគ្គលណាម្នាក់នោះ ចៅក្រមស៊ើបសួរត្រូវដាក់បុគ្គលនោះឲ្យស្ថិតក្រោមការត្រួតពិនិត្យ។ ចៅក្រមស៊ើបសួរក៏មានសិទ្ធិអំណាចដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យនូវបុគ្គលច្រើនរូប ដែលមានតម្រុយច្បាស់លាស់ជាប់ពាក់ព័ន្ធ ហើយស៊ីចង្វាក់គ្នាថានឹងបានចូលរួមប្រព្រឹត្តបទល្មើសតែមួយជាមួយគ្នា ទោះបីជាគ្មានការចង្អុលបង្ហាញប្រាប់

ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏ដោយហើយចៅក្រមស៊ើបសួរ អាចដាក់បុគ្គលទាំងនោះឲ្យស្ថិតក្រោមការពិនិត្យក្នុងឋានៈជាចារី សហចារី ជាអ្នកផ្ដើមគំនិត ឬជាអ្នកសមគំនិត។

## ក. ករណីគ្មានខ្លួន

ក្រោយពីស៊ើបសួរមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់គ្នាខ្លាំង ចៅក្រមស៊ើបសួរត្រូវប្រើវិធានការនិរន្តរាយណាមួយដែលសមស្របតាមស្ថានភាពនៃរឿង (ដីកាបង្គាប់ឲ្យចូលខ្លួនដីកាបង្គាប់ឲ្យនាំខ្លួន ឬដីកាបង្គាប់ឲ្យចាប់ខ្លួន)។

•ដីកាបង្គាប់ឲ្យចូលខ្លួន ជាដីកាដែលបញ្ជាឲ្យបុគ្គលបុគ្គលណាម្នាក់ចូលទៅបង្ហាញខ្លួនមុខចៅក្រមស៊ើបសួរ។ ដីកានេះអាចចេញទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។

•ដីកាបង្គាប់ឲ្យនាំខ្លួនជាដីកាដែលបញ្ជាឲ្យកងកម្លាំងសាធារណៈឲ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ។ ដីកានេះអាចចេញទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។ ប៉ុន្តែមុននឹងចេញដីការបង្គាប់ឲ្យចាប់ខ្លួនត្រូវតែទទួលយោបល់ពីព្រះរាជអាជ្ញាជាមុនសិន។

•ដីកាបង្គាប់ឲ្យចាប់ខ្លួនជាដីកាដែលចេញទៅលើជនជាប់ចោទជនត្រូវចោទ ឬបុគ្គលណាមួយដែលមានតម្រុយពិរុទ្ធភាព។ ករណីដែលអាចចេញដីកានេះបានលុះត្រាតែ ៖

១.បទល្មើសដែលចោទប្រកាន់ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ។

២.បុគ្គលដែលបានគេចខ្លួន ដែលពុំដឹងថាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

## ខ. ករណីមានខ្លួន

លដែលជនត្រូវចោទបង្ហាញខ្លួនជាលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណជនត្រូវចោទប្រាប់ជននេះឲ្យបានដឹងអំពីរឿងរ៉ាវដែលគេបានធ្វើការចោទប្រកាន់មកលើខ្លួន និងប្រាប់ពីឈ្មោះបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្តដែលបានកំណត់ដោយច្បាប់នោះ។ ចៅក្រមស៊ើបសួរត្រូវប្រាប់ជនត្រូវចោទថា ខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី។ ចៅក្រមស៊ើបសួរត្រូវប្រាប់ជនចោទឲ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬការស្នើសុំឲ្យមានការចាត់តាំងមេធាវីឲ្យខ្លួនដោយអនុវត្តតាមច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។ ចំពោះអនីតិជនត្រូវតែមានមេធាវីអមជានិច្ច។ ប្រសិនបើចៅក្រមស៊ើបសួរមានបំណងដាក់ជនជាប់ចោទឲ្យនៅក្រៅឃុំ ឬដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការនោះ ជននោះត្រូវប្រាប់ចៅក្រមស៊ើបសួរអំពីអាស័យដ្ឋានរបស់

ខ្លួន និងត្រូវជូនព័ត៌មានទាំងឡាយដល់ចៅក្រមស៊ើបសួរ ប្រសិនបើមានការផ្លាស់ប្តូរអាស័យដ្ឋានទៅកាន់ទីកន្លែងផ្សេងទៀត។

## ២.៣. ការឃុំខ្លួនបណ្តោះអាសន្ន

ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព ប៉ុន្តែក្នុងករណីពិសេសជនត្រូវចោទអាចឃុំខ្លួនបណ្តោះអាសន្នដែលអាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់បានកំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ឆ្នាំ។

ប្រសិនបើសម្រេចឃុំខ្លួនជនត្រូវចោទ ជាបណ្តោះអាសន្ននោះ ចៅក្រមស៊ើបសួរត្រូវធ្វើ ៖

•កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ

•ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

•ដីការបង្គាប់ឲ្យឃុំខ្លួន

ទោះបីជាព្រះរាជអាជ្ញាមិនឯកភាព ហើយប្តឹងឧទ្ធរណ៍ក៏នៅតែត្រូវយកជនត្រូវចោទទៅឃុំខ្លួនដដែល ដោយរង់ចាំការសម្រេចរបស់សភាស៊ើបសួរជាក្រោយ។

ចំពោះអនីតិជនដែលមានអាយុក្រោម ១៥ឆ្នាំមិនអាចឃុំខ្លួនបណ្តោះអាសន្នបានឡើយ។ ប្រសិនបើសម្រេចមិនឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ននោះ ចៅក្រមស៊ើបសួរត្រូវធ្វើ៖

•ការដាក់ឲ្យស្ថិតក្រោមការត្រួតពិត្យរបស់តុលាការសម្រាប់ "បទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ" ដោយកំណត់ឲ្យគោរពនូវកាតព្វកិច្ចមួយ ឬច្រើន។ ចំពោះអនីតិជនដែលមានអាយុក្រោម ១៥ឆ្នាំ មិនអាចឃុំខ្លួនបណ្តោះអាសន្នបានឡើយ។

•ដីការសម្រេចមិនឃុំខ្លួនៈ ត្រូវធ្វើឡើងក្នុងរយៈពេល ៥ថ្ងៃ "ដោយគ្មានសំអាងហេតុ" ប្រសិនបើមានការស្នើសុំឲ្យឃុំខ្លួនពីព្រះរាជអាជ្ញាតាមរយៈដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

## ២.៤. ការសួរចម្លើយ និងការស្តាប់ចម្លើយ

### ២.៤.១. ការសួរចម្លើយជនត្រូវចោទ

ប្រសិនបើជនត្រូវចោទមានមេធាវី ចៅក្រមស៊ើបសួរអាចសួរចម្លើយបានតែនៅចំពោះមុខមេធាវីតែប៉ុណ្ណោះ ការកោះហៅមេធាវីត្រូវធ្វើមុនយ៉ាងតិច ៥ថ្ងៃមុនការសាកសួរជនត្រូវចោទ ប៉ុន្តែចៅក្រមស៊ើបសួរក៏អាចសួរជនត្រូវចោទដោយគ្មានវត្តមានមេធាវីផងដែរ ប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយមិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអោយសួរចម្លើយជនត្រូវចោទដោយគ្មានវត្តមានមេធាវី។ ក្នុងករណីពិសេស ចៅក្រមស៊ើបសួរអាចសួរជនត្រូវចោទដោយមិនចាំបាច់កោះហៅមេធាវី ប្រសិនបើជនត្រូវចោទបោះបង់ចោលយ៉ាងជាក់

លាក់នូវវត្តមានរបស់មេធាវីខ្លួន "ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុមួយផ្សេងទៀតពីកំណត់ហេតុសួរចម្លើយនេះ"។ ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរដោយមិនបាច់មានការកោះហៅមេធាវីបានដែរ ភាពបន្ទាន់នេះដោយសារតែមានគ្រោះថ្នាក់ដល់ស្លាប់ ចំពោះជនត្រូវចោទដែលមានការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង ប្រភេទនៃភាពបន្ទាន់នេះត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុ។

ចំពោះព្រះរាជអាជ្ញា និងមេធាវីវិញក៏អាចលើកជាសំណួរបានដែរ ប៉ុន្តែត្រូវមានការអនុញ្ញាតពីចៅក្រមស៊ើបសួរជាមុនសិន ទើបអាចសួរជនត្រូវចោទបាន។ ប្រសិនបើចៅក្រមស៊ើបសួរមិនអនុញ្ញាតទេនោះត្រូវចុះក្នុងនិទ្ទេសនៅក្នុងកំណត់ហេតុ។

### ២.៤.២. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីមានមេធាវីអមនោះ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយបានតែនៅចំពោះមុខមេធាវីប៉ុណ្ណោះ (ការកោះហៅមេធាវីត្រូវធ្វើមុនយ៉ាងតិច ៥ថ្ងៃមុនការស្តាប់ចម្លើយ)។

ចៅក្រមស៊ើបសួរក៏អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយគ្មានវត្តមានមេធាវីផងដែរក្នុងករណី ៖

- កោះហៅត្រឹមត្រូវហើយ តែមេធាវីមិនបានចូលតាមពេលវេលាកំណត់ (ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសពីការអវត្តមាននេះក្នុងការកំណត់ហេតុស្តាប់ចម្លើយនោះ)។
- ដើមបណ្តឹងរដ្ឋប្បវេណីបោះបង់ចោលនូវសិទ្ធមានមេធាវីនេះ (ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ ហេតុមួយផ្សេងទៀតពីកំណត់ហេតុស្តាប់ចម្លើយនេះ)។
- ករណីបន្ទាន់ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដោយមិនបាច់មានការកោះហៅមេធាវីក៏បានដែរ។ ភាពបន្ទាន់នេះដោយសារតែមានគ្រោះថ្នាក់ដល់ស្លាប់ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលមានការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង (ប្រភេទនៃភាពបន្ទាន់នេះត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុ)។

ចំពោះព្រះរាជអាជ្ញា និងមេធាវីវិញក៏អាចលើកជាសំណួរបានដែរ ប៉ុន្តែត្រូវមានការអនុញ្ញាតពីចៅក្រមស៊ើបសួរជាមុនសិន ទើបអាចសួរដើមបណ្តឹងរដ្ឋប្បវេណីបាន។ ប្រសិនបើចៅក្រមស៊ើបសួរមិនអនុញ្ញាតទេនោះ ត្រូវចុះក្នុងនិទ្ទេសនៅក្នុងកំណត់ហេតុ។

### ២.៤.៣. ការស្តាប់ចម្លើយសាក្សី

ចៅក្រមស៊ើបសួរ អាចមានសិទ្ធិស្តាប់ចម្លើយចំពោះជនគ្រប់រូបដែលខ្លួន យល់ឃើញថាអាចមានប្រយោជន៍ក្នុងការសំដែងឲ្យឃើញការពិតនោះ។ ចៅក្រមស៊ើបសួរធ្វើការស្តាប់ចម្លើយសាក្សីដាច់ដោយឡែកពីគ្នាដោយគ្មានវត្តមានជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ប៉ុន្តែចៅក្រមស៊ើបសួរក៏អាចធ្វើការសួរតទល់គ្នារវាងជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីរួមជាមួយគ្នាបានផងដែរ។ បុគ្គលគ្រប់រូបដែលត្រូវបានចៅក្រមស៊ើបសួរបានកោះហៅឲ្យចូលមកបង្ហាញខ្លួនក្នុងឋានៈជាសាក្សីនោះ ត្រូវតែមកបង្ហាញខ្លួនភ្លាម ប្រសិនបើរឹងទទឹងនោះ ចៅក្រមស៊ើបសួរអាចសុំឲ្យកម្លាំងសាធារណៈបង្ខំឲ្យចូលខ្លួនបានផងដែរ។

ដើម្បីគោរពនូវសិទ្ធិការពារខ្លួនចៅក្រមស៊ើបសួរ មិនអាចស្តាប់ចម្លើយបុគ្គលណាមួយក្នុងឋានៈជាសាក្សីដែលមានតម្រុយពិរុទ្ធភាពថាបានប្រព្រឹត្តបទល្មើសនោះទេ ប្រសិនបើមានករណីនេះកើតឡើង ចៅក្រមស៊ើបសួរត្រូវដាក់បុគ្គលនោះឲ្យស្ថិតក្រោមការត្រួតពិនិត្យវិញ។

## ២.៥. ការឆែកឆេរ និងការចាប់យកវត្ថុតាង

ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបានដោយគោរពនូវវិធានការអនុវត្តចំពោះមុខ។ មានន័យថា ចៅក្រមស៊ើបសួរត្រូវធ្វើការឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង តែប្រសិនបើពុំមានវត្តមានអ្នកកាន់កាប់ទីកន្លែង ការឆែកឆេរត្រូវធ្វើឡើងនៅចំពោះមុខសាក្សី ២នាក់ដែលខ្លួនបានចាត់តាំង។ ការឆែកឆេរធ្វើបានចាប់ពីម៉ោង ៦ព្រឹក ដល់ម៉ោង ១៨ល្ងាចប៉ុណ្ណោះ លើកលែងតែករណី៖

- ឆែកឆេរនៅទីកន្លែងដែលបើកចំហរដល់សាធារណៈជន
- ឆែកឆេរនៅទីកន្លែងដែល ផលិត រក្សាទុក ចែកចាយ ឬប្រើប្រាស់គ្រឿងញៀន។

រាល់វត្ថុតាងដែលធ្វើការចាប់យកនៅទីកន្លែងឆែកឆេរត្រូវតែបិទស្លាក បោះត្រា លើវត្ថុតាងទាំងនោះ និងធ្វើកំណត់ហេតុស្តីពីការចាប់យកវត្ថុតាង ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលបានចាប់យកនោះផងដែរ។ នៅពេលដែលមិនទាន់ចេញដីកាដំណោះស្រាយទេនោះ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចប្រគល់សងនូវវត្ថុដែលចាប់បានទៅម្ចាស់ដើមវិញ កាលណាពុំមានការជំទាស់អ្វីប្រាកដប្រជាទេ ក្រោយពីទទួលមតិពីព្រះរាជអាជ្ញា។

### ២.៥.១. ការស្តាប់ទូរស័ព្ទ

ប្រសិនបើមានភាពចាំបាច់ដើម្បីបង្ហាញឲ្យឃើញនូវការពិតនោះ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យស្តាប់ និងថតការសន្ទនាតាមទូស័ព្ទបាន "ទោះបីជាកន្លែងយោធាក៏ដោយ"។ ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឲ្យចាប់ និងថតរាល់ការឆ្លើយឆ្លងគ្នាតាមមធ្យោបាយទូរគមនាគមន៍បានផងដែរដូចជាសារតាមទូរសារ ឬសារតាមបណ្តាញអ៊ិនធើណែត (Internet)ជាដើម។ ម៉្យាងវិញទៀត ចៅក្រម

ស៊ើបសួរអាចសុំឲ្យគ្រប់អង្គភាពសាធារណៈ ឬមន្ត្រីជំនាញទាំងអស់ ដើម្បីធ្វើការតាំង ឧបករណ៍បច្ចេកទេស និងធ្វើការថតចាប់យកសម្លេងក្នុងអំឡុងពេលបំពេញភារកិច្ចរបស់ខ្លួន តាមការចាត់តាំងនៃពាក្យស្នើសុំរបស់ចៅក្រមស៊ើបសួរនោះ។ ដើម្បីជាប្រយោជន៍ក្នុងការបង្ហាញ**ភស្តុតាង**អង្គភាពសាធារណៈ ឬមន្ត្រីជំនាញទាំងអស់ក៏មានសិទ្ធិជូននូវព័ត៌មានលំបាក ដែលអាចកើតមានជាយថាហេតុក្នុងពេលបំពេញភារកិច្ចដល់ចៅក្រមស៊ើបសួរផងដែរ។

## ២.៦. ដីកាចាត់ឲ្យស៊ើបសួរជំនួស

ដីកាចាត់ឲ្យស៊ើបសួរជំនួស ត្រូវបញ្ជាក់អំពីប្រភេទកិច្ចដែលត្រូវធ្វើការស៊ើបសួរ កិច្ចនេះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើស ដែលព្រះរាជអាជ្ញាបានចោទប្រកាន់។ ដីកានេះមិនអាចមានលក្ខណៈទូទៅទេ ត្រូវតែមានការណែនាំ និងកំណត់ពេលវេលាឲ្យបានច្បាស់លាស់។

ចៅក្រមនៃតុលាការដែលត្រូវបានចាត់តាំងឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបំពេញកិច្ចស៊ើបសួរនេះឲ្យបានត្រឹមត្រូវទៅតាមដីកាចាត់ឲ្យស៊ើបសួរជំនួសនេះ នៅពេលដែលចៅក្រមស៊ើបសួរបានប្រគល់សិទ្ធិនេះឲ្យ។ ចៅក្រមស៊ើបសួរអាចដកហូតដីកាចាត់ឲ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលាប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌នោះ មិនគោរពទៅតាមការណែនាំដែលមានចែងនៅក្នុង ដីកាចាត់ឲ្យស៊ើបសួរជំនួស ឬមានការរំលោភនីតិវិធីនៃការស៊ើបសួរ ឬក៏ការស៊ើបសួរហួសដែនសមត្ថកិច្ចរបស់ខ្លួនដោយមិនបានរាយការណ៍ជូនទៅចៅក្រមស៊ើបសួរជាមុន។

ចំពោះមន្ត្រីនគរបាលយុត្តិធម៌ ដែលចៅក្រមស៊ើបសួរចាត់ឲ្យស៊ើបសួរជំនួសនេះត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ជូនទៅចៅក្រមស៊ើបសួរនេះតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យភស្តុតាងនានារបស់ខ្លួនជូនទៅចៅក្រមស៊ើបសួរផងដែរ។ នៅក្នុងការស៊ើបសួរនេះដែរដើម្បីគោរពនូវសិទ្ធិការពារខ្លួនមន្ត្រីនគរបាលយុត្តិធម៌ មិនអាចស្តាប់ចម្លើយរបស់បុគ្គលណាមួយក្នុងឋានៈជាសាក្សីដែលមានតម្រុយពិរុទ្ធភាពបាននោះទេ។ ក្នុងករណីនេះមន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ឈប់ការស្តាប់ចម្លើយនោះភ្លាម ហើយរាយការណ៍ជូនចៅក្រមស៊ើបសួរ។ ការស៊ើបសួររបស់មន្ត្រីនគរបាលយុត្តិធម៌តាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួសនេះ មន្ត្រីនគរបាលយុត្តិធម៌មិនអាចសួរចម្លើយបុគ្គលផ្សេងដែលមិនបានបញ្ជាក់នៅក្នុងដីកានេះបានទេ។ តាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួសនេះផងដែរ មន្ត្រីនគរបាលយុត្តិធម៌ក៏មានសិទ្ធធ្វើការឆែកឆេរ និងចាប់យកវត្ថុតាងនានា ដែលខ្លួនយល់ឃើញថាមានជាប់ពាក់ព័ន្ធ នឹងអង្គហេតុព្រមទាំងមានសិទ្ធិឃាត់ខ្លួន និងបញ្ជូនខ្លួនជនត្រូវចោទទៅឲ្យព្រះរាជអាជ្ញា ឬនាំខ្លួនជនត្រូវចោទទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរបានទៀតផង។

## ២.៧. ដីកាសម្រេចឲ្យនៅក្រៅឃុំ

ចៅក្រមស៊ើបសួរ អាចបង្គាប់ឲ្យដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំវិញបានគ្រប់ពេលកាលណាចៅក្រមស៊ើបសួរមានបំណងដោះលែងជនត្រូវចោទ ឲ្យនៅក្រៅឃុំនោះចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញាពិនិត្យ។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងជនត្រូវចោទភ្លាមដោយមិនចាំបាច់ត្រូវការយោបល់របស់ព្រះរាជអាជ្ញានោះទេ ដោយគ្រាន់តែមានការចង្អុលបង្ហាញប្រាប់ពីមូលហេតុនៃការបន្ទាន់របស់ខ្លួនតែប៉ុណ្ណោះ។ ព្រះរាជអាជ្ញា ឬជនត្រូវចោទក៏អាចមានសិទ្ធសុំឲ្យដោះលែង ឬអាចដាក់ពាក្យសុំឲ្យដោះលែងឲ្យនៅក្រៅឃុំបានផងដែរ។

ចំពោះដីកាសម្រេចឲ្យនៅក្រៅឃុំនេះ ចៅក្រមស៊ើបសួរត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ហើយនៅពេលដែលសម្រេចឲ្យដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំរួចហើយ នោះចៅក្រមស៊ើបសួរអាចដាក់ជននេះឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន។

### ២.៧.១. ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ក្នុងការដាក់ជនត្រូវចោទ ឲ្យស្ថិតក្រោមការត្រួតពិត្យតាមផ្លូវតុលាការនេះ ចៅក្រមស៊ើបសួរអាចមានសិទ្ធិ ឬកាតព្វកិច្ចដូចខាងក្រោម ៖

- អាចដាក់ជនត្រូវចោទដែលនៅក្រៅឃុំ ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះដោយកំណត់នូវកាតព្វកិច្ចមួយ ឬច្រើនឲ្យជនត្រូវចោទគោរព។
- ការដាក់ឲ្យស្ថិតក្រោមការត្រួតពិត្យតាមផ្លូវតុលាការនេះ អាចធ្វើតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ឬតាមរយៈដីកាសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា។
- អាចធ្វើការកែប្រែខ្លឹមសារ នៃកាតព្វកិច្ចលុបចោលឬបញ្ចូលកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលា។
- ព្រះរាជអាជ្ញា និងជនត្រូវចោទអាចសុំឲ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលាផងដែរ។ ក្នុងករណីដែលជនត្រូវចោទគេចវេះដោយចេតនាពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឲ្យឃុំខ្លួនវិញបានទោះបីជាទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានថេរវេលាប៉ុន្មានក៏ដោយ ហើយទោះបីជាត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរមាក៏ដោយ។

## ២.៨. ការបិទការស៊ើបសួរ

ចៅក្រមស៊ើបសួរយល់ថា ការស៊ើបសួរត្រូវបានបញ្ចប់ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា ជនត្រូវចោទដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី ហើយ២ថ្ងៃក្រោយមកចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីធ្វើការពិនិត្យ។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថានៅមានចំណុចខ្វះខាតត្រង់ណា ឬមានប្រយោជន៍ទាក់ទងនឹងអង្គហេតុនោះ ព្រះរាជអាជ្ញាអាចស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរជាថ្មីទៀតបាន។

នៅក្នុងរយៈពេល ១៥ថ្ងៃ បើជនជាប់ចោទត្រូវឃុំខ្លួន និងរយៈពេល ១ខែ បើជនជាប់ចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់មកជាមួយផង ប្រសិនបើព្រះរាជអាជ្ញាយល់ថា កាស៊ើបសួរត្រូវបញ្ចប់ដូចចៅក្រមស៊ើបសួរដែរ។

ក្នុងករណីនេះព្រះរាជអាជ្ញា អាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរបញ្ជូនខ្លួនទៅតុលាការជំនុំជម្រះ ឬលើកលែងការចោទប្រកាន់។

### ២.៨.១. ដីកាដំណោះស្រាយ

ចៅក្រមស៊ើបសួរបិទការស៊ើបសួរ តាមដីកាដំណោះស្រាយដែលជាដីការបញ្ជូនដំណឹងទៅជំនុំជម្រះឬដីកាលើកលែងការចោទប្រកាន់ហើយដីកានេះត្រូវតែមានសំអាងហេតុជានិច្ច។ ចៅក្រមស៊ើបសួរអាចសម្រេចបញ្ជូនជនត្រូវទៅជំនុំជម្រះបើយល់ឃើញថា អំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។ ចៅក្រមស៊ើបសួរ ក៏អាចលើកលែងការចោទប្រកាន់បានផងដែរក្នុងករណីដូចតទៅ៖

- អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ
- ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ

ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ច ដោយត្រូវគោរពតាមសេចក្តីសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ។ ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណីក្នុងរយៈពេលដ៏ខ្លីបំផុត។

### ២.៨.២. ដីកាដំណោះស្រាយបញ្ចប់

ការឃុំខ្លួនបណ្តោះអាសន្ន តាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឲ្យនៅជាប់ឃុំខ្លួនបណ្តោះអាសន្ន រហូតដល់ពេលបង្ហាញនូវតុលាការ។ សេចក្តីសម្រេចនេះលែងមានអានុភាពក្នុងរយៈពេល ៤ខែ។

ការត្រួតពិនិត្យតាមផ្លូវតុលាការតាមសេចក្ដីសម្រេចដោយឡែក នៃដីកាដំណោះស្រាយចៅក្រម ស៊ើបសួរអាចរក្សាជនត្រូវចោទ ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរហូតពេលចូលបង្ហាញខ្លួននៅតុលាការ។ បើចៅក្រមស៊ើបសួរសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះចៅក្រមស៊ើបសួរត្រូវ បញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។

## ផ្នែកទី ២. ការបង្ហាញ និងការវាយតម្លៃលើភស្តុតាង

### កថាខណ្ឌទី១ ការបង្ហាញភស្តុតាង

### ១.១. មធ្យោបាយនៃការបង្ហាញភស្តុតាង

តាមគោលការណ៍ដែលបានចែងនៅក្នុងច្បាប់ លើកលែងតែបទប្បញ្ញត្តិផ្ទុយពីនេះភស្តុតាងក្នុងរឿងព្រហ្មទណ្ឌអាចជូនបានដោយសេរី។ តុលាការថ្លឹងថ្លែងដោយឥស្សរចិត្តអំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យដោយផ្អែកទៅ ជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន។ តុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿងឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនការប៉ុណ្ណោះ។ ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែលត្រូវដាក់ជូនតុលាការថ្លឹងថ្លែង។

ដូច្នេះយើងអាចបញ្ជាក់បានថា ភស្តុតាងនៃបទល្មើសព្រហ្មទណ្ឌអាចធ្វើបានដោយប្រើគ្រប់មធ្យោបាយទាំងអស់ដើម្បីឱ្យចៅក្រមមានភាពជឿទុកចិត្តបាន។

គ្រប់មធ្យោបាយ និង ភស្តុតាងទាំងអស់អាចត្រូវយកមកប្រើប្រាស់ដោយភាគីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដោយភស្តុតាងនីមួយៗពុំមានតម្លៃធ្ងន់ ឬស្រាលជាងគ្នានោះទេដោយច្បាប់ទុកលទ្ធភាពឱ្យចៅក្រមសម្រេចសេចក្តីដោយផ្អែកទៅលើជំនឿស្មោះត្រង់។ ហើយភស្តុតាងក្នុងរឿងក្តីព្រហ្មទណ្ឌនេះ អាចដាក់ជូនដោយសេរីលើកលែងតែមានច្បាប់ចែងផ្ទុយហើយរាល់ហេតុការណ៍ទាំងអស់ដែលចៅក្រមបានដឹង ឬឮដោយផ្ទាល់ខ្លួន តែមិនមាននៅក្នុងរឿងក្តីទេ ចៅក្រមពុំអាចយកមកធ្វើជាភស្តុតាងក្នុងការសម្រេចសេចក្តីបានឡើយ។

ជាគោលការណ៍ ភស្តុតាងទាំងអស់ចៅក្រមសុទ្ធអាចយកមកធ្វើជាសំអាងដើម្បីសម្រេចសេចក្តី ក៏ប៉ុន្តែភស្តុតាងមួយចំនួនត្រូវតែធ្វើការបដិសេធចោលដោយមូលហេតុច្បាស់លាស់ប្រសិនបើច្បាប់បានកំណត់។

សរុបមកមធ្យោបាយនៃការបង្ហាញភស្តុតាងមានសក្ខីភាព ការសារភាព និងការពិនិត្យគ្រប់មុខសញ្ញា។

### ១.១.១. ភស្តុតាងដែលបង្ហាញតាមរយៈសាក្សី

សាក្សី គឺជាជនដែលនិយាយពីអ្វីដែលខ្លួនបានឃើញ ឬបានឮដោយផ្ទាល់។ ក្នុងនោះមន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវចាត់ទុកជាសាក្សីនៅក្នុងរឿងក្តីព្រហ្មទណ្ឌផងដែរ។ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលចម្លើយនោះមានប្រយោជន៍នៅក្នុងការសម្តែងឱ្យឃើញការពិត[20]។ ការស្វែងរកសាក្សីដែលបានដឹង ឬបានឮអំពីហេតុការណ៍ដែលទាក់ទីនទៅនឹងបទល្មើសចៅក្រមព្រះរាជអាជ្ញា និងមន្ត្រីនគរបាលយុត្តិធម៌ អាចប្រើប្រាស់វិធីសាស្ត្រផ្សេងៗដែលច្បាប់បានអនុញ្ញាត។

### ១.១.២. ការសារភាព

ចៅក្រម ព្រះរាជអាជ្ញា និងនគរបាលយុត្តិធម៌មានសមត្ថកិច្ច អាចសួរចម្លើយជនដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស ដោយកត់ត្រាចម្លើយនៅក្នុងកំណត់ហេតុ។ មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានឱ្យតម្លៃទៅលើការសារភាពទេ។ នៅក្នុងកថាខណ្ឌទី៤ នៃមាត្រា ៣២១ នៃក្រមនីតិវិធីនេះដដែល បានចាត់ទុកការសារភាពជាប្រភេទមួយនៃភស្តុតាងដែរ។ ចម្លើយដែលទទួលបានក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្ត គ្មានតម្លៃជាភស្តុតាងទេ។

### ១.១.៣. ការពិនិត្យគ្រប់មុខសញ្ញា

ដើម្បីទទួលបាននូវការពិតចៅក្រមត្រូវតែធ្វើការពិនិត្យគ្រប់មុខសញ្ញាទាំងអស់ដែលមាននៅក្នុងសំណុំរឿងក្តី ដើម្បីធ្វើជាមូលដ្ឋាននៃការផ្តន្ទាទោស ឬមិនផ្តន្ទាទោស។ ក្នុងករណីខាងលើនេះ ចៅក្រមជំនុំជម្រះធ្វើការពិនិត្យទៅលើកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ការកោសល្យវិច្ច័យរបស់អ្នកជំនាញវត្ថុតាងនានាដែលមន្ត្រីនគរបាលយុត្តិធម៌ប្រគល់ឱ្យ ឬដែលចៅក្រមស៊ើបសួរចាត់ឱ្យប្រមូល។ល។

ដូច្នេះហើយចៅក្រមស៊ើបសួរ អាចចុះទៅពិនិត្យដល់ទីកន្លែងកើតហេតុផ្ទាល់ ដើម្បីបានដឹងពីការពិតជាក់ស្តែង និងកាលៈទេសៈនៃបទល្មើស។

ការពិនិត្យគ្រប់មុខសញ្ញាអាចឱ្យចៅក្រមឈានទៅរកការសន្និដ្ឋានមួយបានទៅលើអង្គហេតុដែលបានកើតឡើងមានពិតដោយផ្អែកទៅលើការពិចារណាការប្រៀបធៀបជាដើម។ ការសន្និដ្ឋានអាចត្រូវគ្នាជាមួយនឹងចម្លើយរបស់សាក្សី ជនរងគ្រោះ ឬជនជាប់ចោទ។ សម្រាប់ករណីមួយចំនួនបានផ្តល់សិទ្ធិឱ្យចៅក្រមធ្វើការថ្លឹងថ្លែងដោយឥស្សរចិត្តរបស់ខ្លួនចំពោះភស្តុតាង។

រាល់មធ្យោបាយនៃការបង្ហាញភស្តុតាងខាងលើនេះ គឺសុទ្ធតែមានតម្លៃជាភស្តុតាងដូចៗគ្នាពោលគឺជាធាតុផ្សំសម្រាប់ឱ្យចៅក្រមពង្រឹងជំនឿរបស់ខ្លួនដើម្បីកាត់សេចក្តី។ ទោះយ៉ាងណា នៅ

[20] មាត្រា១៥៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ពេលសវនាការជំនុំជម្រះ រាល់ភស្តុតាងដែលទទួលបានត្រូវលើកយកមកជជែកវែកញែកដោយភាគីនៃរឿងក្តី ដើម្បីរកឱ្យឃើញពីភាពគួរជឿជាក់បាន ឬមិនគួរឱ្យជឿជាក់បាននៃភស្តុតាង។

កំណត់ហេតុរបស់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ "ឯកសារដើម" មានន័យថាត្រូវទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ ហើយភស្តុតាងផ្ទុយនេះអាចជូនមកចៅក្រមបានដោយសេរីតាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់[21]។

## ១.២. លក្ខខណ្ឌនៃការបញ្ជាក់ភស្តុតាង និងការបង្ហាញភស្តុតាង

តាមគោលការណ៍ដែលបានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី លើកលែងតែបញ្ញត្តិផ្ទុយពីនេះ ភស្តុតាងក្នុងរឿងក្តីព្រហ្មទណ្ឌអាចដាក់បានដោយសេរី។ តុលាការអាចថ្លឹងថ្លែងដោយឥស្សរចិត្តចំពោះតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន។ តុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនការប៉ុណ្ណោះ ការសារភាពក៏ជាប្រភពនៃភស្តុតាងដែលមានតម្លៃដូចភស្តុតាងដទៃទៀតដែរដែលត្រូវដាក់ជូនតុលាការធ្វើថ្លឹងថ្លែង"។

ដូច្នោះយើងអាចឃើញបានថា ភស្តុតាងក្នុងរឿងក្តីព្រហ្មទណ្ឌ គឺអាចគ្រប់មធ្យោបាយទាំងអស់ដើម្បីញ៉ាំងឱ្យចៅក្រមមានភាពជឿជាក់ទៅបាន។

ក្នុងករណីៈ ការទទួលសារភាពដោយចម្លើយរបស់សាក្សីឆ្លើយមកសមហេតុផល និងមានភាពជាក់លាក់ដោយការពិនិត្យគ្រប់មុខសញ្ញាដោយការធ្វើកោសល្យវិច័យឬដោយតាម មធ្យោបាយត្រឹមត្រូវតាមច្បាប់ដទៃទៀត ដូចជាការចុះទៅពិនិត្យកន្លែងកើតហេតុជាដើម។

ដើម្បីធ្វើការដោះស្រាយឱ្យបានត្រឹមត្រូវទៅលើចំណាត់ការនៃរឿងក្តីព្រហ្មទណ្ឌស្ថាប័នស៊ើបអង្កេត ឬស្ថាប័នតុលាការត្រូវតែពឹងផ្អែកទាំងស្រុងទៅលើភស្តុតាងនានាដែលប្រមូលបាន។ គ្រប់ភស្តុតាងដែលបានកើតចេញពីព្រឹត្តិការណ៍ណាមួយនៃរឿងក្តីព្រហ្មទណ្ឌភស្តុតាង ឬអង្គហេតុទាំងនោះ ត្រូវបានប្រមូលទៅតាមវិធានជាក់លាក់មួយជាកំណត់ដោយវិធានទាំងលាក់នេះបញ្ញត្តិដោយច្បាប់នីតិវិធីដែលគេហៅថាៈ «មធ្យោបាយនៃការបញ្ជាក់ភស្តុតាង»។

## ១.២.១. វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ

ក្នុងគោលការណ៍សច្ចធារណ៍នៃនិរទោសនេះ គេអាចឃើញមានលក្ខខណ្ឌមួយទៀតដែលមានអត្ថន័យសំខាន់នៅក្នុងការអនុវត្តរបស់តុលាការ។ ជាគោលការណ៍នៅក្នុងច្បាប់បានចែងថាៈ «វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ដរាបណាតុលាការមិនទាន់កាត់ទោសជា

[21] មាត្រា១១០ និងមាត្រា១១៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ស្ថាពរ»[22]។ កាលណាភស្តុតាងទាំងឡាយមានភាពប្រឈមគ្នា និងមានភាពទំនាស់គ្នា (ផ្ទុយគ្នា) ប្រសិនបើតុលាការពុំទាន់មានអំណះអំណាងឱ្យបានគ្រប់គ្រាន់ ក្នុងការដាក់បង្ហាញឱ្យឃើញពីកំហុសជាទូទៅរបស់បុគ្គល ឬក៏មិនអាចបង្ហាញនូវចំណែកណាមួយដែលពាក់ព័ន្ធទៅនឹងអង្គហេតុតាមរយៈនៃការចោទប្រកាន់នោះទេ និងប្រសិនបើអង្គហេតុណាមួយមានរបកគំហើញផ្សេងគ្នាដោយមិនមានភាពស៊ីសង្វាក់គ្នាបាននោះ នៅទីបញ្ចប់តុលាការ ត្រូវតែធ្វើសេចក្តីសម្រេចមួយដោយសេចក្តីសម្រេចបែបនេះមានលំអៀងទៅរក ឬប្រយោជន៍របស់ជនជាប់ចោទ[23]។ ច្បាប់បានចែងថា «វិមតិសង្ស័យត្រូវតែបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច[24]»។ តាមគោលការណ៍នៃការឃុំខ្លួនបណ្តោះអាសន្នមានន័យថា «ជនជាប់ចោទត្រូវតែមានសេរីភាព»។ នៅលើឡឹករណ៍ទាំងនេះជាការបញ្ជាក់ថា ការសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ហើយជនជាប់ចោទក៏ត្រូវចាត់ទុកជាជនគ្មានទោសផងដែរ។ មានគោលការណ៍មួយផ្សេងទៀតដែលបានគាំទ្រផងដែរ នៅគោលការណ៍ខាងលើ «ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោសដ៏រាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ»។

ចំពោះវិធាននៃការដោះស្រាយចំពោះវិមតិសង្ស័យ គោលការណ៍នេះ តុលាការបានធ្វើសេចក្តីសម្រេចទៅលើអង្គសេចក្តីដោយរកឃើញថាមានទោស ឬគ្មានទោសចំពោះជនជាប់ចោទ លុះត្រាតែ ភស្តុតាងទាំងនោះបានដាក់បង្ហាញយ៉ាងច្បាស់ដោយគ្មានភាពសង្ស័យ។ ការសង្ស័យណាមួយ ដែលបានកើតឡើងនៅក្នុងដំណាក់កាលស៊ើបអង្កេត នោះគេត្រូវចាត់វិធានការផ្ទៀងផ្ទាត់ឱ្យបានប្រាកដប្រជាទៅលើភស្តុតាងទាំងនោះ។ ប៉ុន្តែនេះមិនមែនមានន័យថា ការផ្ទៀងផ្ទាត់បែបនេះវាជាកាតព្វកិច្ច តែម្នាក់គត់របស់អ្នកស៊ើបអង្កេតនោះទេ វាក៏ជាសិទ្ធិអំណាចនិងកាតព្វកិច្ចរបស់តុលាការជំនុំជម្រះផងដែរ។ ព្រោះថាស្ថាប័នដែលធ្វើការស៊ើបអង្កេត ឬធ្វើការចោទប្រកាន់គឺមានកាតព្វកិច្ចបង្ហាញពីសក្ខីកម្មក្នុងការដាក់បន្ទុកទៅលើជនត្រូវចោទ។ នៅពេលមានការសង្ស័យក្នុងពេលស៊ើបសួរ តុលាការមានវិធានការនិរន្តរាយ ប៉ុន្តែបើការសង្ស័យនោះកើតមាននៅក្នុងដំណាក់កាលជំនុំជម្រះវិញ តុលាការមានវិធានការស្រាវជ្រាវជាថ្មីបន្ថែមដែលមានកំណត់នៅក្នុងមាត្រា ៣៣៩ កថាខណ្ឌ១ «ប្រសិនបើយល់ឃើញថាការស្រាវជ្រាវថ្មីមានការចាំបាច់ តុលាការអាចបង្គាប់តាមសាលក្រមឱ្យធ្វើការស៊ើបសួរបន្ថែម»[25]។

[22] មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[23]នីតិភស្តុតាង របស់ចៅក្រម អ៊ិន បុផា បោះពុម្ពលើកទី២ ទំព័រ៥២ ឆ្នាំ២០១៦

[24] មាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[25] មាត្រា៣៣៩នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

## ១.២.២. ការផ្ទៀងផ្ទាត់ភស្តុតាង

ក្នុងការសម្រេចសេចក្តីក្នុងរឿងក្តីព្រហ្មទណ្ឌ ចៅក្រមត្រូវតែផ្អែកទៅលើភស្តុតាងជាកត្តាសំខាន់បំផុត និងដោយផ្អែកទៅលើគោលការណ៍នៃសម្មតិកម្ម។ នៅក្នុងគោលការណ៍នៃការផ្ទៀងផ្ទាត់ភស្តុតាង ក៏វាមិនសូវជាខុសគ្នាច្រើនប៉ុន្មានដែរពីគោលការណ៍នៃការវាយតម្លៃទៅលើភស្តុតាង។ ការផ្ទៀងផ្ទាត់គឺជាភារកិច្ចរបស់អ្នកស៊ើបអង្កេត ព្រះរាជអាជ្ញា ឬតុលាការ ដើម្បីធ្វើការកំណត់អំពីភាពជឿជាក់ទៅលើគុណភាពជាក់ស្តែងនៃប្រភពនានាដែលទទួលបាន។ បុគ្គលដែលមានសមត្ថកិច្ចអនុវត្តនៅក្នុងនីតិវិធីនៃប្រព័ន្ធយុត្តាធិការនេះ ត្រូវធ្វើឡើងប្រកបដោយភាពហ្មត់ចត់គ្រប់ជ្រុងជ្រោយ និងចំគោលដៅសម្រាប់ធ្វើសេចក្តីសម្រេចដ៏ត្រឹមត្រូវមួយទៅលើចំណុចទាំងឡាយនៃសំណុំរឿងក្តីព្រហ្មទណ្ឌ។

ការផ្ទៀងផ្ទាត់ភស្តុតាងមានលក្ខណៈច្រើនប្រភេទណាស់ យើងនឹងលើកយកចំណុចខ្លះៗមកនិយាយដែលមានន័យដូចខាងក្រោមនេះ ៖

### ក. ការផ្ទៀងផ្ទាត់ភស្តុតាង

ការផ្ទៀងផ្ទាត់ គឺត្រូវតែបំពេញកិច្ចគ្រប់ដំណាក់កាលនៃនីតិវិធីហើយរាល់ប្រភពទាំងឡាយដែលទទួលបានក៏ដូចជាភស្តុតាងផងដែរ គឺត្រូវតែយកទៅធ្វើការផ្ទៀងផ្ទាត់នៅក្នុងលក្ខខណ្ឌដាច់ដោយឡែកៗពីគ្នា និងត្រូវធ្វើការផ្តុំចូលគ្នាវិញជាមួយភស្តុតាងដទៃផ្សេងទៀត។

ចំពោះអ្នកមានសមត្ថកិច្ចក្នុងការធ្វើការផ្ទៀងផ្ទាត់នេះវិញ គឺជាបុគ្គលដែលមានអំណាចរដ្ឋហើយទទួលបន្ទុកក្នុងការធ្វើការសេចក្តីសម្រេចតាមនីតិវិធីដូចជាតុលាការជាដើម(ចៅក្រម)។ ការផ្ទៀងផ្ទាត់បែបនេះគឺរាប់បញ្ចូលដូចគ្នាទៅនឹងការវិភាគបែបកត្តវិជ្ជមានផងដែរដោយក្នុងនោះវាផ្ទុកនូវព័ត៌មានទាំងឡាយ ដែលមានមធ្យោបាយធ្វើការប្រដូចគ្នាជាមួយនឹងខ្លឹមសារនៃភស្តុតាងដែលមាន។ ការប្រដូចខ្លឹមសារនៃភស្តុតាងនេះគឺត្រូវតែឈរនៅលើមូលដ្ឋាននៃការវិភាគចំពោះសកម្មភាពនានា ចាំបាច់របស់ស្ថាប័នស៊ើបអង្កេត និងតុលាការ។

### ខ. ការប្រដូចគ្នានៃភស្តុតាង

ការប្រដូចនៃភស្តុតាងមួយទៅនឹងភស្តុតាងមួយផ្សេងទៀត ដែលមាននូវក្នុងសំណុំរឿងក្តីព្រហ្មទណ្ឌមានន័យថាភស្តុតាងនីមួយៗតែងតែមានភាពជាប់ទាក់ទងគ្នាជាមួយភស្តុតាងផ្សេងៗទៀតហើយអាចធ្វើការផ្ទៀងផ្ទាត់គ្នាបាន ដាក់ក្នុងបណ្តុំមួយបានទៅតាមកិច្ចការនៃភស្តុតាង។ គ្មានភស្តុតាងណាមួយក្នុងចំណោមភស្តុតាងទាំងអស់នោះមានឥទ្ធិពលគ្របដណ្តប់ទៅលើភស្តុតាងមួយផ្សេងទៀតបានឡើយនៅពេលមានការលេចឡើងនូវភាពប្រឈមគ្នានៅក្នុងភស្តុតាងទាំងនោះចាំបាច់ត្រូវតែរុករកទៅលើភស្តុតាងនីមួយៗ រួចហើយត្រូវធ្វើការបង្ហាញឱ្យមានភាពច្បាស់លាស់

ចំពោះភាពប្រឈមគ្នាទាំងនោះ។ ទោះបីនៅក្នុងក្រមព្រហ្មទណ្ឌមិនបានអនុញ្ញាតឱ្យមានប្តឹងតវ៉ាចំពោះភស្តុតាងក៏ពិតមែន ប៉ុន្តែកាតព្វកិច្ចនេះត្រូវបានចងនូវក្នុងកំណត់ហេតុពេលសួរដេញដោយវិញ។

ដោយភស្តុតាងនីមួយៗនូវក្នុងរឿងក្តីព្រហ្មទណ្ឌត្រូវតែមានប្រភពរបស់វា ដោយហេតុនេះហើយបានជាការផ្ទៀងផ្ទាត់ភស្តុតាងនេះឱ្យយើងធ្វើការកំណត់បាននូវប្រភពជាក់ស្តែងបាន ពោលគឺយកប្រភពនៃភស្តុតាងមកធ្វើជាគោលតែម្តង។

## គ. ការផ្ទៀងផ្ទាត់នៅលើប្រភពនៃភស្តុតាង

ជាវិធីដែលអាចធ្វើឱ្យបញ្ចេញច្បាស់ នៅក្នុងការកំណត់អង្គហេតុទាំងឡាយដែលបានផ្សារភ្ជាប់គ្នាជាមួយនឹងសមត្ថភាពរបស់បុគ្គល ដែលជាអ្នកផ្តល់ព័ត៌មានរួចទាំងទំនាក់ទំនងអញ្ញមញ្ញនានាជាមួយអ្នកចូលរួចផ្សេងទៀតនៅក្នុងដំណើរការនៃការផ្ទៀងផ្ទាត់នោះ។ ក្នុងន័យនេះគឺវាមិនជាខុសគ្នាប៉ុន្មានទេទៅនឹងសកម្មភាពនៃការស៊ើបសួរ (ក្នុងករណីជនជាប់ចោទបានធ្វើការបដិសេធន៍នូវចម្លើយសារភាពនៅក្នុងដំណាក់កាលជំនុំជម្រះទៅលើដំណាក់កាលដំបូងៗ ដែលបានធ្វើឡើងដោយមន្ត្រីស៊ើបអង្កេត)។

ហើយដំណើរការផ្ទៀងផ្ទាត់ភស្តុតាង អាចចាប់ផ្តើមតាំងពីបានទទួលភស្តុតាងនោះមកម្លេះមានន័យថា ក្រោយពីទទួលបាននូវភស្តុតាងភ្លាម ការផ្ទៀងផ្ទាត់ក៏ត្រូវតែចាប់ផ្តើមធ្វើដែរដោយមិនចាំបាច់ត្រូវរង់ចាំដល់ពេលជំនុំជម្រះនោះទេ។ តែប្រសិនណាទុកដល់ពេលជំនុំជម្រះអាចធ្វើឱ្យភស្តុតាងមួយចំនួនត្រូវបាត់បង់នូវដានរបស់វាដូចជា បទល្មើសរំលោភសេពសន្ថវៈ ក្រោយពេលដែលជនរងគ្រោះបញ្ជាក់ថាខ្លួនបានធ្វើការតបតទៅលើជនល្មើសវិញតាមមធ្យោបាយខ្ចៅនឹងក្រចកដៃ ចំណុចនេះត្រូវមានកំណត់ហេតុពិនិត្យលើខ្លួនប្រាណរបស់ជនជាប់ចោទភ្លាមៗ ប្រសិនណាជនជាប់ចោទត្រូវឃាត់ខ្លួនបានបន្ទាប់ពីកើតហេតុ។

ដូច្នេះក្នុងវិធានទាំងឡាយដែលបានរៀបរាប់ខាងលើនេះ វាគ្រាន់តែជាផែនទីបង្ហាញផ្លូវគោលមួយប៉ុណ្ណោះគឺមិនមានន័យថាវាបានបង្ហាញគ្រប់ជ្រុងជ្រោយនោះទេពីព្រោះវិធានទាំងនោះវាមានការប្រែប្រួលទៅតាមប្រភេទនៃភស្តុតាង អាស្រ័យទៅលើអង្គហេតុជាក់ស្តែងដែលបានកើតឡើងនៅក្នុងព្រឹត្តិការណ៍នីមួយៗ ហើយវាបានស្តែងចេញពីព្រឹត្តិការណ៍នេះគេអាចកំណត់បាននូវអំពើដែលបានល្មើស។ ដើម្បីយល់ដឹងទៅលើវិធានទាំងនេះអ្នកសិក្សាត្រូវតែចាំបាច់ត្រូវតែស្គាល់នូវគោលបំណងរួមនៃប្រភេទរបស់ភស្តុតាង ហើយប្រៀបផ្ទឹមទៅអង្គហេតុនានាមាននូវក្នុរឿងក្តី។

ការបកស្រាយទៅលើចំណុចទាំងនេះមានដូចខាងក្រោម ៖

## គ.១. អំពីអត្ថិភាព ឬនត្ថិភាពនៃប្រភេទអង្គហេតុ

មានន័យថាពេលមានព្រឹត្តិការណ៍នៃបទល្មើសកើតឡើង អ្នកស៊ើបអង្កេត ឬចៅក្រមត្រូវតែព្យាយាមរកនូវប្រភពនៃអង្គហេតុតាមរយៈនៃព័ត៌មាននានាតាមគ្រប់មធ្យោបាយទាំងអស់ដែលច្បាប់បានកំណត់ទុក។ ដូច្នេះត្រូវប្រាកដក្នុងចិត្តជាមុនថាអង្គហេតុណាជាអង្គហេតុពិតសិនទើបអាចធ្វើការផ្ទៀងផ្ទាត់ទៅលើភស្តុតាងនោះបាន។ ដោយត្រូវកំណត់ឱ្យបានច្បាស់ថាតើប្រភពព័ត៌មានដែលនៅក្នុងអង្គហេតុនោះវាមានលក្ខណៈពិតត្រឹមត្រូវដែរឬទេ និងគួរឱ្យជឿទុកចិត្តបានដែរឬទេ? វាពិតជាពិបាកនិងមានភាពស្មុគស្មាញណាស់ក្នុងការវាយតម្លៃទៅលើប្រភពព័ត៌មានដែលទទួលបានពីអង្គហេតុនានា ប៉ុន្តែអ្នកធ្វើការវាយតម្លៃត្រូវតែមានភាពរឹងមាំនិងមានម្ចាស់ការចំពោះប្រភពនៃភស្តុតាងនិងប្រភពព័ត៌មានបែបនេះ។

## គ.២. អំពីហេតុផលនៃអត្ថិភាព និងនត្ថិភាពចំពោះអង្គហេតុ

ហេតុផលនៃអត្ថិភាពនិងនត្ថិភាព អ្នកអនុវត្តច្បាស់ត្រូវតែមានគោលគំនិតនិងចំណេះដឹងផ្នែកភស្តុតាងសម្រាប់ធ្វើការបកស្រាយ។ ប្រសិនបើប្រភពនៃព័ត៌មាន វាត្រឹមត្រូវនិងអាចជឿទុកចិត្តបាន តើអាចធ្វើការសន្និដ្ឋានចំពោះទោសកំហុសរបស់ជនល្មើសក្នុងអង្គហេតុនោះបានដែរ ឬទេ? ផ្ទុយទៅវិញអ្នកធ្វើការផ្ទៀងផ្ទាត់ទៅលើភស្តុតាងដូចជាស្ថាប័នតុលាការជាដើមនោះមិនមែនសុទ្ធតែប្រាកដថាគ្រប់អង្គហេតុទាំងអស់គឺសុទ្ធតែជាការពិតប្រាកដនោះទេ ក៏ព្រោះថាមានភស្តុតាងខ្លះបានមកដោយប្រយោលតែប៉ុណ្ណោះ ដូចនេះគឺត្រូវតែធ្វើការផ្ទៀងផ្ទាត់ឡើងវិញ។

ភស្តុតាងត្រូវបានចាត់ទុកដូចជាប្រភពមួយក្នុងការផ្តល់ព័ត៌មានស្តីអំពីអង្គហេតុមួយពិតប្រាកដដែលគេតែងហៅថា «មធ្យោបាយនៃការបញ្ជាក់ភស្តុតាងឬមធ្យោបាយនៃការផ្តល់សក្ខីកម្ម»។

ករណី ៖ ការបំភ្លឺរបស់សាក្សីអំពីអង្គហេតុណាមួយនោះ គឺមានប្រភពមួយច្បាស់លាស់ដែលប្រភពនោះធ្វើឱ្យមានហេតុផលយ៉ាងជាក់លាក់បំផុត ហើយនាំឱ្យតុលាការទទួលបាននូវព័ត៌មានអំពីអង្គហេតុមួយយ៉ាងពេញលេញ។ ការស្វែងរកបានអំពីសកម្មភាពកាន់តែពិតប្រាកដទៅលើអង្គហេតុនោះ គឺជាវិធាននានារបស់ស្ថាប័នមានសមត្ថកិច្ចក្នុងកិច្ចប្រតិបត្តិការចំពោះការបញ្ជាក់នូវសក្ខីកម្មទាំងឡាយតាមរយៈហេតុផលណាមួយដែលហេតុផលនោះត្រូវបានកំណត់ដោយអង្គហេតុពិតក្នុងអង្គហេតុទាំងអស់ ទោះបីជាវាមានខ្លឹមសារជាវិជ្ជមានក្តី ឬអវិជ្ជមានក្តីចំពោះអត្ថិភាព ឬនត្ថិភាពនៃបទល្មើសណាមួយក្តី ក៏អង្គហេតុទាំងនោះសុទ្ធតែមានប្រភពដើមរបស់វា ហើយអង្គហេតុពិតទាំងនោះអាចជាវត្ថុបញ្ជាក់ពីសក្ខីកម្មបាន។ ប៉ុន្តែចំពោះអង្គហេតុប្រឌិតវិញ មិនអាចធ្វើការបញ្ជាក់អំពីសក្ខីកម្មនោះទេពីព្រោះថាប្រភពរបស់វាកើតចេញពីការបំផ្លើសអង្គហេតុ ឬដោយការក្លែងបន្លំនូវភស្តុតាង។

## កថាខណ្ឌទី២ ការវាយតម្លៃទៅលើភស្តុតាង

### ២.១. វិធីសាស្ត្រក្នុងការវាយតម្លៃលើភស្តុតាង

ការវាយតម្លៃទៅលើភស្តុតាង គឺជាការសរុបលទ្ធផលមួយដែលកើតចេញពីការផ្ទៀងផ្ទាត់ទៅលើអត្ថិភាពនៃភស្តុតាងទាំងឡាយដែលមាននៅក្នុងរឿងក្តី ដោយលទ្ធផលបែបនេះបានដាក់ចេញអំពីការទទួលស្គាល់ទៅលើអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុទាំងនោះ។ យើងក៏អាចនិយាយម្យ៉ាងទៀតថាការវាយតម្លៃទៅលើភស្តុតាង គឺជាការធ្វើសេចក្តីសន្និដ្ឋានសរុបអំពីភាពអាចជឿជាក់បាន ឬភាពមិនអាចជឿជាក់បានទៅលើភស្តុតាង។

ការវាយតម្លៃទៅលើភស្តុតាង គឺជាភារកិច្ចរបស់ចៅក្រម ព្រះរាជអាជ្ញា និងអ្នកស៊ើបអង្កេត ដែលជាភារកិច្ចរបស់បុគ្គល ទាំងនេះត្រូវបានស្តែងចេញតាមរយៈការធ្វើអំណះអំណាងរបស់បុគ្គលទាំងនោះក្នុងលក្ខខណ្ឌនៃបរមត្ថធម៌ជាពិសេសអំណះអំណាងទាំងនេះត្រូវឈរលើមូលដ្ឋាននៃការពិចារណាទៅលើភស្តុតាងនានា រួមមានបណ្តុំនៃភស្តុតាងទាំងនោះប្រកបដោយលក្ខណៈពេញលេញចំគោលដៅ និងគ្រប់ជ្រុងជ្រោយសមស្របតាមច្បាប់ និងមនសិការគតិយុត្តិ។

ចៅក្រម ព្រះរាជអាជ្ញា និងអ្នកស៊ើបអង្កេត ពួកគេត្រូវដោះស្រាយអង្គហេតុនានាប្រកបដោយបញ្ញាស្មារតី នៃភាពដែលអាចទទួលយកបាន ភាពទាក់ទិននឹងអង្គហេតុ ភាពជឿជាក់ទៅលើភស្តុតាងនីមួយៗ ព្រមទាំងភាពគ្រប់គ្រាន់នៃភស្តុតាងទាំងអស់សម្រាប់ធ្វើការអនុម័តដើម្បីអាចទទួលយកបាននូវសេចក្តីសម្រេចមួយប្រកបដោយវិជ្ជាជីវៈ និងយុត្តិធម៌។

ទោះបីជានៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងឱ្យជាក់លាក់ទៅលើប្រភេទនៃភស្តុតាងក្តី ប៉ុន្តែច្បាប់ផ្តល់សិទ្ធិទៅឱ្យស្ថាប័នតុលាការមានចៅក្រម ឬព្រះរាជអាជ្ញា «តុលាការទទួលថ្លឹងថ្លែងដោយឥស្សរចិត្តអំពីតម្លៃ នៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន»[26] ហេតុផលដែលច្បាប់មិនបានកំណត់ឱ្យច្បាស់លាស់អំពីវិធាននៃភស្តុតាងបែបនេះអាចមកពីភស្តុតាងមានសភាពប្រែប្រួលច្រើន អាស្រ័យទៅតាមបទល្មើសដែលបានកើតឡើង។ កាលណាបើច្បាប់នីតិវិធីបានកំណត់នូវវិធាននិងគោលការណ៍ឱ្យបានច្រើនទាក់ទិននឹងភស្តុតាងនោះ វាជាគុណវិបត្តិមួយដល់ការវាយតម្លៃទៅលើភស្តុតាងមុនឈានដល់ការធ្វើសេចក្តីសម្រេចរបស់តុលាការ។ ម្យ៉ាងទៀតបើច្បាប់នីតិវិធីបានកំណត់ពីគោលការណ៍ និងវិធានដែលមានលក្ខណៈស៊ីជម្រៅពេកហើយចៅក្រមមានការយល់ដឹងខាងផ្នែកទ្រឹស្តីនៃនីតិសាស្ត្រនៅមានកំរិត ក៏

[26] មាត្រា៣២១នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

អាចជាហេតុនាំឱ្យមានការប៉ះពាល់ដល់ការវិនិច្ឆ័យច្បាប់ ឬក៏ចៅក្រម អាចយកតែទម្លាប់មកប្រើជំនួសវិញ ជាជាងយកច្បាប់ដែលកំណត់អំពីវិធានភស្តុតាងមកប្រើ។

ដូច្នេះហើយបានជាលេចឡើងនូវគោលការណ៍ «ជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន» ន័យបែបនេះ គឺចង់សំដៅទៅលើអគតិធម៌បួនរបស់ចៅក្រមក្នុងការសម្រេចសេចក្តីដែលមាន **ឆន្ទាគតិ ទោសាគតិ ភយាគតិ និងមោហាគតិ** ដោយធម៌បួននេះ ចៅក្រមត្រូវប្រកាន់ភ្ជាប់ក្នុងខ្លួនជានិច្ចពេលធ្វើការសម្រេចសេចក្តីក្នុងរឿងក្តីណាមួយដែលខ្លួនទទួលភារកិច្ច។

## ២.១.១. លក្ខណៈក្នុងការវាយតម្លៃ

ភាពដែលអាចទទួលយកបាននៃភស្តុតាង គឺជាការទទួលស្គាល់ដោយអ្នកច្បាប់ទៅលើផលប្រយោជន៍ ដែលកើតចេញពីប្រភពនៃភស្តុតាងទាំងឡាយ ហើយដោយផលប្រយោជន៍ទាំងនេះវាបានបម្រើមធ្យោបាយមួយ ក្នុងការបញ្ជាក់សក្ខីកម្មបាន។ ហើយនៅក្នុងពេលបំពេញកិច្ចក្នុងប្រព័ន្ធយុត្តាធិការ តុលាការមិនអនុញ្ញាតឱ្យប្រើប្រាស់នូវភស្តុតាងទាំងឡាយណាដែលបំពានច្បាប់នោះឡើយ។ ប៉ុន្តែក្នុងករណីណាដែលភស្តុតាងទទួលបានដែលមានការបំពានច្បាប់ នោះតុលាការត្រូវតែលើកយកហេតុផលមកបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ប៉ុន្តែលើកលែងតែភស្តុតាងដែលបានកើតចេញពីបណ្តឹងនៃរឿងក្តីនោះ។ (តុលាការត្រូវតែបង្ហាញឱ្យឃើញនូវអ្វីដែលភស្តុតាងនោះវាបានបំពានទៅលើច្បាប់)។

ករណី៖ ជនជាប់បានបង្ហាញនូវកិច្ចសន្យាមួយដែលខ្លួន បានធ្វើឡើងជាមួយជនរងគ្រោះ (ជនរងគ្រោះជាអ្នកជំងឺ) និង(ជនជាប់ចោទជាគ្រូពេទ្យ) ដែលនៅក្នុងកិច្ចសន្យានោះបានសរសេរថាខ្លួនមានជំងឺហារីកខួរក្បាលពិបាកទ្រាំរស់នៅណាស់។ ហើយបានធ្វើកិច្ចសន្យាមិនប្តឹងគ្រូពេទ្យទេ ដែលបានជួយចាក់ថ្នាំឱ្យខ្លួន(អ្នកជំងឺ)ឆាប់ស្លាប់។ ជាការពិតណាស់កិច្ចសន្យានេះវាបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងភស្តុតាងនោះ។ ប៉ុន្តែវាមិនអាចធ្វើការដោះបន្ទុកបានទេព្រោះថាវាគឺជា កិច្ចសន្យាខុសច្បាប់។ ជាទូទៅអ្នកដែលមានគំនិតទទួលស្គាល់ភស្តុតាងណាមួយថាមិនអាចទទួលយកបានច្រើនតែកើតចេញពីអ្នកបំពេញកិច្ចស៊ើបអង្កេតដំបូង តុលាការ ជនសង្ស័យ ជនជាប់ចោទ និងមេធាវីជនជាប់ចោទជាដើម។

ហើយនៅក្នុងរឿងព្រហ្មទណ្ឌ ក្រមនីតិវិធីមិនបានចែងពីវិធានក្នុងការវាយតម្លៃទៅលើប្រភេទនៃភស្តុតាងនោះទេ ដោយច្បាប់ផ្តល់សិទ្ធិយ៉ាងធំធេងបំផុតដល់ចៅក្រមជំនុំជម្រះសម្រាប់ធ្វើការវាយតម្លៃទៅលើភស្តុតាងវិញ។ ដូចដែលមានចែងនៅក្នុងមាត្រា ៣២៥ និងមាត្រា ៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលនិយាយអំពីការសួរចម្លើយជនជាប់ចោទ និងការស្តាប់ចម្លើយរបស់ភាគី។ ការផ្តល់សិទ្ធិអំណាចធំធេងក្នុងការវាយតម្លៃទៅលើប្រភេទនៃភស្តុតាងបែបនេះ ប្រធានជំនុំ

ជម្រះមិនអាចចេះតែសម្រេចសេចក្ដីទៅតាមទំនើងចិត្តបាននោះទេ ព្រោះថារាល់ពេលជំនុំជម្រះនៅក្នុងសវនាការម្ដងៗ គឺមានក្រឡាបញ្ជីជាអ្នកសរសេរកំណត់ហេតុ រាល់សំណួរដែលបានសួរ និងចម្លើយដែលបានឆ្លើយ ដូចដែលមានចែងនៅក្នុងមាត្រា ៣៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

លក្ខណៈតូចៗផ្សេងទៀតសម្រាប់ធ្វើការវាយតម្លៃចំពោះភស្តុតាងរួមមាន ៖

## ក. ការវិភាគចំពោះភស្តុតាង

ចំពោះការវិភាគចំពោះភស្តុតាង គឺអាចឆ្លុះបញ្ចាំងអំពីកំរិតសមត្ថភាពរបស់ចៅក្រមដែលមានសិទ្ធិអំណាចនូវក្នុងការសេចក្ដីសម្រេចចំពោះរឿងក្ដី។ វាអាចជាការវាស់កំរិតយល់ដឹងរបស់ចៅក្រមផងដែរទៅលើផ្នែកខាងទ្រឹស្ដីនៃភស្តុតាង ប្រសិនជាគាត់មានការយល់ដឹងខ្ពស់ នោះគាត់អាចធ្វើការវិភាគបានយ៉ាងហ្មត់ចត់ចំពោះខ្លឹមសារនេះ និងសម្ព័ន្ធភាពនៃអង្គហេតុ។

## ខ. ការចែកជាផ្នែកចំពោះភស្តុតាង

ការចែកជាផ្នែកចំពោះភស្តុតាង ឬបណ្ដុំទាំងឡាយនៃភស្តុតាងដែលបានប្រមូលត្រូវបែងចែកទៅតាមប្រភេទរបស់ភស្តុតាង(កិច្ចទៅតាមប្រភេទនៃភស្តុតាង) ដោយឱ្យភស្តុតាងទាំងនោះញែកចេញដាច់ពីគ្នា។ ការធ្វើបែបនេះដើម្បីងាយស្រួលក្នុងកំណត់នូវភស្តុតាងទៅតាមប្រភេទនីមួយៗ។

ក្នុងករណីនេះ៖ ភស្តុតាងដែលប្រមូលបាននៅក្នុងសំណុំរឿងក្ដីមូលមួយស្ដីពីឃាតកម្មដែលមានដូចជា ចម្លើយរបស់បុគ្គលមួយចំនួនមានជាអាទិ៍៖ សាក្សី ជនរងគ្រោះ ដើមបណ្ដឹងរដ្ឋប្បវេណី ជនជាប់ចោទ និងភស្តុតាងជាប្រភេទវត្ថុរួមមាន៖ កាំបិតស្បែកជើងជនល្មើសស្នាមដាននានាជាដើម។ ភស្តុតាងទាំងអស់គឺជាបណ្ដុំ ឬសំណុំមួយនៃអង្គហេតុ ប៉ុន្តែចម្លើយរបស់សាក្សី វត្ថុតាងជាកាំបិត ស្បែកជើង វាគឺជាភស្តុតាងដែលបានញែកចេញពីអង្គហេតុ។ ហើយការធ្វើការចែកបែបនេះគឺ ចង់សំដៅទៅលើប្រភេទនៃភស្តុតាង ដែលមានភស្តុតាងជាវត្ថុ ភស្តុតាងជាសាក្សី ភស្តុតាងជាឯកសារ និងភស្តុតាងជាកំណត់ហេតុស្ដីពីការធ្វើកោសល្យវិច័យជាដើម។

## គ. ការចែកជាផ្នែកឱ្យដាច់ពីគ្នានៃភស្តុតាង

ការចែកជាផ្នែកៗ ចំពោះភស្តុតាងទាំងឡាយដែលស្ថិតក្នុងប្រភេទនៃភស្តុតាង ដោយក្នុងនោះគេត្រូវកំណត់ទៅលើភាគផ្សំរបស់ភស្តុតាង នេះជាការញែកចេញនៅក្នុងភស្តុតាងដោយបញ្ជាក់នូវអង្គហេតុដោយឡែកៗ ឬក៏បញ្ជាក់នូវការអះអាងផ្សេងៗ និងបានបញ្ជាក់នូវលក្ខណៈផ្សេងៗដទៃទៀតដូចជាខណៈនានានៃព្រឹត្តិការណ៍ជាដើម។

ដូចជាស្បែកជើងមានលេខប៉ុន្មាន? មានម៉ាកអ្វី ? មានពណ៌អ្វី? ចាស់ឬថ្មី? ផលិតពីសារធាតុអ្វី? កាំបិតប្រភេទអ្វី? កាំបិតខ្លី ឬវែង?(នេះជាភស្តុតាងជាប្រភេទវត្ថុ)។ ចំពោះចម្លើយវិញ សាក្សី

«ក» បានឃើញជនល្មើសដើរនៅថ្ងៃកើតហេតុ តើស្ថិតក្នុងខណៈណាខ្លះ? ជាពេលព្រឹក ឬពេលល្ងាច ម៉ោង? កាលបរិច្ឆេទ? ដើរទៅណា មកណា? មានកាន់អ្វីឬអត់? ចំពោះស្លាកស្នាមវិញមានទំហំប៉ុន្មាន? ជម្រៅណា? មានប៉ុន្មានកន្លែង? ជាដើម។ល។ មានន័យថាត្រូវតែរំលេចចេញនូវលក្ខណៈសម្បត្តិ ឬអត្តសញ្ញាណនានាទៅលើប្រភេទនៃភស្តុតាង។ ក្នុងគោលបំណងនេះគឺយកប្រភេទនៃភស្តុតាងទៅអង្កន់ឱ្យលំអិតដោយឡែកៗជាបន្តទៀតនោះ គឺដើម្បីឱ្យមានការយល់ដឹងបន្ថែមទៀតទៅលើខណៈនានានៃធាតុផ្សំរបស់អង្គហេតុនោះ។

### ឃ. ការប្រៀបធៀបតាមលំដាប់

ត្រូវធ្វើការប្រៀបធៀបទៅតាមលំដាប់ នៃភស្តុតាងដោយឡែកៗទាំងនោះនូវរាល់ភស្តុតាងនីមួយៗ ជាមួយនឹងវត្ថុធាតុផ្សេងៗទៀត។ ករណីស្នាមដានស្បែកជើង ឬស្នាមជើងមានភាពស៊ីគ្នាឬទេ? តើចម្លើយរបស់សាក្សី «ក» និង«ខ» មានភាពស៊ីសង្វាក់ទៅនឹងខណៈណាមួយនៃភស្តុតាងផ្សេងទៀតឬទេ?

### ង. ការធ្វើសំយោគទៅលើភស្តុតាង

ការធ្វើសំយោគនៃភស្តុតាង គឺជាការទទួលបាននូវសេចក្តីវិនិច្ឆ័យមួយដែលមានកើតចេញពីការងារប្រមូលភស្តុតាងនានា ដោយក្នុងនោះការវិនិច្ឆ័យបែបនេះត្រូវផ្អែកតាមភស្តុតាងទាំងឡាយដែលប្រមូលបានពីស្ថាប័នស៊ើបអង្កេត និងស្ថាប័នតុលាការ។ ការធ្វើសំយោគទៅលើភស្តុតាងបែបនេះ គឺជាការធ្វើសេចក្តីសម្រេចចុងក្រោយមួយបន្ទាប់ពីការធ្វើ ការវិភាគរួចរាល់ ការធ្វើ សំយោគ និងការវាយតម្លៃទៅលើភស្តុតាងទាំងអស់នេះ វាមិនអាចស្ថិតនូវម្នាក់ឯងបានទេ ដោយការធ្វើការវិភាគ និងការធ្វើសំយោគ វាមានទំនាក់ទំនងគ្នាមិនអាចកាត់ផ្តាច់បានឡើយអំពីសម្ព័ន្ធភាពនៃខ្លឹមសារ។

### ២.១.២. ការជឿជាក់ទៅលើភស្តុតាង

អំពីការជឿជាក់របស់អ្នកស៊ើបអង្កេត ព្រះរាជអាជ្ញា និងតុលាការទៅលើភស្តុតាង ក្នុងន័យនេះភាពជឿជាក់នៃភស្តុតាង អ្នកស៊ើបអង្កេត ព្រះរាជអាជ្ញា និងតុលាការត្រូវតែធ្វើការវាយតម្លៃទៅលើភស្តុតាងទាំងឡាយណាដែលពួកគេទទួលបានមកពីសកម្មភាពនានាដែលពួកគេបានបំពេញ។ កិច្ចដំបូងនោះ អ្នកមានសមត្ថកិច្ចត្រូវធ្វើការផ្ទៀងផ្ទាត់ទៅលើប្រភពនៃអ្នកផ្តល់ភស្តុតាងថាមានគុណសម្បត្តិបែបណាចំពោះភស្តុតាងដែលបានផ្តល់ឱ្យនោះ។

ចំពោះករណី ការផ្ទៀងផ្ទាត់ទៅលើសាក្សីមិនត្រឹមតែត្រូវធ្វើទៅលើការបំភ្លឺរបស់គាត់ប៉ុណ្ណោះទេ ប៉ុន្តែត្រូវតែបញ្ជាក់អំពីការទទួលបានអង្គហេតុមធ្យោបាយ និងការចងចាំនានារបស់សាក្សីនោះផងដែរ។

ហើយក៏ត្រូវធ្វើការពិនិត្យផងដែរ ទៅលើភាពគ្រប់គ្រាន់នៃភស្តុតាងផងដែរ ដែលជាមូលដ្ឋានគ្រឹះមួយដែលកើតចេញពីការប្រមូលភស្តុតាងទាំងឡាយដោយមូលដ្ឋានគ្រឹះនេះអាចកំណត់បាននូវអត្ថិភាពនៃខណៈនានា ដែលខណៈទាំងនោះបានឆ្ពោះទៅរកការបញ្ជាក់ពីសក្ខីកម្មបាន។ ស្ថាប័នយុត្តាធិការត្រូវធ្វើការផ្ទៀងផ្ទាត់ឱ្យបានពេញលេញទៅលើកិច្ចការទាំងឡាយនៃការប្រមូលភស្តុតាងគ្រប់ដំណាក់កាលនៃចំណាត់ការរឿងក្តីទាំងអស់។ ប្រសិនបើភស្តុតាងទាំងឡាយពុំមានមូលដ្ឋានកំណត់នូវខណៈនានាទេ មានន័យថាភស្តុតាងទាំងនោះមិនអាចក្លាយជាកម្មវត្ថុនៃការបញ្ជាក់សក្ខីកម្មបានទេ។

ចំពោះការជឿជាក់ ឬមិនជឿជាក់គ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់ ការបញ្ជាក់បាន ឬមិនអាចបញ្ជាក់បានទៅលើខណៈទាំងឡាយនោះ វាជាកាតព្វកិច្ចរបស់អ្នកដែលមានសិទ្ធិធ្វើការបញ្ជាក់សក្ខីកម្ម។ (ស្ថាប័នស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា និងចៅក្រម)។

## ២.២. ភស្តុតាងពេញលេញ ឬលក្ខណៈពេញលេញនៃភស្តុតាង

នៅក្នុងរឿងក្តីនីមួយៗមានចំណុចអង្គហេតុជាច្រើនរួមគ្នា ទើបបង្កើតបានជាដំណើររឿងមួយ ចាត់តាំងពីមុនពេលកើតហេតុ ពេលកើតហេតុ នឹងក្រោយពេលកើតហេតុ។ ដូច្នេះលក្ខណៈពេញលេញនៃភស្តុតាង គឺជាភស្តុតាងដែលបញ្ជាក់បាននូវគ្រប់ចំណុចនៃអង្គហេតុ ពោលគឺមិនត្រូវមានភាពខ្វះចន្លោះនូវចំណុចណាមួយនៃអង្គហេតុឡើយ។ ភាពខ្វះចន្លោះមិនអាចឱ្យយើងតភ្ជាប់នូវដំណើររឿងក្តីនោះបានទេ ហើយលក្ខណៈពេញលេញនៃភស្តុតាង គឺត្រូវតែបញ្ជាក់ប្រាប់ ពីឬសគល់រហូតដល់មែកធាងនៃអង្គហេតុ។

### ២.២.១. លក្ខណៈគ្រប់គ្រាន់នៃភស្តុតាង

លក្ខណៈគ្រប់គ្រាន់នៃភស្តុតាង ត្រូវពិនិត្យមើលថា តើភស្តុតាងដែលស្រាវជ្រាវប្រមូលបានមកនោះមានលក្ខណៈគ្រប់គ្រាន់ដើម្បីធ្វើជាមូលដ្ឋានសម្រាប់កំណត់អង្គហេតុ និងអង្គច្បាប់បានហើយឬនៅ? បើពិនិត្យឃើញថាមិនទាន់គ្រប់គ្រាន់ទេស្រាវជ្រាវបន្ថែមទៀត។ ប៉ុន្តែបើពិនិត្យឃើញថាមានលក្ខណៈគ្រប់គ្រាន់ហើយនោះ មិនចាំបាច់ស្រាវជ្រាវយកចម្លើយសាក្សីដែលបានដឹងបានឮនូវរឿងក្តីបន្ថែមទៀតទេ។

ដូចជារឿងក្តីមួយជនជាប់ចោទបានឆ្លើយសារភាព មានលក្ខណៈស៊ីសង្វាក់គ្នានឹងចម្លើយជនរងគ្រោះស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់សាក្សី ស៊ីសង្វាក់គ្នាទៅនឹងវត្ថុតាង និងស៊ីសង្វាក់គ្នាទៅនឹងលិខិតគតិយុត្តិនានា។ ប្រសិនយើងអាចកំណត់បាននូវអង្គហេតុ និងអង្គច្បាប់នៃរឿងនេះបានគ្រប់គ្រាន់ ដូច្នេះហើយមិនចាំបាច់ស្រាវជ្រាវយកចម្លើយសាក្សីដែលបានដឹងឮក្នុងរឿងក្តីនេះទៀតទេ។

ភស្តុតាងត្រូវមានលក្ខណៈច្បាស់លាស់មិនមែនមានលក្ខណៈស្រពិចស្រពិលទេ អ្វីជាភាពច្បាស់លាស់? គ្មានការភ័ន្តច្រឡំគ្នា គ្មានភាពស្រពិចស្រពិល ដែលអាចឱ្យយើងយកមកធ្វើជាមូលដ្ឋាន ដើម្បីកំណត់បាននូវអង្គហេតុ និងអង្គច្បាប់។ ដើម្បីភាពច្បាស់លាស់ ភស្តុតាងទាមទារឱ្យមានការវិភាគ និងពិចារណាតាមបែបផែនបច្ចេកទេសវិទ្យាសាស្រ្តផងដែរ។

ភស្តុតាងត្រូវតែមានលក្ខណៈជាក់លាក់ ដោយភស្តុតាងទាំងឡាយអាចនឹងបញ្ជាក់បានអំពីទំនាក់ទំនងរវាងហេតុ និងផលហើយអំពីអត្តសញ្ញាណជនប្រព្រឹត្តបទល្មើស និងវត្ថុតាង។ ថាតើព្យសនកម្មដែលមានលើជនរងគ្រោះប្រាកដជាបណ្តាលមកពីអំពើរបស់ជនជាប់ចោទមែនដែរឬទេ? ជនជាប់ចោទពិតជាអ្នកដែលប្រព្រឹត្តិបទល្មើសមែនដែរឬទេ? ឬអាចមានការភ័ន្តច្រឡំ? ហើយរាល់វត្ថុតាងដែលត្រូវរឹបអូសនានាពិតជាវត្ថុតាង នៃអំពើល្មើសមែនដែរឬទេ?

នៅក្នុងលក្ខណៈពិតប្រាកដនៃភស្តុតាងវិញ ត្រូវតែមានលក្ខណៈពិតប្រាកដ ហើយលក្ខណៈនៃភស្តុតាងនេះ គឺជាភស្តុតាងដែលគ្មានការក្លែងបន្លំ គ្មានការភូតកុហក គ្មានការបោកបញ្ឆោត គ្មានការប្រឌិត គ្មានការគំរាមកំហែង និងគ្មានការបង្ខិតបង្ខំណាមួយឡើយ។ ភស្តុតាងទាំងនោះបានមកដោយកិច្ចប្រតិបត្តិការរបស់មន្រ្តីមានសមត្ថកិច្ចដោយអនុវត្តត្រឹមត្រូវតាមច្បាប់ និងបានមកពីភាគីដែលបានដាក់ជូននូវភស្តុតាងដែលប្រកបដោយស្មារតីសុច្ចរិត និងទៀងត្រង់ដែលវាស្របទៅនឹងច្បាប់ដែលបានកំណត់។

ម្យ៉ាងវិញទៀតភស្តុតាងត្រូវតែមានភាពស៊ីសង្វាក់គ្នា ដើម្បីកំណត់បានអំពីអង្គហេតុជាក់លាក់ និងកំណត់ឱ្យបានត្រឹមត្រូវទៅតាមអង្គច្បាប់ក្នុងរឿងក្តីព្រហ្មទណ្ឌណាមួយ ភស្តុតាងទាំងឡាយត្រូវតែមានភាពស៊ីសង្វាក់គ្នារវាងភស្តុតាងផ្ទាល់និងភស្តុតាងផ្ទាល់រវាងភស្តុតាងផ្ទាល់ទៅនឹងភស្តុតាងប្រយោល ហើយត្រូវតែស្របគ្នាទៅនិងអង្គហេតុ ដែលមិនប្រែប្រួលឬហៅថា"ដើមកំណើតនៃភស្តុតាង"។

## ២.៣. អានុភាពនៃការវាយតម្លៃលើភស្តុតាង

អានុភាពនៃការវាយតម្លៃទៅលើភស្តុតាងរបស់មន្រ្តីនគរបាលយុត្តិធម៌ បើសិនណាជាមន្រ្តីនគរបាលយុត្តិធម៌វាយតម្លៃថាមានភស្តុតាងដាក់បន្ទុកទៅលើជនប្រព្រឹត្តល្មើស មន្រ្តីនគរបាលយុត្តិធម៌អាចកំណត់បាននូវជនសង្ស័យ ហើយនឹងបញ្ជូនសំណុំរឿង ព្រមទាំងជនសង្ស័យទៅតំណាងអយ្យការ ដើម្បីធ្វើបណ្តឹងអាជ្ញាចោទប្រកាន់ជននោះស្របទៅតាមនីតិវិធី បើប្រសិនណាក្នុងករណីគ្មានវត្តមានជនសង្ស័យទេ មន្រ្តីនគរបាលយុត្តិធម៌ក៏អាចបញ្ជូនសំណុំរឿងទៅឱ្យតំណាងអយ្យការបានដែរ។

ប៉ុន្តែក្នុងករណីមន្ត្រីនគរបាលយុត្តិធម៌វាយតម្លៃថា គ្មានភស្តុតាងសម្រាប់ដាក់បន្ទុកទៅលើជនប្រព្រឹត្តិបទល្មើសទេ មន្ត្រីនគរបាលយុត្តិធម៌ ក៏ត្រូវតែបញ្ជូនសំណុំរឿងទៅកាន់តំណាងអយ្យការដែរ ព្រោះខ្លួនគ្មានសិទ្ធិអំណាចតម្កល់រឿងឥតចាត់ការបានឡើយ។ ក្នុងករណីដែលមានជនប្រព្រឹត្តិបទល្មើសច្រើននាក់ ត្រូវបានឃាត់ខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌ បើមន្ត្រីនគរបាលយុត្តិធម៌យល់ឃើញថាគ្មានភស្តុតាងដាក់បន្ទុកទៅលើជនទាំងឡាយនោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំយោបល់ពីតំណាងអយ្យការ ហើយសម្រេចដោះលែងជនទាំងនោះវិញដោយមានការយល់ព្រមពីតំណាងអយ្យការតាមរយៈដីកាសម្រេចរបស់តំណាងអយ្យការ។

### ២.៣.១. អានុភាពនៃការវាយតម្លៃដោយតំណាងអយ្យការចំពោះភស្តុតាង

ក្នុងករណីដែលព្រះរាជអាជ្ញាយល់ឃើញថា មានភស្តុតាងដាក់បន្ទុកទៅលើជនសង្ស័យនោះនាំឱ្យតំណាងអយ្យការធ្វើបណ្តឹងអាជ្ញាចោទប្រកាន់ទៅលើជនសង្ស័យនោះ។តំណាងអយ្យការមានសមត្ថកិច្ចក្នុងការធ្វើបណ្តឹងអាជ្ញាដូចជា៖

- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ
- ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ឬភ្លាម
- ដីកាសន្និដ្ឋានស្ថាពរ
- បើគ្មានភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកទៅលើជនសង្ស័យបានទេ តំណាងអយ្យការ ត្រូវសម្រេចដោះលែងជនជាប់ចោទ ហើយតម្កល់រឿងទុកឥតចាត់ការបាន។

### ២.៣.២. អានុភាពនៃការវាយតម្លៃដោយចៅក្រមស៊ើបសួរចំពោះភស្តុតាង

ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្ត រាជធានី និងតុលាការយោធាប្រសិនណាយល់ឃើញថា ៖

- មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ហើយនោះ ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿង និងជនជាប់ចោទទៅជំនុំជម្រះតែម្តង
- តែបើគ្មានភស្តុតាងដាក់បន្ទុកទេ ជនជាប់ចោទត្រូវបានដោះលែងឱ្យមានសេរីភាពវិញ

### ២.៣.៣. អានុភាពនៃវាយតម្លៃក្នុងពេលជំនុំជម្រះ

ប្រសិនបើការវាយតម្លៃរបស់ចៅក្រមជំនុំជម្រះយល់ឃើញថា មានភស្តុតាងដាក់បន្ទុកទៅលើជនជាប់ចោទ អានុភាពនៃការវាយតម្លៃទៅលើភស្តុតាងនេះត្រូវធ្វើការចោទប្រកាន់ទៅលើជនជាប់ចោទនោះ តែបើការវាយតម្លៃរបស់ចៅក្រមជំនុំជម្រះយល់ឃើញថា ពុំមានតម្លៃគ្រប់គ្រាន់ ភស្តុ

តាងនោះមិនអាចដាក់បន្ទុកបានទេ ដែលជនជាប់ចោទត្រូវបានសម្រេចឱ្យរួចផុតពីការចោទប្រកាន់។

### ២.៣.៤. អានុភាពនៃការសម្រេចលើកលែងការចោទប្រកាន់

កាលណាចៅក្រមស៊ើបសួរ ឬក៏ចៅក្រមរឹបអូសជំនុំជម្រះសម្រេចលើកលែងការចោទប្រកាន់ ហើយសម្រេចឱ្យរួចផុតពីបទចោទនោះ វត្ថុតាងដែលបានរឹបអូសពីជនជាប់ចោទកន្លងមកត្រូវតែប្រគល់ឱ្យទៅជនជាប់ចោទ ឬជនសង្ស័យវិញ លើកលែងតែវត្ថុតាងណាដែលច្បាប់បានហាមឃាត់តែប៉ុណ្ណោះ។

ជនជាប់ចោទដែលបានរួចខ្លួនពីការចោទប្រកាន់តាមរយៈដីការលើកលែងការចោទប្រកាន់ចូលជាស្អាតហើយបុគ្គលនោះអាចមានសិទ្ធិប្ដឹងសុំការជួសជុលសំណងជំងឺចិត្ត និងការខូចខាតពីដើមបណ្ដឹងរដ្ឋប្បវេណីបាន។

### ២.៤. ការមោឃភាពចំពោះកិច្ចនៃនីតិវិធី

មានតែសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ប៉ុណ្ណោះ ដែលមានសមត្ថកិច្ចដើម្បីពិនិត្យទៅលើមោឃភាពនៃនីតិវិធីថាតើការបំពេញកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរស្របទៅតាមវិធាន និងទម្រង់ដែលមានចែងនៅក្នុងនីតិវិធីព្រហ្មទណ្ឌស្ដីពីបទបញ្ញត្តិទូទៅនៃនីតិវិធីស៊ើបសួរដែរ ឬយ៉ាងណា? ហើយការដែលមិនគោរពនូវវិធាន និងទម្រង់ស្ដីអំពីនីតិវិធីស៊ើបសួរនេះនាំឱ្យសភាស៊ើបសួរមោឃភាពចំពោះកិច្ចនៃនីតិវិធីណាមួយនោះ តាមរយៈប្ដឹងទាមទារពីចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ឬជនជាប់ចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏មេធាវីរបស់ជនត្រូវចោទ និងមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រសិនពួកគេយល់ឃើញថាលិខិតណាមួយនៃនីតិវិធីនោះមានមោឃភាព[27]។

សភាស៊ើបសួរផ្ទៀងផ្ទាត់មើលជាអាទិ៍ លក្ខណៈនៃការអនុវត្តបទបញ្ញត្តិស្ដីពីអំពីការឃុំខ្លួនបណ្ដោះអាសន្នដីកាតុលាការផ្សេងៗ ដីកាចាត់ឱ្យស៊ើបសួរជំនួស និងកោសល្យវិច្ច័យ ព្រមទាំងរ៉ាប់រង ពិនិត្យមើលកុំឱ្យនីតិវិធីទាំងឡាយមានការយឺតយ៉ាវដោយមិនសមហេតុផល[28]។

[27] មាត្រា២៥៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[28] មាត្រា២៨៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ២.៤.១. ការសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលសភាស៊ើបសួរលើកមកជំនុំជម្រះ

សភាស៊ើបសួរមានសិទ្ធិពិនិត្យ និងសម្រេចលើកយកដីកាសម្រេចរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូង មកធ្វើការជំនុំជម្រះបានដូចជា ៖

- ដីកាសម្រេចឃុំខ្លួន
- ដីកាសម្រេចមិនឃុំខ្លួន
- ដីកាដោះលែងឱ្យជនត្រូវចោទនៅក្រៅឃុំបណ្ដោះអាសន្ន
- ដីកាលើកលែងចោទប្រកាន់
- ដីកាបដិសេធពាក្យសុំធ្វើកិច្ចស៊ើបសួរ
- ដីកាសម្រេចមិនព្រមប្រគល់វត្ថុតាងឱ្យម្ចាស់ដើមវិញ
- ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសល្យវិច័យ ឬពាក្យសុំឱ្យធ្វើកោសល្យវិច្ច័យបន្ថែម ឬពាក្យសុំឱ្យធ្វើប្រតិបត្តិកោសល្យវិច្ច័យ
- ដីកាសម្រេចដាក់ត្រួតពិនិត្យតាមផ្លូវតុលាការ

### ២.៤.២. ការបង្ហាញភស្តុតាងដាក់បន្ទុកក្នុងពេលសវនាការ

តំណាងអយ្យការ គឺជាម្ចាស់បណ្ដឹងអាជ្ញា ដូច្នេះដើម្បីការពារនូវបណ្ដឹងរបស់ខ្លួនតំណាងអយ្យការមានតួនាទីជាអ្នកបង្ហាញនូវភស្តុតាងដាក់បន្ទុកទៅលើជនត្រូវចោទក្នុងពេលសវនាការ។ ការបង្ហាញភស្តុតាងនេះ តំណាងអយ្យការត្រូវបង្ហាញភស្តុតាងឱ្យឃើញនូវភស្តុតាងទាំងឡាយណាដែលកំណត់បាននូវអង្គហេតុពិតប្រាកដច្បាស់លាស់ និងឱ្យហួសពីការមន្ទិលសង្ស័យ។

### ២.៤.៣. បន្ទុកជាចម្បងរបស់ព្រះរាជអាជ្ញា

នៅក្នុងរឿងក្ដីព្រហ្មទណ្ឌ ដែលមានការពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិបទល្មើសអ្វីមួយដែលអំពើល្មើសទាំងនោះ បានធ្វើឱ្យមានការប៉ះពាល់ដល់សណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ និងសន្តិសុខរបស់សង្គម។

កាលណាមានបទល្មើសកើតឡើងនាំឱ្យមានទំនាស់រវាងជនល្មើស និងសង្គមផ្ទុយពីសណ្ដាប់ធ្នាប់សាធារណៈរដ្ឋប្បវេណីល្អ។ ដូច្នេះហើយដើម្បីការពារផលប្រយោជន៍សង្គមច្បាប់បានប្រគល់សិទ្ធិអំណាចឱ្យស្ថាប័នតុលាការ ដើម្បីធ្វើការស្វែង និងបង្ហាញភស្តុតា ដាក់បន្ទុកទៅលើជនណាម្នាក់ថាបានប្រព្រឹត្តិបទល្មើស (ស្ថាប័នអយ្យការ)។

ដោយផ្អែកលើគោលការណ៍សច្ចធារណ៍នៃនិរទោសមានន័យថា ជនជាប់ចោទគ្មានកាតព្វកិច្ចបង្ហាញភស្តុតាងដោះបន្ទុកនោះទេ ដូច្នេះដើម្បីអាចដាក់ទោសទៅលើជនជាប់ចោទបាន លុះត្រាតែព្រះរាជអាជ្ញា ដែលជាអ្នកការពារផលប្រយោជន៍ជូនសង្គម ត្រូវតែធ្វើការបង្ហាញនូវរាល់ភស្តុតាងដាក់បន្ទុកមកលើជនជាប់ចោទឱ្យហួសពីមន្ទិលសង្ស័យ បើមិនដូច្នេះទេ ជនជាប់ចោទនឹងត្រូវរួចខ្លួន។

## ២.៥. បន្ទុកបង្ហាញភស្តុតាងជាបន្ទាប់បន្សំ

ថ្វីត្បិតតែការបង្ហាញវាជាកាតព្វកិច្ចរបស់ព្រះរាជអាជ្ញាក៏ពិតមែន ប៉ុន្តែក៏បានអនុញ្ញាតឱ្យជនរងគ្រោះដែលជាម្ចាស់បណ្តឹងរដ្ឋប្បវេណី ឬជនជាប់ចោទបង្ហាញភស្តុតាងក្នុងពេលសវនាការដែរ។

ជនរងគ្រោះនៅចំពោះមុខតុលាការព្រហ្មទណ្ឌ ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចបង្ហាញភស្តុតាងដាក់បន្ទុកទៅលើជនជាប់ចោទដូចជា ការបង្ហាញអំពីអត្ថិភាពនៃបទល្មើសការចង្អុល បង្ហាញអំពីអត្តសញ្ញាណរបស់ជនល្មើស ឬបង្ហាញពីព្យសនកម្មទាំងខាងផ្លូវកាយផ្លូវចិត្ត ឬសម្ភារៈកើតពីអំពើល្មើសរបស់ជនជាប់ចោទជាដើម។ ការបង្ហាញភស្តុតាងទាំងនេះជនរងគ្រោះអាចធ្វើតាមរយៈខ្លួនឯងផ្ទាល់ ឬមេធាវីរបស់ខ្លួន។

ចំពោះជនជាប់ចោទវិញគឺជាជនដែលត្រូវតំណាងអយ្យការធ្វើការចោទប្រកាន់ ថាបានប្រព្រឹត្តិបទល្មើសអ្វីមួយ។ តាមគោលការណ៍សច្ចធារណ៍នៃនិរទោសជនជាប់គ្មានកាតព្វកិច្ចក្នុងការស្វែងរកភស្តុតាងដោះបន្ទុកទេ ក៏ប៉ុន្តែជនជាប់ចោទមានសិទ្ធិស្វែងរក និងបង្ហាញភស្តុតាងដោះបន្ទុក ពីការចោទប្រកាន់របស់តំណាងអយ្យការបាន។ ហើយការស្វែងរក និងការបង្ហាញភស្តុតាងតតាំងរបស់ជនជាប់ចោទ គឺមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ជនជាប់ចោទ ដើម្បីបង្ហាញពីអត្ថិភាព នៃមូលហេតុដែលអាចនាំឱ្យមានការមិនទទួលខុសត្រូវខាងព្រហ្មទណ្ឌ។

ដោយការបង្ហាញភស្តុតាងទាំងនេះអាចធ្វើឡើងតាមរយៈជនជាប់ចោទខ្លួនឯង ឬតាមរយៈអ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី ឬតាមរយៈមេធាវីរបស់ជនជាប់ចោទ។

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវ ក៏ដូចជាធ្វើការតាក់តែងនូវសារណាស្ដីអំពីភស្តុតាងនៅក្នុងរឿងក្ដីព្រហ្មទណ្ឌរួចមក បានធ្វើឲ្យយើងអាចយល់ដឹងកាន់តែច្បាស់អំពីអ្វីទៅជាភស្តុតាងនៅក្នុងបទល្មើសព្រហ្មទណ្ឌដើម្បីឲ្យស្របទៅតាមនីតិវិធីច្បាប់។ ក្នុងនោះផងដែរយើងក៏អាចស្វែងយល់នៅផលវិបាកនានាក្នុងប្រព័ន្ធយុត្តាធិការរបស់ប្រទេសកម្ពុជា។ គ្រប់បទល្មើសទាំងឡាយដែលកើតមានឡើងនៅក្នុងសង្គមទោះបីជារឿងក្ដីរដ្ឋប្បវេណី ឬព្រហ្មទណ្ឌក៏ដោយមុននឹងឈានទៅដល់ការចោទប្រកាន់ឬធ្វើការសម្រេចសេចក្ដីទៅលើជនណាម្នាក់នោះ ជាការចាំបាច់បំផុតត្រូវតែពឹងផ្អែកទៅលើភស្តុតាងជាដាច់ខាតដើម្បីអាចជាមូលដ្ឋាននៃការកាត់សេចក្ដី។ ស្ថាប័នយុត្តាធិការជាស្ថាប័នដែលមានសមត្ថកិច្ចត្រូវស្វែងរក និងស្រាវជ្រាវឲ្យឃើញនូវមូលហេតុព្រមទាំងភស្តុតាងឱ្យបានច្បាស់លាស់និងពិតប្រាកដដែលបានជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុនៃរឿងក្ដីជាមុនសិនទើបចៅក្រម ឬព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់ឬដោះលែងជនសង្ស័យនោះ។ ការស្រាវជ្រាវនិងស្វែងរកភស្តុតាងនេះផងដែរត្រូវបានបញ្ញត្តិក្នុងច្បាប់ ដែលតម្រូវឲ្យអ្នកអនុវត្តត្រូវតែគោរពតាមជាដាច់ខាតផងដែរ។ គ្រប់ដំណើរការស៊ើបអង្កេតនិងស៊ើបសួរទាំងអស់របស់ស្ថាប័នយុត្តាធិការជាទង្វើដែលមានសារៈសំខាន់ក្នុងការជួយឲ្យប្រព័ន្ធយុត្តិធម៌មានដំណើរការល្អ និងមានតម្លាភាពក្នុងការអនុវត្តច្បាប់ ហើយក៏អាចកំណត់បានយ៉ាងច្បាស់លាស់អំពីអត្ថិភាពនៃបទល្មើស និងការដាក់ទណ្ឌកម្មទៅតាមកំហុសឆ្គងរបស់ជនល្មើស ព្រមទាំងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋចំពោះបញ្ហាជាច្រើនដែលពាក់ព័ន្ធនៅក្នុងរឿងក្ដីផងដែរ។ នេះសបញ្ជាក់ឱ្យឃើញថាតួនាទីនិងមុខងាររបស់ស្ថាប័នយុត្តាធិការជាពិសេសមន្ត្រីនគរបាលយុត្តិធម៌ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរបានចូលរួមយ៉ាងសកម្មក្នុងការប្រតិបត្តិនិងការអនុវត្តច្បាប់។ជាងនេះទៅទៀតនៅក្នុងជំពូកនីមួយនៃសារណាក៏បានបង្ហាញអំពីមធ្យោបាយនៃការបង្ហាញភស្តុតាង និងការពន្យល់ការបកស្រាយយ៉ាងក្បោះក្បាយផងដែរអំពីប្រភេទភស្តុតាងដើម្បីជាឯកសារជំនួយទៅដល់ការបំពេញមុខងាររបស់មន្ត្រី នគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរផងដែរទាក់ទងទៅនឹងការស៊ើបអង្កេតការស្វែងរកភស្តុតាងការកំណត់ទៅលើទម្រង់ភស្តុតាងនៃបទល្មើសព្រហ្មទណ្ឌ ព្រមទាំងបង្ហាញអំពីប្រភពទាំងឡាយរបស់ភស្តុតាងតម្លៃនៃសក្ខីភាពរបស់សាក្សីដែលជាធាតុផ្សំដ៏សំខាន់មួយមុននឹងឈានទៅដល់នីតិវិធីនៃការជំនុំជម្រះ។ សម្រាប់ប្រទេសកម្ពុជាឃើញថាការអនុវត្តច្បាប់យុទ្ធសាស្ត្រក្នុងការស្រាវជ្រាវនិងបច្ចេកទេសក្នុងការស៊ើបអង្កេតស្វែងរកភស្តុតាងនៅមានកំរិតនៅឡើយ ដែលអាចនិយាយបានថាមានចន្លោះប្រហោងមួយចំនួននៅពេលប្រតិបត្តិ។ ដោយសារតែនាពេលបច្ចុប្បន្ននៅពេលមានការ

ប្រព្រឹត្តបទល្មើស និងការបំបាត់ដាននៃភស្តុតាងរបស់ជនល្មើសមានលក្ខណៈជឿនលឿន ដែលមានការប្រើប្រាស់បច្ចេកទេស និងស្របទៅតាមយុគ្គសម័យផងដែរ។

ដូច្នេះហើយទាមទារឲ្យស្ថាប័នយុត្តាធិការនេះត្រូវពង្រីកនូវបច្ចេកទេស និងបទពិសោធន៍កាន់តែខ្ពស់ក្នុងការស្វែងរកភស្តុតាងដាក់បន្ទុក និងដោះបន្ទុកឲ្យបានគ្រប់គ្រាន់ទៅតាមនីតិវិធី និងក្បួនខ្នាតត្រឹមត្រូវតាមច្បាប់កំណត់។

# អនុសាសន៍

ដើម្បីការអនុវត្តច្បាប់ និងការស្រាវជ្រាវភស្តុតាងនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានភាពកាន់តែល្អប្រសើរបន្ថែមទៀតនោះ យើងខ្ញុំសូមជូននៅអនុសាសន៍មួយចំនួនដូចខាងក្រោមនេះ ៖

សូមឱ្យក្រសួងយុត្តិធម៌ធ្វើការជ្រើសរើសអ្នកបម្រើការការងារនៅក្នុងវិស័យយុត្តិធម៌ (ព្រះរាជអាជ្ញា ចៅក្រម ...) ដោយសុក្រឹតភាព គ្មានអំពើពុករលួយគ្រប់ការប្រឡងជ្រើសរើសត្រូវតែឆ្លងកាត់គណៈកម្មការត្រួតពិនិត្យយ៉ាងលំអិត និងកើតចេញពីសមត្ថភាពពិត គ្មានការស៊ីសំណូក។

ក្រសួងយុត្តិធម៌ គួរណាស់តែសហការជាមួយក្រសួងអប់រំ ដើម្បីត្រួតពិនិត្យទៅសាកលវិទ្យាល័យនានាដែលមានបង្រៀនមុខវិជ្ជា នីតិសាស្ត្រ ហើយបញ្ជូនអ្នកជំនាញផ្នែកភស្តុតាងរបស់ខ្លួនទៅតាមសាកលវិទ្យាល័យនោះ ដើម្បីធ្វើបទបង្ហាញអំពីគោលការណ៍នៃការកំណត់ និងរបៀបស្រាវជ្រាវភស្តុតាងដល់និស្សិត ដែលកំពុងសិក្សានៅសាលា ឬក៏ធ្វើការផ្សព្វផ្សាយជាធារណៈ អំពីនីតិវិធីក្នុងការទទួលបានភស្តុតាងដែលស្របច្បាប់យ៉ាងតិចបីខែម្តង ដើម្បីឱ្យអ្នកសិក្សាលើជំនាញនីតិសាស្ត្រអាចចូលរួមទទួលចំណេះដឹងបន្ថែមទៀត។ លើសពីនេះទៅទៀតនោះសម្រាប់ការបង្រៀនទូទៅលើមុខវិជ្ជានីតិសាស្ត្រនេះ ក្រសួងយុត្តិធម៌ និងក្រសួងអប់រំ គួរតែមានការសហការគ្នា ដើម្បីអាចអនុញ្ញាតឱ្យ សិស្សានុសិស្សដែលកំពុងសិក្សារៀនសូត្រមានការចុះទៅសិក្សាផ្ទាល់នៅទីកន្លែងអនុវត្តនីតិវិធី(សាជំបូងរាជធានីខេត្ត សាលាឧទ្ធរណ៍ ឬតុលាការកំពូល.......) ដើម្បីជាការពង្រឹងនៅចំណេះដឹងនានាបន្ថែមទៀតដែលមាននៅក្នុងការអនុវត្តប្រចាំថ្ងៃ។

ហើយលើសពីនេះចំពោះ សិស្សចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការត្រូវខិតខំសិក្សា ដោយយកចិត្តទុកដាក់បំផុត ពីព្រោះថាវាជាមូលដ្ឋានដ៏សំខាន់សម្រាប់អ្នកអនុវត្តន៍ច្បាប់។

ព្រះរាជអាជ្ញា ចៅក្រម ឬអ្នកប្រកបវិជ្ជាជីវៈនៅក្នុងវិស័យតុលាការ ត្រូវតែប្រកាន់ភ្ជាប់នូវវិជ្ជាជីវៈរបស់ខ្លួនដោយមិនត្រូវយកការសង្ស័យណាមួយដែលគ្មានភស្តុតាងមកធ្វើការសម្រេចសេចក្តីទេ ពោលគឺរាល់ការធ្វើសេចក្តីសម្រេចត្រូវផ្អែកលើគោលការណ៍នៃភស្តុតាងដែលបានកំណត់ដោយច្បាប់ មិនមែនជាភស្តុតាងដែលមានចរិតលក្ខណៈទុច្ចរិតឡើយ។

មន្ត្រីនគរបាលយុត្តិធម៌ ដែលជាអ្នកអនុវត្តច្បាប់ផ្ទាល់ និងជាអ្នកស្រាវជ្រាវភស្តុតាង ចំពោះបទល្មើសនានាដែលបានកើតឡើងផងនោះ គួរតែបានសិក្សាច្បាស់លាស់អំពីនីតិវិធីនៃការប្រមូលភស្តុតាង ការពិនិត្យភស្តុតាង ព្រមទាំងនីតិវិធីនានាផ្សេងទៀតដែលត្រូវយកមកប្រើប្រាស់ដើម្បីបំពេញភារកិច្ច។ ព្រោះថាសព្វថ្ងៃនេះ មន្ត្រីនគរបាលយុត្តិធម៌មួយចំនួនពុំសូវបានយល់ដឹងអំពីនីតិវិធីក្នុងការស្រាវជ្រាវភស្តុតាងនេះនូវមានកម្រិត។ ហេតុដូចនេះហើយ ក្រសួងមានសមត្ថកិច្ចគួរតែ

បើកវគ្គបណ្តុះបណ្តាលបន្ថែមដល់មន្ត្រីនគរបាលយុត្តិធម៌ ស្តីអំពីការស្រាវជ្រាវភស្តុតាងឱ្យបានជាប្រចាំជាពិសេសនោះគឺ ការប្រើប្រាស់នៅបច្ចេកវិទ្យានានាដែលមានស្រាប់ដើម្បីជាភាពងាយស្រួល និងឆាប់ រហ័សក្នុងការបំពេញភារកិច្ច។

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៣ ខែ កញ្ញា ឆ្នាំ ១៩៩៣
- ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសអោយប្រើនៅថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០០៧ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌ ប្រកាសអោយប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១០
- ច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤ ។

## សៀវភៅ និងអត្ថបទផ្សេងៗ

- សៀវភៅ **នីតិភស្តុតាង** សាស្ត្រាចារ្យ **អ៊ុន បូផា** បោះពុម្ពលើកទី២ ឆ្នាំ ២០១៦
- សៀវភៅ **នីតិវិធីព្រហ្មទណ្ឌ** លោកសាស្ត្រាចារ្យ**រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ**ចាំង ស៊ីណា** បោះពុម្ពឆ្នាំ ២០១៥
- សៀវភៅ **ភស្តុតាងក្នុងរឿងក្តីព្រហ្មទណ្ឌ** សាស្ត្រាចារ្យ **ហ៊ីង ធីឫទ្ធិ** បោះពុម្ពលើកទី១ ឆ្នាំ ២០០៨ ។

## ឧបសម្ព័ន្ធ
## និតិវិធីក្នុងការធ្វើសម្បថ

ការធ្វើសច្ចាប្រណិធាន ត្រូវដឹកនាំដោយក្រឡាបញ្ជីមួយរូប ហើយត្រូវធ្វើនៅចំពោះមុខវត្ថុសក្តិសិទ្ធិ នៅទីកន្លែងនៃតុលាការនីមួយៗ ។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀន ធូប បូជាចំពោះវត្ថុសក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ ។ បន្ទាប់មកក្រឡាបញ្ជីត្រូវអានប្រារព្ធវាទខ្លាំងៗ ច្បាស់ៗ ឱ្យអ្នកស្បថស្តាប់ រួចអាន **ពាក្យសច្ចាប្រណិធាន** ឱ្យអ្នកស្បថ ថាតាម ។

ក្រោយពីធ្វើសម្បថរួច ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុដែលបានឱ្យស្បថនោះ បញ្ជាក់ថា បានធ្វើត្រឹមត្រូវហើយ សេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណា ត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង។

### ប្រារព្ធវាទ

បពិត្រអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា និងបារមីដ៏សក្តិសិទ្ធិ មានព្រះអង្គដងកើរ ព្រះអង្គ ក្រពុំឈូក ព្រះអង្គស្វេតឆ្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតា ក្រហមក លោកតាដំបងដែក លោកតាដំបងក្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះ ជីវិវត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្លែង ជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតី ក្នុងពិធីសម្បថនេះ ត្បិតគូក្តីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថាជាអ្នកបានដឹង បានឃើញ បានឮ និងបានចាំដោយផ្ទាល់ ហើយច្បាប់តម្រូវឱ្យយកអ្នកទាំងនេះ មកធ្វើជាសាក្សី ឱ្យឆ្លើយឱ្យបានទៀងត្រង់តាមពិត ។

បើអ្នកណាឆ្លើយមិនពិត តាមដែលខ្លួនបានដឹង បានឃើញ បានឮ និងបានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា យាយទេព និងបារមីដ៏សក្តិសិទ្ធិ បំផ្លាញឱ្យលាញឱ្យស្លាប់តែហោង យ៉ាងវេទនា ដោយគ្រាប់កាំភ្លើង ខ្សែភ្លើងឆក់ រន្ទះបាញ់ ខ្លាខាំពស់ចឹក លុះអនាគតជាតិឱ្យព្រាត់ប្រាសឪពុកម្តាយ បងប្អូន កូនចៅ ឱ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនា អស់ប្រាំរយជាតិ ។

បើអ្នកណាឆ្លើយឱ្យការណ៍ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលំអៀង

ព្រោះជាញាតិសាលោហិត មិនសមគំនិត ព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា យាយទេព និងបារមីដ៏សក្តិសិទ្ធិក្នុងលោកជួយឱ្យគេមានអាយុយឺនយូរ មានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ មានញាតិផៅគោរពស្រលាញ់ រាប់អាន លុះអនាគតជាតិបានជួបតែសេចក្តីល្អ ចម្រុងចម្រើន ថ្កុំថ្កើង រុងរឿង សមដូចសេចក្តី បំណងប៉ងប្រាថ្នា កុំបីអាក់ខានឡើយ ។

## ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំថ្នាល់ ។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្សអ្នកតា និងបារមីដ៏សក្តិសិទ្ធិទាំងអស់ បរាមុខខ្ញុំ ឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោង យ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូន ញាតិផៅសន្តាន ជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**********

តុលាការខេត្ត-ក្រុង
..............................
*********

សាលក្រមព្រហ្មទណ្ឌលេខ........................
ចុះថ្ងៃទី ......... ខែ ........... ឆ្នាំ ..........
សំណុំរឿងព្រហ្មទណ្ឌលេខ .................
ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ ..........

តាងនាមប្រជារាស្ត្រខ្មែរ តុលាការខេត្ត-ក្រុង ............................
បង្កើតឡើងតាម ..............................................................
..............................................................................
បានបើកសវនាការជាសាធារណៈ នៅតុលាការខេត្ត-ក្រុង ......
............................. ថ្ងៃទី ......... ខែ ............ ឆ្នាំ .........

ដែលមានសមាសភាពដូចតទៅ:-

- លោក ............................................................ ជាចៅក្រមជំនុំជម្រះ
- លោក ............................................................. ជាតំណាងអយ្យការ
- លោក .......................................................... ជាក្រឡាបញ្ជីសវនាការ

ដោយមានលោក .......................................... ជាមេធាវី របស់ ...........................................

លោក ............................................ ជាមេធាវី របស់ ...........................................

ដើម្បីជំនុំជម្រះលើជនជាប់ចោទឈ្មោះ............................................................ ភេទ............ អាយុ .................ឆ្នាំ
ជាតិ............. របររកស៊ី................................ ទីលំនៅបច្ចុប្បន្ននៅភូមិ.........................ឃុំ-សង្កាត់..................

ស្រុក-ខណ្ឌ............................................ខេត្ត-ក្រុង........................................ទោសពីមុន ..........................។

ឪពុកឈ្មោះ.................................................. ''រ-ស'' ម្តាយឈ្មោះ ............................................... ''រ-ស''

ប្តីឬប្រពន្ធឈ្មោះ.........................................''រ-ស'' មានកូន ឬនៅលីវ .................................. ត្រូវជាប់ចោទ

ពីបទ............................................................................ ប្រព្រឹត្តនៅភូមិ.........................................................

ឃុំ-សង្កាត់............................ ស្រុក-ខណ្ឌ................................ ខេត្ត-ក្រុង.......................................កាលពី

ថ្ងៃទី ................ ខែ ...................... ឆ្នាំ ..................... ត្រូវចាប់ខ្លួនពីថ្ងៃទី ........... ខែ ................. ឆ្នាំ ...........

និងឃុំខ្លួននៅថ្ងៃទី ................ខែ .................. ឆ្នាំ .................. បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស

តាមមាត្រា ................................ នៃច្បាប់ ......................................................................................... ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ [១]:-

១.- និយាយអំពីដំណើររឿង ឬអង្គហេតុនៃសំណុំរឿងក្តីនេះ ក្រោយពីបញ្ចប់ការស៊ើបអង្កេត និងសួរដេញដោល

បានឃើញ[២] ..........................................................................................................

..................................................................................................................................

..................................................................................................................................

..........................................................................................................................។

បានឃើញ ..........................................................................................................

..................................................................................................................................

..................................................................................................................................

..........................................................................................................................។

បានឃើញ ..........................................................................................................

..................................................................................................................................

..................................................................................................................................

..........................................................................................................................។

បានឃើញ ..........................................................................................................

..................................................................................................................................

..................................................................................................................................

..........................................................................................................................។

បានឃើញ ..........................................................................................................

..................................................................................................................................

..................................................................................................................................

..........................................................................................................................។

បានឃើញ ..........................................................................................................

..................................................................................................................................

..................................................................................................................................

..........................................................................................................................។

បានឃើញ ..........................................................................................................

..................................................................................................................................

..................................................................................................................................

---

២.- លើកយកលិខិត និងភស្តុតាង ដែលជាសំអាងផ្សេងៗ សំរាប់ធ្វើជាមូលដ្ឋានក្នុងការយល់ឃើញរបស់ខ្លួនដើម្បីសំរេចសេចក្ដីឱ្យបានត្រឹមត្រូវតាមច្បាប់។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់ចម្លើយសាក្សី
- ក្រោយពីបានពិនិត្យភស្តុតាង
- ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់ ជនជាប់ចោទធ្វើសំណូមពរជាសំដីចុងក្រោយ
- ក្រោយពីបានពិនិត្យ ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការខេត្ត-ក្រុង ..............................................................

យល់ឃើញថា [៣] .............................................................................................................................
.............................................................................................................................
.............................................................................................................................។

យល់ឃើញថា .............................................................................................................................
.............................................................................................................................
.............................................................................................................................។

យល់ឃើញថា .............................................................................................................................
.............................................................................................................................
.............................................................................................................................។

យល់ឃើញថា .............................................................................................................................
.............................................................................................................................
.............................................................................................................................។

យល់ឃើញថា .............................................................................................................................
.............................................................................................................................
.............................................................................................................................។

យល់ឃើញថា .............................................................................................................................
.............................................................................................................................
.............................................................................................................................។

យល់ឃើញថា .............................................................................................................................

[៣] .- ការសន្និដ្ឋានវាយតំលៃ ពីអំពើរបស់ជនត្រូវចោទ ទៅលើធាតុផ្សំនៃបទល្មើស សំរាប់បញ្ជាក់ថា មាន ឬគ្មានពិរុទ្ធភាពគ្រប់គ្រាន់ ឬស្មាប់ ឬគេចខ្លួនបាត់ មាន ឬគ្មានសាវតាជាតិ ។

ហេតុដូច្នេះ តុលាការខេត្ត-ក្រុង ..................................................

## វិនិច្ឆ័យសេចក្តី [៤]

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

